

Translator Sovicheth Meta standing in front of a painting by Artist Asasax, titled: "Burning Forest, Burning Women." Photo by Try Socheata/DC-Cam Archives

## កំណាព្យ "ល្បួងលោមចិត្ត"

នៅពេលដែលទុក្ខព្រួយកើតមាន គឺប្រៀបបានដូចជាពេលរាត្រីដែលចូលមកដល់
ព្រៃដ៏ធំធេង គឺជាកន្លែងដែលមនុស្សវង្វេង
តើមាននរណាជឿទៅលើពន្លឺដែលនៅដ៏សែនឆ្ងាយសន្លឹម ?
ពន្លឺចិញ្ចែងចិញ្ចាចដែលមានហើយក៏រលត់បាត់ទៅវិញនោះ
ដូចជាការលេងសើចមួយ
ពេលខ្លះមានពន្លឺចិញ្ចែងចិញ្ចាច
ហើយពេលខ្លះទៀតក៏រលត់បាត់ទៅវិញ
តើមាននរណាដែលចាត់ទុកខ្មោចចង្កៀង
ថាជាអ្នកដែលមានចង្កៀងសម្រាប់បំភ្លឺភាពអន្ធការ ?

ស៊ុយអែត Sverige

USAID FROM THE AMERICAN PEOPLE

Funded by the Swedish International Development Cooperation Agency (Sida) with the core support from United States Agency for International Development (USAID)

Questions I Am Asked About the Holocaust by Hédi Fried
Translated from the English by Sovicheth Meta
DOCUMENTATION CENTER OF CAMBODIA – TRANSLATION SERIES No. 20
Copyright ©2019

9 789924 907862

បូជាយញ្ញ HOLOCAUST បកប្រែជាភាសាខ្មែរដោយ សុវិចិត្រ មេត្តា



# បូជាយញ្ញ

# HOLOCAUST

បកប្រែជាភាសាខ្មែរដោយ សុវិចិត្រ មេត្តា

មជ្ឈមណ្ឌលឯកសារកម្ពុជា

# បូជាភ្លើង
HOLOCAUST



បកប្រែជាភាសាខ្មែរដោយ សូវិចិត្រ មេត្តា

មជ្ឈមណ្ឌលឯកសារកម្ពុជា

២០១៩

ឯកសារបកប្រែជាភាសាខ្មែរលើកទី២០ មជ្ឈមណ្ឌលឯកសារកម្ពុជា

- ❖ បូជាភ្លើង សំណួរដែលបានសួរមកខ្ញុំអំពីការសម្លាប់រង្គាលនៅអឺរ៉ុប
- ❖ និពន្ធដោយ ហេឌី ហ្រ៊ាយ
- ❖ បកប្រែជាភាសាខ្មែរដោយ សូវិចិត្រ មេត្តា
- ❖ ពិនិត្យកែសម្រួលឃ្លោងឃ្លានិងអក្ខរាវិរុទ្ធដោយ ឆាំង យុ
- ❖ ក្រាហ្វិកនិងកុំព្យូទ័រការីដោយ លី សេនសូនីឡា
- ❖ រចនាក្របនិងតួសៀវភៅដោយ ឆាំង យុ
- ❖ គូសផែនទីដោយ លី កុកឆាយ
- ❖ រូបគំនូរក្របមុខដោយ ជ្រិន ជ័យស័ក្ត
- ❖ បោះពុម្ពនៅកម្ពុជាឆ្នាំ ២០១៩

**JUSTICE & MEMORY**

Documentation Center of Cambodia
Villa No. 66, Preah Sihanouk Blvd.,
Phnom Penh 12000
Cambodia
t: +855 (23) 211 875
e: dccam@online.com.kh
w: dccam.org
Published by agreement with Partners in Stories Stockholm AB, Ferkens gränd 1, S-111 30 Stockholm, Sweden. Dated of agreement: November 28, 2018.

The translation is funded by the Swedish International Development Cooperation Agency (Sida) with the core support from United States Agency for International Development (USAID).

រក្សាសិទ្ធិឆ្នាំ ២០១៩ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជារក្សាសិទ្ធិគ្រប់យ៉ាង។ មិនមានផ្នែកណាមួយនៃសៀវភៅនេះត្រូវបានបោះពុម្ពឡើងវិញឬប្រើប្រាស់ក្នុងទម្រង់ឬក្នុងមធ្យោបាយបែបណាឡើយ ដែលរួមមាន ការថតចម្លង ការកត់ត្រាឬការថតទុកនៅក្នុងប្រព័ន្ធផ្ទុកពត៌មានផ្សេងៗទៀត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកបោះពុម្ពបានឡើយ។

# សំណួរដែលបានសួរមកខ្ញុំ អំពីការសម្លាប់រង្គាលនៅអ៊ឺរ៉ុប

ហេឌី ប្រ៊ាយ



# កាតព្វកិច្ចក្នុងការចងចាំ

មិនថានៅក្នុងកាលៈទេសៈបែបណាក៏ដោយ អរិយធម៌របស់ប្រទេសនីមួយៗមិនអាចរីកចម្រើនបានទេលុះត្រាណាតែមានការចងចាំ។ ការចងចាំអំពីសុភមង្គល សន្តិភាព និងវិបុលភាព គឺមិនពិបាកនោះឡើយ។ ជាធម្មតា រដ្ឋាភិបាលតែងតែរម្លឹកនិងស្ញើចសរសើរលើប្រវត្តិសាស្ត្រណាដែលបង្ហាញអំពីវីរភាព ភាពស្រស់ស្អាត និងគុណធម៌ដែលផ្តល់ប្រយោជន៍ដល់ស្ថាប័ននាពេលបច្ចុប្បន្ន គំនិត និងជំនឿតែប៉ុណ្ណោះ។ ប៉ុន្តែសង្គមត្រូវតែសួរសំណួរបន្ថែមទៀតអំពីអតីតកាល ព្រមទាំងស្រាវជ្រាវអំពីកំហុសឆ្គង ឧក្រិដ្ឋកម្ម និងភាពភ័យរន្ធត់ដែលបានបំផ្លាញមនុស្សជាតិ ប្រសិនបើចង់យកឈ្នះលើអតីតកាលរបស់ខ្លួន។ ការសិក្សាស្រាវជ្រាវអំពីភាពអមនុស្សធម៌ពីអតីតកាល គឺជាកិច្ចការដ៏លំបាកបំផុតសម្រាប់សង្គមក្រោយជម្លោះ។ ជាការពិតណាស់ ការស្រាវជ្រាវ និងអប់រំមនុស្សជំនាន់ក្រោយអំពីភាពភ័យរន្ធត់ដែលបានកើតឡើងនាពេលអតីតកាល គឺហួសពីអ្វីដែលតុលាការទាំងឡាយអាចសម្រេចបាននូវជោគជ័យមួយ។

ស្របពេលដែលតុលាការមានសមត្ថភាពធ្វើការសម្រេចសេចក្តីចុងក្រោយ ធានាយុត្តិធម៌ និងបង្ហាញថាសំណុំរឿងបានបញ្ចប់ជាស្ថាពរ កត្តាមួយចំនួនដូចជា ទីកន្លែង ពេលវេលា និងធនធានគឺជាកត្តាដែលធ្វើឲ្យរាំងស្ទះដែនសមត្ថកិច្ចរបស់តុលាការ។ ផ្ទុយទៅវិញការសិក្សា ការអប់រំ និងសុន្ទរកថាសាធារណៈ គឺពឹងផ្អែកទៅលើការសម្រេចចិត្តរបស់បុគ្គល ស្ថាប័ន និងសង្គមនាពេលបច្ចុប្បន្ន។ យើងមានកាតព្វកិច្ចក្នុងការចងចាំ ហើយវាគឺមិនមែនជាកាតព្វកិច្ចដែលត្រូវបានកំណត់នៅក្នុងដែនអនុសញ្ញា រដ្ឋធម្មនុញ្ញ ឬច្បាប់ណាមួយឡើយ។ ផ្ទុយទៅវិញ វាគឺជាកាតព្វកិច្ចមួយដែលកើតឡើងពីការប្តេជ្ញាចិត្តរបស់មនុស្សចំពោះមនុស្សជាតិ។ ដូចជាព័ត៌មានទាំងអស់ដែរប្រវត្តិសាស្ត្រអាចត្រូវបានបំភ្លៃឬបំផ្លាញ និងលុបចោល ហើយដំណោះស្រាយតែមួយគត់ដើម្បីបង្ការបញ្ហាទាំងអស់នេះ គឺការប្តេជ្ញាចិត្តរបស់បុគ្គលម្នាក់ៗក្នុងការចងចាំ។ នៅក្នុងបរិបទនេះ ការចងចាំគឺមិនមែនជាឯកជនភាពនោះទេ។

វាគឺមិនអាចជាការចងចាំដែលមិនបង្ហាញចេញមកក្រៅ នៅស្ងៀមស្ងាត់ ឬមិនផ្លាស់ប្តូរទៅរកអ្វីដែលល្អប្រសើរ។ អ្នកដែលបានហែលឆ្លងកាត់ប្រវត្តិសាស្ត្រទាំងឡាយត្រូវតែចែករំលែកចំណេះដឹងរបស់ខ្លួនទៅដល់មនុស្សជំនាន់ក្រោយ ហើយមនុស្សជំនាន់ក្រោយមានកាតព្វកិច្ចក្នុងការរៀនសូត្រ និងផ្សព្វផ្សាយចំណេះដឹងនេះជាបន្តបន្ទាប់។ ការចងចាំគឺជាការចាប់ផ្តើម និងជាសេចក្តីបញ្ចប់ចំពោះបេសកកម្មក្នុងការស្វែងរកយុត្តិធម៌ សន្តិភាព និងការពិត។ រីឯកាតព្វកិច្ចក្នុងការចងចាំ គឺចាប់ផ្តើមនិងបញ្ចប់ដោយបុគ្គលម្នាក់ៗធ្វើការសម្រេចចិត្តអំពីសារសំខាន់របស់ប្រវត្តិសាស្ត្រមិនត្រឹមចំពោះខ្លួនឯងផ្ទាល់តែប៉ុណ្ណោះទេ ប៉ុន្តែក៏ចំពោះមនុស្សជំនាន់ក្រោយឯទៀតដែរ។

**ឆាំង យុ**

នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

# PREFACE
# DUTY TO REMEMBER

No matter the circumstance, civilization cannot advance unless it remembers. It is never difficult to remember happiness, peace, and prosperity. Governments will naturally extol (or reinterpret) historical narratives that illuminate heroism, beauty, and virtue from the past that supports contemporary institutions, ideas, and beliefs. Yet societies must inquire further—researching the mistakes, crimes, and horrors that undermined, if not destroyed, humanity if they are ever to overcome the circumstances of their past. Researching the inhumanity of the past can be the most difficult task for a post-conflict society. Indeed, researching and educating future generations about the horrors of the past goes beyond what any court of law could ever endeavor to achieve. Whereas courts have the ability to determine legal conclusions, ensure justice, and provide a sense of closure, space, time, and resources limit their jurisdiction. Unlike law, however, scholarship, education, and public discourse can only be bounded by the discretion of the individual, institution, and society in the moment. We have a duty to remember. It is not a duty that is expressed in any particular convention, constitution, or law; rather, it is a duty that arises out of a common commitment to humanity. Like all information, history can be diluted, warped, and even erased, and the only assurance against these circumstances is a commitment to remember. Memory, in this context, cannot be private. It must not be exclusively personal, silent, or static. The generation that experienced this history must pass on their knowledge to the next generation, and the generations that follow bear a responsibility to learn and continue to pass on this knowledge. Memory is the beginning and end to any search for true justice and peace, and the duty to remember begins and ends with the individual, who can determine not only what the past means to him or her, but what it should mean for future generations.

**Youk Chhang**

Director

Documentation Center of Cambodia

# កំណត់ហេតុអ្នកបកប្រែ

នាងខ្ញុំឈ្មោះ សូវិចិត្រ មេត្តា គឺជាកូនច្បងនៅក្នុងចំណោមបងប្អូនចំនួន ៥ នាក់។ ខ្ញុំកើតនៅទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៩៧។ នៅក្នុងឆ្នាំ ២០១៨ ខ្ញុំបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកសិក្សាអន្តរជាតិពីវិទ្យាស្ថានភាសាបរទេសនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ក្នុងអំឡុងពេលសិក្សា ខ្ញុំមានចំណាប់អារម្មណ៍ជាច្រើនទៅលើការងារសង្គម ដូច្នេះហើយខ្ញុំបានធ្វើការស្ម័គ្រចិត្តនៅតាមអង្គការក្រៅរដ្ឋាភិបាលជាច្រើនកន្លែង ដែលធ្វើការទាក់ទងអំពីកុមារក្រីក្រ លើកស្ទួយអភិវឌ្ឍន៍សហគមន៍ និងលើកកំពស់សិទ្ធិស្ត្រី។ នៅពេលដែលខ្ញុំមានអាយុ១៣ឆ្នាំ ម្តាយរបស់ខ្ញុំបានបាត់បង់ជីវិតដោយសារតែជំងឺមហារីក ទើបខ្ញុំនិងប្អូនៗធំធាត់ឡើងនៅក្រោមការបីបាច់ថែរក្សាយ៉ាងល្អរបស់ជីដូន និងក្រោមការលើកទឹកចិត្តព្រមទាំងភាពកក់ក្តៅរបស់ឪពុកដ៏ល្អម្នាក់។ ប៉ុន្តែជារឿយៗការចងចាំអំពីម្តាយរបស់ខ្ញុំក៏ជាកម្លាំងចិត្តដ៏រឹងមាំមួយដែលធ្វើឱ្យខ្ញុំខិតខំប្រឹងប្រែងរៀនសូត្រ។នៅក្នុងខែមិថុនា ឆ្នាំ២០១៨ ខ្ញុំត្រូវបានណែនាំឱ្យស្គាល់មជ្ឈមណ្ឌលឯកសារកម្ពុជាខ្ញុំក៏បានសម្រេចចិត្តចូលធ្វើជាបុគ្គលិកស្ម័គ្រចិត្តរហូតបានក្លាយទៅជាបុគ្គលិកពេញម៉ោង។ ក្នុងអំឡុងពេលធ្វើការស្ម័គ្រចិត្ត ខ្ញុំមានឱកាសដើម្បីអានឯកសារនិងអត្ថបទជាច្រើនដែលទាក់ទងអំពីរបបខ្មែរក្រហម។ទន្ទឹមនឹងពេលនោះដែរខ្ញុំពិតជាមានការងឿងឆ្ងល់ជាច្រើនដែលទាក់ទងអំពីរបបមួយនេះ ហើយក៏ភ្ញាក់ខ្លួនដែរថា ហេតុអ្វីបានជាខ្ញុំមិនធ្លាប់បានសួរនាំគ្រួសាររបស់ខ្ញុំអំពីប្រវត្តិសាស្ត្រដ៏ជូរចត់មួយនេះ។ ហេតុអ្វីបានជាសាលារៀនរបស់ខ្ញុំមិនបានបង្រៀនអំពីរបបមួយនេះ។

ខ្ញុំក៏អៀនខ្មាសនឹងខ្លួនឯងដែលតែងតែប្រាប់ប្អូនៗថា ក្នុងនាមជានិស្សិតដែលរៀនជំនាញសិក្សាអន្តរជាតិ ខ្ញុំអាចឆ្លើយសំណួរអំពីប្រវត្តិសាស្ត្រពិភពលោករបស់ពួកគេបាន។ប៉ុន្តែជាក់ស្តែងខ្ញុំបែរជាមិនបានដឹងច្បាស់អំពីប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួនទៅវិញ។ សៀវភៅនេះគឺជាស្នាដៃបកប្រែលើកទី១របស់ខ្ញុំ ហើយខ្ញុំក៏សូមថ្លែងអំណរគុណដល់លោកនាយក ឆាំង យុ ដែលបានផ្តល់ឱកាសនេះមកដល់ខ្ញុំ។ ខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងក្លាយទៅជាឯកសារដ៏សំខាន់ព្រមទាំងជាក់លាក់មួយដែលទោះបីជាកន្លងហួសអស់រយៈពេលប៉ុន្មានឆ្នាំទៅមុខទៀតក៏តែងតែអាចយកមកប្រើប្រាស់ ដើម្បីរំឭកអំពីអំពើកាចសាហាវព្រៃផ្សៃរបស់មនុស្សទៅលើមនុស្សដូចគ្នា និងអាចបង្រៀនមនុស្សឱ្យអាចជៀសផុតអំពីប្រវត្តិសាស្ត្រច្រំដែលបាន។ខ្ញុំនឹកឃើញសុភាសិតខ្មែរមួយដែលនិយាយថា "ក្អែកមួយក្លាយទៅជាក្អែកដប់" ប្រវត្តិសាស្ត្របន្ទាប់ពីប៉ុន្មានឆ្នាំទៅមុខទៀតអាចនឹងត្រូវបានជនខិលខូចបំភ្លៃហើយបាត់បង់ការពិត ប៉ុន្តែជាមួយនឹងឯកសារជាក់ស្តែង ទោះបីជាលែងមានជនរងគ្រោះនៅសេសសល់ដើម្បីនិយាយប្រាប់ ក៏ប្រវត្តិសាស្ត្រនេះមិនត្រូវអាចបាត់បង់ទៅណា អំពើឃោរឃៅក៏មិនត្រូវបានគេបំភ្លេច។ ចំណែកឯជនរងគ្រោះដែលបានបាត់បង់ជីវិតយ៉ាងអយុត្តិធម៌ នោះនឹងនៅតែមានក្នុងការចងចាំរបស់ពិភពលោកនេះជារៀងរហូត។

**សូវិចិត្រ មេត្តា**

ភ្នំពេញ ថ្ងៃទី៩ ខែមករា ឆ្នាំ២០១៩

# A NOTE FROM THE TRANSLATOR

My name is Sovicheth Meta, and I am the oldest child out of my five siblings. I was born in Phnom Penh in 1997. I received my Bachelor of Arts degree in International Studies in 2018 from the Institute of Foreign Languages of the Royal University of Phnom Penh. During my Studies, I took a particular interest in social work, so I volunteered in several non-governmental organization projects focusing on child poverty, community development and women's rights. My commitment to give back to society draws from childhood loss. I was just 13 years old when cancer took my mother and since that time I have dedicated my life to making myself a better person so I can contribute to the world in her name. The Documentation Center of Cambodia (DC-Cam) has given me an opportunity to contribute to my country's struggle for identity in the wake of the Khmer Rouge regime. I first came to work for DC-Cam in June 2018 as a volunteer. During my volunteer work, I had the opportunity to conduct research on the Khmer Rouge regime, which compelled me to seek and obtain a more permanent position at the Center. The Center exposed me to a harsh reality of my self and my country. I recall always proudly telling my younger siblings that, as a university student majoring in international studies, I can answer any questions they had about world history. Whereas I still feel I relatively knowledgeable on world history, my work in studying the Khmer Rouge period exposed me to the harsh fact that I knew very little of my country's history. Listening to survivors and reading primary source documents on the history of the Khmer Rouge humbled and inspired me to learn this history so I could educate the next generation. This book is my first translation, and I am always grateful to director Youk Chhang for giving me the opportunity to contribute to the organization's mission to facilitate the country's search for truth. I hope that this book will become a tool that both inspires as well as educates. The hatred that conditioned people to commit unspeakable acts must be remembered as much as the survivors' resilience. Indeed we must ensure history is never diluted, changed, or discarded; rather, we must use history to re-imagine a new world through the preservation of our ancestors' experiences and lessons.

**Sovicheth Meta**

9 January, 2019, Phnom Penh



**HEDI FRIED** | ហេឌី ហ្វ្រាយ

# សទ្ទានុក្រម

| | |
|---|---|
| អូសឈ្វិច (Auschwitz) | គឺជាទីក្រុងមួយនៅក្នុងភាគខាងត្បូងនៃប្រទេសប៉ូឡូញ។ ក្នុងអំឡុងសង្គ្រាម លោកលើកទីពីរ វាគឺជាជំរំប្រមូលផ្តុំដ៏ធំជាងគេរបស់របបណាហ្ស៊ី។ |
| ប្រទេសរូម៉ានី (Romania) | គឺជាប្រទេសមួយដែលស្ថិតនៅក្នុងទ្វីបអ៊ឺរ៉ុប ដែលមានព្រំប្រទល់ជាប់នឹងសមុទ្រខ្មៅ ប្រទេសប៊ុលហ្គារី ប្រទេសអ៊ុយក្រែន ប្រទេសហុងគ្រី ប្រទេសស៊ែប៊ី និងប្រទេសម៉ុលដាវី។ |
| ប្រទេសហុងគ្រី (Hungary) | គឺជាប្រទេសមួយដែលស្ថិតនៅក្នុងអ៊ឺរ៉ុបកណ្តាល ដែលមានព្រំប្រទល់ជាប់ប្រទេសស្លូវ៉ាគី អូទ្រីស ស្លូវេនី ក្រូអាស៊ី ស៊ែប៊ី រ៉ូមានី និងអ៊ុយក្រែន។ |
| ប្រទេសម៉ុលដាវី (Moldavia) | មានឈ្មោះជាផ្លូវការថាសាធារណរដ្ឋម៉ុលដាវីស្ថិតនៅក្នុងអ៊ឺរ៉ុបខាងកើតមានព្រំប្រទល់ជាប់ប្រទេសរូម៉ានីនៅខាងលិច និងអ៊ុយក្រែននៅទិសខាងជើង ខាងកើត និងខាងត្បូង។ |
| ប្រទេសអ៊ុយក្រែន (Ukraine) | គឺជាប្រទេសមួយស្ថិតនៅក្នុងអ៊ឺរ៉ុបខាងកើត។ |
| សង្កាត់អាស្ពុដិន (Aspudden) | គឺជាសង្កាត់មួយស្ថិតនៅជាយក្រុងភាគខាងត្បូងនៃទីក្រុងស្តុកខុលនៃប្រទេសស៊ុយអែត។ |
| ប្រទេសស៊ុយអែត (Sweden) | មានឈ្មោះជាផ្លូវការថាព្រះរាជាណាចក្រស៊ុយអែតស្ថិតនៅក្នុងអ៊ឺរ៉ុបភាគខាងជើង និងមានព្រំប្រទល់ជាប់ប្រទេសហ្វាំងឡង់ ណ័រវេ និង ដាណឺម៉ាក។ |
| វរគុតា (Vorkuta) | គឺជាទីក្រុងរុករករ៉ែធ្យូងថ្មមួយនៅក្នុងសាធារណរដ្ឋកូមិនៃប្រទេសរុស្ស៊ី។ |

| | |
|---|---|
| **ហូឡូខសន៍ (Holocaust)** | គឺជាការធ្វើបាបឃាឃី និងការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ទៅលើជនជាតិជ្វីហ្វចំនួន ៦លាននាក់ ដោយរបបណាហ្ស៊ីរបស់ហ៊ីត្លែរ ចាប់តាំងពីឆ្នាំ ១៩៣៣ រហូតដល់ចុងបញ្ចប់សង្គ្រាមលោកលើកទី២។ ហូឡូខសន៍ គឺជាពាក្យដើមនៃភាសាក្រិក ដែលមានន័យថា "បូជាដោយភ្លើង"។ នៅក្នុងភាសាខ្មែរ ខ្ញុំសូមប្រើថា "បូជាភ្លើង"។ |
| **ទីក្រុងស្តុកខុល (Stockholm)** | គឺជារដ្ឋធានីរបស់ប្រទេសស៊ុយអែត។ |
| **សូប៊ីប័រ (Sobibor)** | គឺជាជំរំសម្លាប់របស់ណាហ្ស៊ីនៅក្នុងសង្គ្រាមលោកលើកទី២ ដែលមានទីតាំងស្ថិតនៅជិតភូមិសូប៊ីប័រ នៅភាគខាងកើតនៃស្រុកលូប្លីន ប្រទេសប៉ូឡូញ។ជំរំនេះមានចម្ងាយ៥ គីឡូម៉ែត្រ ពីទន្លេបាក់ដែលសព្វថ្ងៃនេះ គឺជាព្រំដែនរវាងប្រទេសប៉ូឡូញ និងប្រទេសអ៊ុយក្រែន។ |
| **ទីក្រុងវ៉ាសូវី (Warsaw)** | គឺជាទីក្រុងដែលធំបង្អស់នៅក្នុងប្រទេសប៉ូឡូញ។ |
| **ប្រទេសហ្វាំងឡង់ (Finland)** | មានឈ្មោះជាផ្លូវការថាសាធារណរដ្ឋហ្វាំងឡង់ស្ថិតនៅអឺរ៉ុបខាងជើង។ |
| **ប៉ាឡេស្ទីន (Palestine)** | មានឈ្មោះជាផ្លូវការថារដ្ឋប៉ាឡេស្ទីន មានព្រំប្រទល់ជាប់ប្រទេសអេហ្ស៊ីប អ៊ីស្រាអែល និងប្រទេសហ្ស៊កដានី។ |
| **ប្រទេសអ៊ីស្រាអែល (Israel)** | មានឈ្មោះជាផ្លូវការថារដ្ឋអ៊ីស្រាអែល។ នៅក្នុងឆ្នាំ ១៩៤៨ គឺជាប្រទេសមួយនៅអាស៊ីខាងលិចដែលមានទីតាំងស្ថិតនៅលើច្រាំងសមុទ្រទិសអាគ្នេយ៍នៃសមុទ្រមេឌីទែរ៉ាណេ និងឆ្នេរភាគខាងជើងនៃសមុទ្រក្រហម។ |
| **ត្រេប្លាំងកា (Treblinka)** | គឺជាជំរំសម្លាប់មនុស្សរបស់ ណាហ្ស៊ី នៅក្នុងប្រទេសប៉ូឡូញអំឡុងពេលសង្គ្រាមលោកលើកទី២ដែលមានទីតាំងស្ថិតនៅក្នុងព្រៃទិសឦសាននៃទីក្រុងវ៉ាសូវី។ |
| **បេលហ្សេក៍ (Belzec)** | គឺជាជំរំសម្លាប់ដែលស្ថិតនៅភាគខាងកើតប្រទេសប៉ូឡូញនៅក្នុងសង្កាត់លូប្លីន។ |
| **ឆេលណូ (Chelmno)** | គឺជាជំរំសម្លាប់មនុស្សដំបូងបង្អស់របស់របប ណាហ្ស៊ី បន្ទាប់ពីឈ្លានពានប្រទេសប៉ូឡូញបានជោគជ័យ។ ជំរំនេះមានចម្ងាយ៥០គីឡូម៉ែត្រ ពីភូមិឆេលណូ។ |
| **ម៉ាជ៍ដាណេក (Majdanek)** | គឺជាជំរំប្រមូលផ្តុំ និងសម្លាប់របស់ ណាហ្ស៊ី នៅជាយទីក្រុងលូប្លីន។ |
| **ត្រង់ស៊ីលវ៉ានី (Translyvania)** | គឺជាតំបន់ប្រវត្តិសាស្រ្តមួយស្ថិតនៅក្នុងប្រទេសរូម៉ានី។ |
| **ត្រង់ស្នីស្ទ្រៀ (Transnistria)** | គឺជារដ្ឋមួយដែលមិនត្រូវបានគេទទួលស្គាល់ជាផ្លូវការក្រោយពីបានបំបែកខ្លួនចេញពីប្រទេស ម៉ុលដាវី បន្ទាប់ពីការដួលរលំរបស់សហភាពសូវៀត។ តំបន់នេះត្រូវបានអង្គការសហប្រជាជាតិចាត់ទុកថាជាផ្នែកមួយរបស់ប្រទេសម៉ុលដាវី។ |
| **ទីក្រុងស៊ីហ្គេត (Sighet)** | គឺជាទីក្រុងតូចមួយដែលបច្ចុប្បន្ននេះមានឈ្មោះហៅថាស៊ីហ្គេតូ ម៉ាម៉ាទៀ ស្ថិតនៅក្នុងត្រង់ស៊ីលវ៉ានី និងកាន់កាប់ដោយប្រទេសរូម៉ានី បន្ទាប់ពីសង្គ្រាមលោកលើក ២ បានបញ្ចប់ទៅ។ នៅក្នុងដើមឆ្នាំ ១៩៤៤ ជនជាតិជ្វីហ្វចំនួន ១៤០០០នាក់ នៅក្នុងទីក្រុងមួយនេះត្រូវបានបញ្ជូនទៅអូសឈ្វិច និងមានចំនួនតែប៉ុន្មានរយនាក់ប៉ុណ្ណោះដែលបានរួចរស់រានមានជីវិតបន្ទាប់ពីចប់សង្គ្រាម។ |

| | |
|---|---|
| **បឺជិន បែលសិន**<br>**(Bergen-Belsen)** | គឺជាភូមិមួយនៅក្នុងប្រទេស អាល្លឺម៉ង់ នៅខាងជើងហាណូវើ។ វាគឺជាជំរំប្រមូលផ្តុំរបស់ណាហ្ស៊ីក្នុងអំឡុងសង្គ្រាមលោកលើកទី២។ |
| **ថេរ៉េស៊ីនស្តាដ**<br>**(Theresienstadt)** | គឺជាជំរំមួយបានបង្កើតឡើងដោយណាហ្ស៊ីសម្រាប់ធ្វើជាជំរំប្រមូលផ្តុំ និងហ្គេតូក្នុងឆ្នាំ១៩៤១ នៅក្នុងសាធារណរដ្ឋឆែក។ |
| **កោះរូដស៍**<br>**(Rhodes Island)** | គឺជាកោះមួយនៅក្នុងប្រទេសក្រិក។ |
| **ប្រទេសអាហ្សង់ទីន**<br>**(Argentina)** | គឺជាប្រទេសមួយដែលមានឈ្មោះជាផ្លូវការថាសាធា-រណរដ្ឋអាហ្សង់ទីន មានទីតាំងស្ថិតនៅភាគខាងត្បូងនៃទ្វីបអាមេរិកខាងត្បូង។ |
| **ទីក្រុងឡូសអាន់ជឺឡែស**<br>**(Los Angeles)** | គឺជាទីក្រុងមួយនៅក្នុងរដ្ឋកាលីហ្វ៊ូញ៉ានៃប្រទេសសហរដ្ឋអាមេរិក |
| **ទីក្រុងប្រាក**<br>**(Prague)** | គឺជាទីក្រុងធំបង្អស់របស់សាធារណរដ្ឋឆែក។ |
| **ទីក្រុងបែរឡាំង**<br>**(Berlin)** | គឺជាទីក្រុងរបស់ប្រទេសអាល្លឺម៉ង់។ |
| **ទីក្រុងហែមបឺក**<br>**(Hemberg)** | គឺជាទីក្រុងធំទី២នៅក្នុងប្រទេសអាល្លឺម៉ង់ដែលមានប្រជាជនជាង ១លាននាក់រស់នៅ។ |
| **ទីក្រុងម៉ាល់ម៉ូ**<br>**(Malmo)** | គឺជាទីក្រុងធំទី៣របស់ប្រទេសស៊ុយអែត។ |
| **ទីក្រុងតាប៊ី**<br>**(Taby)** | គឺជាឈ្មោះទីក្រុងមួយនៅក្នុងប្រទេស ស៊ុយអែត។ |
| **ប្រទេសណាមីប៊ី**<br>**(Namibia)** | មានឈ្មោះជាផ្លូវការថាសាធារណរដ្ឋណាមីប៊ី ដែលគឺជាប្រទេសមួយដែលស្ថិតនៅក្នុងអាហ្វ្រិកខាងត្បូង។ |
| **ប្រទេសរវ៉ាន់ដា**<br>**(Rwanda)** | មានឈ្មោះជាផ្លូវការថាសាធារណរដ្ឋរវ៉ាន់ដា ដែលគឺជាប្រទេសដែលស្ថិតនៅក្នុង អាហ្វ្រិក កណ្តាល និងអាហ្វ្រិកខាងកើត។ |
| **ភ្នំកាផាធៀន**<br>**(Carpathian Mountain)** | គឺជាជួរភ្នំមួយដែលមានប្រវែងប្រហែល ១៥០០ គីឡូម៉ែត្រស្ថិតនៅទ្វីបអ៊ឺរ៉ុបភាគកណ្តាល និងខាងកើត។ |
| **ប្រទេសស៊ែប៊ី**<br>**(Serbia)** | គឺជាប្រទេសដែលមានព្រំប្រទល់ជាប់ជាមួយប្រទេសហុងគ្រី រូម៉ានី ប៊ុលហ្គារី ម៉ាសេដ្វាន ក្រូអាស៊ី បូស្នីហឺហ្សេហ្គោវីណា និងម៉ុងតេណេហ្គ្រោ។ |

# កំណាព្យ "លួងលោមចិត្ត"

នៅពេលដែលទុក្ខព្រួយកើតមាន គឺប្រៀបបានដូចជាពេលរាត្រីដែលចូលមកដល់[១]
ព្រៃដ៏ធំធេង គឺជាកន្លែងដែលមនុស្សវង្វេង
តើមាននរណាជឿទៅលើពន្លឺដែលនៅដ៏សែនឆ្ងាយសន្លឹម ?
ពន្លឺចិញ្ចែងចិញ្ចាចដែលមានហើយក៏រលត់បាត់ទៅវិញនោះ
ដូចជាការលេងសើចមួយ
ពេលខ្លះមានពន្លឺចិញ្ចែងចិញ្ចាច
ហើយពេលខ្លះទៀតក៏រលត់បាត់ទៅវិញ
តើមាននរណាដែលចាត់ទុកខ្មោចចង្កៀង
ថាជាអ្នកដែលមានចង្កៀងសម្រាប់បំភ្លឺភាពអន្ធការ ?

When the sorrow comes, as when the night falls
In the wild woods, where a man goes astray,
Who believe in the light that in the distance calls?
And the glow that appears and then fades away?
In jest do they fade and in jest do they burn
Who takes a lantern man for a man with a lantern?

# ជូនចំពោះ
# ក្មេងជំនាន់ក្រោយទូទាំងពិភពលោក

---

[១] គឺជាកំណាព្យដែលនិពន្ធដោយជនជាតិស៊ុយអែតម្នាក់ឈ្មោះថា ហ្គូស្តាហ្វ ហ្វ្រូឌីង (Gustaf Fröding) នៅក្នុងអំឡុងសតវត្សរ៍ទី១៨ ដល់ដើមសតវត្សរ៍ទី១៩។ កំណាព្យនេះត្រូវបានបកប្រែដោយ អាលីស អុលសុន (Alice E. Olsson) នៅក្នុងសៀវភៅបូជាភ្លើងជាភាសាអង់គ្លេសដោយដាក់ចំណងជើងថា “Solace” ឬជាភាសាខ្មែរមានន័យថា "លួងលោមចិត្ត"។

# ផែនទីជំរំប្រមូលផ្តុំរបស់ណាហ្ស៊ី

(គូសផែនទីដោយ លី កុកឆាយ)



# ផែនទីប្រទេស និងកន្លែងដែលអ្នកនិពន្ធ លើកឡើងនៅក្នុងសៀវភៅ

(គូសផែនទីដោយ លី កុកឆាយ)



# អារម្ភកថា

ពេលវេលាបានកន្លងផុតទៅអស់ជាច្រើនឆ្នាំហើយ បន្ទាប់ពីខ្ញុំបានសរសេរអំពីជីវប្រវត្តិរបស់ខ្ញុំនៅក្នុងសៀវភៅដំណើរទៅ អូសឈ្វិច៖ បំណែកជីវិត[២]និងសៀវភៅបន្ទាប់ៗមកទៀតរបស់ខ្ញុំ។ ចាប់តាំងពីពេលនោះមក ខ្ញុំបានបង្រៀនសិស្សនៅតាមវិទ្យាល័យ និងមហាវិទ្យាល័យជាច្រើនជាមួយនឹងជំនឿយ៉ាងមុតមាំថាក្មេងៗជំនាន់ក្រោយត្រូវតែមានការចងចាំអំពីហូឡូខសន៍[៣] **(មានន័យជាភាសាខ្មែរថា បូជាដោយភ្លើង ឬ បូជាភ្លើង )** ប្រសិនបើយើងមិនចង់ឱ្យវាកើតឡើងជាថ្មីម្តងទៀត។ អ្វីដែលបានកើតឡើងរួចម្តងមកហើយអាចនឹងកើតឡើងបានម្តងទៀត ទោះបីជាវាមិនដូចគ្នាទាំងស្រុងយ៉ាងណាក៏ដោយ។ ដើម្បីទប់ស្កាត់ហេតុការណ៍នេះ យើងចាំបាច់ត្រូវមានការចងចាំពីព្រោះអតីតកាលបានបន្សល់ទុកស្លាកស្នាមរហូតដល់បច្ចុប្បន្នកាល និងបន្តចោលស្រមោលអន្ធការរបស់ខ្លួនទៅអនាគតកាល។

នៅដើមខែកញ្ញាក្នុងឆ្នាំ១៩៤០ត្រង់ស៊ីលវ៉ានីខាងជើង[៤]ត្រូវបានប្រគល់ឱ្យប្រទេសហុងគ្រី[៥]វិញ។ នៅពេលនោះខ្ញុំពិតជាអស់សង្ឃឹមខ្លាំងណាស់។ ការធ្វើបាបយាយីទៅលើជនជាតិជ្វីហ្វ បានចាប់ផ្តើម ទោះបីជាមិនទាន់ប្រែប្រួលទៅជាការគំរាមកំហែងផ្ទាល់ចំពោះជីវិតរបស់យើងក៏ដោយ។ ប៉ុន្តែមិនយូរប៉ុន្មានផងក៏មានលេចឮដំណឹងពីប្រទេសរូម៉ានី[៦] អំពីការសម្លាប់និងការធ្វើបាបជនជាតិជ្វីហ្វ។

[២] គឺជាចំណងជើងសៀវភៅដែលហេឌីប្រ្វាយសរសេរដំបូងបង្អស់ដោយមានឈ្មោះជាភាសាអង់គ្លេសថា The Road to Auschwitz: Fragments of Life។

[៣] គឺជាការធ្វើបាបយាយី និងអំពើប្រល័យពូជសាសន៍ទៅលើជនជាតិជ្វីហ្វចំនួន៦លាននាក់ដោយរបបណាហ្ស៊ីរបស់ហ៊ីត្លែរចាប់តាំងពីឆ្នាំ១៩៣៣ រហូតដល់ចុងបញ្ចប់សង្គ្រាមលោកលើកទី២។ ហូឡូខសន៍គឺជាពាក្យដើមនៃភាសាក្រិកមានន័យថា "បូជាដោយភ្លើង" ឬ "បូជាភ្លើង"។

[៤] គឺជាតំបន់ប្រវត្តិសាស្ត្រមួយស្ថិតនៅក្នុងប្រទេស រូម៉ានី។

[៥] គឺជាប្រទេសមួយដែលស្ថិតនៅក្នុងអឺរ៉ុបកណ្តាលដោយមានព្រំប្រទល់ជាប់ប្រទេសស្លូវ៉ាគី អូទ្រីស ស្លូវេនី ក្រូអាស៊ី ស៊ែប៊ី រូម៉ានី និងអ៊ុយក្រែន។

[៦] គឺជាប្រទេសមួយដែលស្ថិតនៅក្នុងទ្វីបអឺរ៉ុបដែលមានព្រំប្រទល់ជាប់នឹងសមុទ្រខ្មៅ ប្រទេសប៊ុលហ្គារី អ៊ុយក្រែន ហុងគ្រី ស៊ែប៊ី និងម៉ុលដាវី។



នៅប្រទេសម៉ុលដាវី[៧] ជនជាតិជ្វីហ្វ ត្រូវបានគេចាប់បញ្ជូនទៅប្រទេសអ៊ុយក្រែន[៨] តាមរថភ្លើងដែលនៅទីនោះ ពួកគេត្រូវបានបង្ខំឱ្យជីកផ្នូររបស់ខ្លួនមុនពេលដែលត្រូវបានបាញ់សម្លាប់ចោល។ នៅពេលនោះ ខ្ញុំពិតជាសប្បាយចិត្តណាស់ ដែលយើងរស់នៅក្រោមការគ្រប់គ្រងរបស់ប្រទេសហុងគ្រី។ បន្ទាប់មក នៅក្នុងរដូវរងារក៏មានពាក្យនិយាយតៗគ្នាថាជនជាតិជ្វីហ្វនៅតំបន់ខាងកើតជាច្រើននាក់ត្រូវបានបញ្ជូនតាមរថភ្លើងទៅប្រទេសត្រង់នីស្ទ្រៀ[៩] និងអ៊ុយក្រែន។ មកដល់ពេលនេះ ខ្ញុំបានទម្លាប់ខ្លួនទៅហើយជាមួយនឹងការផ្លាស់ប្តូរពីភាពធូរធាទៅភាពមិនសូវមានបានរបស់យើងនៅហុងគ្រី ហើយក៏រីករាយដែរ ដែលយើងមិនបាននៅក្រោមការគ្រប់គ្រងរបស់រូម៉ានីទៀត។ ខ្ញុំនៅតែអាចស្រមៃឃើញទិដ្ឋភាពរបស់ខ្លួនឯងនៅពេលនោះដែលខ្ញុំកំពុងតែអង្គុយចាក់ស្រោមជើងរោមសត្វសម្រាប់អ្នកដ៏គួរឱ្យអាណិតទាំងនោះដែលមិនត្រូវបានគេអនុញ្ញាតឱ្យយកសម្លៀកបំពាក់កក់ក្តៅជាប់ទៅជាមួយ។ បន្ទាប់មកនៅក្នុងខែមីនាឆ្នាំ១៩៤៤ អាល្លឺម៉ង់បានចូលឈ្លានពានប្រទេសហុងគ្រីហើយពេលនោះដែរគឺជាពេលវេលាមួយដែលខ្ញុំត្រូវសោកស្តាយដោយយើងមិនបាននៅក្រោមការគ្រប់គ្រងរបស់រូម៉ានីតទៅទៀត ។ ប្រទេសរូម៉ានី មិនបានប្រគល់ជនជាតិជ្វីហ្វ ទៅឱ្យប្រទេសអាល្លឺម៉ង់ទេផ្ទុយទៅវិញពួកគេធ្វើជំនួញជាមួយសហរដ្ឋអាមេរិកដោយបង់ប្រាក់ចំនួន១០០ដុល្លារក្នុងមួយនាក់ សម្រាប់ឱ្យជនជាតិជ្វីហ្វ ទៅអ៊ីស្រាអែល[១០]។

នៅទីបំផុត ខ្ញុំគ្រាន់តែជាមនុស្សម្នាក់ក្នុងចំណោមមនុស្សមានសំណាងល្អដ៏ទៃទៀតតែប៉ុណ្ណោះ។ ខ្ញុំមានសំណាងល្អជាច្រើនលើក។

[៧] មានឈ្មោះជាផ្លូវការថាសាធារណរដ្ឋម៉ុលដាវីស្ថិតនៅក្នុងអឺរ៉ុបខាងកើត មានព្រំប្រទល់ជាប់ប្រទេសរូម៉ានីនៅខាងលិច និងអ៊ុយក្រែននៅទិសខាងជើង ខាងកើតនិងខាងត្បូង។

[៨] គឺជាប្រទេសមួយស្ថិតនៅក្នុងអឺរ៉ុបខាងកើត។

[៩] គឺជារដ្ឋមួយដែលមិនត្រូវបានគេទទួលស្គាល់ជាផ្លូវការនិងបានបំបែកចេញពីប្រទេសម៉ុលដាវីបន្ទាប់ពីការដួលរលំរបស់សហភាពសូវៀត។ តំបន់នេះត្រូវបានអង្គការសហប្រជាជាតិចាត់ទុកថាជាផ្នែកមួយរបស់ប្រទេសម៉ុលដាវី។

[១០] មានឈ្មោះជាផ្លូវការថារដ្ឋអ៊ីស្រាអែលនៅក្នុងឆ្នាំ១៩៤៨ គឺជាប្រទេសមួយនៅអាស៊ីខាងលិចដែលមានទីតាំងស្ថិតនៅលើច្រាំងសមុទ្រទិសអាគ្នេយ៍នៃសមុទ្រមេឌីទែរ៉ាណេ និងឆ្នេរភាគខាងជើងនៃសមុទ្រក្រហម។

សំណាងល្អរបស់ខ្ញុំចាប់ផ្តើមនៅពេលដែលយើងបានទៅដល់អូសឈ្វិច[១១] ដែលនៅទីនោះប្អូនស្រីខ្ញុំនិងខ្ញុំបានរួចផុតពីការជ្រើសរើសដែលមានន័យថា យើងបានគេចផុតពីការបញ្ជូនទៅបន្ទប់ផ្សែងពុល។ ហេតុការណ៍ចៃដន្យល្អៗបានកើតឡើងជារឿយៗ នៅក្នុងអំឡុងពេលដែលខ្ញុំត្រូវបានគេឃុំឃាំងខ្លួន។ អ្វីដែលសំខាន់នោះ គឺខ្ញុំមិនត្រូវបានគេបញ្ជូនទៅជំរំដែលមានស្ថានភាពអាក្រក់ខ្លាំងនោះទេ។

ពីអូសឈ្វិច ខ្ញុំត្រូវបានគេបញ្ជូនទៅជំរំបីផ្សេងៗពីគ្នាដែលនៅទីកន្លែងនោះកិច្ចការរបស់យើងជាទូទៅ គឺត្រូវសម្អាតសំណង់បាក់បែក។ មនុស្សជាច្រើនទៀតត្រូវបានដាក់នៅក្នុងជំរំដែលពួកគេត្រូវធ្វើការផ្លាស់វេនគ្នានៅក្នុងរោងចក្រក្រោមដី អណ្តូងរ៉ែ ឬក៏កន្លែងជីករ៉ែ។ ជាច្រើនដងមកហើយដែលខ្ញុំបានស្ថិតនៅក្នុងស្ថានការណ៍មួយដែលខ្ញុំប្រាកដក្នុងចិត្តថាគឺជាពេលវេលាចុងក្រោយនៃជីវិតរបស់ខ្ញុំ ប៉ុន្តែរឿងអ្វីមួយផ្សេងទៀតបានកើតឡើង ហើយខ្ញុំក៏បានរួចជីវិត។

នៅក្នុងជំរំ យើងមិនអាចដឹងបានទេថា ការផ្លាស់ប្តូរនឹងមានន័យថាសេចក្តីស្លាប់ឬរស់។ សូម្បីតែពេលខ្លះនៅក្នុងជីវិតប្រចាំថ្ងៃ ក៏យើងមិនអាចដឹងមុនបានទេថាតើជីវិតនឹងមានអ្វីកើតឡើងទេ ។ យើងរស់នៅក្នុងជីវិតមួយស្ងប់ស្ងាត់ ហើយពេលវេលាចេះតែកន្លងផុតទៅដោយយើងមិនបានចាប់អារម្មណ៍អំពីអ្វីទាំងអស់។ ការផ្លាស់ប្តូរកើតឡើងបន្តិចម្តងៗរហូតទាល់តែរំពេចនោះវាបានបង្ហាញចេញជារូបភាពយ៉ាងច្បាស់ក្រឡែតទើបយើងចាប់ផ្តើមឆ្ងល់ថា តើរឿងនេះអាចកើតឡើងបានដោយរបៀបណា? ជីវិតបានបង្រៀនយើងថាអ្វីៗទាំងអស់អាចផ្លាស់ប្តូរបានក្នុងមួយប៉ប្រិចភ្នែក ហើយយើងក៏មិនអាចដឹងមុនបានដែរថាការផ្លាស់ប្តូរនោះនឹងនាំយើងឆ្ពោះទៅរកអ្វីមួយដែលកាន់តែល្អប្រសើរឬក៏កាន់តែអាក្រក់នោះទេ។

ការបង្រៀនរបស់ខ្ញុំនៅក្នុងសាលារៀនជាធម្មតាមាន៣ផ្នែក ដែលផ្តោតសំខាន់ទៅលើផ្នែកទី៣។ ខ្ញុំចាប់ផ្តើមពីការព្យាយាមបង្ហាញអំពីមនុស្ស

[១១] គឺជាក្រុងមួយនៅក្នុងប្រទេសប៉ូឡូញភាគខាងត្បូងដែលគឺជាជំរំប្រមូលផ្តុំធំជាងគេរបស់របបណាហ្ស៊ីក្នុងអំឡុងសង្គ្រាម លោកលើកទីពីរ។



នាពេលអតីតកាលនិងស្ថានភាពរស់នៅរបស់ពួកគេ ដែលជាចំណែកមួយធ្វើឱ្យមានហូឡូខសន៍[១២]។ ក្រោយមកទៀត ខ្ញុំបន្តធ្វើបាឋកថានៅតាមសាលារៀនជាមួយនឹងរឿងរ៉ាវនៃបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំដែលតែងតែបញ្ចប់ជាមួយពេលវេលាគ្រប់គ្រាន់សម្រាប់ឆ្លើយសំណួរសិស្ស។

ខ្ញុំបានបញ្ជាក់ថាគ្មានសំណួរណាជាសំណួរល្ងីល្ងើ ឬក៏ត្រូវហាមឃាត់សួរនោះទេ ប៉ុន្តែសម្រាប់សំណួរខ្លះគឺគ្មានចម្លើយតែម្តង។ ឧទាហរណ៍គឺគ្មានចម្លើយមួយណាច្បាស់លាស់នោះទេសម្រាប់សំណួរថា **"ហេតុអ្វីបានជាហូឡូខសន៍[១៣] កើតឡើង?"** ដល់អ៊ីចឹងវាធ្វើឱ្យសំណួរដែលពាក់ព័ន្ធជាច្រើនទៀតកាន់តែមានសារសំខាន់ឡើង។

ខ្ញុំបានប្រមូលសំណួរទូទៅដែលត្រូវបានសិស្សសួរជាញឹកញាប់មកដាក់ក្នុងសៀវភៅនេះដើម្បីជួយដល់អ្នកដែលចង់ដឹងបន្ថែមអំពីការសម្លាប់រង្គាលនៅអឺរ៉ុប។ ក្តីសង្ឃឹមរបស់ខ្ញុំគឺថា សៀវភៅនេះនឹងត្រូវបានអានព្រមទាំងផ្តល់ជាប្រយោជន៍ដល់យុវវ័យសម័យបច្ចុប្បន្ននិងជំនាន់ក្រោយៗតទៀត។

គោលបំណងនៃសៀវភៅនេះគឺដើម្បីបង្រៀនយើងឱ្យជៀសវាងពីកំហុសប្រវត្តិសាស្ត្រ។ ខ្ញុំសង្ឃឹមថាសៀវភៅនេះនឹងធ្វើឱ្យអ្នកអានទាំងអស់គ្នាដែលបានអានយល់ឃើញថាយើងទាំងអស់គ្នាមិនត្រូវបានជោគវាសនាកំណត់ឱ្យជាស្រេចថានឹងដើរតួជាឧក្រិដ្ឋជន ឬជាអ្នកដែលឈរមើលបំណាំនោះទេ។ ក្នុងនាមជាបុគ្គលម្នាក់ៗ យើងត្រូវមានឆន្ទៈនិងការទទួលខុសត្រូវ ហើយការចាប់យកការទទួលខុសត្រូវនេះហើយដែលធ្វើឱ្យយើងទាំងអស់គ្នាអាចជៀសផុតពីប្រវត្តិសាស្ត្រច្រំដែលបាន។

ខែធ្នូ ឆ្នាំ២០១៦ ហេឌី ហ្វ្រាយ

[១២, ១៣] គឺជាការធ្វើបាបយាយីនិងអំពើប្រល័យពូជសាសន៍ទៅលើជនជាតិជ្វីហ្វចំនួន៦លាននាក់ដោយរបបណាហ្ស៊ីរបស់ហ៊ីត្លែរចាប់តាំងពីឆ្នាំ១៩៣៣ រហូតដល់ចុងបញ្ចប់សង្គ្រាមលោកលើកទី២។ ហូឡូខសន៍គឺជាពាក្យដើមនៃភាសាក្រិកមានន័យថា "បូជាដោយភ្លើង" ឬ "បូជាភ្លើង" ។

“

# VAD ÄR DET VÄRSTA DU VARIT MED OM?

” “

# WHAT IS THE WORST THING THAT HAS HAPPENED TO YOU?

”



## "តើហេតុការណ៍អាក្រក់ខ្លាំងមួយណាដែលបានកើតឡើងចំពោះអ្នក ?"

ប្រសិនបើអ្នកសួរខ្ញុំថា ហេតុការណ៍អាក្រក់មួយណាដែលបានកើតឡើងចំពោះខ្ញុំ នោះខ្ញុំអាចឆ្លើយដោយប្រើតែប្រយោគមួយវាគឺជាពេលដែលខ្ញុំត្រូវបានបំបែកចេញពីឪពុកម្តាយរបស់ខ្ញុំ។

ប៉ុន្តែខ្ញុំចង់ផ្តល់ចម្លើយដែលវែងជាងនេះ។ ខ្ញុំនឹងរៀបរាប់ប្រាប់អ្នកអំពីរឿងរ៉ាវដែលបានកើតឡើង។ គម្រោងការរបស់អាល្លឺម៉ង់ដើម្បីសម្លាប់ផ្តាច់ពូជជនជាតិជ្វីហ្វគឺជាដំណើរការមួយដែលយឺត ហើយត្រូវបានគិតគូរយ៉ាងល្អិតល្អន់។ អ្វីៗប្រៀបបានទៅនឹងភ្នែកទទេដែលមិនអាចសង្កេតឃើញអំពីដំណើរការផ្លាស់ប្តូររូបរាងរបស់ផ្កាដែលប្រែប្រួលចេញពីពន្លករហូតបានក្លាយទៅជាផ្កាកុលាបក្រពុំមួយ។ យើងមិនបានកត់សម្គាល់អំពីជំហានតូចៗ ដែលនាំឆ្ពោះទៅរកភាពជោគជ័យដែលអ្នកមិនអាចស្រមៃឃើញសូម្បីតែនៅក្នុងក្តីសុបិនក៏ដោយ។ គ្រាន់តែក្នុងមួយរំពេចប៉ុណ្ណោះ ការផ្លាស់ប្តូរដ៏អាក្រក់បានកើតឡើង ប៉ុន្តែយើងអាចរស់នៅជាមួយនឹងការផ្លាស់ប្តូរនេះបាន។ យើងបានគិតថា ការផ្លាស់ប្តូរនេះនឹងរំលងផុតទៅ។ ប៉ុន្តែវាមិនបានរំលងផុតនោះទេ ហើយផ្ទុយទៅវិញការផ្លាស់ប្តូរនេះបែរជាមានការផ្លាស់ប្តូរថ្មីថែមមួយទៀត។ ជាថ្មីម្តងទៀតយើងបានសង្ឃឹមថាការផ្លាស់ប្តូរនេះនឹងរំលងហួសទៅដោយរហ័ស។ យើងក៏មិនអាចនឹកស្មានទាល់តែសោះថាជំហានបន្ទាប់ទៀតគឺជាអ្វីនោះឡើយ។

ទោះបីជាខ្ញុំបានឆ្លងកាត់រឿងរ៉ាវទាំងអស់នេះក៏ដោយ ខ្ញុំមានសំណាងល្អ។ រឿងដ៏អាក្រក់បំផុតដែលអាចកើតឡើងចំពោះមនុស្សម្នាក់មិនបានកើតឡើងចំពោះខ្ញុំនោះទេ។ ដំបូងឡើយខ្ញុំមិនត្រូវបានជាប់នៅក្នុង

សំណាញ់របស់អាល្លឺម៉ង់ទេ គឺរហូតទាល់តែជិតចុងបញ្ចប់នៃសង្គ្រាម នារដូវផ្ការីកក្នុងឆ្នាំ១៩៤៤ ដែលនៅពេលនោះជនជាតិជ្វីហ្វនៅអ៊ឺរ៉ុប ជាច្រើននាក់ត្រូវបានចាប់ខ្លួនធ្វើជាអ្នកទោសបាត់អស់ទៅហើយ។ ខ្ញុំកើតនៅស៊ីហ្គេត[១៤] គឺជាទីក្រុងតូចមួយនៅក្នុងប្រទេសរូម៉ានីនៅភាគខាងជើងនៃប្រទេសត្រង់ស៊ីលវ៉ានីនិងគឺជាតំបន់មួយដែលប្រទេសហុងគ្រី និងរូម៉ានីបានវាយដណ្តើមគ្នាអស់រយៈពេលជាច្រើនសតវត្សរ៍។ រហូតមកទល់បច្ចុប្បន្ន ប្រទេសទាំងពីរក៏នៅតែចាត់ទុកថាខ្លួនមានសិទ្ធិទៅលើតំបន់នោះនៅឡើយ។ មុនសង្គ្រាមលោកលើកទី១ ស៊ីហ្គេត គឺជាកម្មសិទ្ធិរបស់ប្រទេសហុងគ្រី និងជាកម្មសិទ្ធិរបស់រាជាធិបតេយ្យអូស្រ្ត-ហុងគ្រី។ ប៉ុន្តែបន្ទាប់ពីសន្ធិសញ្ញាទ្រីអាណុណ[១៥] ក្នុងឆ្នាំ១៩២០ វាត្រូវបានប្រគល់ឱ្យប្រទេសរូម៉ានី ហើយនៅពេលដែលសង្គ្រាមលោកលើកទី២ ផ្ទុះឡើង អាល្លឺម៉ង់ បានដាក់សម្ពាធឱ្យប្រគល់តំបន់នេះទៅឱ្យហុងគ្រីវិញ។ នៅក្នុងខែកញ្ញាឆ្នាំ១៩៤០ ហុងគ្រី បានសម្រុកចូលទៅ ត្រង់ស៊ីលវ៉ានីខាងជើងហើយជោគវាសនារបស់យើងក៏ត្រូវបានកំណត់នៅពេលនោះ។

ច្បាប់ណូរ៉េមប៊ឺក[១៦] មួយចំនួនត្រូវបានអនុវត្តភ្លាមៗដែលមានន័យថាស្ថានភាពហិរញ្ញវត្ថុរបស់ជនជាតិជ្វីហ្វក៏កាន់តែធ្លាក់ដុនដាបជាងមុន។ មន្ត្រីរាជការដែលជាជនជាតិជ្វីហ្វត្រូវបានបញ្ឈប់ពីការងារ។ វេជ្ជបណ្ឌិត និងមេធាវី ដែលជាជនជាតិជ្វីហ្វត្រូវបានអនុញ្ញាតឱ្យព្យាបាល និងធ្វើជាតំណាងរបស់ជនជាតិជ្វីហ្វគ្នាឯងតែប៉ុណ្ណោះ។ ឯអ្នកដែលមិនមែនជាជនជាតិជ្វីហ្វ មិនត្រូវបានអនុញ្ញាតឱ្យទៅទិញអីវ៉ាន់នៅតាមហាងរបស់ជនជាតិជ្វីហ្វទេ។ ហើយក្មេងៗជនជាតិជ្វីហ្វក៏មិនត្រូវបានអនុញ្ញាតឱ្យ

[១៤] បច្ចុប្បន្នហៅថាស៊ីហ្គេតូ ម៉ាម៉ាទៀគឺជាទីក្រុងតូចមួយដែលស្ថិតនៅក្នុងត្រង់ស៊ីលវ៉ានី និងកាន់កាប់ដោយប្រទេសរូម៉ានីបន្ទាប់ពីសង្គ្រាមលោកលើក២បានបញ្ចប់ទៅ។ នៅក្នុងដើមឆ្នាំ១៩៤៤ ជនជាតិជ្វីហ្វចំនួន១៤០០០នាក់ នៅក្នុងទីក្រុងមួយនេះត្រូវបានបញ្ជូនទៅអូសឈ្វិច និងមានចំនួនតែប៉ុន្មានរយនាក់ប៉ុណ្ណោះដែលរួចជីវិតបន្ទាប់ពីចប់សង្គ្រាម។

[១៥] គឺជាកិច្ចព្រមព្រៀងសន្តិភាពដោយក្រុមសម្ព័ន្ធមិត្តនិងប្រទេសហុងគ្រីក្នុងឆ្នាំ១៩២០ ដែលបង្កើតឡើងដើម្បីបញ្ចប់ជាស្ថាពរនូវសង្គ្រាមលោកលើកទី១។

[១៦] គឺជាប្រមុខរដ្ឋមន្ត្រីរបស់ប្រទេសហុងគ្រីដែលកាន់តំណែងចាប់ពីខែមីនា ឆ្នាំ១៩២០ដល់ ខែតុលា ឆ្នាំ១៩៤៤។



ទៅសាលារៀនដែរ។ ស្ថានភាព គឺពិតជាអាក្រក់ខ្លាំងណាស់ ប៉ុន្តែជីវិតរបស់យើងមិនត្រូវបានគំរាមកំហែងឡើយ។ យើងអាចទម្លាប់ខ្លួនទៅនឹងអ្វីៗគ្រប់យ៉ាងបាន។

មេរៀនមួយដែលយើងអាចរៀនបានគឺ មិនត្រូវទម្លាប់ជាមួយនឹងភាពអយុត្តិធម៌ទេ។ ភាពអយុត្តិធម៌ គឺប្រៀបបានដូចជាគ្រាប់ខ្សាច់នៅក្នុងដៃ យើងមិនអាចដឹងអំពីទម្ងន់របស់វាបានទេ។ ប៉ុន្តែភាពអយុត្តិធម៌មានទំនោរក្នុងការកើនឡើង និងមានកាន់តែច្រើនឡើងៗ ហើយមិនយូរមិនឆាប់អ្នកមិនអាចទ្រាំទ្របានទៀតទេ។ ក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណោះដែលភាពអយុត្តិធម៌មួយទៀតនឹងកើតមានឡើង។

យើងត្រូវតែសម្របខ្លួនទៅតាមកាលៈទេសៈរបស់យើង ហើយប្រសិនបើគិតទៅលើអ្វីៗ ដែលកំពុងតែកើតឡើងនៅក្នុងប្រទេសអាល្លឺម៉ង់ និងពិភពលោកទាំងមូល យើងរីករាយដែលយើងនៅតែរស់នៅដោយមិនមានគ្រោះថ្នាក់គំរាមកំហែងដល់ជីវិតរបស់យើង។

ប៉ុន្តែ ហ៊ីត្លែរ មិនអាចទទួលយកបានទេដែលហុងគ្រី-ជ្វីហ្វ ចំនួន ៨០ម៉ឺននាក់រស់នៅដោយសុខស្រួលហើយក៏បានទាមទារឱ្យមានការផ្លាស់ប្តូរឈ្លើយសឹកចំពោះអ្នកទាំងនោះ។ មុនដំបូងប្រមុខរដ្ឋមន្ត្រីមីខលូស ហរហ្ស៊ី[១៧] បានបដិសេធ ប៉ុន្តែគាត់ត្រូវបានគេចាប់ខ្លួនហើយអាល្លឺម៉ង់ក៏បានតែងតាំងមេដឹកនាំចលនារបស់ណាហ្ស៊ីឱ្យធ្វើជានាយករដ្ឋមន្ត្រីជំនួសវិញ។ ហ្វីរេន សាឡាស៊ី[១៨] ក៏ជាអ្នកដែលមានបំណងចង់កំចាត់ជនជាតិជ្វីហ្វម្នាក់ដែរ ដូច្នេះហើយទើបនៅថ្ងៃទី១៩ ខែមីនាឆ្នាំ១៩៤៤ ព្រំប្រទល់ត្រូវបានបើកឱ្យកងទ័ពអាល្លឺម៉ង់ចូលលុក ឬ លុកលុយ។

[១៧] មានតួនាទីជាប្រមុខរដ្ឋមន្ត្រី និងនាយករដ្ឋមន្ត្រីរបស់ប្រទេសហុងគ្រីចាប់ពីខែតុលា ឆ្នាំ១៩៤៤ ដល់ខែមីនា ឆ្នាំ១៩៤៥ បន្ទាប់ពីធ្វើការទម្លាក់ប្រមុខរដ្ឋមន្ត្រីមីខលូស ហរហ្ស៊ីចេញពីតំណែង។

[១៨] មានតួនាទីជាប្រមុខរដ្ឋមន្ត្រីនិងនាយករដ្ឋមន្ត្រីរបស់ប្រទេសហុងគ្រីចាប់ពីខែតុលា ឆ្នាំ១៩៤៤ ដល់ខែមីនា ឆ្នាំ១៩៤៥ បន្ទាប់ពីធ្វើការទម្លាក់ប្រមុខរដ្ឋមន្ត្រីមីខលូស ហរហ្ស៊ី ចេញពីតំណែង។

ចាប់តាំងពីថ្ងៃនោះមក អ្វីៗបានកើតឡើងយ៉ាងឆាប់រហ័ស។ ក្នុងមួយរំពេចជនជាតិជ្វីហ្វនៅក្នុងប្រទេស ហុងគ្រី ត្រូវបានបញ្ជាឱ្យធ្វើផ្កាយពណ៌លឿង ហើយត្រូវពាក់ជាប់អាវរាល់ពេលដែលចេញទៅក្រៅ។ ជនជាតិជ្វីហ្វមិនត្រូវបានអនុញ្ញាតឱ្យចេញក្រៅទេ លុះត្រាតែត្រូវធ្វើការកិច្ចបន្ទាន់។ ជនជាតិជ្វីហ្វមិនអាចឈប់ហើយនិយាយរកគ្នាតាមផ្លូវ មិនអាចទៅរោងភាពយន្ត មិនអាចបរិភោគនៅតាមភោជនីយដ្ឋាន ហើយក៏មិនអាចដើរលេងតាមឧទ្យានបានដែរ។ ច្បាប់ទាំងអស់នេះត្រូវតែគោរពតាម ការមិនស្តាប់បង្គាប់នឹងត្រូវមានទោសសម្លាប់ចោល។ ជាថ្មីម្តងទៀត នេះគឺគ្រាន់តែជាជំហានមួយទៀតរបស់អាល្លឺម៉ង់ ហើយមនុស្សគ្រប់ៗគ្នាក៏បានត្រឹមតែសង្ឃឹមថាអ្វីៗនឹងមិនមានកើតឡើងបន្ថែមទៀតទេ។ ក៏ប៉ុន្តែអ្វីៗបានបន្តកើតមានឡើងតទៅទៀត។

សឹងតែមិនបានបួនសប្តាហ៍ផង យើងត្រូវបានគេប្រាប់ថានៅថ្ងៃបន្ទាប់ការរើទីលំនៅរបស់ជនជាតិជ្វីហ្វចេញពីទីក្រុងទៅនៅកន្លែងផ្សេងនឹងចាប់ផ្តើម។ ជនជាតិជ្វីហ្វដែលរស់នៅក្នុងទីក្រុងទាំងអស់ ត្រូវរើចេញពីមួយផ្លូវទៅមួយផ្លូវដើម្បីទៅហ្គេតូ[១៩] ដែលនៅភាគខាងជើងនៃទីក្រុង។ ផ្លូវរបស់យើងត្រូវបានរើចេញមុនគេ។ យើងត្រូវបានអនុញ្ញាតឱ្យយកតែសម្ភារណាដែលអាចយកទៅតាមខ្លួនបាន និងវេទេះរុញតែប៉ុណ្ណោះ។

អំឡុងពេលដែលយើងចាប់ផ្តើមរៀបចំសម្ភារ ខ្ញុំបានដើរជុំវិញផ្ទះហើយនិយាយពាក្យលាវត្ថុទាំងឡាយណាដែលខ្ញុំមិនអាចយកទៅតាមខ្លួនបាន។ មុនដំបូងខ្ញុំបានលាក់សៀវភៅកំណត់ហេតុរបស់ខ្ញុំនៅក្រោមដំបូលផ្ទះ បន្ទាប់មកខ្ញុំលេងព្យាណូជាលើកចុងក្រោយ ហើយក៏អង្អែលគម្របពេលដែលខ្ញុំបិទ។ ខ្ញុំបានសម្លឹងមើលទៅកាន់ទូរសៀវភៅរបស់ខ្ញុំ អង្អែលសៀវភៅដែលខ្ញុំស្រឡាញ់ ហើយក៏រត់ទៅក្រោយផ្ទះដើម្បីឱបឆ្កែយាមផ្ទះដ៏ស្មោះត្រង់របស់យើងដែលមានឈ្មោះថាបតរី។ ខ្ញុំព្យាយាមរម្ងាប់

[១៩] គឺជាកន្លែងដែលបង្កើតឡើងដោយណាហ្ស៊ីនៅតាមតំបន់តូចៗនៃទីក្រុងដើម្បីបំបែក និងឃុំខ្លួនជនជាតិជ្វីហ្វ។



អារម្មណ៍របស់ខ្ញុំ និងវាដោយគិតថាអ្នកជិតខាងរបស់យើងប្រាកដជាមិនភ្លេចមើលថែវាឡើយ។ត្រឡប់ចូលទៅក្នុងផ្ទះវិញ ខ្ញុំបានឈប់នៅពីខាងមុខរូបថតយាយតារបស់ខ្ញុំហើយសុំឱ្យពួកគាត់ជួយមើលថែរក្សាផ្ទះរបស់យើងពេលដែលយើងមិននៅ។

ខ្ញុំបានជឿជាក់ថាយើងនឹងត្រឡប់មកវិញ។ ការធ្វើសង្គ្រាមរបស់អាល្លឺម៉ង់មិនបានដំណើរការល្អដូចពីមុនទៀតទេពីព្រោះរុស្ស៊ី នៅទីបំផុតមានកម្លាំងរឹងប៉ឹងមិនងាយបំបាក់បានខុសពីការគិតទុកពីមុនមករបស់ពួកអាល្លឺម៉ង់។ ដោយមិនបានគិតជិតដល់ ខ្ញុំគិតថាអាល្លឺម៉ង់នឹងចាញ់សង្គ្រាមឆាប់ៗនេះ ហើយរូម៉ានីនឹងទទួលបានកម្មសិទ្ធិទៅលើទឹកដីរបស់ខ្លួនវិញ។ អ្វីៗគ្រប់យ៉ាងនឹងអាចវិលត្រឡប់មកជាធម្មតាវិញហើយខ្ញុំនឹងអាចទៅរៀននៅមហាវិទ្យាល័យ។

នៅព្រឹកថ្ងៃបន្ទាប់ ខ្ញុំបានដឹងច្បាស់អំពីការពិត។ ប៉ូលីសបានមកផ្ទះរបស់យើង ឪពុកខ្ញុំបានចាក់សោផ្ទះ ហើយទុកកូនសោនៅក្នុងហោប៉ៅរបស់គាត់ បន្ទាប់មកយើងក៏ចាកចេញទៅហ្គេតូ។ ឥឡូវនេះ ពេលវេលាដែលកាន់តែពិបាកបានចាប់ផ្តើមហើយ។ ប៉ុន្តែម្តងទៀត យើងត្រូវតែទម្លាប់ខ្លួនជាមួយនឹងពេលវេលានេះ។ ក្តីសង្ឃឹមថាសង្គ្រាមនឹងឆាប់រលត់ទៅគឺនៅតែមានបន្តជានិច្ច។

ជាថ្មីម្តងទៀត មិនទាន់បានបួនសប្តាហ៍ផង នៅពីរខែបន្ទាប់ពីអាល្លឺម៉ង់បានចូលឈ្លានពានយើងបានឮសំឡេងអ្នកគោះស្គរនៅកាច់ជ្រុងផ្លូវស្រែកថា "យកចិត្តទុកដាក់ស្តាប់! យកចិត្តទុកដាក់ស្តាប់! ជនជាតិជ្វីហ្វទាំងអស់ត្រូវតែរើចេញពីទីនេះ។ ពួកអ្នកអាចវេចអីវ៉ាន់យកតាមខ្លួន២០គីឡូក្រាម ក្នុងម្នាក់ហើយថ្ងៃស្អែកត្រូវតែឈរនៅមុខរបងហ្គេតូដើម្បីត្រៀមខ្លួនចេញដំណើរ"។

ទៅទីណា? គ្មានអ្នកណាដឹងទេ។ ម្ដាយរបស់ខ្ញុំពិតជាពិបាកចិត្តខ្លាំងណាស់។ "ពួកគេប្រាកដជាសម្លាប់យើងចោលជាក់ជាមិនខាន" ម្ដាយរបស់ខ្ញុំនិយាយបណ្ដើរយំបណ្ដើរ។

ខ្ញុំមិនអាចទទួលយកការចុះចាញ់របស់គាត់បានទេ ហើយក៏បានឆ្លើយតបនឹងគាត់ថា "ទេ, ហេតុអ្វីបានជាពួកគេត្រូវធ្វើបែបនោះ។ យើងមិនបានធ្វើអ្វីខុសទេ។ យើងនឹងត្រូវបានគេបញ្ជូនទៅធ្វើការនៅតាមចម្ការពីព្រោះនៅទីនោះគេត្រូវការកម្លាំងដើម្បីសាបព្រួសគ្រាប់ពូជមុនរដូវធ្លាក់ព្រិលមកដល់ រីឯមនុស្សប្រុសនឹងត្រូវបញ្ជូនទៅសមរភូមិ "។

នៅពេលដែលឮបែបនេះ ម្ដាយរបស់ខ្ញុំក៏រម្ងាប់អារម្មណ៍។

តើអ្នកនឹងយកអ្វីទៅតាមខ្លួន ប្រសិនបើគេអនុញ្ញាតឱ្យអ្នកយកបានត្រឹមតែ ២០គីឡូក្រាម? ម្ដាយរបស់ខ្ញុំភាគច្រើនវេចខ្ចប់អាហារ និងយករបស់ណាដែលអាចរក្សាទុកបានយូរ។ យើងបានស្លៀកសម្លៀកបំពាក់ជាច្រើនជាន់ និងពាក់ស្បែកជើងណាដែលរឹងមាំ។ ចំណែកខ្ញុំបានរៀបចំកាបូបតូចមួយដែលមានខោស្ទីបមួយធុត សៀវភៅកំណត់ហេតុរបស់ខ្ញុំ និងសៀវភៅកំណាព្យដោយកវីមួយរូបដែលខ្ញុំចូលចិត្តមានឈ្មោះថា ចូសែវ អាទីលឡា ។ យើងមិនបាននឹកស្មានទាល់តែសោះថាសូម្បីតែទ្រព្យសម្បត្តិចុងក្រោយរបស់យើងក៏ត្រូវបានគេដកហូតដែរ។ នៅព្រឹកថ្ងៃបន្ទាប់ យើងឈរនៅមុខរបងជាមួយអីវ៉ាន់របស់យើង។ យើងត្រូវបានគេបង្គាប់ឱ្យឈរជា៥ជួរ ហើយបន្ទាប់មកធ្វើដំណើរតាមដងផ្លូវនៅក្នុងទីក្រុងទៅកាន់ស្ថានីយរថភ្លើងដែលមានទូរថភ្លើងកំពុងរង់ចាំ។

នៅលើជញ្ជាំងម្ខាងនៃទូរថភ្លើងមានសរសេរពាក្យថា "សម្រាប់សេះ ៨ក្បាល" បន្ទាប់មកពួកយើងត្រូវបានគេរុញប្រជ្រៀតគ្នាចូលទៅក្នុងទូរថភ្លើងដោយក្នុងមួយទូមានមនុស្សចំនួន១០០នាក់។ នៅខាងក្នុងទូរថភ្លើងមានសភាពណែនផ្លឹះហើយងងឹតឈឹង។ មានតែប្រហោងតូចមួយប៉ុណ្ណោះសម្រាប់ឱ្យពន្លឺ និងខ្យល់ចេញចូល។ យើងខំប្រឹងប្រជ្រៀតគ្នាប៉ុន្តែនៅតែគ្មានកន្លែងគ្រប់គ្រាន់សម្រាប់ឱ្យអ្នកទាំងអស់គ្នាអង្គុយទេ។ នៅក្នុងទូរថភ្លើងមានធុងចំនួនពីរសម្រាប់ឱ្យយើងបត់ជើង និងមានធុងទឹកចំនួនពីរផ្សេងទៀត។ ទ្វារត្រូវបានរុញបិតជិតហើយចាក់សោពីក្រៅបន្ទាប់មករថភ្លើងក៏បានចេញដំណើរ។ ការធ្វើដំណើរបានចំណាយអស់រយៈពេលបីថ្ងៃបីយប់នៅក្នុងស្ថានភាពដ៏គួរឱ្យខ្ពើមរអើម។

រថភ្លើងបានឈប់នៅតាមចំណតម្ដងម្កាល ហើយក្លិនស្អុយ និងការស្រេកទឹកស្ទើរតែមិនអាចធ្វើឱ្យយើងទ្រាំទ្របាន។ យើងបានសុំអង្វរឱ្យជួយប៉ុន្តែការអង្វររបស់យើង គឺគ្មានប្រយោជន៍ទាល់តែសោះ ហើយស្ថានភាពបែបនេះបន្តរហូតដល់ថ្ងៃទី១៧ និងទី១៨ខែឧសភា។ នៅពេលនោះគឺជាពេលដែលយើងបានទៅដល់អូសឈ្វិច។

“VARFÖR HATADE HITLER JUDARNA?” 

“WHY DID HITLER HATE THE JEWS?”

# "ហេតុអ្វីបានជា ហ៊ីត្លែរ ស្អប់ជនជាតិជ្វីហ្វ?"

ខ្ញុំបានចងចាំកំប្លែងដ៏គួរឱ្យស្អប់មួយ ដែលនិយាយតៗគ្នាក្នុងអំឡុងពេលសង្គ្រាម។ ចេកុប បានសួរ ដាណៀល ថា "អ្នកណាជាអ្នកចាប់ផ្តើមសង្គ្រាម?" ហើយ ដាណៀល បានឆ្លើយតបទៅវិញថា "ជនជាតិជ្វីហ្វ និងអ្នកជិះកង់"។ "ហេតុអ្វីបានជាអ្នកជិះកង់?" ចេកុបសួរ "ហេតុអ្វីបានជាជនជាតិជ្វីហ្វ?" ដាណៀលឆ្លើយតប។

ពេលធំដឹងក្តី ខ្ញុំបានចាប់ផ្តើមដឹងអំពីពិភពលោកដ៏ធំធេងដែលនៅក្រៅបន្ទប់តូចរបស់ខ្ញុំ។ ខ្ញុំដឹងថាក្មេងៗដទៃទៀតរស់នៅក្នុងជីវភាពផ្សេងពីខ្ញុំ។ មនុស្សទាំងអស់មិននិយាយភាសាដូចគ្នានោះទេ ហើយមនុស្សទាំងអស់នោះក៏មិនទៅវិហារជ្វីហ្វដូចខ្ញុំដែរ។ ខ្ញុំយល់អំពីការសន្ទនារបស់ឪពុកម្តាយខ្ញុំបានច្រើន ហើយខ្ញុំក៏ចាប់ផ្តើមមានអារម្មណ៍ថាភ័យខ្លាច។ តើមានរឿងអ្វីបានកើតឡើង? ឪពុកម្តាយរបស់ខ្ញុំបានពិភាក្សាអំពីរឿងនយោបាយ អំពីការបោះឆ្នោតខាងមុខនេះថែមទាំងគ្រោះថ្នាក់ដែលអាចនឹងកើតមានឡើងចំពោះយើងដែលជាជនជាតិជ្វីហ្វ ប្រសិនបើគណបក្សប្រឆាំងនឹងជនជាតិជ្វីហ្វឈ្នះឆ្នោត។ នៅពេលនោះពួកសេរីកំពុងតែកាន់កាប់អំណាចនៅឡើយ ហើយខ្ញុំក៏មានមោទនភាពខ្លាំងដែលអ៊ំរបស់ខ្ញុំ គឺជាសមាជិកម្នាក់របស់រដ្ឋសភា។ ខ្ញុំក៏បានស្តាប់ពីការពិភាក្សាអំពីប្រទេសអាល្លឺម៉ង់ដែលជាប្រទេសមួយដែលនៅឆ្ងាយ ហើយបក្សដែលធ្វើបាបយាយីទៅលើជនជាតិជ្វីហ្វ កំពុងតែកាន់អំណាច។ "ហេតុអ្វី?" ខ្ញុំសួរ។

ឪពុករបស់ខ្ញុំបានប្រាប់ខ្ញុំអំពីប្រវត្តិរបស់ក្រុមប្រឆាំងនឹងជនជាតិជ្វីហ្វ។ អំពីជំនឿរបស់មនុស្សនៅទីក្រុងអឺរ[២០] ទៅលើព្រះផ្សេងៗពីគ្នាកាលពីជំនាន់មុន។

នៅមេសូប៉ូតាមៀ[២១] មានក្រុមកុលសម្ព័ន្ធតូចមួយដែលដឹកនាំដោយបុរសម្នាក់មានឈ្មោះថាថេរា ដែលជាជាងសូនរូបព្រះ។ ប៉ុន្តែកូនប្រុសរបស់គាត់ឈ្មោះ អាប្រាហាម មិនជឿថារូបព្រះដែលសង់ពីដីហើយគ្មានជីវិតនោះអាចនឹងគ្រប់គ្រងពិភពលោកបានទេ។ គាត់បានជឿជាក់ថាប្រាកដជាមានថាមពលខ្លាំងក្លាជាងនេះដែលមិនអាចមើលឃើញបាន។ សាសនាថ្មីក៏បានករកើតឡើង ដែលជឿទៅលើព្រះតែមួយគត់ ហើយអាប្រាហាម គឺជាស្ថាបនិក។ សាសនានេះត្រូវបានគេដាក់ឈ្មោះថា សាសនាយូដា[២២] ហើយត្រូវបានផ្សព្វផ្សាយពាសពេញពិភពលោក។ ប៉ុន្តែមនុស្សមួយចំនួននៅក្នុងពិភពលោកមិនអាចទទួលស្គាល់សាសនានេះបាននោះទេ។

បន្ទាប់ពីការប្រសូតរបស់ព្រះយេស៊ូ ជំនឿទៅលើព្រះថ្មីមួយទៀតបានចាប់ផ្តើមរីកពលដាលហើយត្រូវបានគេស្គាល់ថាជាសាសនាគ្រិស្ត។ ព្រះយេស៊ូផ្ទាល់ក៏ជាជនជាតិជ្វីហ្វ ដែលទ្រង់គឺជាគ្រូបុព្វជិតម្នាក់ក្នុងចំណោមក្រុមជនជាតិជ្វីហ្វដ៏ទៃទៀតដែលបង្រៀននិងផ្សព្វផ្សាយពីច្បាប់របស់ជ្វីហ្វ។

មិនយូរមិនឆាប់ មនុស្សជាច្រើនបានចាប់ផ្តើមជឿទៅលើព្រះយេស៊ូ ហើយកូនសិស្សរបស់គាត់ក៏បានចេញទៅពិភពលោកខាងក្រៅដើម្បីផ្លាស់ប្តូរអ្នកដែលមិនកាន់សាសនាឱ្យជឿទៅលើព្រះ។ អ្នកបង្រៀនសាសនាគ្រិស្តក៏បានព្យាយាមបញ្ចុះបញ្ចូលជនជាតិជ្វីហ្វឱ្យជឿទៅលើព្រះយេស៊ូ

[២០] គឺជាទីក្រុងស៊ូមីរៀនបុរាណដែលធ្លាប់មានទីតាំងនៅតាមដងទន្លេយ៉ូប្រេហ្វ្រតនៅភាគខាងត្បូងប្រទេសអ៊ីរ៉ាក់ដែល គឺជាទីក្រុងមួយក្នុងចំណោមទីក្រុងដែលចាស់ជាងគេរបស់មេសូប៉ូតាមៀតាំងពីសម័យសហាស្សវត្សរ៍ទី៤ មុនគ.ស។

[២១] គឺជាតំបន់បុរាណមួយនៅភាគខាងកើតនៃសមុទ្រមេឌីទែរ៉ាណេ និងមានព្រំប្រទល់ភាគខាងជើងឆៀងខាងលិចជាប់ភ្នំហ្សាគ្រុសរីឯភាគអាគ្នេយ៍ជាប់ប្រទេសអ៊ីរ៉ាន ស៊ីរី និងតួគី។

[២២] គឺជាសាសនាបុរាណមួយរបស់ជនជាតិជហ្វីហ្វដែលមានជំនឿទៅលើព្រះតែមួយគត់។



ប៉ុន្តែនៅពេលដែលជនជាតិជ្វីហ្វបដិសេធយ៉ាងម៉ឺងម៉ាត់ ពួកគេបែរជាត្រូវបានចោទប្រកាន់ថា បានសម្លាប់ព្រះយេស៊ូទៅវិញ។ ការបៀតបៀនទៅលើជនជាតិជ្វីហ្វក៏បានកើតឡើងយ៉ាងខ្លាំងនៅក្នុងទម្រង់មួយដែលមានតែភាពស្អប់ខ្ពើម។

ការចោទប្រកាន់ដែលគ្មានភស្តុតាងជាច្រើនបានរីករាលដាល ហើយការតាមចាប់រកធ្មប់ដែលជាជនជាតិជ្វីហ្វ នៅតាមកន្លែងជាច្រើនបានក្លាយទៅជារឿងសាមញ្ញមួយដែលកើតឡើងតៗគ្នាជាច្រើនសតវត្សរ៍។ ការចោទប្រកាន់ពីរនៅតែកើតមានឡើងរហូតមកទល់សព្វថ្ងៃ ទោះបីជាការពិតត្រូវបានបញ្ជាក់ជាច្រើនដងថាការចោទប្រកាន់នោះគ្មានភ័ស្តុតាងពិតប្រាកដណាមួយក៏ដោយ។

ការចោទប្រកាន់មួយបាននិយាយថា ជនជាតិជ្វីហ្វបានសម្លាប់ក្មេងតូចៗ ដើម្បីយកឈាមរបស់ពួកក្មេងៗទាំងនោះមកដុតនំប៉័ងសំរាប់បុណ្យអ៊ីសស្ទឺ[២៣] ។ ពាក្យចចាមអារ៉ាមនេះបានរីករាលដាលដំបូងនៅក្នុងមជ្ឈិមសម័យ នៅក្នុងភូមិមួយនៅប៉ែកខាងជើងនៃអឺរ៉ុប។ នាថ្ងៃមួយនៅដើមរដូវផ្ការីក ក្មេងប្រុសសាសនាគ្រិស្តម្នាក់បានបាត់ខ្លួន ហើយអ្នកដុតនំប៉័ងជនជាតិជ្វីហ្វម្នាក់ ត្រូវបានទទួលរងការចោទប្រកាន់ថាបានសម្លាប់ក្មេងប្រុសម្នាក់នោះដើម្បីយកឈាមមកដុតនំប៉័ង អ៊ីសស្ទឺ។ សាក្សីក្លែងក្លាយជាច្រើនបានចេញមុខ ហើយអះអាងថាខ្លួនបានឃើញហេតុការណ៍នោះផ្ទាល់។ ការអះអាងនេះ គឺគ្រប់គ្រាន់ក្នុងការធ្វើឱ្យអ្នកភូមិទាំងអស់ដាក់ដំបងតាមខ្លួន និងបង្កើតចលនាមួយដើម្បីសម្លាប់ផ្តាច់ពូជជនជាតិជ្វីហ្វ។

បន្ទាប់មក នៅពេលដែលផ្ទាំងទឹកកកនៅលើទន្លេមួយនៅក្បែរភូមិបានរលាយ សាកសពរបស់ក្មេងប្រុសម្នាក់នោះបានអណ្តែតចេញមក ប៉ុន្តែវាមិនអាចជួយអ្វីបានទេ។ ភូមិដទៃទៀតនៅតែមានការចោទប្រកាន់បែប

[២៣] បុណ្យអ៊ីសស្ទឺ គឺជាពិធីបុណ្យរបស់គ្រិស្តបរិស័ទដែលប្រារព្ធឡើងដើម្បីអបអរការរស់ឡើងវិញរបស់ព្រះយេស៊ូគ្រិស្ត។

នេះនៅពេលណាដែលមានក្មេងស្លាប់ក្នុងភូមិ។ ការកាត់ក្តីលើកចុងក្រោយទៅលើហេតុការណ៍បែបនេះត្រូវបានធ្វើឡើងនៅប្រទេសហុងគ្រីអំឡុងឆ្នាំ១៨៨៣។ ការចោទប្រកាន់គ្មានមូលដ្ឋានច្បាស់លាស់មួយទៀត គឺពិធីសាររបស់ក្រុមព្រឹទ្ធាចារ្យហ្សាយអ៊ុន[២៤] ដែលជារឿងប្រឌិតមានប្រភពចេញមកពីរាជវង្សត្សារនៃប្រទេសរុស្ស៊ី។ ការចោទប្រកាន់នេះគឺជារឿងប្រឌិតឡើងថា ជនជាតិជ្វីហ្វ បានកាន់អំណាចជាអ្នកដឹកនាំពាសពេញពិភពលោក។ នៅក្នុងកិច្ចប្រជុំមួយនៅចុងសតវត្សរ៍ទី១៩ ពួកគេត្រូវបានអះអាងថា បានរៀបចំផែនការលម្អិតមួយដើម្បីសម្រេចបាននូវផែនការត្រួតត្រាពិភពលោក។ ហ៊ីត្លែរ បានចាត់ទុករឿងព្រេងនិទាននេះថាជាការពិតដែលធ្វើឱ្យគាត់មានអារម្មណ៍ភ័យខ្លាចចំពោះជនជាតិជ្វីហ្វ ហើយក៏សម្តែងចេញនូវការស្អប់ខ្ពើម និងប្តេជ្ញាចិត្តក្នុងការសម្លាប់ផ្តាច់ពូជជនជាតិជ្វីហ្វ។

ភាពស្អប់ខ្ពើមរបស់ហ៊ីត្លែរចំពោះជនជាតិជ្វីហ្វ គឺខ្លាំងក្លាណាស់ រហូតដល់អ្នកអាចនិយាយបានថា ហ៊ីត្លែរ មិនមែនធ្វើសង្គ្រាមប្រឆាំងនឹងក្រុមសម្ព័ន្ធមិត្តទេ ប៉ុន្តែគឺជាមួយនឹងជនជាតិជ្វីហ្វឯណោះទៅវិញ។ ទោះបីជាអាល្លឺម៉ង់គ្មានរថភ្លើងគ្រប់គ្រាន់សម្រាប់ដឹកជញ្ជូនទាហានទៅកាន់សមរភូមិយ៉ាងណាក៏ដោយ ក៏ហ៊ីត្លែរនៅតែខំប្រឹងប្រមែប្រមូលរទេះដើម្បីដឹកជនជាតិជ្វីហ្វទៅអូសឈ្វិចដែរ។

ប្រជាជនអាល្លឺម៉ង់ភាគច្រើនមិនមែនជាអ្នកប្រឆាំងនឹងជនជាតិជ្វីហ្វទេ។ ដូច្នេះហើយទើបបានជាមានតម្រូវការខ្លាំងក្លាមួយក្នុងការជំរុញឱ្យមានការប្រឆាំងនឹងជនជាតិជ្វីហ្វនៅក្នុងចំណោមប្រជាជនអាល្លឺម៉ង់ ចំណែកឯរដ្ឋមន្ត្រីឃោសនារបស់ណាហ្ស៊ីដែលមានឈ្មោះថាហ្គូបេល[២៥]

[២៤] មានឈ្មោះជាភាសាអង់គ្លេស The Protocols of the Elders of Zion គឺជាសៀវភៅដែលបោះពុម្ពឡើងនៅក្នុង ប្រទេសរុស្ស៊ីនៅចុងសតវត្សរ៍ទី១៩ ដើម្បីផ្សព្វផ្សាយប្រឆាំងនឹងជនជាតិជ្វីហ្វ។ នៅក្នុងសៀវភៅនេះគឺបានប្រឌិតឡើងអំពីគម្រោងរបស់ជនជាតិជ្វីហ្វក្នុងការគ្រប់គ្រងពិភពលោក។

[២៥] ហ្គូបេល (Goebbel) គឺជារដ្ឋមន្ត្រីឃោសនារបស់ណាហ្ស៊ីចាប់តាំងពីឆ្នាំ ១៩៣៣ ដល់ ១៩៤៥ ។ ហ្គូបេលគឺជាអ្នកដែលជិតស្និទ្ធជាមួយនឹងហ៊ីត្លែរហើយក៏ជាអ្នកដែលគាំទ្រហ៊ីត្លែរខ្លាំងបំផុតដែរ។



ក៏មានភាពប៉ិនប្រសប់នឹងភារកិច្ចនេះដែរ។ ខ្សែភាពយន្ត សិល្បៈ អក្សរសិល្ប៍ និង ការអប់រំ និងអ្វីៗផ្សេងទៀតសុទ្ធសឹងតែបានបង្ហាញតាមរយៈគោលលទ្ធិប្រឆាំងនឹងជនជាតិជ្វីហ្វ។ ការប្រកាន់ពូជសាសន៍ត្រូវបានផ្តិតជាប់យ៉ាងមាំនៅក្នុងគំនិតរបស់ជនជាតិអាល្លឺម៉ង់។ ក្មេងៗជនជាតិអាល្លឺម៉ង់ត្រូវបានគេបង្រៀនថាជនជាតិជ្វីហ្វមិនមែនជាមនុស្សទេ យើងត្រូវតែកំចាត់ចោលពួកគេទាំងអស់នោះ។ ជនជាតិជ្វីហ្វ គឺជាសត្វល្អិតចង្រៃដែលត្រូវតែកំចាត់ចោល ហើយជនជាតិជ្វីហ្វក៏ជាមេរោគមហារីកដែលកំពុងតែកកើតឡើងនៅលើរាងកាយស្អាតរបស់ចក្រភពអាល្លឺម៉ង់ ហើយមហារីកនេះត្រូវតែកំចាត់ចោល។

ចម្លើយយ៉ាងសាមញ្ញបំផុតសម្រាប់សំណួរខាងលើគឺ ហ៊ីត្លែរ ស្អប់ជនជាតិជ្វីហ្វដោយសារតែពួកគេគឺជា ជ្វីហ្វ ហ្នឹងឯង។

“

# HUR LEVDE NI FÖRE KRIGET?

” “

# WHAT WAS YOUR LIFE LIKE BEFORE THE WAR?

”



# "តើជីវិតរបស់អ្នកមុនពេលសង្គ្រាមមានលក្ខណៈយ៉ាងដូចម្តេចដែរ?"

ជីវិតនៅក្នុងទីក្រុងតូចដ៏ស្ងប់ស្ងាត់មួយនៅស៊ីហ្គេត មិនសូវមានព្រឹត្តិការណ៍សំខាន់ៗកើតឡើងទេ។ ប្រជាជនចំនួន៣ម៉ឺននាក់ ដែលរស់នៅទីក្រុងនេះគឺសម្បូរទៅដោយជនជាតិភាគតិចផ្សេងៗគ្នា ហើយភាគច្រើនគឺជាជនជាតិជ្វីហ្វ។ នៅពេលដែលខ្ញុំគិតអំពីវា ខ្ញុំបាននឹកឃើញអនុស្សាវរីយ៍មួយចំនួនដែលអាចបង្ហាញឱ្យឃើញថាជីវិតពេលនោះមានលក្ខណៈបែបណា។

នៅពេលនោះខ្ញុំមានអាយុ៣ឆ្នាំ ហើយទើបតែចាប់ផ្តើមចូលរៀនថ្នាក់មត្តេយ្យសិក្សា។ ពេលនោះខ្ញុំមានអារម្មណ៍ថាខ្លួនឯងធំហើយ។ ប៉ុន្មានថ្ងៃបន្ទាប់មកខ្ញុំបានទាមទារមិនឱ្យមាននរណាទៅទទួលខ្ញុំពីសាលារៀនទេពីព្រោះខ្ញុំចង់ដើរមកផ្ទះដោយខ្លួនឯង។ ម្តាយរបស់ខ្ញុំមិនចង់យល់ព្រមទេ ប៉ុន្តែចុងក្រោយភាពចចេសរឹងរូសរបស់ខ្ញុំក៏បានឈ្នះ។ នៅពេលនោះគឺម៉ោង១២ថ្ងៃត្រង់ ហើយក្មេងតូចៗ មួយក្រុមចេញទៅខាងក្រៅរបងសាលាដើម្បីចេញទៅផ្ទះហើយមានខ្ញុំនៅកណ្តាលគេ។ អ្នកខ្លះទៅស្តាំឯអ្នកខ្លះទៀតទៅឆ្វេង។ ខ្ញុំរវល់តែយកចិត្តទុកដាក់ស្តាប់ការសន្ទនារបស់ពួកម៉ាកដែលមានអាយុច្រើនជាង ក៏មិនបាននឹកគិតថានឹងទៅផ្ទះតាមផ្លូវណា។ ដោយមិនបានសម្លឹងមើលជុំវិញខ្លួន ខ្ញុំក៏បានដើរតាមពួកម៉ាករបស់ខ្ញុំទៅខាងឆ្វេងដៃ។

នៅពេលដែលយើងកំពុងតែដើរ ខ្ញុំចាប់អារម្មណ៍ថាមិត្តរួមថ្នាក់របស់ខ្ញុំចាប់ផ្តើមដើរទៅផ្លូវផ្សេងៗពីគ្នារហូតសល់តែខ្ញុំនឹងពួកម៉ាករបស់ខ្ញុំម្នាក់ទៀតដែលកំពុងតែនិយាយគ្នា។ ប៉ុន្តែភ្លាមៗនោះពាក្យដែលត្រូវនិយាយទាំងប៉ុន្មានត្រូវបានគាំងជាប់នៅពេលដែលពួកម៉ាករបស់ខ្ញុំបានឈប់នៅ

មុខរបងផ្ទះមួយ។ ខ្ញុំនៅតែម្នាក់ឯងទេ។ ពេលនោះហើយគឺជាពេលដែលខ្ញុំចាប់ផ្ដើមមើលជុំវិញខ្លួន ហើយមិនដឹងថាខ្លួនឯងនៅទីណានោះទេ។ ខ្ញុំមានអារម្មណ៍ភ័យខ្លាចយ៉ាងខ្លាំងពេលដែលដឹងថាខ្លួនឯងកំពុងតែវង្វេងផ្លូវ។ ខ្ញុំក៏ចាប់ផ្ដើមយំយ៉ាងខ្លាំង។

មានមនុស្សស្រីម្នាក់បានអើតចេញមកក្រៅបង្អួចហើយសួរថាហេតុអ្វីបានជាខ្ញុំយំ។ ខ្ញុំបានឆ្លើយប្រាប់គាត់ថាខ្ញុំមិនស្គាល់ផ្លូវទៅផ្ទះរបស់ខ្ញុំវិញនោះទេ។

"តើឯងឈ្មោះអ្វី?" គាត់សួរ

"ហេឌី" ខ្ញុំឆ្លើយ។

"តើឯងជាកូនរបស់អ្នកណា?"

"ឪពុករបស់ខ្ញុំ"

"តើឯងរស់នៅឯណា?"

"នៅក្នុងផ្ទះដែលមានរបងពណ៌ក្រហម"។

"កុំយំអីហេឌី" គាត់បាននិយាយបន្ត "ខ្ញុំនឹងជូនឯងទៅផ្ទះ" ។ ទីក្រុងដែលខ្ញុំរស់នៅមានទំហំតូចល្មមដែលអាចធ្វើឱ្យគាត់ចំណាំខ្ញុំបាន ពីព្រោះខ្ញុំមានមុខមាត់ដូចឪពុករបស់ខ្ញុំ។

មនុស្សជាច្រើននៅស៊ីហ្គេតស្គាល់គ្នាទោះបីជាពួកគេមិនដែលមានទំនាក់ទំនងជាមួយគ្នាក៏ដោយ។ ជីវិតរស់នៅក៏ទៅតាមរបៀបស្រដៀងគ្នារវាងប្រជាជននៅក្នុងក្រុមផ្សេងៗពីគ្នាហើយការបែងចែកជាក្រុម គឺសំដៅទៅលើវណ្ណៈជាជាងតាមជាតិសាសន៍។ មានអ្នកដែលក្រខ្លាំងនិងអ្នកដែលមានជាង។ ក្រុមគ្រួសាររបស់យើងគឺនៅក្នុងក្រុមដែលជាអ្នកមានជាង។ អ្នកទាំងអស់គ្នាដែលនៅក្នុងក្រុមនេះមានអ្នកជំនួយតាមផ្ទះឬសព្វថ្ងៃនេះគេហៅថាអ្នកបម្រើ។



អាន់ណា អ្នកបម្រើរបស់យើងក្រោកពីដំណេកនៅម៉ោង៦ព្រឹកហើយអុជភ្លើងចង្ក្រានដើម្បីកុំឱ្យយើងភ្ញាក់ពីគេងនៅក្នុងបន្ទប់ដែលត្រជាក់ខ្លាំង។ អាន់ណា ត្រូវលួងលោមយើងឱ្យភ្ញាក់ពីគេងរាល់ព្រឹកពីព្រោះតែយើងរងាហើយមិនចង់ក្រោកចេញពីគ្រែ បន្ទាប់មកគាត់ស្លៀកសម្លៀកបំពាក់ឱ្យពួកយើង បញ្ចុកអាហារពេលព្រឹករួចមកទើបនាំយើងទៅសាលារៀន។ បន្ទាប់ពីនេះទើបឪពុកម្ដាយរបស់យើងក្រោកពីដំណេក។ បន្ទាប់ពីអាហារពេលព្រឹករួចឪពុករបស់ខ្ញុំទៅធ្វើការ រីឯម្ដាយរបស់ខ្ញុំទៅផ្សារដើម្បីទិញអីវ៉ាន់។

“

# NÄR FÖRSTOD DU ATT DIN FAMILJ VAR I FARA?

” “

# WHEN DID YOU REALISE THAT YOUR FAMILY WAS IN DANGER?

”



## "តើនៅពេលណាដែលអ្នកដឹងថាគ្រួសាររបស់អ្នកស្ថិតនៅក្នុងគ្រោះថ្នាក់ ?"

ខ្ញុំមិនអាចចាំបានទេថានៅពេលណាដែលខ្ញុំដឹងថាគ្រួសាររបស់ខ្ញុំមានគ្រោះថ្នាក់។ ប៉ុន្តែនៅពេលដែលខ្ញុំដឹង ខ្ញុំដឹងថានោះគឺជាគ្រោះថ្នាក់ដែលជនជាតិជ្វីហ្វទាំងអស់ជួបប្រទះមិនមែនមានតែគ្រួសាររបស់ខ្ញុំទេ។ គំនិតបែបនេះប្រាកដជាមាននៅក្នុងខួរក្បាលរបស់ខ្ញុំយូរមកហើយមុនពេលដែលវាចាប់ផ្តើមពញ្ញាក់ស្មារតីរបស់ខ្ញុំនៅពេលវ័យជំទង់។

វាចាប់ផ្តើមនៅពេលដែលខ្ញុំមានអាយុ១៤ឆ្នាំ ហើយបានស្រឡាញ់បុរសម្នាក់ដែលធ្វើការនៅក្នុងការិយាល័យប្រៃសណីយ៍មួយ។ ពាក្យចចាមអារ៉ាមអំពីសង្គ្រាមបានផ្សព្វផ្សាយ ហើយសាលារៀនបានបង្ហាត់បង្រៀនមនុស្សវ័យក្មេងឱ្យចេះជួយគ្នានៅពេលណាដែលជម្លោះផ្ទុះឡើង។ យើងត្រូវបានអនុញ្ញាតឱ្យជ្រើសរើសមុខជំនាញដែលយើងចង់រៀន។ អ្នកខ្លះជ្រើសរើសយកមន្ទីរពេទ្យដើម្បីរៀនធ្វើជាគិលានុបដ្ឋាយិកា រីឯខ្លះទៀតជ្រើសរើសនគរបាល ចំណែកឯខ្ញុំជ្រើសយកការិយាល័យប្រៃសណីយ៍។

យើងមានគ្នា៦នាក់ដែលដឹកនាំដោយគ្រូសិល្បៈបានដើរចូលទៅក្នុងការិយាល័យប្រៃសណីយ៍។ ខ្ញុំសប្បាយចិត្តនិងរំភើបយ៉ាងខ្លាំង។ ខ្ញុំនឹងបានជួបបុរសដែលខ្ញុំស្រលាញ់ ហើយព្រមទាំងអាចរៀនអំពីលេខកូដសម្ងាត់ម៉ស[២៦] ដែលខ្ញុំចូលចិត្ត។ យើងត្រូវបានប្រធានប្រៃសណីយ៍ផ្តល់ការស្វាគមន៍យ៉ាងអធិកអធម បន្ទាប់មកគាត់បានពន្យល់យើងអំពីភាពមិនច្បាស់លាស់របស់ស្ថានភាពនយោបាយ និងសារសំខាន់របស់សេវាប្រៃសណីយ៍នៅក្នុងពេលនេះ។ គាត់ក៏បានរៀបរាប់អំពីកិច្ចការដែលបានធ្វើឡើងនៅការិយាល័យប្រៃសណីយ៍...មកដល់ទីនេះគាត់បាន

[២៦] លេខកូដសម្ងាត់ម៉ស គឺជាមធ្យាបាយទំនាក់ទំនងដោយប្រើសម្លេងវែងឬខ្លីដែលតំណាងឱ្យអក្សរឡាតាំង នីមួយៗ និងលេខ។ សារសម្ងាត់នេះជាទូរទៅគឺផ្ញើតាមទូរលេខអគ្គិសនី។

ឈប់និយាយហើយសម្លឹងជុំវិញបន្ទាប់មកក៏សួរថា "ខ្ញុំចាត់ទុកថាអ្នកនៅទីនេះទាំងអស់គឺជាជនជាតិ រ៉ូម៉ានី ?"

គ្រូបានមើលមកខ្ញុំហើយឆ្លើយយ៉ាងស្ទាក់ស្ទើរថា "អត់ទេមិនមែនទាំងអស់គ្នាទេ"។

ប្រធានប្រៃសណីយ៍បានដាក់ក្រដាសនៅក្នុងដៃគាត់ចុះ ហើយនិយាយថា "ប្រសិនបើបែបនេះ យើងមិនអាចបន្តបានទៀតទេ"។ យើងទាំងអស់គ្នាត្រូវត្រឡប់ទៅផ្ទះវិញ។ ខ្ញុំត្រឡប់មកផ្ទះវិញ ហើយយំយ៉ាងខ្លាំង។ ម្តាយរបស់ខ្ញុំគាត់ខ្លាចណាស់ គាត់គិតថារឿងអាក្រក់បានកើតឡើងមកលើរូបខ្ញុំ។ "តើមានរឿងអ្វីកើតឡើង ?" គាត់សួរហើយសួរទៀត។ ខ្ញុំបានត្រឹមតែយំ។ ចុងក្រោយខ្ញុំក៏ប្រាប់គាត់។ ខ្ញុំពិតជាខឹង និងអាម៉ាស់ខ្លាំងណាស់។ ខ្ញុំចង់ឱ្យម្តាយរបស់ខ្ញុំសន្យាថាយើងនឹងចាកចេញពីប្រទេសមួយនេះ។ ខ្ញុំមិនអាចរស់នៅក្នុងកន្លែងដែលមើលងាយខ្ញុំ ហើយចាត់ទុកខ្ញុំជាអនុប្រជាជននោះទេ។ ទន្ទឹមនឹងនោះដែរ ឪពុករបស់ខ្ញុំបានមកផ្ទះដើម្បីពិសាអាហារថ្ងៃត្រង់ ហើយគាត់ទាំងពីរក៏ព្យាយាមលួងលោមឱ្យខ្ញុំផ្លាស់ប្តូរចិត្ត។ ឪពុកម្តាយរបស់ខ្ញុំបានព្យាយាមពន្យល់ថា យើងមិនមានកន្លែងដែលត្រូវទៅទេ ហើយការប្រឆាំងនឹងជនជាតិជ្វីហ្វ កើតមានឡើងគ្រប់កន្លែងទាំងអស់នៅក្នុងពិភពលោក ដរាបណាយើងគ្មានប្រទេសដែលជារបស់យើងៗគ្មានជម្រើសនោះទេ យើងត្រូវតែសម្របខ្លួន។ ខ្ញុំមិនចង់សម្របខ្លួនទេ ហើយក៏មិនចង់ទទួលស្គាល់ហេតុការណ៍ទាំងអស់នេះដែរ ប៉ុន្តែចុងក្រោយខ្ញុំបានរម្ងាប់អារម្មណ៍របស់ខ្លួនឯង។ នេះគឺប្រហែលជាការភ្ញាក់ខ្លួនដំបូងរបស់ខ្ញុំ។

ពេលវេលាបានកន្លងផុតទៅ ការគំរាមកំហែងក៏កាន់តែខិតជិតចូលមកដល់។ ខ្ញុំមិនអាចចងចាំអំពីអារម្មណ៍ភ័យខ្លាចបានទេ។ អ្វីៗប្រៀបបានដូចជាអារម្មណ៍មួយដែលពិបាកនឹងពន្យល់ដូចជាសម្ពាធមួយនៅក្នុងដើមទ្រូងរបស់ខ្ញុំ ពេលខ្លះវាខ្លាំង ឯពេលខ្លះទៀតវាខ្សោយ ប៉ុន្តែវាមិនដែលបាត់ទៅណាទេ។ មនុស្សទូទៅមិនដែលចង់ជឿទេថារឿងមិនល្អអាចនឹង



កើតឡើងមកលើខ្លួន។ ឯខ្ញុំចង់ជឿទៅលើពាក្យរបស់កងការពារណាហ្ស៊ី[២៧] ដែលបានប្រាប់ឪពុករបស់ខ្ញុំថាអ្វីៗ ដែលបានឮអំពីការធ្វើបាបយាយីទៅលើជនជាតិជ្វីហ្វ គឺគ្រាន់តែជាពាក្យចចាមអារ៉ាមតែប៉ុណ្ណោះជនជាតិអាល្លឺម៉ង់គឺជាពលរដ្ឋដែលមានអរិយធម៌ខ្ពង់ខ្ពស់។

ពេលខ្លះខ្ញុំគិតអំពីអ្វីដែលម្តាយរបស់ខ្ញុំបាននិយាយអំពីការសម្របខ្លួនហើយតើវាមានភាពងាយស្រួលយ៉ាងណា។

ខ្ញុំគ្មានថ្ងៃអាចសម្របខ្លួនបានទេ ខ្ញុំបាននិយាយបែបនេះប៉ុន្តែនៅពេលដែលខ្ញុំត្រឡប់មកមើលអ្វីដែលបានកើតឡើងម្តងទៀត ការសម្របខ្លួនគឺជាអ្វីដែលខ្ញុំបានធ្វើ។ ឆន្ទៈរបស់មនុស្សដើម្បីរស់មានភាពខ្លាំងក្លាណាស់ដែលមិនងាយនឹងចុះចាញ់ លុះត្រាណាតែមានអារម្មណ៍ថាមានចុងកំបិតនៅនឹងបំពង់ក។ មកដល់ពេលនេះគេប្រហែលជាលែងអើពើហើយក៏គិតថា "វាលែងសំខាន់ទៀតហើយ គ្រាន់តែឱ្យវាឆាប់ចប់ទៅ"។ នេះគឺជាអ្វីដែលខ្ញុំបានគិតនៅពេលដែលខ្ញុំទៅដល់អូសឈ្វិច ហើយមានអ្នកជាប់ទោសបុរសម្នាក់បានប្រាប់ខ្ញុំថាយើងបានចូលមកដល់ជំរំសម្លាប់។ ដូចនេះមានន័យថា "មានតែសេចក្តីស្លាប់ហើយមែនទេ ដែលកំពុងតែរង់ចាំ ? បើដូច្នេះឱ្យវាឆាប់ចប់ទៅ"។ នៅពេលដែលខ្ញុំត្រូវបានគេបំបែកចេញពីម្តាយរបស់ខ្ញុំ ខ្ញុំមានអារម្មណ៍ថាធូរចិត្ត។ ខ្ញុំដឹងថាក្មេងៗនឹងមិនត្រូវបានគេសម្លាប់ទេ។ ប៉ុន្តែនៅពេលនោះដែរខ្ញុំក៏មានទុក្ខព្រួយយ៉ាងខ្លាំង " តើនឹងមានរឿងអ្វីកើតឡើងចំពោះម្តាយរបស់ខ្ញុំ ?" មកដល់សព្វថ្ងៃនេះខ្ញុំនៅតែមិនហ៊ានសន្និដ្ឋានការគិតមួយនោះទេ។

ភាពអយុត្តិធម៌ត្រូវតែលុបបំបាត់។ នៅអាល្លឺម៉ង់ប្រតិកម្មតបទៅនឹងអំពើអយុត្តិធម៌គួរតែចាប់ផ្តើមមានតាំងពីដើមឆ្នាំ១៩៣០ មកម្ល៉េះ។ ទើបតែចាប់ផ្តើមមានបន្ទាប់ពីអ្វីៗគ្រប់យ៉ាងបានកើតឡើង គឺហួសពេលទៅហើយ។

[២៧] គឺជាក្រុមកងការពារដែលបកប្រែពីភាសាអាល្លឺម៉ង់ថា ហ្ស៊ូត ស្តាហ្វែល (Schutzstaffel) ត្រូវបានបង្កើតឡើងដំបូងជាអង្គរក្សផ្ទាល់ខ្លួនរបស់ ហ៊ីត្លែរ។ ក្រោយមកកងការពារនេះបានក្លាយទៅជាកងការពារឆ្មាំរបស់ហ៊ីត្លែរ និងអនុវត្តរាល់ការកិច្ចទាំងអស់ដែលទាក់ទងទៅនឹងសន្តិសុខដោយមិនគិតអំពីផ្លូវច្បាប់។

“ HUR KUNDE ETT HELT FOLK STÄLLA UPP BAKOM HITLER? ”

“ HOW COULD AN ENTIRE PEOPLE GET BEHIND HITLER? ”



## "តើប្រជាជនអាល្លឺម៉ង់ទាំងអស់គាំទ្រហ៊ីត្លែរបានដោយរបៀបណា?"

ការប្រកាន់ជាតិសាសន៍ដែលបណ្តាលឱ្យមានការសម្លាប់រង្គាលនេះមានប្រភពយូរណាស់មកហើយ។ វាគឺអំពីការបណ្តុំរបស់មនុស្សដែលមានជាតិសាសន៍ដូចគ្នា ភាពលោភលន់ និងភាពភ័យខ្លាច។ ទាំងអស់នេះគឺជាអ្វីដែល ហ៊ីត្លែរ បានយកមកប្រើជាយុទ្ធសាស្រ្តដើម្បីជ្រើសរើសសមាជិកថ្មីសម្រាប់បក្សរបស់ខ្លួន។

សុន្ទរកថាដ៏រំជើបរំជួលរបស់ហ៊ីត្លែរបានអំពាវនាវឱ្យមានសាមគ្គីភាពគ្នារវាងសាសន៍អាល្លឺម៉ង់ដ៏អស្ចារ្យ ការស្តារឡើងវិញនូវទឹកដីដែលបានបាត់បង់ ហើយនិងភាពភ័យខ្លាចចំពោះផែនការរបស់ជនជាតិជ្វីហ្វក្នុងការគ្រប់គ្រងពិភពលោកដែលរាប់បញ្ចូលទាំងមូលធននិយម និងកុម្មុយនីស្ត។ នៅពេលនោះប្រជាជនអាល្លឺម៉ង់មិនសប្បាយចិត្តជាមួយនឹងស្ថានភាពប្រទេសរបស់ខ្លួន ដែលមានអ្នកនយោបាយទន់ខ្សោយ និងអត្រាអ្នកអត់ការងារធ្វើខ្ពស់នោះទេ។ ហ៊ីត្លែរ បានប្រើប្រាស់អារម្មណ៍ដែលត្រូវបានគេក្បត់របស់ជនជាតិអាល្លឺម៉ង់នៅចុងបញ្ចប់សង្គ្រាមលោកលើកទី១ ភាពអាម៉ាស់របស់បូរណភាពទឹកដី ហើយនិងការរងទុករបស់ប្រជាជនមកទាមទារឱ្យមានសំណង។ ហ៊ីត្លែរអំពាវនាវឱ្យមានភាពរួបរួមជាតិព្រមទាំងសន្យាឱ្យនំប៉័ងនិងការងារធ្វើ។

នៅដើមឆ្នាំ១៩៣០ ណាហ្ស៊ីមិនសូវមានអ្នកគាំទ្រច្រើនទេ។ ប៉ុន្តែដោយសារតែភាពអង់អាច និងរបៀបនៃការនិយាយស្តីដ៏ល្អរបស់ហ៊ីត្លែរមនុស្សជាច្រើនចាប់ផ្តើមចូលរួមគាំទ្របក្សរបស់គាត់ និងមានគ្រប់ស្រទាប់វណ្ណៈទាំងអស់ដូចជាអ្នកធ្វើជំនួញ និងអាជីវកម្មធំៗដែលគិតថាខ្លួននឹងអាចទទួលបានផលចំណេញពីគោលនយោបាយរបស់ហ៊ីត្លែរ នាយទាហាន

ដែលចូលចិត្តគំនិតប្រកាន់ជាតិសាសន៍និយមរបស់ហ៊ីត្លែរ មនុស្សសាមញ្ញដែលធុញទ្រាន់នឹងភាពក្រីក្រ ហើយនិងមនុស្សស្រីដែលលង់នឹងភាពទាក់ទាញរបស់ហ៊ីត្លែរ។ ហ៊ីត្លែរ មានកម្លាំងមួយដែលអាចសណ្តំមនុស្សស្រីឱ្យក្លាយទៅជាអ្នកដែលគាំទ្រគាត់យ៉ាងស្មោះស្ម័គ្រ។ ត្រង់ចំណុចនេះគឺហាក់បីដូចជាចម្លែកខ្លាំងណាស់ពីព្រោះចំពោះ ហ៊ីត្លែរ តួនាទីរបស់ស្ត្រីគឺអាចសង្ខេបបានដោយត្រឹមតែអក្សរ ខេ(K) ខេ(K) ខេ(K) ឬ ភាសាអាល្លឺម៉ង់ឃីនដឺ (Kinder), ឃូហ្សេ (Küche), ឃឺហ្សេ (Kirche)[២៨] ដែលមានន័យថា កុមារ ចង្ក្រានបាយ វិហារ។

ហ៊ីត្លែរមានអ្នកជំនាញជាច្រើនចាំជួយគាត់។ មុខសញ្ញារបស់ពួកគេគឺមនុស្សវ័យក្មេង និងការបង្កើតគម្រោងឃោសនាមនោគមន៍វិជ្ជាដ៏មានឥទ្ធិពលតាមរយៈខ្សែភាពយន្ត អក្សរសិល្ប៍និងសិល្បៈ។ ជនជាតិជ្វីហ្វ ត្រូវបានចាត់ទុកថាគឺជាសត្វល្អិតចង្រៃ។ ការឃោសនាប្រឆាំងនឹងជនជាតិជ្វីហ្វ គឺសំដៅទៅលើគ្រប់ស្រទាប់អាយុទាំងអស់របស់ប្រជាជនអាល្លឺម៉ង់។ ការចាប់ផ្តើមដំបូង គឺសំដៅលើកុមារតូចៗ បន្ទាប់មកតាមរយៈសៀវភៅនៅសាលារៀន និងតាមអក្សរសិល្ប៍ និងភាពយន្តរបស់មនុស្សពេញវ័យ។ រហូតមកទល់សព្វថ្ងៃនេះ ភាពយន្តរបស់ លេនី រៀហ្វេនស្តាល់ **"Triumph of The Will"**[២៩] នៅតែជាគំរូដែលមានប្រសិទ្ធភាពសម្រាប់ការឃោសនាមនោគមន៍វិជ្ជា។

នៅក្នុងសៀវភៅសិក្សា មានការផ្សព្វផ្សាយឃោសនាមនោគមន៍វិជ្ជានៅតាមគ្រប់មុខវិជ្ជាទាំងអស់។ ឧទាហរណ៍ លំហាត់គណិតវិទ្យា នៅក្នុង

[២៨] គឺជាពាក្យស្លោករបស់ប្រទេសអាល្លឺម៉ង់ដែលយកមកប្រើប្រាស់ដំបូងក្នុងអំឡុងឆ្នាំ១៨៨៩ ដល់ឆ្នាំ១៩១៨ ដើម្បីដាក់កំហិតទៅលើតួនាទីរបស់ស្ត្រីជនជាតិអាល្លឺម៉ង់។ ពាក្យស្លោកនេះ ត្រូវបានយកមកប្រើជាមនោគមន៍វិជ្ជារបស់ណាហ្ស៊ីដើម្បីឱ្យស្ត្រីជនជាតិអាល្លឺម៉ង់បង្កើតកូនឱ្យបានច្រើន។

[២៩] គឺជាខ្សែភាពយន្តឃោសនាមនោគមន៍វិជ្ជារបស់ណាហ្ស៊ីក្នុងឆ្នាំ១៩៣៥ ដែលដឹកនាំផលិតកែសម្រួលនិងសហនិពន្ធដោយ លេនី រៀហ្វេនស្តាល់។ ខ្សែភាពយន្តនេះបង្ហាញអំពីសមាជគណបក្សណាហ្ស៊ីក្នុងឆ្នាំ១៩៣៤ នៅក្នុងទីក្រុងណួរែមប៊ឺក ដែលចូលរួមដោយអ្នកគាំទ្រណាហ្ស៊ីជាង ៧០ម៉ឺននាក់។



សៀវភៅសិស្សវិទ្យាល័យដែលបានបោះពុម្ពក្នុងឆ្នាំ១៩៣៥ មួយមានសំណួរថា "តើមានប្រាក់កម្ចីរបស់រដ្ឋប៉ុន្មានដែលអាចផ្តល់ឱ្យអ្នកដែលទើបតែរៀបការ បើប្រៀបធៀបទៅនឹងប្រាក់ដែលរដ្ឋាភិបាលចំណាយទៅលើជនពិការ ឧក្រិដ្ឋជន និងមនុស្សវិកលចរិត?"

ណាហ្ស៊ីបានផ្តោតសំខាន់ខ្លាំងទៅលើការអប់រំរបស់មនុស្សវ័យក្មេងដែលត្រូវបានពង្រឹងទាំងផ្លូវកាយ និងសតិអារម្មណ៍។ ពួកគេត្រូវបានជ្រើសរើសឱ្យចូលក្នុងហ៊ីត្លែរជូយេន៍ឬយុវជនរបស់ហ៊ីត្លែរ[៣០] ដែលជីវិតនៅក្នុងជំរំ និងសាមគ្គីភាពប្រែក្លាយឱ្យអ្នកទាំងនោះក្លាយទៅជាអ្នកបម្រើដ៏ស្មោះត្រង់។

នារីក៏មានក្រុមសម្រាប់ខ្លួនដែរ គឺមានឈ្មោះថាសម្ព័ន្ធនៃក្មេងស្រីអាល្លឺម៉ង់[៣១] ដែលនៅក្នុងក្រុមនេះនារីត្រូវបានបង្ហាត់បង្រៀនឱ្យក្លាយទៅជាប្រជាពលរដ្ឋគំរូ និងក្លាយទៅជាមាតារបស់កុមារជាច្រើននាក់នាពេលអនាគត។

ទោះបីជាមានការកើនឡើងនៃអ្នកគាំទ្រក៏ដោយ ក៏ប្រជាជនមួយចំនួនធំមិនមែនជាអ្នកដែលប្រឆាំងនឹងជនជាតិជ្វីហ្វទេ និងមួយចំនួនតូចគឺដោយសារតែជឿលើការឃោសនាមនោគមន៍វិជ្ជា។ អ្នកខ្លះចូលបក្សគឺដោយសារតែអ្នកទាំងអស់នោះចង់សាកល្បងអ្វីដែលថ្មីៗ ឯអ្នកខ្លះទៀតដោយសារតែមានសម្ពាធពីមិត្តភក្តិ។

បុរសវ័យក្មេងដែលជានិស្សិតច្បាប់ម្នាក់បានពន្យល់ប្រាប់ថាមិត្តភក្តិជិតស្និទ្ធរបស់គាត់២នាក់ និងមិត្តរួមការងាររបស់គាត់ដែលធ្លាប់តែប្រឆាំងនឹងហ៊ីត្លែរបានផ្លាស់ប្តូរបន្តិចម្តងៗ។ ក្នុងចំណោមនោះមានម្នាក់បាន

[៣០] គឺជាអង្គភាពយុវជនរបស់គណបក្សណាហ្ស៊ីដែលបង្កើតឡើងដំបូងក្នុងឆ្នាំ ១៩២២ ហើយដាក់ឈ្មោះថាហ៊ីត្លែរជូយេន៍នៅក្នុងឆ្នាំ១៩២៦។

[៣១] គឺជាក្រុមក្មេងស្រីនៃចលនាយុវជនរបស់គណបក្សណាហ្ស៊ីដែលបានបង្កើតឡើងក្នុងឆ្នាំ១៩៣០ ហើយគឺជាអង្គភាពយុវនារីតែមួយគត់នៅក្នុងអាល្លឺម៉ង់។ សមាជិកក្នុងក្រុមនេះត្រូវតែមានជាតិសាសន៍អាល្លឺម៉ង់ និងមិនមានជំងឺតំណពូជ។

និយាយថាបក្សទាំង៥៤នោះ គឺគ្មានមួយណាដែលមានដំណោះស្រាយទៅនឹងនយោបាយ និងស្ថានភាពហិរញ្ញវត្ថុដែលធ្លាក់ចុះដុនដាបនោះទេ។ ឯអ្នកខ្លះទៀតត្រូវបានអូសទាញដោយសារតែកំណើននៃចំនួនមនុស្សដែលបានចូលរួមបក្សហើយក៏ចាប់ផ្ដើមគិតថា "មហាជនមិនអាចខុសបានទេ"។ និស្សិតដែលបាននិយាយអំពីរឿងនេះមិនដែលឱ្យខ្លួនគាត់ចុះចាញ់ក្រោមឥទ្ធិពលមនោគមន៍វិជ្ជារបស់ណាហ្ស៊ីនោះទេដោយ គាត់បានប្ដូរទៅរស់នៅក្រៅប្រទេសវិញ។ ពេលវេលាកាន់តែកន្លងផុតទៅ ហើយអ្នកដែលប្រឆាំងក៏មានកាន់តែតិចទៅៗ។

# “VARFÖR GJORDE NI INTE MOTSTÅND?”

# “WHY DID YOU NOT FIGHT BACK?”

# "ហេតុអ្វីបានជាអ្នកមិនប្រឆាំងតបតទៅវិញ ?"

ការប្រឆាំងតបតទៅវិញដោយប្រើអំពើហិង្សានៅក្នុងឆ្នាំ ១៩៤៤ ប្រៀបបានដូចជាការធ្វើអត្តឃាតខ្លួនឯង។ ការតស៊ូបែបនេះគួរតែមានតាំងពីមុនពេលដែលណាហ្ស៊ីឡើងក្តោបក្តាប់អំណាចមកម្ល៉េះ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយការតស៊ូដោយអហិង្សានៅតែបន្តមាននៅស៊ុយហ្គេត។ លទ្ធិកុម្មុយនីស្តមួយត្រូវបានរៀបចំឡើងយ៉ាងសម្ងាត់។ វាពិតជាសម្ងាត់ណាស់ហើយខ្ញុំដែលជាសមាជិកក្មេងជាងគេត្រូវបានអនុញ្ញាតឱ្យចូលរួមតែវគ្គបណ្តុះបណ្តាលមនោគមន៍វិជ្ជាប៉ុណ្ណោះ។ ខ្ញុំបានអានសៀវភៅរបស់កាល់ម៉ាក្ស[៣២] និងហ្វ្រាយរីដ៍អេនហ្គល្ស[៣៣] មិនយូរប៉ុន្មានខ្ញុំក៏បានក្លាយជាអ្នកកាន់លទ្ធិកុម្មុយនីស្តយ៉ាងស្មោះស្ម័គ្រ ហើយជំនួសឱ្យការសូត្រពាក្យអធិដ្ឋាននៅពេលល្ងាចដែលលោកតារបស់ខ្ញុំបានបង្រៀន ឥឡូវខ្ញុំបែរជាច្រៀងបទ "The internationale"[៣៤] ទៅវិញ។ នៅក្នុងលទ្ធិកុម្មុយនីស្ត អ្នកដែលអាចជួយឱ្យយើងរួចផុតពីណាហ្ស៊ីបានព្រមទាំងយុវជនដទៃទៀតបានរត់ឆ្លងប្រទេសទៅសហភាពសូវៀតជាមួយក្តីសង្ឃឹមថានឹងអាចមានអ្នកជួយបាននៅទីនោះ ហើយក៏មានក្តីសង្ឃឹមដែរថានឹងអាចប្រឆាំងជាមួយអាល្លឺម៉ង់បានតាមរយៈសហភាពសូវៀត។ ថ្ងៃមួយនៅចុងទសវត្សរ៍ឆ្នាំ ១៩៤០ បន្ទាប់ពីសង្គ្រាមបានបញ្ចប់ទៅ កណ្តឹងផ្ទះរបស់ខ្ញុំនៅអាស្តុជិន[៣៥] ប្រទេសស៊ុយអ៊ែត[៣៦] បានបន្លឺសំឡេងរោទ៍។ ខ្ញុំបើកទ្វារផ្ទះហើយក៏បានជួបយុវជនពីរនាក់ដែលខ្ញុំមិនបានចំណាំមុខ។ យុវជនពីរនាក់នោះបានណែនាំខ្លួនឯងថាជា មោយស៊ី កោមម៉ាន់ និងដេវីដ ស្ទីន អតីតមិត្តរួមការងាររបស់ឪពុកខ្ញុំនៅឯរោងចក្រក្រដាសកាតុង។ ខ្ញុំចំណាំគ្នា គាត់ម្នាក់។ គាត់គឺជាអ្នកដែលបានរត់ទៅសហភាពសូវៀត។ ខ្ញុំតែងតែប្រណែននឹងគាត់ដែលហ៊ានរត់គេចខ្លួន ហើយបានរួចផុតពីហូឡូខសន៍[៣៧]។ ប៉ុន្តែឥឡូវនេះខ្ញុំបានស្តាប់រឿងដែលខុសគ្នាទាំងស្រុងអំពីអ្វីដែលខ្ញុំបានដឹង។ នៅយប់មួយ គាត់ហើយនិងមិត្តរបស់គាត់បានឡើងទៅសូឡូវ៉ានដែលជាជើងភ្នំខាផាធៀន[៣៨] ដើម្បីជួបជាមួយអ្នកនាំផ្លូវម្នាក់ដែលអាចជួយឱ្យពួកគាត់ឆ្លងទៅសហភាពសូវៀតបាន។ បន្ទាប់ពីបង់ប្រាក់ដែលជាលុយសន្សំចុងក្រោយរបស់ខ្លួន ពួកគាត់ក៏ធ្វើដំណើរឆ្លងកាត់ព្រៃដែលងងឹតសូន្យឈឹង។ ពួកគាត់លាក់ខ្លួននៅពេលថ្ងៃហើយដេកតែប៉ុន្មានម៉ោងប៉ុណ្ណោះ បន្ទាប់មកក៏បន្តដំណើរនៅពេលយប់។ បន្ទាប់ពីធ្វើដំណើរអស់រយៈពេលបីថ្ងៃពួកគាត់បានទៅដល់ព្រំប្រទល់។ ទៅដល់ទីនោះ អ្នកនាំផ្លូវបានណែនាំឱ្យពួកគាត់ធ្វើដំណើរបន្តដោយខ្លួនឯង។ ចាប់ពីទីកន្លែងនោះមក ពួកគាត់ត្រូវតែស្វែងរកផ្លូវដោយខ្លួនឯងដើម្បីទៅដល់ជ្រលងភ្នំនៅខាងក្រោមដែលនៅទីនោះពួកគាត់នឹងទទួលបានសេរីភាព។ពួកគាត់នៅតែបន្តដំណើរទៅមុខទៀត ប៉ុន្តែព្រៃឈើហាក់បីដូចជាគ្មានទីបញ្ចប់សោះ។ បន្ទាប់មកពួកគាត់បានវង្វេងផ្លូវ និងអស់គ្រឿងផ្គត់ផ្គង់អាហារ ប៉ុន្តែនៅតែមិនទាន់ឃើញសូម្បីតែស្រមោលមនុស្សម្នាក់ផង។ ប៉ុន្មានថ្ងៃបន្ទាប់មក ពួកគាត់ត្រូវបានអ្នកត្រួតពិនិត្យនៅតាមព្រំដែនឃាត់ខ្លួន ហើយបានសួរសំណួរជាច្រើន បន្ទាប់មកក៏ចាប់ខ្លួនពួកគាត់ដាក់គុក។ ទោះបីជាពួកគាត់ព្យាយាមពន្យល់ថាខ្លួន គឺជាជនជាតិជ្វីហ្វ ហើយជាអ្នកកាន់លទ្ធិកុម្មុយនីស្តយ៉ាងណា

[៣២] កាល់ម៉ាក្ស គឺជាទស្សនវិទូជនជាតិអាល្លឺម៉ង់ម្នាក់ដែលទ្រឹស្តីដ៏ល្បីល្បាញរបស់គាត់អំពីសង្គមសេដ្ឋកិច្ចនិងនយោបាយត្រូវបានគេស្គាល់ជាទូទៅថាជាម៉ាក្សស៊ីហ្សឹម។ នៅក្នុងទ្រឹស្តីម៉ាក្សស៊ីហ្សឹមគឺ ប្រកាន់ខ្ជាប់ថាសង្គមមនុស្សគឺវិវត្តតាមរយៈការតស៊ូវណ្ណៈ។

[៣៣] ហ្វ្រាយរីដ៍ អេនហ្គល្សក៏ជាអ្នកទស្សនាវិទូជនជាតិអាល្លឺម៉ង់ម្នាក់ដែរ។ គាត់និងកាល់ ម៉ាក្សធ្វើការរួមគ្នាក្នុងការបង្កើតទ្រឹស្តីម៉ាក្សស៊ីហ្សឹម។

[៣៤] គឺជាបទចម្រៀងរបស់លទ្ធិកុម្មុយនីស្ត។

[៣៥] គឺជាសង្កាត់មួយនៅជាយក្រុងភាគខាងត្បូងនៃទីក្រុងស្តុកខុល នៃប្រទេសស៊ុយអែត។

[៣៦] មានឈ្មោះជាផ្លូវការថាព្រះរាជាណាចក្រស៊ុយអែត ស្ថិតនៅក្នុងអឺរ៉ុបភាគខាងជើង និងមានព្រំប្រទល់ជាប់ប្រទេសហ្វាំងឡង់ ន័រវេស និងដាណឺម៉ាក។

[៣៧] គឺជាការធ្វើបាបឃាឃីនិងអំពើប្រល័យពូជសាសន៍ទៅលើជនជាតិជ្វីហ្វ៦លាននាក់ ដោយរបបណាហ្ស៊ីរបស់ហ៊ីត្លែរចាប់តាំងពីឆ្នាំ១៩៣៣ រហូតដល់ចុងបញ្ចប់សង្គ្រាម លោកលើកទី២។ ហូឡូខសន៍គឺជាពាក្យដើមនៃភាសាក្រិកមានន័យថា "បូជាដោយភ្លើង" ឬ "បូជាភ្លើង" ។

[៣៨] គឺជាជួរភ្នំមួយដែលមានប្រវែងប្រហែល ១៥០០គីឡូម៉ែត្រស្ថិតនៅទ្វីបអឺរ៉ុបភាគកណ្តាលនិងខាងកើត។

ក៏ដោយ ក៏អ្នកយាមទាំងនោះមិនជឿពួកគាត់ទេ។ ជនជាតិរុស្ស៊ីទាំងនោះគិតថាពួកគាត់គឺជាអ្នកស៊ើបការណ៍របស់អាល្លឺម៉ង់។ ដោយគ្មានការបកស្រាយច្បាស់លាស់ពីអ្នកយាម ពួកគាត់ត្រូវបានគេនាំខ្លួនទៅដាក់ក្នុងរថភ្លើងជាមួយនឹងមនុស្សរាប់រយអ្នកផ្សេងទៀត ហើយបន្ទាប់ពីធ្វើដំណើរអស់រយៈពេលជាច្រើនសប្តាហ៍ក៏ត្រូវបានគេយកទៅទម្លាក់ចោលនៅក្នុងវរគុតា[៣៩] នៃទីក្រុងស៊ីប៊េរី ។ បន្ទាប់ពីរងទុក្ខលំបាកអស់ជាច្រើនឆ្នាំ ពួកគាត់បានរត់គេចខ្លួនចេញពីជំរំ។ មកដល់ប្រទេសហ្វាំងឡង់[៤០] ទើបពួកគាត់ដឹងថាសង្គ្រាមបានបញ្ចប់បាត់ទៅហើយ។ បន្ទាប់មកទើបពួកគាត់បានធ្វើដំណើរទៅប្រទេសស៊ុយអែត ហើយសព្វថ្ងៃនេះកំពុងរស់នៅក្នុងទីក្រុងស្តុកខុល[៤១] ដើម្បីបន្តដំណើរទៅទឹកដីប៉ាឡេស្ទីន[៤២]។ ក្នុងពេលដែលមនុស្សមួយចំនួនរត់ទៅសហភាពសូវៀត អ្នកមួយចំនួនទៀតធ្វើការប្រឆាំងដោយអហិង្សាដែលបានគេចទៅលាក់ខ្លួននៅក្នុងរូងភ្នំ។ ហើយក៏មានអ្នកមួយចំនួនទៀតដែលព្យាយាមលាក់ខ្លួនបន្តនៅស៊ីហ្គេត ប៉ុន្តែមិនបានសម្រេចពីព្រោះពួកគេត្រូវបានបកអាក្រាតដោយអ្នកប្រឆាំងនឹងជនជាតិជ្វីហ្វ ដោយសារតែអ្នកទាំងនោះយល់ឃើញថានឹងអាចរកប្រាក់កម្រៃបានតាមរយៈការបកអាក្រាតនេះ។ នៅពេលដែលយើងបានទៅដល់ជំរំ គ្នាយើងមួយចំនួនធំមិនបានចាប់អារម្មណ៍អើពើនឹងការតស៊ូនោះទេ។ គ្មាននរណាម្នាក់មានកម្លាំងក្នុងការគិតនោះទេ យើងបានត្រឹមតែចាំស្តាប់បញ្ជាតែប៉ុណ្ណោះ។

យើងត្រូវតែប្រឹងរស់ ទោះបីជាស្ថិតនៅក្នុងស្ថានភាពពិបាកយ៉ាងណាក៏ដោយ។ អ្វីៗនៅតែបន្តបែបនេះ រហូតទាល់តែអ្នកទោសមួយចំនួនគិតថាស្ថានភាពនេះពិតជាគ្មានសង្ឃឹមទៀតនោះទេដែលមុននឹងក្រោយគង់តែអស់ជីវិតទើបអ្នកទោសទាំងនោះសម្រេចចិត្តធ្វើការប្រយុទ្ធតបត

[៣៩] គឺជាទីក្រុងរុករករ៉ែធ្យូងថ្មមួយនៅក្នុងសាធារណរដ្ឋកូមិនៃប្រទេសរុស្ស៊ី។
[៤០] មានឈ្មោះជាផ្លូវការថាសាធារណរដ្ឋហ្វាំងឡង់ស្ថិតនៅ អឺរ៉ុបខាងជើង ។
[៤១] គឺជាទីក្រុងរបស់ប្រទេសស៊ុយអែត។
[៤២] ត្រូវបានគេហៅថារដ្ឋប៉ាឡេស្ទីន មានព្រំប្រទល់ជាប់ប្រទេសអេហ្ស៊ីប អ៊ីស្រាអែល និង ប្រទេសហ្ស៊កដានី។



វិញ។ អ្នកទោសនៅសូប៊ីប័រ[៤៣] បានប៉ុនប៉ងរត់ចេញពីជំរំ។ ពួកគេមិនទទួលបានជោគជ័យទាំងស្រុងទេ។ អ្នកទោសមួយចំនួនបានរត់គេចខ្លួនចំណែកឯអ្នកមួយចំនួនទៀតត្រូវបានបាញ់សម្លាប់ ឬស្លាប់នៅក្នុងព្រៃ។

នៅវ៉ាសូវី[៤៤] ជនជាតិជ្វីហ្វដែលនៅតាមជំរំទាំងអស់នឹងត្រូវសម្លាប់ចោល ហើយគ្មាននរណាម្នាក់អាចជៀសផុតពីការបញ្ជូនទៅក្នុងបន្ទប់ផ្សែងពុលនោះទេ។ ដោយមានការជួយពីចលនាតស៊ូរបស់ប៉ូឡូញក្នុងការនាំយកអាវុធទៅឱ្យអ្នកទោសក្នុងជំរំ អ្នកទោសទាំងនោះអាចតស៊ូបានរយៈពេល ៤០ថ្ងៃ។ ឯមួយចំនួនទៀតបានរត់គេចខ្លួនទៅតាមលូទឹក។ ទីបញ្ចប់កងការពារណាហ្ស៊ីបានប្រើភ្លើងដុតជំរំហើយមានអ្នករួចជីវិតតែ ២០នាក់តែប៉ុណ្ណោះដែលត្រូវបានគេនាំចេញមកខាងក្រៅ។ នៅរដូវស្លឹកឈើជ្រុះអំឡុងឆ្នាំ១៩៤៤ សនដឹកកូម៉ាន់ដូ[៤៥] ដែលជាក្រុមអ្នកទោសធ្វើការនៅឈាបនដ្ឋាន៣ និង៤ នៅអូសឈ្វិច បានសម្រេចចិត្តដាក់គ្រាប់បែកក្នុងអគារពីព្រោះអ្នកទាំងនោះដឹងច្បាស់ថាទោះបីជាយ៉ាងណាក៏ដោយខ្លួននឹងត្រូវបានបញ្ជូនទៅបន្ទប់ផ្សែងពុល។ អ្នកដែលធ្វើការនៅក្នុងក្រុមសនដឹកកូម៉ាន់ដូ គឺត្រូវបានផ្លាស់ប្តូរក្នុងរយៈពេល៦ខែម្តង ដោយពួកគេត្រូវបានណាហ្ស៊ីយកទៅសម្លាប់ចោលពីព្រោះអ្នកទាំងនោះដឹងរឿងច្រើនពេកដែលមិនអាចទុកជីវិតឱ្យបានទេ។ មានថ្ងៃមួយអ្នកទោសមួយក្រុមបានទាក់ទងក្មេងស្រីប្រាំមួយនាក់ដែលធ្វើការនៅក្នុងរោងចក្រគ្រាប់រំសេវ ហើយបានឱ្យក្មេងស្រីទាំងនោះលួចយករំសេវផ្ទុះចូលទៅក្នុងគុក។ ការដាក់គ្រាប់បែកនេះទទួលបានជោគជ័យ ហើយអាល្លឺម៉ង់បានខឹងសម្បាយ៉ាងខ្លាំង។ អ្នកទោសបុរសទាំងនោះត្រូវបានយកទៅសម្លាប់នៅក្នុងបន្ទប់ផ្សែងពុលហើយចំណែកឯក្មេងស្រីត្រូវបានយកទៅព្យួរកនៅពីមុខអ្នកទោសក្នុងជំរំទាំងអស់។

[៤៣] គឺជាជំរំសម្លាប់របស់ណាហ្ស៊ីនៅក្នុងសង្គ្រាមលោកលើកទី២ដែលមានទីតាំងស្ថិតនៅជិតភូមិសូប៊ីប័រនៅភាគខាងកើតនៃស្រុកលូប្លីនប្រទេសប៉ូឡូញ។ ជំរំនេះមានចម្ងាយ៥គីឡូម៉ែត្រពីទន្លេបាក់ដែលសព្វថ្ងៃនេះជាព្រំដែនរវាងប្រទេសប៉ូឡូញនិងអ៊ុយក្រែន។
[៤៤] គឺជាទីក្រុងដែលធំបង្អស់នៅក្នុងប្រទេសប៉ូឡូញ។
[៤៥] គឺជាអង្គភាពដែលបង្កើតឡើងដោយអ្នកទោសជំរំសម្លាប់របស់ណាហ្ស៊ី។ អង្គភាពនេះជាទូទៅគឺប្រមូលផ្តុំដោយអ្នកទោសជនជាតិជ្វីហ្វដែលត្រូវបានបង្ខំនិងគំរាមកំហែងឱ្យធ្វើការងារដែលទាក់ទងនឹងការដុតឬបំផ្លាញសាកសពជនរងគ្រោះដែលស្លាប់ដោយសារបន្ទប់ផ្សែងពុល។

# "
# VAD MINNS DU FRÅN ANKOMSTEN TILL AUSCHWITZ?
# " "
# WHAT DO YOU REMEMBER FROM YOUR ARRIVAL AT AUSCHWITZ?
# "



## "តើអ្នកបានចងចាំអ្វីខ្លះអំពីការទៅដល់របស់អ្នកនៅអូសឈ្វិច ?"

ពេលនោះគឺជាពាក់កណ្ដាលយប់នៅថ្ងៃទី១៧និងថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៤៤។បន្ទាប់ពីធ្វើដំណើរអស់រយៈពេលជាច្រើនថ្ងៃ ទូរថភ្លើងដែលពេញទៅដោយជនជាតិហុងគ្រី-ជ្វីហ្វចំនួន ៣០០៧នាក់ មកពីទីក្រុងស៊ីហ្គេត និងប្រទេសត្រង់ស៊ីលវ៉ានី បានទៅដល់ចំណតមួយដែលមានផ្លាកសរសេរថាអូសឈ្វិច។

ទ្វារទូរថភ្លើងត្រូវបានទាញបើកយ៉ាងខ្លាំង ពន្លឺក៏បានជះចាំងភ្នែករបស់យើងហើយក៏មានសំឡេងរញ៉េរញ៉ៃបន្លឺមក។ សំឡេងស្រែករបស់កងការពារណាហ្ស៊ី លាយឡំជាមួយនឹងសំឡេងឆ្កែព្រុស និងសំឡេងក្មេងយំ។ យើងត្រូវចុះចេញពីទូរថភ្លើងឱ្យបានលឿនដោយមនុស្សប្រុសត្រូវចុះទៅខាងស្ដាំ រីឯមនុស្សស្រីត្រូវចុះទៅខាងឆ្វេង ហើយអ្វីៗដែលយើងយកមកជាមួយត្រូវទុកចោលមួយកន្លែង។ ក្រុមបុរសពាក់អាវក្រឡាឆ្នូតដែលមានកាន់ដំបងប៉ូលីសបានមកជួយកងការពារណាហ្ស៊ីដើម្បីជម្លៀសយើងចេញពីទូរថភ្លើង។ ពួកគេស្រែកភាសាអាល្លឺម៉ង់ថា **Schnell! Schnell!** (ស្នែល! ស្នែល!) គឺមានន័យថាលឿនឡើង លឿនឡើង។គ្រួសារខ្លះឈរឆ្កឹងនៅមួយកន្លែងដោយសារតែមិនចង់បែកចេញពីគ្នា។ កងការពារណាហ្ស៊ីគ្រវីដំបងរបស់ខ្លួនហើយស្រែកសម្ដីជានាអះអាងថាគ្រួសារនឹងបានជួបជុំគ្នាម្ដងទៀតនៅថ្ងៃស្អែក ព្រមទាំងបញ្ជាក់ថាអីវ៉ាន់ទាំងអស់នឹងបញ្ជូនទៅម្ចាស់ដើមវិញ។ បន្ទាប់មកយើងត្រូវបានគេដេញឱ្យចុះមកឈរនៅច្រកចេញចូល។ ឪពុករបស់ខ្ញុំនិងខ្ញុំ នៅធ្មឹងមួយកន្លែង។ តើយើងបានមកដល់ទីណា? យើងមិនបានឃើញកងការពារណាហ្ស៊ីនៅក្នុងទូរថភ្លើងទេ ឪពុករបស់ខ្ញុំសួរទៅកាន់បុរសពាក់អាវឆ្នូតម្នាក់ដែលមានមុខមាត់ដូចជាជនជាតិជ្វីហ្វ។ បន្ទាប់ពីបានក្រឡេកមើលជុំវិញខ្លួនបុរសម្នាក់នោះក៏បានខ្សឹបប្រាប់យើងថា **"Vernich-**

**Tungslager**(វឺនីស្តុងស្លាកឺ)” គឺមានន័យថាជំរំសម្លាប់។ នៅពេលនោះហើយទើបធ្វើឱ្យខ្ញុំដឹងថាម្តាយរបស់ខ្ញុំប្រហែលជាដឹងថាប្រាកដជាមានរឿងអ្វីមួយកើតឡើងនៅពេលដែលគាត់និយាយថា "ពួកគេប្រាកដជាសម្លាប់យើង" ។

នៅក្រោមសំឡេងស្រែកបញ្ជានិងជេរប្រទេចផ្តាសារបស់អាល្លឺម៉ង់អ្នកដែលកំពុងតែយំ និងវង្វេងវង្វាន់ក៏បានប្រញាប់ប្រញាល់ចុះចេញពីលើទូរថភ្លើងដើម្បីជៀសវាងពីការវាយដំ។ សមាជិកគ្រួសារបានបែកបាក់គ្នាដោយមិនបាននិយាយពាក្យលាគ្នានោះឡើយ។ លឿនឡើង លឿនឡើង, ខ្ញុំក៏បានហក់ចុះទៅលើច្រកចេញចូលហើយឈរនៅពីមុខអ្នកកាត់ក្តីរបស់ខ្ញុំ។ ខ្ញុំហក់ចុះពីលើទូរថភ្លើង ហើយក៏បានដកដង្ហើមយ៉ាងជ្រៅ។ បន្ទាប់ពីរយៈពេលបីថ្ងៃនៅក្នុងរថភ្លើងដែលចង្អៀតផ្អឹះ និងមានក្លិនស្អុយគឺពិតជាធូរស្បើយណាស់ដែលបានដកដង្ហើមស្រួលទោះបីជាធំខ្លិនមិនសូវល្អក៏ដោយ។ អំពូលភ្លើងបានជះពន្លឺនៅពេលយប់ដោយពន្លឺភ្លឺបភ្លែតៗ។ វាបានបញ្ចេញពន្លឺទៅលើហ្វូងមនុស្សដែលមានទឹកមុខស្រងូតស្រងាត់ទៅលើផ្លូវរថភ្លើង និងកាំភ្លើងរបស់កងការពារណាហ្ស៊ី។ ដោយមានម្តាយនៅកណ្តាលខ្ញុំនិងប្អូនស្រី យើងដើរតាមជួរមនុស្សស្រីដែលសំដៅទៅរបងបន្លាលួស។ គ្រូពេទ្យដ៏អាក្រក់ឈ្មោះថា ដុកទ័រម៉េនជីលី[៤៦] គឺជាអ្នកដែលបានបំបែកខ្ញុំនិងប្អូនស្រីខ្ញុំឱ្យទៅខាងឆ្វេងហើយម្តាយរបស់ខ្ញុំទៅខាងស្តាំ។

យប់នោះគឺជាយប់ដែលខ្ញុំបានបាត់បង់ឪពុកម្តាយរបស់ខ្ញុំ។ ពួកគាត់ត្រូវបានគេបោកប្រាស់ឱ្យជឿថាពួកគាត់នឹងត្រូវបាននាំទៅបន្ទប់ងូតទឹក ប៉ុន្តែជំនួសឱ្យទឹកវាគឺជាហ្ស៊ីក្លូនប៊ី[៤៧] ទៅវិញទេដែលត្រូវបានចាក់បំពេញនៅក្នុងបន្ទប់នោះ។

ខ្ញុំមិនបាននិយាយពាក្យថាលាទៅកាន់ឪពុកម្តាយរបស់ខ្ញុំនោះទេ ហើយខ្ញុំក៏មិនបានឱបពួកគាត់ជាលើកចុងក្រោយដែរ។

[៤៦] គឺជាគ្រូពេទ្យជនជាតិអាល្លឺម៉ង់នៅក្នុងជំរំសម្លាប់ អូសឈ្វិច ដែលមានកេរ្តិ៍ឈ្មោះអាក្រក់ដោយសារតែបានធ្វើការពិសោធន៍ដ៏ព្រៃផ្សៃជាច្រើនទៅលើអ្នកទោស ហើយក៏ជាសមាជិកក្រុមគ្រូពេទ្យដែលជ្រើសរើសជនរងគ្រោះឱ្យទៅស្លាប់នៅក្នុងបន្ទប់ផ្សែងពុល។

[៤៧] គឺជាសារធាតុគីមីដែលណាហ្ស៊ីប្រើសម្រាប់សម្លាប់អ្នកទោសនៅក្នុងបន្ទប់ផ្សែងពុល។



# “VAD BETYDDE DET ATT HA SIN SYSTER MED I LÄGREN?”

# “WHAT DID IT MEAN TO HAVE YOUR SISTER WITH YOU IN THE CAMPS?”

# " តើមានន័យយ៉ាងដូចម្តេចទៅ ពេលដែលមានប្អូនស្រីរស់នៅក្នុងជំរំជាមួយគ្នា ?"

បន្ទាប់ពីត្រូវបានបំបែកចេញពីឪពុកម្តាយ ប្អូនស្រីរបស់ខ្ញុំឈ្មោះ លីវី ហើយនិងខ្ញុំបានកាន់ដៃគ្នាបន្តដំណើរទៅមុខទៀត។ ពេលនេះយើងមានគ្នាតែ២នាក់ទេ។ ឪពុករបស់ខ្ញុំត្រូវបានបំបែកចេញពីយើងតាំងពីនៅក្នុងទូរថភ្លើងហើយពេលនេះម្តាយរបស់ខ្ញុំ...ខ្ញុំមិនហ៊ានគិតអំពីអ្វីដែលកើតឡើងទៅលើពួកគាត់ទេ។ បេះដូងរបស់ខ្ញុំស្ទើរតែលោតចេញមកខាងក្រៅ។ ឥឡូវនេះខ្ញុំនៅសល់ប្អូនស្រីម្នាក់តែប៉ុណ្ណោះ។ ខ្ញុំកាន់ដៃប្អូនស្រីជាប់។ ខ្ញុំមិនទាន់ដឹងទេថាតើវាសំខាន់យ៉ាងណាដែលយើងមានគ្នាពីរនាក់។ វានឹងកាន់តែបង្ហាញយ៉ាងច្បាស់នៅពេលដែលពេលវេលាដើរទៅមុខបន្តទៀត។ ចាប់តាំងពីពេលនោះមកយើងនៅស្អិតជាប់គ្នារហូត។ យើងមិនដែលលែងដៃគ្នានោះទេបើម្នាក់មិនទៅ ម្នាក់ទៀតក៏មិនទៅដែរ។ យើងតែងតែដេកនៅជិតគ្នា។

ក្រឡេកមើលទៅក្រោយវិញអ្វីៗប្រៀបបានដូចជាការផ្លាស់ប្តូរដ៏គួរឱ្យកត់សម្គាល់មួយ។ ស្ទើរតែពេញមួយជីវិត យើងប្រៀបបានដូចជាសត្វឆ្កែនិងឆ្មា មានទាំងការប្រណែន មានទាំងការវាយដំគ្នា ហើយខ្ញុំមិនដែលចង់មានប្អូនស្រីនៅក្បែរខ្លួនទេ។ ប៉ុន្តែខ្ញុំបានដឹងអំពីការទទួលខុសត្រូវក្នុងនាមជាបងស្រីម្នាក់ពេលដែលនៅក្នុងជំរំ។ ខ្ញុំនឹងការពារប្អូនស្រីរបស់ខ្ញុំអំពីអ្វីៗទាំងអស់។ ប៉ុន្តែមានពេលជាច្រើនដងដែលប្អូនស្រីទេគឺជាអ្នកដែលបានជួយជីវិតខ្ញុំទៅវិញ។

នៅអូសឈ្វិចមានមនុស្សជាច្រើនណាស់ដែលច្រណែននឹងយើងដែលមានគ្នាពីរនាក់។អ្នកទោសដែលនៅទីនោះយូរបាននិយាយថាអ្នកដែលឯកោបានបាត់បង់ឆន្ទៈក្នុងការរស់នៅ។ ឱកាសគឺជាអ្វីៗដែលគ្រប់គ្រងជីវិតនៅក្នុងជំរំ។ ភាពភ្ញាក់ផ្អើលកើតមានឡើងជារៀងរាល់ថ្ងៃ។ យើងមិនអាចដឹងបានទេថាថ្ងៃមួយយើងធ្វើការធម្មតាហើយក្នុងមួយរំពេចសោះអាចត្រូវបានផ្ទេរទៅជំរំមួយផ្សេងទៀត។ ថ្នាក់ដឹកនាំមិនចង់ឱ្យយើងមានអារម្មណ៍ជិតស្និទ្ធទៅនឹងកន្លែងណាមួយនោះទេ។ អាល្លឺម៉ង់ប្រហែលជាភ័យខ្លាចថាយើងនឹងបង្កើតចំណងមិត្តភាពដែលអាចជួយឱ្យយើងធ្វើការបះបោរនាពេលណាមួយ។ នៅក្នុងអំឡុងពេលនេះដែរ មិត្តភក្តិអាចនឹងត្រូវបានបំបែកចេញពីគ្នាហើយនេះ គឺជាអ្វីដែលបានកើតឡើងចំពោះខ្ញុំ និងលីវី នៅក្នុងអូសឈ្វិច ខណៈពេលដែលក្រុមការងារត្រូវបានបែងចែកផ្សេងៗពីគ្នា។ ខ្ញុំត្រូវបានជ្រើសរើសឱ្យទៅជំរំផ្សេង ហើយប្អូនស្រីរបស់ខ្ញុំត្រូវរស់នៅក្នុងជំរំដដែល។ ប្រឆាំងនឹងអ្វីៗទាំងអស់ ខ្ញុំបានលួចរត់ត្រឡប់មកជំរំដែលប្អូនស្រីរបស់ខ្ញុំរស់នៅវិញ។ សំណាងល្អដែលយើងមិនត្រូវបានបំបែកចេញពីគ្នាម្តងទៀត។

"HUR VAR DET ATT LEVA I LÄGREN?" "WHAT WAS IT LIKE TO LIVE IN THE CAMPS?"



# "តើជីវិតនៅក្នុងជំរំមានលក្ខណៈយ៉ាងដូចម្ដេចដែរ ?"

មនុស្សជាច្រើនបានគិតទៅដល់ អូសឈ្វិច នៅពេលណាដែលគេសួរសំណួរនេះ។ ប៉ុន្តែគឺមានភាពខុសគ្នាយ៉ាងខ្លាំងរវាងស្ថានភាពនៅក្នុងជំរំសម្លាប់និងជំរំពលកម្ម។ ជំរំប្រមូលផ្តុំមិនបានបង្កើតឡើងដំបូងដោយអាល្លឺម៉ង់នោះទេ។ ចក្រភពអង់គ្លេស មានជំរំប្រមូលផ្តុំនៅក្នុងប្រទេសឥណ្ឌាទាំងមុននិងអំឡុងពេលសង្គ្រាម។ នៅទីនោះពួកគេបានប្រមូលផ្តុំប្រជាជនពីប្រទេសដែលជាសត្រូវរបស់ខ្លួនដោយសារតែភាពភ័យខ្លាចរបស់ពួកគេថានឹងអាចមានអំពើចារកម្មកើតឡើង។ នៅក្នុងករណីនេះមានន័យថាជំរំប្រមូលផ្តុំគឺជាតំបន់ដាច់ស្រយាលមួយដែលអ្នកទាំងនោះត្រូវបានឃុំឃាំងដោយមិនត្រូវបានគេធ្វើបាបយាយីនិងត្រូវបានរំដោះបន្ទាប់ពីសង្គ្រាមបានបញ្ចប់។

ជំរំប្រមូលផ្តុំរបស់អាល្លឺម៉ង់ផ្ទុយទៅវិញ ត្រូវបានសាងសង់ឡើងសម្រាប់មនុស្សដែលត្រូវបានគេដាក់គុកដោយគ្មានការកំណត់ដោយសារតែជាតិសាសន៍ ជំនឿ ឬផ្លូវភេទរបស់ពួកគេ។ មនុស្សទាំងនេះត្រូវបានប្រើ និងរំលោភបំពាន ហើយចុងបញ្ចប់គឺត្រូវបានគេកម្ទាត់ចោល។ មានជំរំសម្លាប់មនុស្សចំនួន៦ ដែលមានឡសម្រាប់ដុតសាកសព ដូចជានៅអូសឈ្វិច, ត្រេប្លាំងកា[៤៨],បេលដេក៍[៤៩],សូប៊ីប័រ[៥០],ឆេលណូ[៥១] និងម៉ាជ៍ដាណេក[៥២] ។

[៤៨] គឺជាជំរំសម្លាប់របស់ណាហ្ស៊ីនៅក្នុងសង្គ្រាមលោកលើកទី២ដែលមានទីតាំងស្ថិតនៅជិតភូមិសូប៊ីប័រនៅភាគខាងកើតនៃស្រុកលូប្លីនប្រទេសប៉ូឡូញ។ ជំរំនេះមានចម្ងាយ៥គីឡូម៉ែត្រពីទន្លេបាក់ដែលសព្វថ្ងៃនេះជាព្រំដែនរវាងប្រទេសប៉ូឡូញនិងអ៊ុយក្រែន។

[៤៩] គឺជំរំសម្លាប់ដែលស្ថិតនៅភាគខាងកើតប្រទេសប៉ូឡូញនៅក្នុងសង្កាត់លូប្លីន។

[៥០] គឺជាជំរំសម្លាប់របស់ណាហ្ស៊ីនៅក្នុងសង្គ្រាមលោកលើកទី២ដែលមានទីតាំងស្ថិតនៅជិតភូមិសូប៊ីប័រនៅភាគខាងកើតនៃស្រុកលូប្លីនប្រទេសប៉ូឡូញ។ ជំរំនេះមានចម្ងាយ៥គីឡូម៉ែត្រពីទន្លេបាក់ដែលសព្វថ្ងៃនេះជាព្រំដែនរវាងប្រទេសប៉ូឡូញនិងអ៊ុយក្រែន។

[៥១] គឺជាជំរំសម្លាប់ដំបូងបង្អស់របស់ណាហ្ស៊ីបន្ទាប់ពីឈ្លានពានប្រទេសប៉ូឡូញបានជោគជ័យ។ ជំរំនេះមានចម្ងាយ៥០គីឡូម៉ែត្រពីភូមិឆេលណូ។

[៥២] គឺជាជំរំប្រមូលផ្តុំនិងសម្លាប់របស់ណាហ្ស៊ីនៅជាយទីក្រុងលូប្លីន។

នៅទីនោះការសម្លាប់ប្រៀបបានដូចជាប្រតិបត្តិការឧស្សាហកម្មមួយដែលមនុស្សរស់ចូលទៅទីនោះហើយចេញមកវិញក្លាយជាផេះ។ ជំរុំទាំងនេះស្ថិតនៅលើទឹកដីប៉ូឡូញឬអ៊ុយក្រែនពីមុន។ ទាំងនោះគឺជាជំរុំសម្លាប់ក្នុងគោលបំណង គឺដើម្បីកុំឱ្យមាននរណាម្នាក់អាចរួចផុតជីវិតចេញមកបាន។

ជំរុំប្រមូលផ្ដុំដូចជាប៊ឺជិន-បែលសិន[៥៣] និងថេរ៉េស៊ីនស្តាដ[៥៤] មិនមានឡសម្រាប់ដុតសាកសពទេ។ អ្នកទោសមិនត្រូវបានគេសម្លាប់ដោយប្រើប្រាស់ផ្សែងពុល ដូច្នេះហើយជំរុំទាំងនេះមិនមែនជាជំរុំសម្លាប់ទេ។ ប៉ុន្តែវាមានលក្ខណៈអមនុស្សធម៌ស្មើគ្នា។ មនុស្សជាច្រើនបានស្លាប់ដោយសារភាពអត់ឃ្លាន ជំងឺ និងការធ្វើបាប។

អំឡុងពេលដែលយើងនៅអូសឈ្វិច ពួកគេបានយកអ្វីៗគ្រប់យ៉ាងដែលយើងមានសូម្បីតែសម្លៀកបំពាក់របស់យើង។ ប៉ុន្តែយើងនៅតែមានកម្លាំងដើម្បីធ្វើការងារ។ រោងចក្រឧស្សាហកម្មត្រូវការកម្លាំងពលកម្ម ហើយបុរសទាំងអស់ត្រូវបានបញ្ជូនទៅសមរភូមិ។ ដូច្នេះហើយទើបជំរុំការងារជាច្រើនត្រូវបានបង្កើតឡើងនៅទូទាំងប្រទេស។ ក្នុងជំរុំទាំងនេះ អ្នកទោសត្រូវធ្វើការងារដែលមានលក្ខណៈអមនុស្សធម៌ជាច្រើនខណៈពេលដែលទទួលរងនូវការធ្វើបាបនិងកង្វះស្បៀងអាហារ។

ប៉ុន្តែដូចដែលខ្ញុំបានលើកឡើង មនុស្សជាច្រើនដែលសួរសំណួរនេះចង់ដឹងអំពីអ្វីដែលកើតឡើងនៅអូសឈ្វិច។

ជាខ្លីយើងអាចនិយាយបានថា វាប្រៀបបានដូចជាការរស់នៅក្នុងពពុះសាប៊ូពណ៌ប្រផេះមួយ។ ដីមានពណ៌ប្រផេះដោយធូលី ជំរុំដែលយើងរស់នៅពោរពេញទៅដោយពណ៌ប្រផេះ សម្លៀកបំពាក់របស់អ្នកទោសមានពណ៌ប្រផេះ ហើយមេឃមានពណ៌ប្រផេះដោយសារតែផ្សែង។ វាគឺជាជីវិត

[៥៣] គឺជាភូមិមួយនៅប្រទេសអាល្លឺម៉ង់ ស្ថិតនៅខាងជើងហាណូវើដែលគឺជាជំរុំប្រមូលផ្ដុំរបស់ណាហ្ស៊ីក្នុងអំឡុងសង្គ្រាមលោកលើកទី២។

[៥៤] ត្រូវបានបង្កើតឡើងដោយណាហ្ស៊ីសម្រាប់ធ្វើជាជំរុំប្រមូលផ្ដុំនិងហ្គេតូក្នុងឆ្នាំ១៩៤១នៅក្នុងសាធារណរដ្ឋឆែក។



មួយដែលមានតែភាពច្របូកច្របល់ ដោយមិនមានពេលវេលាច្បាស់លាស់។ អ្នកមិនអាចដឹងបានទេថាតើអ្នកបាននៅទីនោះអស់រយៈពេលមួយថ្ងៃ មួយឆ្នាំ ឬពេញមួយជីវិតរបស់អ្នក...

ខ្ញុំសូមដកស្រង់ពាក្យរបស់អ្នករស់រានមានជីវិតម្នាក់ឈ្មោះថា យេហែល ដេណ័រ ដែលបានធ្វើជាសាក្សីនៅក្នុងការជំនុំជម្រះក្ដីរបស់អាដុលហ្វ៍ អាយខ្មាន់[៥៥]។ គាត់បាននិយាយថា អូសឈ្វិច គឺជាភពមួយផ្សេងទៀត។ ពេលវេលាកន្លងផុតទៅតាមមាត្រដ្ឋានដែលខុសពីផែនដី។ គ្មានក្មេងដែលកើតនៅទីនោះ ហើយក៏គ្មានអ្នកដែលកើតចាស់ឈឺស្លាប់។ ឪពុកម្ដាយគ្មានកូន, កូនគ្មានឪពុកម្ដាយ។

គោលបំណងនៃការមិនសម្លាប់អ្នកទោសមួយចំនួនដោយប្រើផ្សែងពុល គឺដោយសារតែពួកគេនឹងត្រូវយកទៅលក់នៅរោងចក្រដែលពួកគេត្រូវធ្វើពលកម្មរហូតដល់លែងមានកម្លាំងគ្រប់គ្រាន់។ ការដោះដូរបែបនេះបានកើតឡើងជាញឹកញាប់ បន្ទាប់ពីការជ្រើសរើសអ្នកដែលត្រូវបានជ្រើសរើសនឹងត្រូវបានបញ្ជូនទៅជំរុំការងារផ្សេងៗពីគ្នាដែលនៅជាប់ជាមួយរោងចក្រ។ ឯអ្នកដែលនៅសល់ត្រូវបានបញ្ជូនទៅបន្ទប់ផ្សែងពុល។

ដោយសារតែអាល្លឺម៉ង់ មិនមានបំណងក្នុងការទុកយើងទាំងអស់គ្នាឱ្យមានជីវិតរស់នៅបានយូរ របបអាហារក៏ត្រូវបានតម្រូវទៅតាមនេះដែរ។ របបអាហារត្រូវបានប៉ាន់ស្មានឱ្យសមល្មមសម្រាប់ចិញ្ចឹមជីវិតមនុស្សតែម្នាក់ក្នុងរយៈពេល៣ខែតែប៉ុណ្ណោះ។ នំប៉័ងពណ៌ខ្មៅទម្ងន់ប្រហែល៣ខាំដែលភាគច្រើនធ្វើមកពីអាចម៍រណា គឺជាអាហារសម្រាប់រយៈពេលពេញមួយថ្ងៃដែលពេលខ្លះនំប៉័ងនេះលាយជាមួយនឹងប័រម៉ាហ្គារីនទម្ងន់៥ខាំ ហើយជួនកាលលាបជាមួយដំណាប់ផ្លែឈើឬ សាច់ក្រកមួយដុំ។ លើសពីនេះក៏មានកាហ្វេដែលមានអត្ថប្រយោជន៍តែមួយគត់គឺវាក្ដៅ។

[៥៥] គឺជាមេបញ្ជាការផ្នែកវាយប្រហារជាន់ខ្ពស់និងជាអ្នកដឹកនាំការសម្លាប់រង្គាលនៅអឺរ៉ុប។

នៅអូសឈ្វិច យើងទទួលបានកាហ្វេក្តៅនៅពេលព្រឹក ហើយនៅថ្ងៃត្រង់យើងទទួលបានស៊ុបដែលមានរូបរាងដូចជាភក់ពណ៌ត្នោតដែលធ្វើមកពីឫសបន្លែនិងសំបកដំឡូង ហើយជួនកាលមានឆ្អឹងមួយដុំ។ នៅក្នុងជំរំពលកម្ម យើងក៏ទទួលបានកាហ្វេនៅពេលព្រឹក ហើយស៊ុបនៅពេលល្ងាចដែរ។ អ្នកទោសមួយចំនួនបានសន្សំសំបែដោយបែងចែកនំប៉័ងជា៣កំណាត់។ ធ្វើដូចនេះទើបវាអាចសេសសល់បានសម្រាប់អាហារ៣ពេល។ឯអ្នកខ្លះទៀតរួមទាំងខ្ញុំមិនអាចហាមឃាត់ខ្លួនឯងមិនឱ្យបរិភោគវាអស់បន្ទាប់ពីបានចែកភ្លាមៗនោះទេ។ យើងដេកនៅលើគ្រែដេកតូចៗដែលមានជាច្រើនជាន់ ហើយជារៀងរាល់ថ្ងៃយើងត្រូវបានរំខានឥតឈប់ឈរដោយ សំឡេងស្រែករាប់ចំនួនអ្នកទោស។ នេះក៏ជាមធ្យោបាយមួយផ្សេងទៀតរបស់ណាហ្ស៊ី ដើម្បីធ្វើទារុណកម្មមកលើយើងដែរ។ ទោះបីជានៅក្នុងអាកាសធាតុបែបណាក៏ដោយ ក៏យើងត្រូវបានគេដេញឱ្យទៅខាងមុខជំរំហើយឈរតម្រង់ជា៥ជួរ ដើម្បីរង់ចាំការរាប់ចំនួនអ្នកទោស។ ជារៀងរាល់ថ្ងៃ យើងត្រូវបានគេដាស់ឱ្យក្រោកតាំងពីព្រឹកព្រលឹមដោយក្មេងស្រីជនជាតិប៉ូឡូញ ឬ ឆែក ដែលទទួលបន្ទុកចេញបញ្ជានៅក្នុងជំរំ។ នាងបានដើរចូលមកបើកភ្លើងដោយប្រញាប់ប្រញាល់ ហើយស្រែកជាភាសាអាល្លឺម៉ង់ថា **Aufstehen** (អ័ហ្វស្ទៀន)! ដែលមានន័យថាដល់ពេលក្រោកហើយ។ ជាមួយនឹងពាក្យជេរប្រទេចនាងដេញយើងឱ្យទៅក្នុងបន្ទប់ទឹក។ យើងត្រូវតែប្រញាប់ប្រញាល់ពីព្រោះដល់ពេលរាប់ចំនួនអ្នកទោសហើយ។ យើងត្រូវឈរឱ្យត្រង់ជួរក្នុងរយៈពេលជាច្រើនម៉ោងស្របពេលដែលអ្នកយាមកំពុងរាប់ចំនួនអ្នកទោស។

ការរាប់ចំនួនអ្នកទោសបានបន្តទោះបីជាយើងឈឺក៏ត្រូវតែឈរឱ្យត្រង់ ហើយប្រសិនបើមានអ្នកស្លាប់នៅពេលយប់ គេនឹងយកសាកសពចេញទៅក្រៅ។ អ្នកដែលត្រួតពិនិត្យតាមក្រុមត្រូវតែប្រាកដថា



មានចំនួនច្បាស់លាស់ ហើយបញ្ជូនបាយការណ៍ទាំងនោះឱ្យទៅកងការពារណាហ្ស៊ី។ ពេលនោះ ពួកគេនឹងពិនិត្យការរាប់ ហើយពេលខ្លះមានការរាប់ចំនួនម្តងទៀតមុនពេលដែលមេបញ្ជាការជំរំបានមកដល់។ នៅពេលដែលមេបញ្ជាការជំរំទទួលបានរបាយការណ៍ រួចហើយទើបយើងអាចត្រឡប់ទៅកន្លែងរបស់យើងវិញ។ ដល់ពេលនោះយើងទាំងអស់គ្នាស្រេកឃ្លាន អស់កំលាំង និងរងារយ៉ាងខ្លាំងហើយយើងទន្ទឹងរង់ចាំការចែកកាហ្វេក្តៅ ។

“

# VAR MAN HUNGRIG HELA TIDEN?

” “

# WERE YOU ALWAYS HUNGRY?

”



## "តើអ្នកតែងតែឃ្លានមែនទេ ?"

យើងបានមកដល់ អូសឈ្វិច បន្ទាប់ពីអត់អាហារ និងទឹកអស់រយៈពេលបីថ្ងៃ ។ ភាពភ័យខ្លាចដែលបានគ្របដណ្ដប់បេះដូងរបស់ខ្ញុំបានរារាំងមិនឱ្យខ្ញុំចាប់អារម្មណ៍ថា ខ្លួនឃ្លានខ្លាំងយ៉ាងណានោះទេ ។ ខ្ញុំប្រៀបបានដូចជាយានយន្តដែលត្រូវបានគ្រប់គ្រងដោយអ្នកដទៃ ហើយតែងតែធ្វើអ្វីដែលគេបានបញ្ជា ។

ព្រឹត្តិការណ៍ផ្សេងៗបានកើតឡើងជាហូរហែ ។ អ្វីៗគ្រប់យ៉ាងបានកើតឡើងយ៉ាងឆាប់រហ័ស រហូតធ្វើឱ្យខ្ញុំមិនបានកត់សម្គាល់ឃើញពីព្រះអាទិត្យរះឡើយ ។ យើងឈរនៅក្រោមទឹកផ្កាឈូក ហើយពេលខ្លះខ្ញុំបានព្យាយាមលិឍដំណក់ទឹកដែលបានស្រក់ចុះមក ។

បន្ទាប់ពីយើងត្រូវបានបញ្ជូនទៅជំរំ ស្បៀងអាហារក៏បានមកដល់ដែលមាននំប៉័ងខ្មៅមួយដុំ ។ នៅពេលនោះ ខ្ញុំនៅតែមានអារម្មណ៍តក់ស្លុតចំពោះហេតុការណ៍ដែលបានកើតឡើងកាលពីយប់ម្សិលមិញ ហើយនឹងក្ដីបារម្ភចំពោះឪពុកម្ដាយរបស់ខ្ញុំ ។ ខ្ញុំមិនអាចលេបអ្វីចូលទៅក្នុងពោះបានទេ ។ ខ្ញុំបានឱ្យនំប៉័ងនោះទៅប្អូនស្រីរបស់ខ្ញុំរួចក៏បន្តធ្វើបែបនេះអស់រយៈពេលជាច្រើនថ្ងៃ ។ ខ្ញុំចាប់ផ្ដើមបរិភោគនំប៉័ងនៅពេលដែលខ្ញុំចាប់ផ្ដើមភ្ញាក់ខ្លួនដឹងថាប្រសិនបើខ្ញុំចង់មានជីវិតរស់នៅបន្តទៀតខ្ញុំមិនអាចបោះបង់ចោលនូវអ្វីដែលខ្ញុំមានដ៏តិចតួចនេះទេ ។

ពួកខ្ញុំមិនដែលបានបរិភោគឆ្អែតនោះទេ ។ ពេលខ្លះនំប៉័ងដែលគ្មានរសជាតិទាំងនេះមិនបានដុតឱ្យឆ្អិនល្អផង ។ វាគ្រាន់តែជាម្សៅគ្រើមៗពណ៌ខ្មៅមួយ និងគ្រាន់តែមានកាឡូរីគ្រប់គ្រាន់ដើម្បីកុំឱ្យយើងស្លាប់តែប៉ុណ្ណោះ ប៉ុន្តែនំប៉័ងនោះគឺតិចតួចណាស់ដើម្បីបន្តជីវិតរបស់យើង ។

នៅពេលដែលខ្ញុំចាប់ផ្តើមហូប ទើបធ្វើឱ្យខ្ញុំដឹងថាខ្លួនឯងឃ្លានខ្លាំងយ៉ាងណា។ វាប្រៀបបានដូចជាមានប្រហោងទទេមួយនៅក្នុងពោះរបស់ខ្ញុំដែលតែងតែបើកចំហ។ ចំណិតនំប៉ុងតូចទាំងនេះមិនអាចបំពេញប្រហោងនៅក្នុងពោះខ្ញុំបានទេ ផ្ទុយទៅវិញគឺបែរជាធ្វើឱ្យខ្ញុំចង់បានច្រើនទៀត។ ពេលវេលាចេះតែកន្លងផុតទៅ ហើយភាពស្រេកឃ្លានសឹងតែហែកពោះវៀនរបស់ខ្ញុំ។ នេះគឺជាភាពស្រេកឃ្លានរួមគ្នា។ យើងក្មេងស្រីៗប៉ុន្មាននាក់គឺជាពោះមួយដែលស្រេកឃ្លានរួមគ្នា យើងមិនដែលនិយាយអំពីអ្វីផ្សេងទេ។ យើងនិយាយតែអំពីអ្វីដែលអាចបន្លប់សេចក្តីស្រេកឃ្លានរបស់យើងតែប៉ុណ្ណោះ។

បន្ទាប់ពីយើងបានមកដល់ជំរំពលកម្ម ភាពស្រេកឃ្លានបានក្លាយទៅជារឿងមួយដែលយើងអាចទម្លាប់បាន។ អារម្មណ៍ដែលឃ្លានបានក្លាយទៅជារឿងធម្មតា។ ជារឿយៗ ពោះរបស់ខ្ញុំបានបះបោរហើយក៏ចាប់ផ្តើមមានអារម្មណ៍ឈឺចាប់ ក៏ប៉ុន្តែនៅពេលដែលអារម្មណ៍នោះកើតឡើងខ្ញុំតែងតែទំពារទឹកមាត់របស់ខ្ញុំដើម្បីបញ្ឆោតក្រពះរបស់ខ្ញុំថា ខ្ញុំកំពុងតែបរិភោគអាហារ។ យើងក៏អាចបញ្ឆោតក្រពះរបស់យើងដោយនិយាយអំពី ការចម្អិនអាហារ រូបមន្តអាហារនិងមុខម្ហូបផ្សេងៗរហូតដល់ហៀរទឹកមាត់។ ការគិតចុងក្រោយរបស់ខ្ញុំមុនពេលដែលខ្ញុំចូលគេងនៅពេលល្ងាច ជាញឹកញាប់គឺនំប៉ុងតូចមួយដែលខ្ញុំនឹងទទួលបាននៅពេលព្រឹក។ យ៉ាងហោចណាស់វាអាចរម្ងាប់ភាពអត់ឃ្លានរបស់ខ្ញុំសម្រាប់ពេលនេះបាន។

យើងតែងតែព្យាយាមរកអ្វីដែលអាចបរិភោគបាន។ វាសំខាន់ណាស់ក្នុងការរាប់អានជាមួយក្មេងស្រីៗដែលធ្វើការនៅក្នុងចង្ក្រានបាយ។ ពេលខ្លះពួកគេបានលួចដំឡូងនិងនំប៉ុងដើម្បីយកមកលើកទឹកចិត្តមិត្តភក្តិ។ ភាពសប្បាយរីករាយក៏អាចកើតឡើងពីការដើរទៅធ្វើការនៅតាមចម្ការដំណាំហើយក៏ជាកន្លែងដែលខ្ញុំប្រថុយប្រថាននឹងការវាយដំដើម្បីលួចស្ពៃ



មួយដើមឬពីរដើម។ នៅពេលនោះ ភាពអត់ឃ្លានគឺខ្លាំងក្លាជាងការភ័យខ្លាចចំពោះការដាក់ទណ្ឌកម្មទៅទៀត។ ខ្ញុំត្រូវបានអនុញ្ញាតឱ្យបរិភោគឆ្អែតត្រឹមតែមួយដងប៉ុណ្ណោះ។ ក្រុមរបស់យើងត្រូវបានបំបែកចេញពីគ្នាបន្ទាប់ពីការបំផ្ទុះនៅឃ្លាំងស្តុកប្រេង។ នៅពេលដែលមានសញ្ញាប្រាប់ពីអាហារថ្ងៃត្រង់ ទឹកស៊ុបរបស់យើងក៏គួរតែចាប់ផ្តើមចែកឱ្យគ្រប់គ្នាប៉ុន្តែយើងបែរជាត្រូវបានគេនាំទៅអាហារដ្ឋានទៅវិញ។ តុអាហារជាច្រើនត្រូវបានរៀបចំឡើងដោយមានកន្ត្រកនំប៉ុងធំមួយនៅចំកណ្តាល។ ខ្ញុំមិនហ៊ានសូម្បីតែគិតពីការប៉ះនំប៉ុងនោះរហូតដល់អ្នកយាមបានទទូចប្រាប់ថាមិនអីទេ។ ខ្ញុំភ្ញាក់ផ្អើលយ៉ាងខ្លាំងពីព្រោះយើងត្រូវបានអនុញ្ញាតឱ្យបរិភោគតាមចិត្តចង់។ នៅពេលដែលកន្ត្រកនោះទទេយើងបានថ្មីមួយទៀត។ វាពិបាកក្នុងការស្វែងយល់អំពីអ្វីដែលកំពុងតែកើតឡើង វាប្រៀបបានដូចជាមានក្រណាត់កម្ទីដែលទន់ល្មើយមួយនៅលើពោះដែលឈឺរបស់ខ្ញុំ។ ខ្ញុំហូបហើយហូបទៀតហូបហើយហូបទៀត។ ខ្ញុំពិតជាសប្បាយចិត្តណាស់។ ខ្ញុំមិនដែលដឹងទេថានំប៉ុងអាចធ្វើឱ្យខ្ញុំសប្បាយចិត្តបែបនេះបាន។ តាំងពីពេលនោះមកខ្ញុំសឹងតែគោរពនំប៉ុងនិងដំឡូងជាសាសនារបស់ខ្ញុំ។ សម្រាប់ខ្ញុំ គ្មានអាហារណាដែលអាចហៅបានថាជាអាហារទេប្រសិនបើមិនមែនជានំប៉ុង។ ភាពសប្បាយរីករាយបានកន្លងផុតទៅយ៉ាងឆាប់រហ័ស។ ខ្ញុំគិតថាប្រាកដជាមាននរណាម្នាក់បានធ្វើអ្វីខុស។ នេះគ្រាន់តែជាព្រឹត្តិការណ៍មួយដែលកើតឡើងតែមួយពេលប៉ុណ្ណោះ ហើយបន្ទាប់ពីថ្ងៃដែលយើងបានបរិភោគឆ្ងាញ់នោះមកអារម្មណ៍ស្រេកឃ្លានក៏កាន់តែមានខ្លាំងឡើងៗ នៅពេលដែលពោះរបស់យើងបង្រួមតូចមកវិញ។ ពេលនេះយើងគ្រាន់តែបន្តលេបទឹកមាត់និងព្យាយាមស្រមៃថាយើងមិនឃ្លាននោះទេ។

យើងរស់នៅបែបនេះរហូតដល់ថ្ងៃរំដោះ។ នៅពេលដែលកងទ័ពអង់គ្លេសបានជួបយើង និងឃើញសភាពរបស់យើងដែលមានភ្នែកខូង

ហើយស្រអាប់ កងទ័ពទាំងនោះចង់ជួយយើង ហើយក៏បានចែករំលែកអាហារកំប៉ុងរបស់គេឱ្យមកយើងដែរ។ យើងភាគច្រើនបរិភោគអាហារកំប៉ុងនោះយ៉ាងតក់ក្រហល់ ដោយមិនបានគិតថាវាអាចធ្វើឱ្យប៉ះពាល់ដល់ជីវិត ពីព្រោះតែក្រពះរបស់យើងមិនអាចរំលាយអាហារបានទាន់ពេល។ ខ្ញុំសំណាងល្អណាស់ដែលមិនបានបរិភោគ។ ប្រសិនបើមានអ្នកណាម្នាក់ឱ្យខ្ញុំប្រហែលជាបរិភោគដែរ។ ប៉ុន្តែពីព្រោះតែសំណាងល្អរបស់ខ្ញុំៗ បានជួបអ្នកដែលឱ្យជំឡូងខ្វីពីរមើម។



# “VILKA SPRÅK PRATADES I AUSCHWITZ?”

# “WHAT LANGUAGES WERE SPOKEN IN AUSCHWITZ?”

# "តើភាសាអ្វីដែលត្រូវបានប្រើប្រាស់នៅក្នុងជំរំអូសឈ្វិច ?"

អូសឈ្វិច គឺជា ប៉មបាបិល[៥៦] ដែលអាចឮគ្រប់ភាសារបស់អឺរ៉ុប។ ប៉ុន្តែភាសាចម្បង គឺភាសាអាល្លឺម៉ង់ ហើយប្រសិនបើយើងមិនយល់ភាសានោះទេយើងនឹងជួបបញ្ហាអាក្រក់។

នេះគឺជារឿងដ៏អាក្រក់បំផុតសំរាប់ជនជាតិ អ៊ីតាលី ដែលមានមនុស្សតិចតួចណាស់អាចនិយាយភាសាអាល្លឺម៉ង់បាន។ កងការពារ ណាហ្ស៊ីមិនបានខ្វល់ទេថាយើងមួយចំនួនមិនយល់ពីភាសារបស់ខ្លួន និងបានចាត់ទុកថា គឺជាការមិនស្តាប់បង្គាប់នៅពេលដែលយើងមិនបានធ្វើតាមបញ្ជា។ ខ្ញុំចាំថាមានស្ត្រីជនជាតិក្រិក ដែលមានរាងតូចម្នាក់មកពីកោះរ៉ូដស៍[៥៧] នាងបាននិយាយអំពីការវាយដំលើរូបរាងកាយរបស់នាងនៅពេលដែលនាងស្តាប់មិនយល់ពីអ្វីដែលគេបានបញ្ជា។ អ្នកដែលមិនយល់ពីបទបញ្ជាមិនដែលមានជីវិតរស់បានយូរនោះទេ ហើយជនជាតិក្រិក និងអ៊ីតាលីភាគច្រើនត្រូវបានសម្លាប់ដោយសារមូលហេតុទាំងនេះ។

ជនជាតិជ្វីហ្វ នៅអឺរ៉ុបខាងជើងមានសំណាងជាងជនជាតិដ៏ទៃទៀត។ ដោយសារតែអ្នកទាំងនោះអាចនិយាយភាសាយីដីស[៥៨] និងយល់អំពីបទបញ្ជា។ ដូច្នេះហើយទើបអ្នកទាំងនោះមិនងាយធ្លាក់ខ្លួនទៅជាជនរងគ្រោះដូចជាជនជាតិអ៊ីតាលី។ ខ្ញុំក៏មានចំណេះដឹងខ្លះអំពីភាសាយីដីសដែរ

[៥៦] នៅក្នុងព្រះគុម្ពី១១: ១-៩បានបកស្រាយថាប៉មបាបិលគឺជាទេវកថាដែលពន្យល់អំពីមូលហេតុធ្វើឲ្យមនុស្សក្នុងពិភពលោកនិយាយភាសាផ្សេងៗពីគ្នា។

[៥៧] គឺជាកោះមួយនៅក្នុងប្រទេសក្រិក។

[៥៨] ភាសាមួយក្នុងចំណោមភាសាអាល្លឺម៉ង់ជាច្រើនដែលត្រូវបានប្រើប្រាស់ដោយជនជាតិអាសកេណាហ្ស៊ីកជ្វីហ្វឬក៏ជ្វីហ្វ-អាល្លឺម៉ង់ ពីព្រោះនៅក្នុងសម័យរ៉ូម៉ាំងធ្លាប់មានជនជាតិជ្វីហ្វរស់នៅក្នុងតំបន់មួយដែលបច្ចុប្បន្ននេះជារបស់ប្រទេសអាល្លឺម៉ង់។



ពីព្រោះឪពុកម្តាយរបស់ខ្ញុំតែងតែនិយាយភាសានេះនៅពេលដែលពួកគាត់មិនចង់ឱ្យកូនៗស្តាប់យល់អំពីអ្វីដែលពួកគាត់និយាយ។ ជាងនេះទៅទៀត ខ្ញុំធ្លាប់បានរៀនភាសាអាល្លឺម៉ង់នៅតាមសាលារៀនរបស់ខ្ញុំ។ ដូច្នេះហើយវាធ្វើឱ្យខ្ញុំមានប្រៀបជាងអ្នកដទៃ។

នៅក្នុងជំរំអូសឈ្វិច-ប៊ីកខិណូ មនុស្សដែលមកពីសញ្ជាតិផ្សេងពីគ្នាមិនសូវមានទំនាក់ទំនងជាមួយគ្នាទេ។ ដូច្នេះហើយខ្ញុំក៏មិនមានឱកាសច្រើនដើម្បីស្តាប់ភាសាដែលនិយាយខុសគ្នាៗទាំងអស់នោះដែរ។ កន្លែងតែមួយគត់ដែលយើងអាចជួបអ្នកដែលមកពីក្រុមផ្សេងគ្នាបានគឺនៅក្នុងបន្ទប់ទឹក។ នៅទីនោះខ្ញុំព្យាយាមបង្កើតសន្ទនាខ្លះៗជាមួយក្មេងស្រីឯទៀត។

ក្រៅពីស្ត្រីដែលជាជនជាតិក្រិកនោះ ខ្ញុំក៏បានជួបរ៉ូសដែលជាក្មេងស្រីតូចម្នាក់មកពីប្រទេសហូឡង់។ នាងនិយាយភាសាអាល្លឺម៉ង់ ប៉ុន្តែខ្ញុំស្តាប់នាងមិនសូវយល់ទេ ព្រោះតែរបៀបបញ្ចេញសំឡេងរបស់នាង។ ប៉ុន្តែសំណាងល្អដែលកងការពារណាហ្ស៊ី នៅតែយល់អំពីអ្វីដែលនាងនិយាយ ហើយនាងក៏បាននិយាយប្រាប់ខ្ញុំអំពីការដែលបានតែងតាំងឱ្យធ្វើជាប្លក់កូវ៉ា[៥៩] ដែលបានធ្វើឱ្យនាងទទួលអត្ថប្រយោជន៍បន្ថែមដូចជាមានអាហារល្អ សម្លៀកបំពាក់ល្អ និងមានសេរីភាពច្រើនជាងមុន។

[៥៩] មានឈ្មោះជាភាសាអាល្លឺម៉ង់ថា **Blockova** ( ប្លក់កូវ៉ា ) គឺជាអ្នកដែលមើលខុសត្រូវនៅតាមជំរំប្រមូលផ្តុំរបស់ណាហ្ស៊ី។

“ VAD HJÄLPTE DIG ATT ÖVERLEVA? ”

“ WHAT HELPED YOU TO SURVIVE? ”



# "តើអ្វីដែលបានជួយអ្នកឱ្យរួចជីវិត ?"

មនុស្សជាច្រើននាក់មិនដែលជឿលើឱកាសនោះទេ ប៉ុន្តែប្រសិនបើខ្ញុំត្រូវឆ្លើយសំណួរថា តើអ្វីដែលបានជួយឱ្យខ្ញុំរួចជីវិត គឺខ្ញុំបានត្រឹមតែឆ្លើយថានោះគឺមកពីឱកាស។ ប្រសិនបើគ្មានឱកាសនោះទេអ្វីៗផ្សេងទៀតក៏មិនអាចជួយបានដែរ។ នៅក្នុងជំរំគឺគ្មានហេតុនិងផលទេ។ យើងមិនអាចដឹងបានទេថាយើងគួរតែនៅកន្លែងណា ឬក៏មិនគួរនៅកន្លែងណាដើម្បីឱ្យបានរួចជីវិត។ យើងអាចនឹងត្រូវកងការពារណាហ្ន៎ សម្លាប់សម្រាប់ការលេងសើចសប្បាយរបស់ពួកគេក៏មាន។ អំពើល្អដែលកងការពារទាំងនោះធ្វើមកលើយើងក៏អាចមានន័យថាបន្ទាប់មក គឺជាសេចក្តីស្លាប់។ ឧទាហរណ៍វេជ្ជបណ្ឌិតម៉េនជីលី ត្រូវបានគេស្គាល់ថា តែងតែឱ្យស្ករគ្រាប់ទៅក្មេងណាដែលគាត់នឹងយកទៅធ្វើពិសោធន៍។

" តើអ្នកអាចសម្របខ្លួនបានដោយរបៀបណា ?" មានសិស្សជាច្រើនបានសួរបែបនេះមកខ្ញុំ។ "ប្រសិនបើជាខ្ញុំ ខ្ញុំអាចនឹងស្លាប់" ។

អ្នកអាចគិតបែបនេះបាន ប៉ុន្តែសេចក្តីស្លាប់គឺមិនងាយស្រួលដូចអ្វីដែលនិយាយនោះទេ។ ការរស់នៅអាចពិបាក ប៉ុន្តែយើងគ្មានជម្រើសផ្សេងទៀតឡើយ យើងនឹងខិតខំត្រដររស់នៅរហូតដល់ទីបញ្ចប់នៃជីវិតរបស់យើង។

ជាច្រើនយប់ បន្ទាប់ពីធ្វើការងារហត់នៅពេលថ្ងៃ ខ្ញុំគិតថាខ្ញុំមិនអាចបន្តជីវិតរស់ទៅថ្ងៃមុខបានទៀតទេ។ ប៉ុន្តែនៅពេលដែលខ្ញុំភ្ញាក់ឡើង ខ្ញុំក៏ក្លាយទៅជាកូនចៀមដែលចាំស្តាប់បង្គាប់ ធ្វើភារកិច្ចដែលគេបានបញ្ជាដូចកាលពីម្សិលមិញម្តងទៀត ដោយក្តីសង្ឃឹមថាដរាបណាខ្ញុំធ្វើអ្វីដែលពួកគេបានបញ្ជា។ ពួកគេនឹងមិនបាញ់សម្លាប់ខ្ញុំទេ។ ដរាបណាដែលយើងនៅមានជីវិតយើងចង់រស់បន្តទោះបីជាមានរឿងអ្វីកើតឡើងក៏ដោយ។ យើងជាច្រើននាក់ត្រូវបានគេធ្វើទារុណកម្ម ប៉ុន្តែនៅតែមិនបោះបង់ចោលក្តីសង្ឃឹម។

ខ្ញុំក៏សង្ឃឹមដែរថាខ្ញុំនឹងនៅតែត្រដររស់នៅក្នុងស្ថានភាពបែបនោះ ប៉ុន្តែយើងក៏មិនអាចដឹងបានដែរថាយើងនឹងធ្វើអ្វីបន្ទាប់មកទៀតនោះទេ។

នៅអូសឈ្វិច ពេលខ្លះខ្ញុំគិតដោយក្តីអស់សង្ឃឹម "មិនអាចមានថ្ងៃមួយទៀតបានទេ ថ្ងៃស្អែកខ្ញុំនឹងលោតចូលបន្ទាលួសអគ្គិសនី" ប៉ុន្តែក៏មានគំនិតថ្មីមួយទៀតលេចឡើងថា "ការសម្លាប់ខ្លួននោះនឹងធ្វើឱ្យសមចិត្តពួកណាហ្ស៊ី ព្រោះអ្វីដែលពួកគេចង់បានគឺការកំចាត់យើងចោល" ។

អ្វីដែលការពារខ្ញុំពីគំនិតដ៏អាប់អួទាំងនេះគឺប្អូនស្រីរបស់ខ្ញុំ។ ភាពទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក ធ្វើឱ្យមានអត្ថន័យចំពោះជីវិតដែលគ្មានន័យរបស់យើង។ ប្រសិនបើប្អូនស្រីរបស់ខ្ញុំបាក់ទឹកចិត្ត ខ្ញុំជួយផ្តល់កម្លាំងចិត្តដល់នាង។ ប្រសិនបើខ្ញុំមិនសប្បាយចិត្ត ប្អូនស្រីរបស់ខ្ញុំនិយាយកំប្លែងឱ្យខ្ញុំស្តាប់។ ប្រសិនបើយើងគ្មានគ្នាពីរនាក់ចាំជួយគ្នាទៅវិញទៅមកនោះទេ យើងប្រាកដជាមិនអាចរស់រានមានជីវិតបានឡើយ។

ភាពសាមគ្គីនិងរង្វង់មិត្តភក្តិរបស់ខ្ញុំនៅក្នុងក្រុមក៏មានអត្ថន័យយ៉ាងខ្លាំងណាស់ដែរ។ នៅពេលល្ងាច យើងអង្គុយជុំគ្នាដើម្បីព្យាយាមបំបាត់គំនិតមិនល្អដោយនិយាយអំពីរឿងចាស់និងថ្មីអំពីកំណាព្យនិងរូបមន្តធ្វើម្ហូប។ យើងព្យាយាមបំបាត់ភាពស្រេកឃ្លានដោយ "ធ្វើម្ហូប" ដែលជាការពន្យល់ឱ្យបានក្បោះក្បាយអំពីរបៀបធ្វើម្ហូបរហូតទាល់តែយើងសឹងតែអាចធំក្លិនស្ពៃញាត់សាច់ជ្រូកចិញ្ច្រាំនិងប្រហិត។

មានរឿងផ្សេងៗជាច្រើនទៀតដែលមានសារសំខាន់ដល់ការរស់រានមានជីវិតរបស់យើងទាំងអស់គ្នាដែលមកពីប្រទេសហុងគ្រី។ អ្វីដែលសំខាន់នោះគឺយើងមិនត្រូវបានចាប់ខ្លួនឱ្យក្លាយទៅជាអ្នកទោសរហូតដល់ឆ្នាំ ១៩៤៤។ វាមានន័យថាយើងបានចំណាយពេលមិនដល់១ឆ្នាំផងនៅក្នុងជំរំ ដែលមិនដូចអ្នកដទៃទៀតដែលរងទុក្ខវេទនាអស់រយៈពេលជាច្រើនឆ្នាំ។

ការខិតខំត្រដររស់ដើម្បីប្រាប់អំពីរឿងរ៉ាវគ្រប់យ៉ាងដែលបានកើតឡើងចំពោះយើងគ្រប់គ្នាបន្ទាប់ពីសង្គ្រាមបានរលត់ទៅតែងតែមាននៅក្នុងផ្នត់គំនិតរបស់យើងជានិច្ច។ ប៉ុន្តែនៅពេលនោះយើងទាំងអស់គ្នាបានសង្ស័យថាគ្មាននរណាម្នាក់ចង់ស្តាប់រឿងរ៉ាវរបស់យើងទេ។



# "HUR VAR SAMMANHÅLLNINGEN I LÄGRET?" "WAS THERE SOLIDARITY IN THE CAMP?"

# "តើនៅក្នុងជំរំមានសាមគ្គីភាពគ្នាដែរឬទេ ?"

អ្នកប្រហែលជាគិតថាពីព្រោះតែជោគវាសនាដែលដូចគ្នារបស់យើងនឹងអាចធ្វើឱ្យយើងចេះសាមគ្គីគ្នា។ ប៉ុន្តែការពិតអ្វីៗដែលបានកើតឡើងគឺមិនមែនជាការសាមគ្គីគ្នានោះទេ។

ជាញឹកញាប់នៅពេលដែលក្រុមការងារមួយបានបង្កើតឡើង ក្រុមតូចៗនៅក្នុងនោះក៏បានបង្កើតឡើងដែរ។ ក្មេងស្រីៗដែលមកពីប្រទេសដូចគ្នារស់នៅជាមួយគ្នាយ៉ាងជិតស្និទ្ធហើយក៏មានការរើសអើងគ្នាដែរ។ ក្មេងស្រីជនជាតិជ្វីហ្វ-ប៉ូឡូញ បានចាត់ទុកថាខ្លួនឯងល្អជាងជនជាតិហុងគ្រីហើយជនជាតិហុងគ្រីគិតថាខ្លួនឯងខ្ពង់ខ្ពស់ជាងជនជាតិប៉ូឡូញ។ នៅក្នុងក្រុមដែលមកពីប្រទេសហុងគ្រី ក៏មានការប្រកាន់បក្សពួកដោយសារតែអ្នកដែលមកពីទីក្រុងដូចគ្នាគឺរាប់អានតែជាមួយអ្នកដែលមកពីទីក្រុងដូចគ្នាតែប៉ុណ្ណោះ។

អ្នកដែលមកពីទីកន្លែងដូចគ្នាឬនៅលើទូរថភ្លើងដូចគ្នា ជួយយកអាសាគ្នាទៅវិញទៅមកដោយអស់ពីចិត្ត។ ឧទាហរណ៍ ប្រសិនបើនរណាម្នាក់ត្រូវបានចាត់តាំងឱ្យធ្វើការងារដូចជានៅក្នុងផ្ទះបាយគឺអាចធ្វើឱ្យអ្នកទាំងនោះចែករបបអាហារច្រើនទៅមិត្តភក្តិរបស់ខ្លួន។ ក្មេងស្រីៗទាំងនោះចែករំលែកអត្ថប្រយោជន៍ជាមួយក្រុមរបស់ខ្លួននិងតែងតែឱ្យអាទិភាពគ្នាទៅវិញទៅមក។ នៅពេលដែលទទួលរបបអាហារ គឺសំខាន់ណាស់ចំពោះការទទួលបានទឹកស៊ុបដែលដួសមកពីបាតឆ្នាំង ព្រោះនេះគឺជាផ្នែកដែលមានបន្លែជួនពេលខ្លះមានកម្ទេចសាច់ទៀតផង។ យើងទាំងអស់គ្នាដែលឈរតម្រង់ជួរចាំទឹកស៊ុបសម្លឹងមើលទៅកាន់វែកដួសដោយក្តីប្រណែន។ តើវែកដួសសម្លនោះបានទម្លាក់ចុះទៅដល់បាតឆ្នាំងដែរឬទេ ?ឬក៏វែកដួសសម្លនោះដួសបានត្រឹមតែទឹកស៊ុបទេសម្រាប់ថ្ងៃនេះ ? ប្រធានក្រុមចាត់ចែងនីមួយៗ



ចង់បង្ហាញអំពីភាពស្មើគ្នានៅពេលដែលចែកទឹកស៊ុប ដូច្នេះហើយទើបប្រធានក្រុមទាំងនោះមិនងើយមើលមុខអ្នកដែលឈរតម្រង់ជួរទេ ដើម្បីបង្ហាញថាវែកដួសសម្លនឹងទម្លាក់ឱ្យទៅដល់បាតឆ្នាំងសម្រាប់អ្នករាល់គ្នាដែរ។ ប៉ុន្តែប្រធានក្រុមទាំងនោះបានដឹងច្បាស់ថាក្រុមរបស់ខ្លួនឈរនៅត្រង់កន្លែងណាមិនថាជួរមុខ កណ្តាល ឬចុងក្រោយគេ។ នៅពេលដែលដល់វេនក្រុមរបស់ខ្លួន នោះវែកដួសសម្លនឹងទម្លាក់ចុះដល់បាតឆ្នាំង។

ការចង់មានជីវិតរស់នៅបន្តគឺខ្លាំងក្លារហូតដល់អាចធ្វើឱ្យអ្នកខ្លះលួចនំប៉័ងពីសាច់ញាតិរបស់ខ្លួន កូនលួចពីម្តាយ រីឯបងប្អូនលួចពីគ្នាទៅវិញទៅមក។ មានអ្នកខ្លះទៀតលះបង់អាហារខ្លួនទៅឱ្យអ្នកដទៃ ប៉ុន្តែហេតុការណ៍នេះមិនសូវកើតឡើងជាញឹកញាប់នោះទេ។ នៅក្នុងក្រុមរបស់ខ្ញុំមានមនុស្សស្រីម្នាក់ត្រូវបានគេស្គាល់ថាគឺជាមនុស្សដែលមានចិត្តកំណាញ់និងអាត្មានិយម។ ប៉ុន្តែនាងបានប្រែទៅជាមនុស្សដែលចេះលះបង់និងមានសណ្តានចិត្តល្អ។ នាងតែងតែជួយឱ្យអស់ពីសមត្ថភាពរបស់ខ្លួន ហើយក៏លះបង់អត្ថប្រយោជន៍របស់នាងទៅអ្នកដែលមានសេចក្តីត្រូវការខ្លាំងជាង។

ការប្តឹងនិងរិះគន់ដោយចំហ មិនមែនជារឿងដែលកម្រកើតមានឡើងនោះទេ។ ដើម្បីបានអត្ថប្រយោជន៍បន្ថែមគឺមានអ្នកខ្លះហ៊ានរាយការណ៍ប្រាប់ពីមិត្តភក្តិរបស់ខ្លួន។ រឿងរ៉ាវទាំងនេះ បានកើតឡើងមកលើរូបខ្ញុំផ្ទាល់។ ខ្ញុំគឺជាអ្នកដែលនៅក្នុងចំណោមមនុស្សមួយចំនួនដែលចេះភាសាអាល្លឺម៉ង់ហើយក៏មានកម្ពស់ខ្ពស់ជាងអ្នកដទៃទៀត។ ដូច្នេះពេលដែលយើងទៅធ្វើការនៅអេដេលស្តេតខ្ញុំត្រូវបានចាត់តាំងឱ្យធ្វើជាការប៉ូ។ នៅពេលក្លាយខ្លួនទៅជាកាប៉ូ គឺមានន័យថា យើងគឺជាដៃជើងរបស់កងការពារណាហ្ស៊ីហើយមានតួនាទីក្នុងការមើលខុសត្រូវថាតើសមាជិកនៅក្នុងក្រុមបានខិតខំប្រឹងប្រែងធ្វើការងារដែរឬទេ។ ការងារនេះធ្វើឲ្យយើងទទួលបានទឹកស៊ុប

បន្ថែមមួយចានទៀត។ យើងមិនអាចបដិសេធការតែងតាំងនេះបានទេ ប៉ុន្តែយើងអាចបំផ្លាញការងារនេះបាន។ បន្ទាប់ពីធ្វើដំណើរបានបន្តិច យើងបានមកដល់រោងចក្រទ្រុឌទ្រោមមួយ ដែលការងាររបស់យើងគឺត្រូវសម្អាតកំទេចថ្ម។ យើងត្រូវឈរជាជួរៗហើយហុចថ្មទៅម្ខាងទៀតដើម្បីដាក់ជាគំនរឱ្យមានរបៀប។ កាតព្វកិច្ចរបស់ខ្ញុំគឺត្រូវមើលក្មេងស្រីៗទាំងនោះឱ្យធ្វើការងារឱ្យអស់ពីសមត្ថភាព ប៉ុន្តែផ្ទុយទៅវិញខ្ញុំបែរជាជួយឃ្លាំមើល និងចាំប្រាប់ក្មេងស្រីៗទាំងនោះនៅពេលណាដែលកងការពារណាហ្ស៊ីដើរមកក្បែរ។ ក្មេងស្រីៗទាំងនោះអាចធ្វើការបានតាមសម្រួលរហូតទាល់តែខ្ញុំឱ្យសញ្ញាទើបអ្នកទាំងនោះចាប់ផ្តើមខិតខំធ្វើការងារវិញ។

ពីរថ្ងៃមិនទាន់បានរំលងផុតទៅផង ខ្ញុំក៏ត្រូវបានរាយការណ៍ដោយក្មេងស្រីជនជាតិប៉ូឡូញម្នាក់។ ចំពោះក្មេងស្រីម្នាក់នោះត្រឹមតែទឹកស៊ុបបន្ថែមមួយចានសោះគឺអាចធ្វើឱ្យនាងហ៊ានធ្វើបែបនេះបាន។



# "HUR VAR DET ATT VARA KVINNA I LÄGREN?"

# "WHAT WAS IT LIKE TO BE A WOMAN IN THE CAMPS?"

## "តើក្នុងនាមជាស្ត្រីម្នាក់ដែលរស់នៅក្នុងជំរំមានលក្ខណៈបែបណាដែរ?"

នៅពេលដែលនិយាយអំពីទង្វើដែលបានប្រព្រឹត្តិទៅលើអ្នកទោស គឺគ្មានភាពខុសគ្នារវាងស្ត្រីនិងបុរសទេ។ ស្ត្រីក៏ត្រូវបានប្រើឱ្យធ្វើការងារធ្ងន់ ហើយក៏ត្រូវបានដាក់ទោសយ៉ាងធ្ងន់ធ្ងរដូចគ្នាដែរ។ កងការពារណាហ្ស៊ីមិនបានចាត់ទុកយើងជាស្ត្រីនោះទេ គឺយើងគ្រាន់តែជាវត្ថុដែលត្រូវបានប្រើប្រាស់ឱ្យធ្វើការងារតែប៉ុណ្ណោះ។ ស្ត្រីជាពិសេស ស្ត្រីវ័យក្មេងបានព្យាយាមរក្សាភាពជាស្ត្រីរបស់ខ្លួនសូម្បីតែនៅក្នុងស្ថានភាពដែលស្ទើរតែមិនអាចទ្រាំទ្របានយ៉ាងណាក៏ដោយ។ នៅពេលដែលយើងទៅដល់ជំរំពលកម្មហើយបានជួបអ្នកទោសសង្គ្រាមបារាំងដែលធ្វើការនៅកន្លែងជាមួយគ្នា យើងបានព្យាយាមស្វែងរកក្រែមលាបមាត់ឬម្សៅលាបមុខនៅតាមសំណង់បាក់បែក។ យើងចាប់ផ្តើមចង់តុបតែងខ្លួនសារជាថ្មីម្តងទៀត ហើយយើងចង់ធ្វើឱ្យខ្លួនយើងមានភាពទាក់ទាញចំពោះបុរសវ័យក្មេងដ៏ស្រស់សង្ហាទាំងនោះ។ រឿងរ៉ាវស្នេហាដែលបរិសុទ្ធក៏បានកើតឡើង មិនយូរប៉ុន្មានក្មេងស្រីនៅទីនោះក៏ចាប់ផ្តើមមានបុរសបារាំងដែលជា "របស់នាង" ។

យើងត្រូវបានហាមផ្តាច់មិនឱ្យមានទំនាក់ទំនងជាមួយគ្នាប៉ុន្តែនៅក្នុងពេលដែលគ្មានអ្នកណាត្រួតពិនិត្យមើលបុរសបារាំងទាំងនោះនឹង "ទម្លាក់" កាដូតូចមួយនៅមុខក្មេងស្រីដែលខ្លួនចាប់អារម្មណ៍ ខណៈពេលដែលនាងដើរឆ្លងកាត់ ហើយក្មេងស្រីនោះនឹង "ទម្លាក់" សំបុត្រដែលមានពាក្យអរគុណពីរឬបីម៉ាត់ត្រឡប់ទៅវិញ។ យើងត្រូវតែប្រុងប្រយ័ត្នថានឹងគ្មានកងការពារណាហ្ស៊ី នៅជិតនៅពេលណាដែលយើងធ្វើរឿងបែបនោះឡើង ពីព្រោះទង្វើបែបនេះនឹងត្រូវបានដាក់ទោសយ៉ាងធ្ងន់ធ្ងរ។ ការដាក់ទោសយ៉ាងធ្ងន់ធ្ងរក៏អាចអនុវត្តនៅពេលណាដែលបុរសនិងនារីត្រូវចាប់បានថានៅជាមួយគ្នាដែរ។ ប៉ុន្តែតាមអ្វីដែលខ្ញុំចាំបានហេតុការណ៍ទាំងនេះ គឺមិនបានកើតឡើងនៅជំរំដែលខ្ញុំរស់នៅទេ។ ដោយឡែកហេតុការណ៍ទាំងនេះបានកើតឡើងនៅ អូសឈ្វិច ។

នៅអូសឈ្វិច យើងរស់នៅក្នុងជំរំធំដែលមានមនុស្សចំនួន៥០០នាក់។ យើងត្រូវបានត្រួតត្រាដោយមេក្រុមម្នាក់ឈ្មោះថា អ៊ីតកា ដែលជាក្មេងស្រីជនជាតិប៉ូឡូញម្នាក់។ នាងមានជំនួយការ ដែលត្រូវជាប្អូនស្រីរបស់នាងមានឈ្មោះថា អេលសា។ ក្មេងស្រីទាំងពីរនាក់នេះមកពីប្រទេសប៉ូឡូញ ហើយបានរស់នៅក្នុង អូសឈ្វិច អស់រយៈពេលពីរឆ្នាំមកហើយ។ ពួកគេទាំងពីរ គឺមានមុខមាត់ស្រស់ស្អាតណាស់ និងមានរបបអាហារបរិភោគគ្រប់គ្រាន់។ អ្នកទាំងពីរក៏ត្រូវបានអនុញ្ញាតឱ្យរក្សាសក់ដ៏ស្រស់ស្អាតរបស់ខ្លួនថែមទាំងមានសម្លៀកបំពាក់ធម្មតា និងទទួលបានរបបអាហារច្រើនជាងអ្នកដទៃ។ មានថ្ងៃមួយ យើងមិនឃើញ អេលសា ទេ ហើយនៅពេលដែលនាងបង្ហាញខ្លួន សក់ក្បាលរបស់នាងត្រូវបានកោរ ហើយភ្នែកនាងហើមស្ពឹង។ យើងឆ្ងល់ថា តើមានរឿងអ្វីបានកើតឡើងចំពោះនាង។ ក្រោយមកនាងក៏បានប្រាប់យើងទាំងអស់គ្នាអំពីដំណាលរឿងថា មានបុរសម្នាក់ដែលធ្វើការងារនៅក្នុងឈាបនដ្ឋានបានទៅរកនាងដោយសម្ងាត់ ហើយប្រគល់ឱ្យនាងនូវវត្ថុចាំបាច់មួយចំនួន។ ជាធម្មតា អារម្មណ៍ផ្លូវភេទក៏បានកើតឡើងរវាងអ្នកទាំងពីរ។ អេលសា បានធ្លាក់ក្នុងអន្លង់ស្នេហ៍បុរសម្នាក់នោះ។ ខ្ញុំមិនបានដឹងទេថារឿងរ៉ាវបានបន្តរហូតដល់ពេលណាប៉ុន្តែថ្ងៃមួយ គូស្នេហ៍មួយគូនេះត្រូវចាប់បានដោយកងការពារ ណាហ្ស៊ី។ អេលសាត្រូវបានកងការពារណាហ្ស៊ីវាយដំ និងកោរសក់ក្បាលហើយអត្ថប្រយោជន៍បន្ថែមរបស់នាងក៏ត្រូវបានដកហូត។ បុរសម្នាក់នោះត្រូវបានគេវាយ និងទំនងជាមិនអាចនឹងរួចផុតជីវិតនោះទេ។

“

# HUR VAR DET ATT HA MENS?

” “

# WHAT WAS IT LIKE TO HAVE YOUR PERIOD?

”



# "តើយ៉ាងដូចម៉េចទៅនៅពេលដែលអ្នកមានរដូវ?"

ស្ត្រីៗបានយកសំឡីអនាម័យទៅតាមខ្លួននៅពេលចេញដំណើរដោយមិនបានសង្ស័យថានឹងមិនត្រូវបានអនុញ្ញាតឱ្យយកអីវ៉ាន់ឬក៏សំឡីអនាម័យទាំងនោះតាមខ្លួនទេ។ ប៉ុន្តែជាក់ស្តែងសំឡីទាំងនោះគ្មានប្រយោជន៍អ្វីសម្រាប់យើងទេ។ ខ្ញុំមានរដូវបានប្រហែលជាមួយឬពីរដងប៉ុណ្ណោះហើយក្នុងពេលនោះគឺពិតជាលំបាកខ្លាំងណាស់។ គ្មានអ្វីដែលអាចទប់ឈាមរបស់យើងបាននោះទេ។ ប្រសិនបើយើងសំណាងល្អ ក្មេងស្រីដែលជាមេក្រុមរបស់យើងអាចនឹងឱ្យក្រណាត់កន្ទបមកខ្លះ។ ពេលខ្លះយើងប្រថុយប្រថាននឹងការដាក់ទោសដោយហែកសម្លៀកបំពាក់ដែលនៅនឹងខ្លួនយកទៅប្រើប្រាស់ ប៉ុន្តែជារឿយៗយើងត្រូវដើរទៅណាមកណាដោយមានឈាមប្រឡាក់ឬមានឈាមហូរតាមជើង។ នៅពេលនោះគឺសំខាន់ណាស់ដែលយើងមិនដើរជួបជាមួយកងការពារណាហ្ស៊ី បើមិនដូច្នេះពួកគេនឹងជេប្រទេចយើងថា **Dreckige Judesau** (ជ្រិចហ្គីកី យូដេសោ) ដែលមានន័យថាជ្រូកជ្វីហ្វស្មោគគ្រោគ ដែលមិនចេះថែរក្សាអនាម័យខ្លួនឯង ហើយក៏វាយយើងរហូតដល់ជាំពេញខ្លួន។ នៅថ្ងៃមួយមិត្តភក្តិរបស់ខ្ញុំឈ្មោះថា ដូរ៉ា បានកត់សម្គាល់ថានាងគួរតែមានរដូវតាំងពីបីថ្ងៃមុនមកម្ល៉េះ។ នាងគិតថាវាពិតជាចម្លែកណាស់ព្រោះនាងមិនដែលបាននៅជាមួយបុរសណាម្នាក់នោះទេ។ បន្ទាប់មកគ្នាយើងជាច្រើននាក់ទៀតក៏ចាប់ផ្តើមជួបរឿងបែបនេះដែរ។ មានមនុស្សស្រីតែប៉ុន្មាននាក់ប៉ុណ្ណោះដែលមានរដូវបន្ទាប់ពីមកដល់ជំរំប្រមូលផ្តុំបានប៉ុន្មានសប្តាហ៍។ ក្មេងស្រីមួយចំនួនគិតថាខ្លួនមានផ្ទៃពោះ ប៉ុន្តែបន្តិចក្រោយ

មកទើបយើងដឹងថាវាមិនមែនជាសញ្ញាដែលមានផ្ទៃពោះនោះទេ។ ការមានរដូវគឺបានឈប់ដោយឯកឯង។ មានពាក្យចចាមអារ៉ាមថានេះគឺដោយសារតែសារធាតុប្រូមីន[៦០] ដែលមាននៅក្នុងនំប៉័ងប៉ុន្តែរឿងនេះមិនត្រូវបានបញ្ជាក់ឱ្យបានច្បាស់លាស់នោះទេ។ វាគឺជាការពិតដែលរដូវអាចឈប់ដោយសារតែរបបអាហារមិនល្អដូចគ្នាទៅនឹងអ្នកដែលមានជំងឺធុញនឹងអាហារ ប៉ុន្តែមូលហេតុនេះមិនអាចយកមកពន្យល់នៅក្នុងករណីរបស់យើងបានទេ។ យើងប្រាកដជាត្រូវបានឱ្យអ្វីដែលអាចប៉ះពាល់ដល់អ័រម៉ូនរបស់យើងជាក់ជាមិនខាន។

យើងទាំងអស់គ្នាខ្លាចថារដូវនឹងមិនមកម្តងទៀតទេហើយនៅពេលអនាគត យើងនឹងមិនអាចមានកូនបានទេ។ ប៉ុន្តែសំណាងល្អដែលរឿងនេះមិនបានកើតឡើង។ រដូវបានមកទៀងទាត់វិញនៅពេលដែលយើងទទួលបានរបបអាហារគ្រប់គ្រាន់។ បន្ទាប់ពីសង្គ្រាមបានបញ្ចប់ មានស្ត្រីមួយចំនួនសម្រេចចិត្តមិនយកកូនពីព្រោះភាពភ័យខ្លាចរបស់អ្នកទាំងនោះដែលបានគិតថាអ្វីៗគ្រប់យ៉ាងដែលខ្លួនបានឆ្លងកាត់អាចនឹងកើតមានឡើងម្តងទៀត។ ប៉ុន្តែបន្ទាប់មក នៅពេលដែលស្ត្រីទាំងនោះមានវ័យចំណាស់ទៅ ពួកគេបានសោកស្តាយដែលមិនមានក្រុមគ្រួសារសម្រាប់ខ្លួនឯង។ អ្នកទាំងនោះមានអារម្មណ៍ឯកោយ៉ាងខ្លាំង។

[៦០] គឺជាសារធាតុគីមីដែលមានពណ៌ក្រហមក្រមៅហើយរលាយនៅក្នុងទឹក។



“BLEV NI VÅLDTAGNA?”

“WERE YOU RAPED?”

# "តើអ្នកត្រូវបានចាប់រំលោភដែរឬទេ ?"

អំពើរំលោភសេពសន្ថវៈតែងតែត្រូវបានប្រើជាវិធីសាស្ត្រមួយសម្រាប់ភាគីម្ខាងក្នុងការបំពានលើ "ទ្រព្យសម្បត្តិ" របស់ភាគីម្ខាងទៀត ដែលក្នុងករណីនេះគឺសំដៅទៅលើមនុស្សស្រី។ នៅអាល្លឺម៉ង់ហេតុការណ៍នេះមិនបានកើតឡើងទេ។ សម្រាប់ពួកណាហ្ស៊ី រំលោភសេពសន្ថវៈត្រូវបានដាក់ចូលក្នុងគោលការណ៍ហាមឃាត់ពីព្រោះទំនាក់ទំនងរវាងជាតិសាសន៍ខុសគ្នាគឺត្រូវបានហាមឃាត់ដោយច្បាប់។ ក៏ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែងគឺមានភាពខុសគ្នាទាំងស្រុង។ សំណាងល្អដែលគ្មាននរណាម្នាក់នៅក្នុងក្រុមរបស់ខ្ញុំត្រូវបានគេចាប់រំលោភ ហើយអស់រយៈពេលជាយូរខ្ញុំមិនបានដឹងថារឿងនេះបានកើតឡើងនៅក្នុងជំរំផ្សេងទៀតនោះទេ។ ខ្ញុំបានដឹងអំពីរឿងនេះបន្ទាប់ពីសង្គ្រាមបានបញ្ចប់ទៅ។ ខ្ញុំបានជួបនារីម្នាក់ដែលបានប្រាប់រឿងរ៉ាវអាក្រក់ទាំងនេះមកខ្ញុំ។ ដើម្បីការពារសីលធម៌ក្នុងចំណោមទាហានណាហ្ស៊ី ផ្ទះបនត្រូវបានបង្កើតឡើងដែលមានដូចជាផ្ទះបនសម្រាប់មន្ត្រីជាន់ខ្ពស់ និងផ្ទះបនសម្រាប់នាយទាហាន។ ក្មេងស្រីជនជាតិជ្វីហ្វត្រូវបានបញ្ជូនទៅទីនោះ ហើយប្រសិនបើយើងចង់មានជីវិតរស់ យើងត្រូវតែស្តាប់បញ្ជា។ បន្ទាប់ពីធ្វើការងារដែលលំបាកអស់រយៈពេលពេញមួយថ្ងៃ ក្មេងស្រីដែលមានរូបរាងស្រស់ស្អាតត្រូវបានគេមកយកទៅផ្ទះបននៅពេលល្ងាច ហើយនឹងបញ្ជូនត្រឡប់មកធ្វើការវិញនៅពេលព្រឹក។

ឯអ្នកខ្លះទៀតត្រូវចាំបម្រើនៅទីនោះគ្រប់ពេលវេលា។ ក្មេងស្រីទាំងនោះមិនអាចមានជីវិតរស់នៅបានយូរនោះទេ។ ប៉ុន្តែមានក្មេងស្រីដែលមានសំណាងល្អមួយចំនួនបានធ្វើឱ្យទាហានអាល្លឺម៉ង់ធ្លាក់ក្នុងអន្លង់ស្នេហ៍ ហើយក្មេងស្រីនោះនឹងរស់នៅក្នុងជីវិតដែលសមរម្យជាមួយទាហានរបស់នាង។ ជាពិសេសប្រសិនបើទាហាននោះមានតំណែងខ្ពស់នៅក្នុងជំរំ។



កងការពារណាហ្ស៊ីដែលមានតំណែងខ្ពស់អាចជ្រើសរើសក្មេងស្រីដើម្បីគ្រប់គ្រងកិច្ចការផ្ទះរបស់ខ្លួនបាន ហើយនាងនឹងត្រូវបានលើកលែងមិនឱ្យធ្វើការងារធ្ងន់នៅខាងក្រៅផ្ទះឡើយ។ ប៉ុន្តែទោះបីជានៅក្នុងលក្ខខណ្ឌនោះក៏ដោយ ក៏មិនអាចធានាបានដែរថាក្មេងស្រីនោះនឹងអាចរួចជីវិតនៅក្នុងពិភពលោកដែលមិនច្បាស់លាស់ និងខ្វះវិចារណញ្ញាណរបស់ពួកណាហ្ស៊ីនោះទេ។

# “ VAR DU RÄDD FÖR DÖDEN? ” “ WERE YOU AFRAID OF DEATH? ”



## " តើអ្នកខ្លាចសេចក្តីស្លាប់ដែរឬទេ ?"

សេចក្តីស្លាប់មិនមែនជាអ្វីដែលខ្ញុំខ្លាចនោះទេ។ អ្វីដែលកាន់តែអាក្រក់ជាងនេះគឺភាពមិនប្រាកដប្រជា ការរង់ចាំដែលគ្មានទីបញ្ចប់ និងសេចក្តីបារម្ភទៅវិញទេ។ សេចក្តីបារម្ភណ៍គឺតែងតែមាននៅក្នុងចិត្តខ្ញុំជានិច្ច។ សេចក្តីបារម្ភណ៍ប្រៀបបានដូចជាសម្លេងរហឹមៗនៅពីខាងក្រោយ នឹងបាត់ទៅវិញលុះត្រាតែនៅពេលណាដែលខ្ញុំមានអារម្មណ៍ភ័យខ្លាចចំពោះការគំរាមកំហែងអាយុជីវិតដែលខិតជិតចូលមកដល់។

អ្វីដែលខ្ញុំខ្លាចគឺថាតើសេចក្តីស្លាប់នឹងមកដល់តាមរបៀបណា។ មិនមានជីវិតបន្តទៀតគឺជាបំណងប្រាថ្នាដ៏ធំបំផុតសម្រាប់យើងទាំងអស់គ្នា ប៉ុន្តែផ្លូវដែលនាំយើងទៅដល់ទីនោះទេដែលធ្វើឱ្យយើងភ័យខ្លាច។ ភាពកាចសាហាវឃោរឃៅរបស់ណាហ្ស៊ីអាចធ្វើឱ្យមានការឈឺចាប់យ៉ាងខ្លាំងមុនពេលដែលសេចក្តីស្លាប់ចូលមកដល់។ នោះហើយគឺជាអ្វីដែលខ្ញុំខ្លាច។ ខ្ញុំចាំបានថា នៅពេលដែលខ្ញុំក្រោកឡើងខ្ញុំបានគិតថា "តើខ្ញុំអាចឆ្លងផុតថ្ងៃនេះបានដែរឬទេ ?" ប៉ុន្តែខ្ញុំគ្មានពេលក្នុងការសញ្ជឹងគិតនោះទេ។ សម្លេងស្រែករបស់កងការពារនាស៊ីណាហ្ស៊ី បានធ្វើឱ្យខ្ញុំស្ទុះចេញពីគ្រែហើយមើលកិច្ចការត្រូវធ្វើដែលកំណត់នៅក្នុងរបៀបវារៈដូចជាធ្វើគ្រែចំបើង ទៅបន្ទប់ទឹក និងការរាប់ចំនួនរបស់អ្នកទោស។ បន្ទាប់មកយើងទាំងអស់គ្នាក៏ចាប់ផ្តើមដើរទៅធ្វើការងារហើយរហូតទាល់តែខ្ញុំត្រឡប់មកវិញនៅពេលយប់ទើបខ្ញុំមានកម្លាំងដើម្បីគិត។

ថ្ងៃរបស់ខ្ញុំបញ្ចប់ដោយខ្ញុំរំឭកពីកំណាព្យមួយដែលនិពន្ធដោយជនជាតិហុងគ្រី ម្នាក់ឈ្មោះថាអារ៉ាណើ ហាណុស ដែលបកប្រែជាគ្រួសៗថា៖

អរគុណព្រះជាម្ចាស់<br>
សម្រាប់ការវិលត្រឡប់មកវិញនៃពេលល្ងាច<br>
ផែនដីដែលរងទុក្ខសោក<br>
ឥឡូវនេះអាចសម្រាកបានដោយស្ងប់ស្ងាត់។

“ HUR VAR NI KLÄDDA? ” “ HOW WERE YOU DRESSED? ”



# "តើអ្នកស្លៀកសម្លៀកបំពាក់យ៉ាងដូចម្តេច ?"

នៅពេលដែលយើងមកដល់ អូសឈ្វិច យើងទាំងអស់គ្នាគឺត្រូវអាក្រាតកាយ។ យើងត្រូវទុកសម្លៀកបំពាក់របស់យើងក្នុងមួយគំនរ ហើយស្បែកជើងរបស់យើងចងជាប់គ្នាដាក់ក្នុងមួយគំនរផ្សេងទៀត។ ខ្ញុំបានគិតដោយស្ងាត់ៗថា តើអ្នកទាំងអស់គ្នានឹងរកសម្លៀកបំពាក់របស់ខ្លួនវិញបានដោយរបៀបណា? ចុងក្រោយទើបខ្ញុំដឹងថា សម្លៀកបំពាក់ទាំងអស់នោះនឹងត្រូវបញ្ជូនទៅប្រទេសអាល្លឺម៉ង់ បន្ទាប់ពីកម្លាំងការងារបានបែងចែកវត្ថុណាដែលមិនអាចប្រើការបានចេញអស់ជាមុន។ សម្លៀកបំពាក់ណាដែលមិនត្រូវបានបញ្ជូនចេញទៅប្រទេសអាល្លឺម៉ង់នឹងត្រូវយកទៅសម្អាតសម្លាប់មេរោគ ហើយលាបឈើឆ្កាងពណ៌លឿងពីលើដើម្បីឱ្យអ្នកទោសប្រើប្រាស់។ យើងត្រូវបានគេឱ្យអាវដៃវែងពណ៌ប្រផេះដែលមានប្រវែងខុសគ្នានិងខោអាវក្នុងដែលមានរូបរាងអាក្រក់ ធ្វើមកពីក្រណាត់គ្រើមៗ។ ខ្ញុំមិនចាំបានទេថាយើងត្រូវបានគេឱ្យស្រោមជើងឬក៏អត់ ប៉ុន្តែយើងទទួលបានកន្សែងបង់កមួយដែលយើងយកមកគ្របក្បាលត្រងោលរបស់យើង។ នៅពេលដែលយើងត្រូវបានជ្រើសរើសឱ្យធ្វើការងារ យើងត្រូវប្តូរទៅស្លៀកសម្លៀកបំពាក់ "ស៊ីវិល" ដែលមានលាបឈើឆ្កាងពណ៌លឿងពីលើ ដើម្បីកុំឱ្យច្រឡំជាមួយអ្នកដែលមិនត្រូវបានជ្រើសរើស។ សម្លៀកបំពាក់នេះត្រូវបានប្តូរនៅពេលខ្លះ។ នៅពេលដែលអាកាសធាតុត្រជាក់ខ្លាំង យើងទទួលបានសម្លៀកបំពាក់បន្ថែមដែលគេហៅថា "សម្លៀកបំពាក់កក់ក្តៅ" ។ ខ្ញុំបានអាវក្រៅមួយទោះបីជាអាវនោះស្តើងក៏ដោយ ចំណែកឯ លីវី បានអាវចាក់ដៃវែងមួយ។ ដើមឡើយអាវនោះ គឺជារបស់ប្អូនស្រីជីដូនមួយឈ្មោះថា ជីតស៊ី ដែលលីវីចូលចិត្តជាងគេ។

ដោយសារតែបែបនេះហើយ ទើបយើងដឹងថាប្អូនស្រីជីដូនមួយក៏បានធ្វើការងារនៅក្រោមផ្លាកសរសេរថា "អាបាយ មាហ៍ ហ្វ្រាយ៍ **Arbeit macht frei**" ការងារធ្វើឱ្យអ្នកមានសេរីភាព ដូចគ្នាដែលជាផ្លាកចំអកព្យូរនៅលើច្រកចូលទៅអូសឈ្វិច។ "សម្លៀកបំពាក់កក់ក្ដៅ" ត្រូវប្រគល់ត្រលប់ទៅវិញនៅរដូវផ្ការីក ហើយអ្វីផ្សេងៗទៀតយើងទុករហូតដល់ថ្ងៃដែលត្រូវបានគេរំដោះ។ បន្ទាប់ពីការរំដោះ យើងចង់កម្ចាត់សម្លៀកបំពាក់នេះចោលឱ្យបានឆាប់បំផុត និងរកសម្លៀកបំពាក់ថ្មីទៀតមកជំនួសវិញ។ នៅពេលខ្លះយើងទទួលបានអំណោយពីទាហានអង់គ្លេស ឬយើងត្រូវចេញទៅខាងក្រៅដើម្បីស្វែងរកសម្លៀកបំពាក់ទាំងអស់នោះដោយខ្លួនឯង។ យើងអាច "ស្វែងរកឃើញ" សម្លៀកបំពាក់ហាលនៅលើស្ទួ ហើយក៏បានលួចយកមកដោយពុំទៀងត្រង់ ប៉ុន្តែអាល្លឺម៉ង់ បានយកទៅពីយើងច្រើនជាងអ្វីដែលយើងបានលួចយកមកនេះណាស់។ នេះមិនមែនហៅថាជាចោរនោះទេ ប៉ុន្តែហៅថា "ការរៀបចំសារជាថ្មីម្តងទៀត" ទៅវិញទេ។ នាពេលនោះដែរគេត្រូវការក្មេងស្រីដែលពូកែដេរជាច្រើនអ្នក។ ភួយនិងកម្រាលជាច្រើនត្រូវបានប្រែក្លាយឱ្យទៅជាសម្លៀកបំពាក់នៅក្រោមម្រាមដៃដ៏រហ័សរហួនរបស់ពួកគេ។ ក្មេងស្រីទាំងនោះបានកែប្រែភួយនិងកម្រាលឱ្យក្លាយទៅជា សំពត់ អាវក្រៅ និងរ៉ូបជាដើម។ ខ្ញុំខ្លួនឯងក៏មានរ៉ូបមួយដែលធ្វើមកពីក្រណាត់វាំងននពណ៌បៃតងនិងបាន "ស្វែងរកឃើញ" ខោទាហានកងនាវីពណ៌ខៀវមួយគូដែលធ្វើពីរោមសត្វ។ ខ្ញុំស្លៀកខោមួយនោះពេលដែលយើងធ្វើដំណើរមកកាន់ប្រទេសស៊ុយអែត។ នៅទីក្រុងលូបេក យើងនិងសម្លៀកបំពាក់ត្រូវបានយកទៅសម្លាប់មេរោគ ហើយមានក្មេងស្រីមួយចំនួនអាចរក្សាទុកសម្លៀកបំពាក់ដែលខ្លួនអាចពាក់បាន។ ចំណែកខ្ញុំបានរក្សាទុកខោទាហានកងនាវីពណ៌ខៀវនោះ និងបានពាក់វាម្តងទៀតទៅកន្លែងធ្វើការដំបូងរបស់ខ្ញុំនៅទីក្រុងស្តុកខុល ។

សម្រាប់ប្រាក់ខែដំបូងរបស់ខ្ញុំ ខ្ញុំបានទិញរ៉ូបពណ៌ខ្មៅមួយធ្វើពីរោមសត្វដែលមានតំលៃ១០០ គ្រូណារ[៦១] ដែលស្មើនឹងប្រាក់ខែខ្ញុំមួយខែពេញ។ រ៉ូបនោះពិតជាសាកសមនឹងតម្លៃណាស់។ នៅទីបំផុតខ្ញុំអាចពាក់អ្វីមួយដែល " ថ្លៃថ្នូរ " ហើយធ្វើឱ្យខ្ញុំមានទំនុកចិត្តពេលដែលខ្ញុំចេញទៅជួបមិត្តភក្តិនៅហាងកាហ្វេនាពេលរសៀលក្នុងថ្ងៃអាទិត្យ។

[៦១] គឺជារូបិយប័ណ្ណផ្លូវការរបស់ប្រទេសស៊ុយអែត (១គ្រូណារស្មើលុយខ្មែរ៤០០រៀល)។

“ BLÊV NI SIUKA? ” “ DID YOU GET SICK? ”

# " តើអ្នកមានជំងឺដែរឬទេ ? "

នៅពេលនោះគឺសំខាន់ណាស់ដែលយើងមិនត្រូវមានជំងឺ។ យើងអាចរួចជីវិតបានយូរដរាបណាយើងអាចធ្វើការបានតែប៉ុណ្ណោះ។ ប្រសិនបើយើងឈឺ យើងនឹងមិនមានប្រយោជន៍សម្រាប់ពួកគេទៀតទេ។ យើងដឹងថាប្រសិនបើយើងត្រូវបានចាត់ទុកថាគ្មានប្រយោជន៍គេនឹងបញ្ជូនយើងទៅបន្ទប់ផ្សែងពុល។ ដូច្នេះហើយ យើងកម្រនឹងឈឺធ្ងន់ធ្ងរណាស់។ គ្នាយើងមួយចំនួនដែលធ្លាប់តែឈឺរ៉ាំរ៉ៃ ភ្លាមៗនោះក៏ជាសះស្បើយអស់ពីជំងឺ។ គ្មានអ្នកឈឺក្បាល ហើយក៏គ្មានជំងឺដំបៅក្រពះទៀតដែរ។ ជួនកាលយើងមានជំងឺតិចតួច ហើយនៅពេលនោះយើងត្រូវទៅមន្ទីរពេទ្យដែលត្រូវបានគេហៅថា "រេវីអឺ"[៦២]។ គ្រូពេទ្យនៅទីនោះក៏ជាអ្នកទោសម្នាក់ដែរ ហើយនាងមិនមានថ្នាំអ្វីច្រើនដើម្បីបំបាត់ការឈឺចាប់របស់យើងទេ។ ថ្នាំលាបដែលមានឈ្មោះថា " អិចធ្យ៉ុល "[៦៣] ត្រូវបានយកមកប្រើសម្រាប់ការឈឺបំពង់កនិងពងបែក។ ភាពធូរស្រាលតែមួយគត់ដែលបានមកពីការទៅមន្ទីរពេទ្យនោះគឺ ពេលវេលាដែលបានសម្រាកនិងពាក្យលួងលោមមួយចំនួន។ ប្រសិនបើនរណាម្នាក់មានជំងឺគ្រុនក្ដៅ ឬឈឺខ្លាំងធ្ងន់ធ្ងរហូតដល់មិនអាចធ្វើការបាន យើងព្យាយាមការពារអ្នកនោះ។ យើងជួយធ្វើការរបស់គាត់ហើយឱ្យគាត់ទៅសម្រាកនៅជ្រុងមួយ និងមានអ្នកចាំឃ្លាំមើលថានឹងមិនមានកងការពារណាហ្ស៊ីរកឃើញគាត់នោះទេ។ ជួនកាលមេបញ្ជាការមានសណ្ដានចិត្តល្អក៏បានឱ្យគាត់អង្គុយសម្រាកនៅក្នុងរោងការងារ និងជួយការពារគាត់ពីកងការពារណាហ្ស៊ី ដោយនិយាយកុហកថាគាត់កំពុងជួយ

[៦២] ពាក្យអាល្លឺម៉ង់ **Revier** ( រេវីអឺ ) មានន័យថាជាតំបន់ឬដែនដីដែលបានកំណត់។ រីឯសម្រាប់ណាស៊ី វាមានន័យថាជាកន្លែងសម្រាប់អ្នកទោសក្នុងជំរំដែលមានជំងឺ។

[៦៣] មានឈ្មោះជាភាសាអង់គ្លេសថា **Ichthyol** ( អិចអ្យុល ) គឺជាប្រភេទថ្នាំដែលយកមកព្យាបាលបញ្ហាស្បែកដូចជារលាកភ្លើង, សត្វ ល្អិត, ជំងឺត្រអកឬស្បែកមុខមុន។

ធ្វើការងារនៅខាងក្នុង។ ប្រសិនបើកងការពារនោះមានអារម្មណ៍ល្អ គេប្រហែលជាឱ្យគាត់នៅ បើមិនដូច្នោះទេគេនឹងដេញគាត់ចេញ។ នៅ រេវីអឺមានគ្រែជាច្រើន ដូច្នេះអ្នកជំងឺអាចនៅទីនោះដោយមិនចាំបាច់ចេញទៅខាងក្រៅដែលមានអាកាសធាតុត្រជាក់នោះទេ។ ហេតុផលដែលធ្វើឱ្យយើងមានភាពភ័យខ្លាចក្នុងការស្នាក់នៅទីនោះ គឺយើងមិនអាចដឹងបានទេថានៅពេលណាដែលគ្រូពេទ្យណាហ្ស៊ីដើរចូលមកដល់។ នៅពេលគ្រូពេទ្យណាហ្ស៊ីចូលមកដល់ អ្នកជំងឺត្រូវតម្រង់ជួរដោយអាក្រាតកាយដើម្បីឱ្យពេទ្យត្រួតពិនិត្យមើល ហើយប្រសិនបើនរណាម្នាក់មានរូបរាងស្គមពេកនោះគឺជាហេតុផលគ្រប់គ្រាន់ដើម្បីកាត់ទោសប្រហារជីវិត។ គ្រូពេទ្យដែលចង់ជួយសង្គ្រោះក្មេងស្រីដែលមានជំងឺអស់ទាំងនោះគឺមិនអាចធ្វើអ្វីបានច្រើនទេ។ ប៉ុន្តែខ្ញុំដឹងពីករណីមួយដែលគ្រូពេទ្យម្នាក់បានលាក់ក្មេងស្រីដែលមានជំងឺធ្ងន់ធ្ងរ និងសន្លប់បានយ៉ាងប៉ិនប្រសប់រហូតដល់នាងមិនត្រូវបានគ្រូពេទ្យណាហ្ស៊ីរកឃើញ។ ក្មេងស្រីម្នាក់នោះបានជាសះស្បើយហើយក៏ចាកចេញពីរេវីអឺ។ ករណីដ៏គួរឱ្យចាប់អារម្មណ៍មួយទៀត គឺនៅពេលដែលគ្រូពេទ្យណាហ្ស៊ី បានស្រឡាញ់ក្មេងស្រីដ៏ស្រស់ស្អាតម្នាក់ដែលដេកឈឺនៅក្នុង រេវីអឺ។ គ្រូពេទ្យនោះមិនបានកាត់ទោសប្រហារជីវិតក្មេងស្រីម្នាក់នោះទេ ផ្ទុយទៅវិញគេបានបញ្ជូននាងឱ្យទៅព្យាបាលនៅក្នុងរេវីអឺរបស់ទាហានណាហ្ស៊ី។ រឿងរ៉ាវដែលកើតឡើងបន្ទាប់ពីនោះ ខ្ញុំមិនបានដឹងទេហើយខ្ញុំក៏មិនដែលបានឃើញនាងម្តងទៀតដែរ។ ខ្ញុំខ្លួនឯងធ្លាប់បានទៅរេវីអឺ ប៉ុន្មានដងដែរ នៅពេលដែលជើងរបស់ខ្ញុំកើតដំបៅធំមួយនៅពេលដែលអាកាសធាតុត្រជាក់ខ្លាំងពីព្រោះតែស្បែកជើងរបស់ខ្ញុំ។ ខ្ញុំមិនដឹងទេថាគឺព្រោះតែថ្នាំលាបដ៏អស្ចារ្យនៅក្នុងរេវីអឺនោះឬក៏មកពីរដូវផ្ការីកដែលជិតនឹងមកដល់នោះទេ ប៉ុន្តែដំបៅនោះក៏ជាសះស្បើយទៅវិញ។

“FANNS DET SNÄLLA SS-SOLDATER”

“WERE THERE KIND SS SOLDIERS?”

# "តើមានកងការពារណាហ្ស៊ីណាមួយដែលចិត្តល្អដែរឬទេ ?"

ខ្ញុំមិនដែលបានជួបកងការពារណាហ្ស៊ីណាម្នាក់ដែលចិត្តល្អនោះទេ។ អ្នកយាមរបស់យើងមិនដែលចាប់អារម្មណ៍ពីយើងទេ។ អ្នកយាមទាំងនោះគ្រាន់តែធ្វើកិច្ចការរបស់ខ្លួន ហើយប្រសិនបើកិច្ចការទាំងនោះទាក់ទងនឹងការវាយដំអ្នកទោស អ្នកយាមទាំងនោះនឹងប្រើដំបង។ អ្នកយាមខ្លះត្រូវបានគេស្គាល់ថាចិត្តអាក្រក់ខ្លាំងចំណែកឯខ្លះទៀត "គ្រាន់តែ" ចិត្តអាក្រក់ ហើយខ្លះទៀតអាចធ្វើបាបយើងដោយគ្មានមូលហេតុអ្វីទាល់តែសោះ។ អ្នកមិនអាចនិយាយបានទេថាខ្ញុំធ្លាប់បានទទួលអំពើល្អមួយយ៉ាងពិតប្រាកដ។ កងការពារណាហ្ស៊ីត្រូវបានហ្វឹកហាត់ឱ្យមានតែភាពឃោរឃៅ និងមិនមានមនោសញ្ចេតនាអ្វីទាំងអស់។

នៅក្នុងសុន្ទរកថាដែលមានឈ្មោះអាក្រក់ និងត្រូវបានដកស្រង់ជារឿយៗរបស់ហ៊ីមឡឺ[៦៤] បានសរសើរអំពីភាពឃោរឃៅរបស់អ្នកបាញ់សម្លាប់ជនជាតិជ្វីហ្វ ដោយបានលើកឡើងថា "បានឆ្លងកាត់រឿងទាំងអស់នេះ ហើយនៅតែមានចិត្តនឹងនរ វាបានធ្វើឱ្យយើងខ្លាំងក្លា។ នេះគឺជាទំព័រដ៏រុងរឿងមួយនៅក្នុងប្រវត្តិសាស្ត្ររបស់យើង"។ កងការពារណាហ្ស៊ីក៏ដូចជាយើងទាំងអស់គ្នាដែរ គឺមានទាំងភាពល្អនិងភាពអាក្រក់នៅក្នុងខ្លួនរបស់គេ ប៉ុន្តែពួកគេបែរជាជ្រើសរើសយកភាពអាក្រក់ទៅវិញ។ ក្រោយមកទើបចាប់ផ្តើមប្រកែកដោះសាថាខ្លួនបាញ់ប្រហារមនុស្សដោយសារតែខ្លួនត្រូវតែធ្វើបែបនោះ។ ប៉ុន្តែការសិក្សាស្រាវជ្រាវបានបង្ហាញឱ្យឃើញថារឿងរ៉ាវវាមិនមែនបែបនេះរហូតនោះទេ។ នៅក្នុងសៀវភៅដែលមានចំណងជើងថា "បុរសសាមញ្ញ"[៦៥] អ្នកប្រវត្តិវិទូ លោកគ្រីស្តូហ្វ័រប្រោននីងបានចង្អុលបង្ហាញថា មានមនុស្សពីរឬបីនាក់តែប៉ុណ្ណោះ ដែលបានដកខ្លួនចេញបើទោះបីជាអ្នកទាំងអស់នោះត្រូវបានប្រាប់ថាពួកគេនឹងត្រូវបានលើកលែងទោសប្រសិនបើមនសិការរបស់ខ្លួនមិនអនុញ្ញាតឱ្យសម្លាប់មនុស្ស។ ជំនួសដោយការជ្រើសរើសសម្រាប់ខ្លួនឯង អ្នកទាំងនោះបានធ្វើតាមសម្ពាធពីមិត្តភក្តិរបស់ខ្លួន។ ដូចគ្នានេះដែរ ជនជាតិអាល្លឺម៉ង់ដែលល្អត្រឹមត្រូវក៏អាចជ្រើសរើសធ្វើរឿងអាក្រក់នៅក្រោមកាលៈទេសៈណាមួយបានដែរ។ យើងទាំងអស់គ្នាសុទ្ធតែមានជម្រើស។ អ្នកយាមរបស់យើងគឺជាទាហានណាហ្ស៊ីវ័យក្មេងដែលបានស្បថស្បែយ៉ាងម៉ឺងម៉ាត់ដើម្បីស្តាប់បង្គាប់ ការពារព្រមទាំងរស់នៅនិងស្លាប់ដើម្បីមេដឹកនាំរបស់ខ្លួន។ ការអប់រំរបស់ណាហ្ស៊ីត្រូវបានចាប់ផ្តើមតាំងពីវ័យក្មេងនៅពេលដែលពួកគេងាយស្រួលនឹងលត់ដំ។ យូរៗម្តងទើបមានអ្នកយាមដែលជាទាហាននៅក្នុងកងទ័ពធម្មតា ដែលជាបុរសវ័យចំណាស់ៗដែលណាហ្ស៊ីបានកេណ្ឌឱ្យធ្វើជាកងទ័ព។ មានភាពខុសគ្នាយ៉ាងខ្លាំងរវាងទាហានពីរក្រុមនេះ គឺក្រុមទាហានក្នុងកងទ័ពធម្មតាមានអត្តចរិតស្លូតជាងពីព្រោះតែចិត្តគំនិតរបស់ពួកគេមិនទាន់ត្រូវបានគេបញ្ចុះបញ្ចូលឱ្យជឿលើមនោគមន៍វិជ្ជាទាំងស្រុងនោះទេ។ មានថ្ងៃមួយនៅពេលដែលយើងដើរទៅកន្លែងធ្វើការ យើងមិនបានអមដោយកងការពារណាហ្ស៊ីវ័យក្មេងដែលកាន់ដំបងនោះទេ ប៉ុន្តែគឺជំនួសទៅដោយក្រុមទាហានដែលមានស្ពាយកាំភ្លើងនៅលើខ្នង។ នេះគឺជាលើកទីមួយនិងតែម្តងគត់ដែលអ្នកយាមនិយាយជាមួយយើងធម្មតា និងមិនស្រែកបញ្ជាមកយើង។ មានទាហានម្នាក់ឈ្មោះថា ហឺម៉ាន់ ហាក់បីដូចជាមាន

[៦៤] គឺជាសមាជិកកងការពារណាហ្ស៊ី និងជាសមាជិកឈានមុខគេនៃគណបក្សណាហ្ស៊ី។ ហ៊ីមឡឺនៅក្នុងចំណោមអ្នកដែលមានអំណាចបំផុតនៅក្នុងណាហ្ស៊ីនិងក្នុងចំណោមអ្នកដែលទទួលខុសត្រូវធំបំផុតចំពោះការសម្លាប់រង្គាលនៅអឺរ៉ុប។

[៦៥] មានឈ្មោះជាភាសាអង់គ្លេសថា "**Ordinary Men**" (បុរសសាមញ្ញ) គឺជាសៀវភៅសរសេរអំពីរឿងពិតនៃការបាញ់សម្លាប់ទ្រង់ទ្រាយធំមួយទៅលើជនជាតិជ្វីហ្វដោយកងវរសេនាតូចប៉ូលីសបម្រុង១០១របស់ប៉ូលីសអាល្លឺម៉ង់នៅក្នុងប្រទេសប៉ូឡូញក្នុងឆ្នាំ១៩៤២។

ការងឿងឆ្ងល់ច្រើន ហើយដោយសារតែខ្ញុំជាមនុស្សម្នាក់ក្នុងចំណោមមនុស្សមួយចំនួនតូចដែលចេះនិយាយភាសាអាល្លឺម៉ង់ គាត់ក៏បានដើរមកក្បែរខ្ញុំនៅពេលដែលយើងកំពុងដើរជាប្រាំជួរ។ គាត់បានចាប់ផ្តើមនិយាយជាមួយខ្ញុំនិងសួរខ្ញុំថាតើឯងជាអ្នកណាហើយមកពីកន្លែងណា។ គាត់បានប្រាប់ខ្ញុំបន្តិចបន្តួចអំពីការលំបាកមួយចំនួនរបស់គាត់។ គាត់មានកូនស្រីម្នាក់ដែលមានអាយុស្របាលខ្ញុំ ហើយប្រហែលជាបែបនេះហើយបានជាគាត់មករកខ្ញុំប៉ុន្មានដងនៅពេល ដែលក្រុមទាហានរបស់គាត់ស្នាក់នៅក្នុងជំរំ។ ពេលខ្លះគាត់យកផ្លែប៉ោមឬដំឡូងមកឱ្យខ្ញុំ។ ប៉ុន្តែគាត់ក៏មានអាហារតែបន្តិចបន្តួចដូចគ្នានឹងខ្ញុំដែរ។ ភាពរាក់ទាក់របស់គាត់គឺជាពន្លឺព្រះអាទិត្យនៅក្នុងជីវិតរបស់ខ្ញុំដែលពោរពេញទៅដោយភាពងងឹត។ ប៉ុន្តែអ្វីៗគឺមានរយៈពេលមួយភ្លែតតែប៉ុណ្ណោះ។ មិនយូរប៉ុន្មានកងការពារណាហ្ស៊ីវ៉ៃក្មេងដែលវាយដំយើងដោយគ្មានប្រណីមេត្តាប្រសិនបើនរណាម្នាក់ដួលឬចេញពីជួរបានវិលត្រឡប់មកយាមវិញ។ មានពេលខ្លះយើងដើរកាត់សួនបន្លែដែលទើបតែប្រមូលផលបានដូចជា សណ្តែកប្រូសែល ខាត់ណានិងបន្លែជាច្រើនទៀត។ នៅពេលណាដែលយើងឃើញបន្លែដែលសេសសល់ដុះចេញពីក្នុងភក់ យើងក៏ស្ទុះទៅដកវាចេញមកបើទោះបីជាប្រឈមនឹងការវាយដំក៏ដោយ ពីព្រោះនេះគឺជាការបន្ថែមដ៏មានតម្លៃទៅនឹងរបបអាហារដ៏ក្រខ្សត់របស់យើង។ ជាពិសេសចំពោះអ្នកដែលឈឺហើយត្រូវបង្ខំខ្លួនទៅធ្វើការងារ។ អេលីហ្សាបែត ដែលជានារីជនជាតិហុងគ្រី-ជ្វីហ្វដ៏ស្រស់ស្អាតម្នាក់មានជំងឺយ៉ាងធ្ងន់ធ្ងរហើយបាត់បង់ស្មារតី។ នាងត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យ។ នៅថ្ងៃបន្ទាប់គ្រូពេទ្យណាហ្ស៊ីបានមកដល់ហើយដើរពិនិត្យតាមគ្រែអ្នកជំងឺគ្រប់ៗគ្នា និងឱ្យគ្រូពេទ្យនៅ រេវីអឺ ដឹងពីការសម្រេចចិត្តរបស់គាត់តាមរយៈការងក់ក្បាល។ មកដល់គ្រែរបស់អេលីហ្សាបែត គាត់សួរអំពីជំងឺរបស់នាង។ គាត់បានហៅនាងជាមួយនឹងពាក្យទន់ភ្លន់ថា " ហើយចុះឯង ក្មេងស្រីតូចតើឯងឈឺអ្វី?" នាងឆ្លើយថា



" ខ្ញុំចុកពោះគ្រប់កន្លែងទាំងអស់ ខ្ញុំមិនមែនជាក្មេងទៀតទេ ខ្ញុំធ្លាប់បានរៀនអំពីប្រភេទថ្នាំពេទ្យម្តងហើយ "។

ពេទ្យណាហ្ស៊ីបន្ទាប់មកបញ្ជាថា នាងគួរតែបញ្ជូនទៅជំរំមួយទៀត។ នៅទីនោះនាងបានវិលត្រឡប់មកមានសុខភាពដូចធម្មតាវិញ។ មនុស្សដដែល ដែលគ្មានមនសិការបន្តិចណាសោះនៅពេលបញ្ជូននរណាម្នាក់ឱ្យទៅស្លាប់ ឥឡូវបានសង្គ្រោះជីវិតអ្នកផ្សេងម្នាក់ទៅវិញ ។ យើងពេលខ្លះក៏ជួបរឿងដែលស្មុគស្មាញបែបនេះនៅក្នុងសង្គម។

មានថ្ងៃមួយទៀត មិត្តរបស់ខ្ញុំឈ្មោះ លីលី បានសន្លប់។ យើងទាំងអស់គ្នាមានទុក្ខព្រួយយ៉ាងខ្លាំងនៅពេលដែលនាងត្រូវបានបញ្ជូនទៅ រេវីអឺ។ បន្ទាប់ពីប៉ុន្មានថ្ងៃបានកន្លងផុតទៅហើយនៅតែមិនទាន់បានឃើញនាងវិលត្រលប់មកវិញទៀត យើងទាំងអស់គ្នាបានសន្និដ្ឋានថាយើងនឹងមិនអាចឃើញនាងម្តងទៀតនោះទេ។ ប៉ុន្តែក្នុងមួយរំពេចសោះ នាងបែរជាកំពុងតែឈរក្នុងអំឡុងពេលរាប់ចំនួនអ្នកទោសទៅវិញ។ នៅពេលដែលយើងសួរនាងថាតើមានរឿងអ្វីបានកើតឡើង នាងបាននិយាយថានាងចាំបានមិនសូវច្បាស់លាស់ទេថា ត្រូវបានគេយកទៅលាក់នៅក្នុងប្រអប់តូចមួយរាល់ពេលដែលគ្រូពេទ្យណាហ្ស៊ី ដើរចូលមកដើម្បីត្រួតពិនិត្យ។ បុគ្គលិកនៅក្នុង រេវីអឺ ក៏ជាអ្នកទោសដូចជាយើងដែរ ហើយភាពឃោរឃៅរបស់កងការពារណាហ្ស៊ីអាចពេលខ្លះកាត់បន្ថយបានដោយភាពសាមគ្គីរវាងអ្នកទោសដូចគ្នា។

សារ៉ា ដែលជាអ្នកទោសម្នាក់មកពីប្រទេសប៉ូឡូញបានប្រាប់ខ្ញុំថា មុនពេលចាប់ខ្លួន គាត់បានលាក់ខ្លួននៅកន្លែងដែលគាត់ជឿជាក់ថាមានសុវត្ថិភាព។ ប៉ុន្តែគាត់ត្រូវតែប្រាប់នរណាម្នាក់អំពីគម្រោងនេះដើម្បីឱ្យប្តីរបស់គាត់អាចរកគាត់ឃើញ។ គាត់បានជ្រើសរើសប្រាប់អ្នកជិតខាងម្នាក់ឈ្មោះថា អេន ដែលតែងតែមានសណ្តានចិត្តល្អចំពោះគ្រួសារគាត់។ ថ្ងៃបន្ទាប់មកប៉ូលីសបានមករកសារ៉ា ហើយនៅពេលនោះហើយដែលគាត់

ដឹងថាសេចក្ដីសប្បុរសធម៌របស់អ្នកជិតខាង គឺតែងតែមានកម្រិតរបស់វា។ សព្វថ្ងៃនេះខ្ញុំតែងតែគិតថា តើខ្ញុំនឹងធ្វើបែបណាប្រសិនបើខ្ញុំអ្នកដែលបានកើតក្នុងឆ្នាំ១៩២៤ នៅទីក្រុងស៊ីហ្គេត បានឃើញពន្លឺថ្ងៃជានារីជនជាតិអាល្លឺម៉ង់ម្នាក់នៅបែរឡាំងវិញនោះ។ ខ្ញុំប្រាកដជាត្រូវបានទទួលការបញ្ចុះបញ្ចូលឱ្យប្ដូរគំនិតនៅក្នុងសមាគមសម្រាប់ក្មេងស្រីអាល្លឺម៉ង់ដែលដូចគ្នាទៅនឹងសមាគមរបស់ក្មេងប្រុសអាល្លឺម៉ង់ដែរ។

ខ្ញុំប្រហែលជាក្លាយទៅជាកងការពារនារីណាហ្ស៊ី។ ពួកគេក៏មិនល្អប្រសើជាងខាងបុរសប៉ុន្មានដែរ។ តើខ្ញុំនឹងធ្វើយ៉ាងណា? តើខ្ញុំអាចវាយអ្នកទោសដែរឬទេ? ជួយអ្នកទោសដែរឬទេ? ប្រសិនបើខ្ញុំមានឪពុកម្ដាយដែលមានក្រមសីលធម៌ខ្ពស់ក្នុងការចិញ្ចឹមបីបាច់កូនដែលអាចទប់ទល់នឹងមនោគមន៍វិជ្ជានៅក្នុងសម្ព័ន្ធនៃក្មេងស្រីអាល្លឺម៉ង់បាន ខ្ញុំប្រហែលអាចជាទាហានម្នាក់ក្នុងចំណោមទាហាន "ចិត្តល្អ" ក្នុងទាហានណាហ្ស៊ី។ ខ្ញុំបានត្រឹមតែសង្ឃឹម។ ប្រសិនបើមនុស្សម្នាក់ដឹងថាខ្លួនមានជម្រើស នោះក៏អាចមានន័យដែរថាគេមានឱកាសក្នុងការជ្រើសរើសអំពើល្អ។

ប៉ុន្តែខ្ញុំអាចប្រាប់អ្នកអំពី ណូអា ដែលមានអាយុ១២ឆ្នាំ ថា ណូអាបានមានប្រតិកម្មបែបណានៅពេលដែលគេផ្ដល់ជម្រើសឱ្យគាត់។ គាត់រស់នៅក្នុងហ្គេតូ ដែលមានតែភាពអត់ឃ្លាន។ អ្នករាល់គ្នានៅទីនោះព្យាយាមស្វែងរកអាហារដើម្បីបរិភោគតាមរយៈការលួច។ កុមារគឺជាអ្នកដែលមានជំនាញលួចជាងគេ។ កុមារទាំងនោះលួចចេញពីហ្គេតូជាមួយនឹងអ្វីដែលអាចប្ដូរយកអាហារបាន។ ជាញឹកញាប់កុមារទាំងនោះបានត្រឡប់មកវិញជាមួយនឹងដំឡូងឬ ឆៃថាវ។

មានថ្ងៃមួយណូអាត្រូវបានចាប់ខ្លួនដោយកងការពារណាហ្ស៊ី ហើយចង់ដឹងថាតើអ្នកណាជាអ្នកនៅពីក្រោយរឿង "ចេញទៅក្រៅ" នេះ។ ណូអាបានបដិសេធមិនឆ្លើយសំណួរ។ កងការពារណាហ្ស៊ី បានល្បួង ណូអា



ដោយនិយាយថា ណូអា អាចរក្សាទុកដំឡូងដែលលួចយកមកបានហើយនិងទទួលបានបន្ថែមមួយទៀតព្រមទាំងអាចបានតែងតាំងឱ្យទៅជាប៉ូលីសហ្គេតូ។ ប៉ូលីសហ្គេតូ ទទួលបានអត្ថប្រយោជន៍បន្ថែមព្រមទាំងទទួលបានម្ហូបអាហារជាច្រើន ខណៈពេលដែលអ្នករស់នៅទីនោះកំពុងតែស្រេកឃ្លាន។ ណូអា បានបដិសេធយ៉ាងម៉ឺងម៉ាត់ក្នុងការធ្វើជាអ្នកផ្ដល់ព័ត៌មានឱ្យកងការពារណាហ្ស៊ី ទោះបីជាដឹងថាខ្លួននឹងត្រូវបានកងការពារណាហ្ស៊ីវាយដំ ព្រោះតែការមិនគោរពកោតខ្លាចយ៉ាងណាក៏ដោយ។

“ DRÖMDE NI PÅ NÄTTERNA? ”

“ DID YOU DREAM AT NIGHT? ”

## " តើអ្នកធ្លាប់សុបិននៅពេលយប់ដែរឬទេ ? "

ភ្លាមៗនោះ ខ្ញុំនឹងឆ្លើយថាទេ។ ប៉ុន្តែអ្វីៗមិនតែងតែដូចគ្នាទាំងអស់ទេ អ្វីទាំងអស់ផ្លាស់ប្តូរអាស្រ័យទៅតាមកន្លែងដែលយើងរស់នៅ។

នៅ អូសឈ្វិច យើងដេកបានតិចម៉ោងណាស់ ហើយយើងដេកដូចជាមនុស្សសន្លប់ បន្ទាប់ពីត្រូវបានវាយ១ដុំថ្ម។ នោះគឺជាការដេកលក់ភ្លឹងដោយមិនមានសុបិនអំពីអ្វីទាំងអស់។ នៅក្នុងជំរំពលកម្មអ្វីៗ គឺខុសគ្នា។ ទោះបីជាម៉ោងដេករបស់យើងមិនមានរយៈពេលយូរក៏សុបិនគឺតែងតែកើតមានជានិច្ច។ ជាធម្មតាយើងសុបិនថាយើងកំពុងតែនៅក្នុងផ្ទះជាមួយនឹងក្រុមគ្រួសារ នៅពេលនោះភ្ញាក់ពីសុបិន គឺមានការឈឺចាប់ខ្លាំងណាស់។ ខ្ញុំសុបិនថាខ្ញុំកំពុងដើរកាន់ដៃជាមួយឪពុករបស់ខ្ញុំនៅលើវាលស្មៅក្រោមពន្លឺព្រះអាទិត្យ ហើយគាត់កំពុងតែប្រាប់ខ្ញុំអំពីរឿងមួយប៉ុន្តែនៅពេលដែលពន្លឺភ្លើងបានបើកសំឡេងឪពុករបស់ខ្ញុំបានប្តូរទៅជាសំឡេងកាចអាក្រក់របស់អាល្លឺម៉ង់ទៅវិញ អ័វហ្វាហិន **(Aufwachen)** ភ្ញាក់ឡើង! ស្នែល **(schnel)** លឿនឡើង! រោស! រោស! **(raus raus)** ចេញ! ចេញ!...

ខ្ញុំបានព្យាយាមស្រមៃថា ក្តីសុបិនគឺជាការពិត ចំណែកឯការងារប្រចាំថ្ងៃរបស់ខ្ញុំ គឺគ្រាន់តែជាក្តីសុបិនអាក្រក់មួយប៉ុណ្ណោះ...ខ្ញុំព្យាយាមរក្សាភាពនឹងនរនៅក្នុងការពិតដ៏ឃោរឃៅមួយនេះជាមួយនឹងការស្រមើស្រមៃរបស់ខ្ញុំ។

"VAD VAR DET BÄSTA?"

"WHAT WAS THE BEST?"



# "តើអ្វីទៅដែលល្អបំផុត?"

ល្អបំផុត? តើមានអ្វីទៅដែលអាចហៅបានថាល្អបំផុត? នៅពេលដែលខ្ញុំទទួលបានសំណួរមួយនេះខ្ញុំស្រឡាំកាំង។ គ្មានអ្វីដែលល្អនោះទេ ប៉ុន្តែមានពេលខ្លះដែលយើងអាចបំភ្លេចបានថាយើងនៅទីកន្លែងណា ព្រមទាំងអាចសើចសប្បាយបាន។ ខ្ញុំមានអារម្មណ៍ល្អនៅពេលយប់វាគឺជាពេលដែលការងារនឿយហត់ទាំងប៉ុន្មានបានចប់សព្វគ្រប់ទៅ ហើយខ្ញុំអាចសណ្តូកជើងដែលចុករោយនៅលើគ្រែដ៏រឹងរបស់ខ្ញុំបាន។ យើងបានរួចជីវិតមួយថ្ងៃទៀតហើយ។ ខ្ញុំដឹងថា ពេលយប់មានរយៈពេលខ្លីណាស់ ហើយខ្ញុំនិងមិនមានពេលសម្រាកច្រើននោះទេ ប៉ុន្តែទោះបីជាយ៉ាងណាពេលនោះគឺខ្ញុំមានអារម្មណ៍ល្អ។

មុនពេលចូលដេក ក្រុមមិត្តភក្តិរបស់ខ្ញុំបានអង្គុយនៅលើគ្រែមួយជុំគ្នាហើយបាន "បើកហាង អក្សរសាស្ត្រ" មួយ។ យើងសូត្រកំណាព្យអានរឿង ហើយសួរថាតើនរណាអាចចងចាំអំពីអ្វីខ្លះឬក៏ពេលខ្លះយើងទាំងអស់គ្នា "ចម្អិនអាហារ" ផ្លាស់ប្តូររូបមន្តធ្វើម្ហូប និងនិយាយអំពីមុខម្ហូបឆ្ងាញ់ៗដែលយើងចង់បរិភោគ។ ខ្ញុំមានបទពិសោធន៍ដ៏ពិសេសមួយនៅអូសឈ្វិច ដែលបានផ្តល់ពន្លឺខ្លះមកក្នុងជីវិតដែលពោរពេញទៅដោយភាពខ្មៅងងឹតរបស់យើង។ មានព្រឹកមួយកងការពារណាហ្ស៊ីបានចូលមកក្នុងបន្ទាយហើយសួរកអ្នកស្ម័គ្រចិត្តពីរនាក់ដើម្បីទៅធ្វើការ។ មិត្តរបស់ខ្ញុំឈ្មោះថាអុលហ្គា និងខ្ញុំបានស្ម័គ្រចិត្ត។ បន្ទាប់មកកងការពារណាហ្ស៊ីដែលមានស្ពាយកាំភ្លើងនៅលើខ្នងនោះនាំយើងចេញទៅ។ យើងបានឆ្លងកាត់ពីតំបន់មួយទៅតំបន់មួយទៀតដែលហ៊ុមព័ទ្ធជុំវិញទៅដោយរបងបន្លាលួសរហូតយើងបានមកដល់កន្លែងមួយដែលមានបន្ទាយតូចជាងជំរំរបស់យើង។ នេះគឺជាជំរំទាហាន ហើយយើងត្រូវបានបញ្ជាឱ្យបោសសម្អាតនិងជុសខាត់

ឥដ្ឋ។ នៅពេលដែលយើងទៅជិតដល់បន្ទាយដើមឈើពណ៌បៃតងស្រស់បានទាក់ទាញចំណាប់អារម្មណ៍របស់ខ្ញុំយ៉ាងខ្លាំង។ នេះប្រៀបបានដូចជាអព្ភូតហេតុមួយនៅពេលដែលយើងបានឃើញរុក្ខជាតិពណ៌បៃតងបែបនេះបន្ទាប់ពីរស់នៅក្នុងអូសឈ្វិចដែលមានតែពណ៌ប្រផេះ។ នៅខាងក្រៅគឺមានជីវិតស្រស់បំព្រង អ្វីៗមិនបានបាត់បង់នោះទេ។ អុលហ្គានិងខ្ញុំបានត្រឹមតែឈរសម្លឹងមើលជុំវិញ។ មុនដំបូងយើងសម្លឹងមើលទៅដើមឈើបន្ទាប់មកមើលមុខគ្នាទៅវិញទៅមក ហើយដោយមិនចាំបាច់ប្រើពាក្យនិយាយ យើងក៏អាចដឹងបានដែរថាម្នាក់ទៀតកំពុងតែគិតអំពីអ្វី។ យើងទាំងពីរនាក់បានសម្រេចចិត្តលួចយកស្លឹកឈើខ្លះចូលទៅក្នុងជំរំដើម្បីឱ្យមិត្តគ្រប់គ្នាបានឃើញដែរ។ ទាហានបានបង្ខំឱ្យយើងប្រញាប់ប្រញាល់ដើរចូលក្នុងជំរំដើម្បីចាប់ផ្តើមធ្វើការងារ។ គេបញ្ជាយើងឱ្យយកធុងដែលមានទឹកត្រជាក់និងក្រណាត់កន្ទបដើម្បីសម្អាតឥដ្ឋ។ វាបានក្លាយទៅជាការងារមួយដែលលំបាក។ ដើម្បីធ្វើឱ្យឥដ្ឋកខ្វក់នោះស្អាតបន្តិចយើងត្រូវការមែកឈើមួយចំនួនដើម្បីឆ្កឹះដីកខ្វក់ចេញពីឥដ្ឋ។ នៅក្រោមការស្រែកជេរប្រទេចដ៏គួរឱ្យរំខានរបស់ពួកទាហានយើងត្រូវធ្វើកិច្ចការយ៉ាងលំបាកនោះដោយប្រើមែកឈើព្រមទាំងក្រញ៉ាដៃ និងក្រចករបស់យើងដើម្បីដុសសម្អាតឥដ្ឋនោះឱ្យបានស្អាត។

នៅពេលដែលមានសញ្ញាប្រាប់ថាពេលវេលាធ្វើការងារបានបញ្ចប់យើងអាចដកដង្ហើមបានស្រួលម្តងទៀត។ "ហ្វីយ៉ាអាបិន **Feuerabend**” ទាហានបាននិយាយថាដល់ពេលល្ងាចហើយ។ យើងត្រូវត្រឡប់ទៅជំរំវិញដើម្បីឈររង់ចាំការរាប់ចំនួនអ្នកទោស។ ខ្ញុំបានលួចបេះស្លឹកឈើមួយចំនួន ប៉ុន្តែនៅតាមផ្លូវត្រឡប់មកវិញខ្ញុំភ័យខ្លាចខ្លាំងណាស់ តើខ្ញុំអាចលួចយកវាចូលទៅក្នុងជំរំបានដោយជោគជ័យដែរឬទេឬយើងទាំងពីរនាក់នឹងត្រូវបានគេឆែកឆេរខ្លួន។ ការនាំយកស្លឹកឈើជាច្រើនចូលក្នុងជំរំត្រូវបានគេហាមឃាត់យ៉ាងតឹងរ៉ឹងបំផុត។ ខ្ញុំបានលាក់មែកឈើនៅក្នុងសម្លៀកបំពាក់របស់ខ្ញុំ និងបានដាក់ស្លឹកឈើនៅក្នុងមាត់។ អុលហ្គា ក៏បានធ្វើបែបនេះដែរ។ ដោយបេះដូងញាប់ញ័រ យើងបានដើរហួសអ្នកយាមរបងហើយយើងក៏បានរួចខ្លួន។ ប៉ុន្តែជើងរបស់យើងនៅតែញ័រនៅពេលដែលយើងឈររង់ចាំការរាប់ចំនួនអ្នកទោសឱ្យដល់ទីបញ្ចប់។ បន្ទាប់មកនៅពេលដែលយើងចូលទៅដល់ក្នុងជំរំ ហើយបង្ហាញស្លឹកឈើនោះទៅមិត្តភក្តិពួកគេមានសេចក្តីរីករាយយ៉ាងខ្លាំង។ ក្តីសង្ឃឹមមួយបានកើតមានឡើងនៅក្នុងចិត្តរបស់យើងទាំងអស់គ្នា ដែលគឺជាក្តីសង្ឃឹមមួយថាអនាគតដ៏ត្រចះត្រចង់មួយកំពុងតែរង់ចាំ។

“

# NÄR FÖRSTOD DU ATT DET PÅGICK ETT FOLKMORD?

” “

# WHEN DID YOU REALISE THAT THERE WAS A GENOCIDE HAPPENING?

”



## " តើអ្នកដឹងនៅពេលណាថា អំពើប្រល័យពូជសាសន៍បានកើតឡើង ? "

ក្នុងអំឡុងពេលសង្គ្រាមលោកលើកទី២ពាក្យថា "អំពើប្រល័យពូជសាសន៍"[៦៦] មិនមានទេ ហើយក៏មិនមាននៅក្នុងវចនានុក្រមរបស់នរណាម្នាក់ដែរ។ ខ្ញុំបានឃើញច្បាស់អំពីការសម្លាប់រង្គាលនៅពេលដែលខ្ញុំនៅក្នុងជំរំ អូសឈ្វិច។ កន្លងមក មិនមានមនុស្សជាច្រើនទេដែលយល់ថានេះគឺមិនមែនគ្រាន់តែជាការសម្លាប់បុគ្គលខ្លះនោះទេ ប៉ុន្តែគឺសំដៅទៅលើមនុស្សទាំងអស់ដែលនឹងត្រូវសម្លាប់ចោលចេញពីលើពិភពលោកនេះ។

---

៦៦ យោងតាមមាត្រាទី២នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីអំពីការបង្ការ និងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្នុងឆ្នាំ១៩៤៨ បានកំណត់អំពើប្រល័យពូជសាសន៍ថាគឺជា " អំពើណាមួយដែលមានគោលបំណងលុបបំបាត់ទាំងស្រុងឬដោយផ្នែកនៃជាតិសាសន៍ ឬក្រុមសាសនា ដែលមានដូចជា ការសម្លាប់សមាជិកនៃក្រុម បង្កឱ្យមានគ្រោះថ្នាក់ដល់រូបរាងកាយឬផ្លូវចិត្តរបស់សមាជិកនៃក្រុម ការដាក់លក្ខខណ្ឌនានាទៅលើជីវិតរបស់ក្រុម ដែលដោយចេតនា គឺដើម្បីបំផ្លិចបំផ្លាញជីវិតក្រុមទាំងមូលឬមួយផ្នែក ការដាក់វិធានការបង្ការកំណើតទារកនៅក្នុងក្រុមហើយការផ្ទេរកុមារដោយបង្ខំពីក្រុមមួយទៅក្រុមមួយទៀត"។

“

# HUR TÄNKTE DU ATT DITT LIV SKULLE BLI EFTER KRIGET?

” “

# HOW DID YOU PICTURE YOUR LIFE AFTER THE WAR?

”



# "តើអ្នកស្រមៃឃើញជីវិតបន្ទាប់ពីសង្គ្រាម បានយ៉ាងដូចម្តេច?"

ខ្ញុំមិនបានគិតដិតដល់នោះទេ។ អាល្លឺម៉ង់នឹងចាញ់សង្គ្រាមគឺជាអ្វីដែលខ្ញុំជឿជាក់យ៉ាងខ្លាំង ខ្ញុំមិនបានដឹងថាអ្វីៗគ្រប់យ៉ាងមិនអាចវិលត្រឡប់ទៅដូចដើមវិញបានទេ។ ខ្ញុំជឿថាបន្ទាប់ពីសង្គ្រាមបានបញ្ចប់ទៅ ត្រង់ស៊ីលវ៉ានី នឹងក្លាយទៅជាផ្នែកមួយនៃប្រទេស រូម៉ានី ម្តងទៀត។ ក្តីសុបិនក្នុងវ័យជំទង់នៅតែមាននៅក្នុងចិត្តរបស់ខ្ញុំជានិច្ច។ ខ្ញុំនឹងត្រលប់មករៀនមុខវិជ្ជាពេទ្យ និងហ្វឹកហាត់ជាវេជ្ជបណ្ឌិតឯកទេសជំងឺកុមារ។ ខ្ញុំនឹងទៅប្រទេសអាហ្វ្រិកដើម្បីព្យាបាលជំងឺ។

ខ្ញុំមិនអាចស្រមៃដឹងទេថា ទោះបីជាក្រុមសម្ព័ន្ធមិត្តបានឈ្នះសង្គ្រាមក៏ដោយ ក៏គ្មានអ្វីដែលអាចវិលត្រឡប់ទៅដូចកាលពីមុនបានដែរ។

តើយើងមិនបានសិក្សាអំពីប្រវត្តិវិទ្យានៅក្នុងសាលារៀនទេឬ? យើងបានសិក្សា ប៉ុន្តែភាគច្រើនគឺអំពី ថ្ងៃខែ ឆ្នាំ ឈ្មោះរបស់អ្នកដែលកាន់អំណាចនិងសមរភូមិតែប៉ុណ្ណោះ។ នេះគឺជាការរៀនសូត្រដែលមិនជិតជាប់អារម្មណ៍របស់យើង ហើយនិងត្រូវបានបំភ្លេចចោលយ៉ាងឆាប់រហ័ស។ ខ្ញុំមិនបានត្រៀមខ្លួននោះទេ។ ខ្ញុំមិនបានយល់ទេថាជីវិតមិនអាចវិលត្រឡប់ទៅដូចកាលពីមុនបានទេ។ ទោះបីជាខិតខំប្រឹងប្រែងខ្លាំងប៉ុនណា ក៏ខ្ញុំមិនអាចស្រមៃមើលឃើញនូវអ្វីដែលកើតឡើងក្រោយពីសង្គ្រាមបានឡើយ។

“

# VAD HÄNDE MED DIN SYSTER?

” “

# WHAT HAPPENED TO YOUR SISTER?

”



## " តើមានរឿងអ្វីបានកើតឡើងទៅលើប្អូនស្រីរបស់អ្នក ?"

លីវីបានជួយជីវិតរបស់ខ្ញុំនៅក្នុងជំរំ បឺជិន-បែលសិន។ ក្នុងអំឡុងពេលចលាចលបន្ទាប់ពីការរំដោះ ខ្ញុំក្តៅខ្លួនយ៉ាងខ្លាំង ហើយបានសន្លប់បាត់បង់ស្មារតី។ លីវី បានរកឃើញគ្រូពេទ្យម្នាក់ក្នុងចំណោមអ្នកទោសរំដោះ ដែលពេលនោះគាត់ក៏ហាក់បីដូចជាត្រូវការគ្រូពេទ្យដើម្បីព្យាបាលខ្លួនឯងដែរ។ ខ្ញុំចាំមុខរបស់គាត់បាននៅពេលដែលគាត់និយាយថា "ត្រូវហើយអ្នកមានជំងឺ ហើយអ្នកដែលឈឺភាគច្រើនស្លាប់នៅទីនេះ" ។ ពេលនោះខ្ញុំយល់ថាខ្ញុំប្រាកដជាស្លាប់ដែរហើយ។ ខ្ញុំបានចុះចាញ់លើដោគវាសនារបស់ខ្លួន ខ្ញុំបិទភ្នែក ហើយបន្ទាប់មកខ្ញុំនឹកចាំអ្វីផ្សេងទៀតមិនបានទេ រហូតដល់ខ្ញុំបើកភ្នែករបស់ខ្ញុំម្តងទៀត។ ខ្ញុំឃើញ លីវី កំពុងតែឈរក្បែរគ្រែរបស់ខ្ញុំ។ បន្ទាប់មកខ្ញុំក៏បានដឹងថា ខ្ញុំត្រូវរៀនពីរបៀបដើរម្តងទៀត។ ខ្ញុំបានសន្លប់អស់រយៈពេលជាច្រើនសប្តាហ៍ ហើយ លីវី គឺជាអ្នកដែលចាំមើលថែរក្សាខ្ញុំឱ្យមានជីវិតសាជាថ្មីឡើងវិញ។

នៅក្នុងរដូវក្តៅឆ្នាំ១៩៤៥ យើងបានសម្រេចចិត្តធ្វើដំណើរមកប្រទេសស៊ុយអែត យើងទាំង២នាក់ក៏រស់នៅទីនេះរហូតមក។ លីវី បានរៀបការនៅពេលដែលនាងមានអាយុវ័យក្មេងនៅឡើយ។ នាងមានអាយុត្រឹមតែ១៧ឆ្នាំ ពេលដែលនាងបានជួបលោកហាន របស់នាងដែលមានអាយុ២៧ឆ្នាំទៅហើយ។ គាត់ក៏គ្រាន់តែជាកុមារម្នាក់នៅពេលដែលគាត់ត្រូវចាកចេញពីឪពុកម្តាយរបស់គាត់ដែលនៅក្នុងប្រទេសអាល្លឺម៉ង់ ដើម្បីជួយសង្គ្រោះជីវិតខ្លួនឯង។ គាត់បានទៅប្រទេសដាណឺម៉ាក ហើយពីទីនោះមកគាត់បានធ្វើដំណើរទៅប្រទេសស៊ុយអែត ជាមួយក្រុមសង្គ្រោះ

ដាណឺម៉ាក។ ពួកគេទាំងពីរនាក់មានកូនដំបូងនៅពេលដែល លីវី មាន អាយុ១៩ឆ្នាំ ហើយបន្ទាប់មកមានកូនពីរនាក់ថែមទៀត។ ហាន បាន ស្លាប់នៅក្នុងឆ្នាំ២០០០ ដោយសារតែជំងឺវង្វេងវង្វាន់។

សព្វថ្ងៃនេះ លីវី ហើយនិងខ្ញុំ រស់នៅក្បែរគ្នា។ នៅពេលដែលយើង នៅវ័យក្មេង យើងឃើញមុខគ្នាជារៀងរាល់ថ្ងៃ។ បច្ចុប្បន្ននេះយើងទាំងពីរ នាក់មានភាពលំបាកក្នុងការដើរ ដូច្នេះហើយទើបយើងនិយាយគ្នាតាម ទូរស័ព្ទជំនួសវិញ។ នៅរៀងរាល់ព្រឹកម៉ោង៩ យើងតែងតែទូរស័ព្ទរកគ្នា និងនៅពេលខ្លះទៀត យើងក៏ព្យាយាមជួបមុខគ្នាជាញឹកញាប់តាមដែល អាចធ្វើបាន។ លីវី មានអាយុជិត៩០[៦៧] ឆ្នាំហើយ ប៉ុន្តែនាងនៅតែទៅ សាលារៀនផ្សេងៗ ដើម្បីនិយាយអំពីរឿងរ៉ាវជីវិតរបស់យើង។

[៦៧] បច្ចុប្បន្ននេះ (ឆ្នាំ២០១៩) លីវី មានអាយុ៩០ឆ្នាំ។ គាត់និងហេឌី រស់នៅផ្ទះជិតគ្នានៅក្នុងទីក្រុងស្តុកខុលនៃប្រទេស ស៊ុយអែត។



# "HUR MÅNGA FRÅN DIN HEMSTAD ÖVERLEVDE KRIGET?"

# "HOW MANY PEOPLE FROM YOUR HOMETOWN SURVIVED THE WAR?"

# តើមានមនុស្សប៉ុន្មាននាក់ដែលមកពីស្រុកកំណើតរបស់អ្នកបានរួចជីវិតបន្ទាប់ពីសង្គ្រាម ?

នេះគឺជាសំណួរដែលមិនអាចឆ្លើយបាន។ អ្នកដែលបានរួចជីវិតបានទៅរស់នៅកន្លែងផ្សេងៗពីគ្នា។ មិនមានមនុស្សច្រើនប៉ុន្មានទេដែលវិលត្រឡប់មកស្រុកកំណើតវិញ។

យើងមានគ្នាប្រុសស្រីនិងកុមារចំនួន៣០០៧នាក់ ត្រូវបានទាហានណាហ្ស៊ីយកទៅផ្ទុកនៅ ក្នុងទូរថភ្លើងនៅព្រឹកថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៤៤។ នៅពេលដែលក្រុមស្ត្រីរបស់យើងត្រូវបានគេរាប់ចំនួន បន្ទាប់ពីការជ្រើសរើសនៅយប់ដែលយើងបានទៅដល់អូសឈ្វិចនៅថ្ងៃទី១៧ ខែឧសភា យើងមានគ្នាចំនួន ៤៨៦នាក់។ តួលេខអាចនឹងស្រដៀងគ្នាជាមួយខាងបុរសដែរ។ ប្រសិនបើយើងសន្មតថាតួលេខទាំងនេះពិតជាដូចគ្នាជាមួយនឹងរថភ្លើង៥ផ្សេងទៀត គឺអាចមានន័យថា៣ភាគ៥នៃតួលេខទាំងនោះបានរួចផុតជីវិតពីការជ្រើសរើសដំបូង។ ប៉ុន្តែតើមានចំនួនប៉ុន្មានអ្នកដែលបានស្លាប់បន្ទាប់ពីនោះ គឺគ្មាននរណាម្នាក់អាចដឹងបានឡើយ។

នៅក្នុងចំណោមសមាជិកគ្រួសារចំនួន ៣១នាក់ របស់ខ្ញុំដែលរស់នៅស៊ីហ្គេត មានចំនួន១០នាក់តែប៉ុណ្ណោះដែលរស់រានមានជីវិត។ បន្ទាប់ពីសង្គ្រាមបានបញ្ចប់ អ្នកមួយចំនួនដែលចង់វិលត្រឡប់មកវិញបានជួបប្រទះការលំបាកយ៉ាងខ្លាំង ពីព្រោះមិនមានបណ្តាញដឹកជញ្ជូនណាដែលមានដំណើរការល្អនោះទេ។ ដូច្នេះមនុស្សភាគច្រើនធ្វើដំណើរដោយថ្មើរជើង សុំជិះរថយន្ត ឬហក់ឡើងជិះរថភ្លើងណាដែលខ្លួនបានជួបប្រទះ។



សានយី ដែលជាប្អូនប្រុសពៅរបស់ឪពុកខ្ញុំបានរួចជីវិត។ គាត់ធ្វើការនៅកន្លែងដុតនំប៉័ងនៅក្នុងជំរំ អូសឈ្វិច ដូច្នេះហើយគាត់មាននំប៉័ងសម្រាប់បរិភោគបានគ្រប់គ្រាន់។ គាត់សង្ឃឹមថានឹងអាចរកឃើញប្រពន្ធរបស់គាត់ឈ្មោះថា ហេឡេន។ នៅពេលដែលសង្គ្រាមបានបញ្ចប់ គាត់បានចេញដំណើរទៅស៊ីហ្គេត ដោយថ្មើរជើង។ បន្ទាប់មកហេតុការណ៍ដែលអស្ចារ្យក៏បានកើតឡើង។ នៅពេលដែលគាត់ទៅដល់ទីក្រុងប្រាក[៦៨] និងកំពុងដើរនៅតាមផ្លូវគាត់បានជួប ហេឡេន។ ហេឡេន ក៏ត្រូវបានរំដោះចេញពីជំរំពលកម្មដូចគ្នាដែរ ហើយក៏កំពុងតែធ្វើដំណើរទៅស៊ីហ្គេតដើម្បីស្វែងរក សានយី។

នេះគឺជាការជួបជុំមួយក្នុងចំណោមការជួបជុំដែលរីករាយដ៏ទៃទៀតពីព្រោះមានមនុស្សជាច្រើន ដែលមិនអាចរកឃើញសូម្បីតែមនុស្សម្នាក់ផងនៅពេលដែលពួកគេត្រឡប់ទៅស៊ីហ្គេតវិញ។ ក្នុងករណីជាច្រើនសូម្បីតែផ្ទះរបស់ពួកគេក៏មិននៅសេសសល់ដែរ។ សានយី និងហេឡេនមានសំណាងល្អម្តងទៀត ពីព្រោះផ្ទះរបស់ពួកគេគឺស្ថិតនៅដូចដើម។ ពួកគេអាចចាប់ផ្តើមជីវិតសារជាថ្មីម្តងទៀតនៅទីនោះ។ ប៉ុន្តែពួកគេមិនបានរស់នៅទីនោះយូរទេ។ ស៊ីហ្គេត ត្រូវបានរំដោះដោយទាហានរុស្ស៊ីនៅរដូវស្លឹកឈើជ្រុះក្នុងឆ្នាំ១៩៤៤ ហើយប្រជាជនត្រូវរស់នៅក្រោមរបបកុម្មុយនីស្តដ៏តឹងរ៉ឹង។ សានយីនិងហេឡេន បានចាកចេញពី រូម៉ានីយ៉ាងឆាប់រហ័ស ហើយចុងក្រោយពួកគេក៏បានតាំងទីលំនៅក្នុងទីក្រុងឡូសអាន់ជើឡែស[៦៩]។

[៦៨] គឺជាទីក្រុងធំជាងគេរបស់សាធារណរដ្ឋឆែក។
[៦៩] គឺជាទីក្រុងមួយនៅក្នុងរដ្ឋកាលីហ្វូញ៉ានៃប្រទេសសហរដ្ឋអាមេរិក។

“JUBLADE DU NÄR NI BEFRIADES?” “WERE YOU JUBILANT WHEN YOU WERE LIBERATED?”



## "តើអ្នករីករាយទេនៅពេលដែលត្រូវបានរំដោះ ?"

យើងត្រូវបានគេរំដោះខណៈពេលដែលភ្លើងសង្គ្រាមកំពុងតែឆេះឆួលយ៉ាងខ្លាំង។ កងទ័ពអង់គ្លេសនៅតាមផ្លូវរបស់ពួកគេទៅទីក្រុងប៊ែរឡាំង[៧០] បានរំដោះយើងចេញពីជំរំបឺដិន-បែលសិន នៅថ្ងៃទី១៥ខែមេសា ក្នុងឆ្នាំ១៩៤៥។ អ្នកប្រហែលជាគិតថាខ្ញុំរីករាយណាស់ ប៉ុន្តែនៅពេលនោះខ្ញុំមានសុខភាពខ្សោយ ហើយមិនបានចាប់អារម្មណ៍អំពីអ្វីទាំងអស់។ ខ្ញុំស្ទើរតែមិនមានអារម្មណ៍សប្បាយរីករាយ។ គំនិតតែមួយគត់របស់ខ្ញុំគឺនៅថ្ងៃបន្ទាប់ខ្ញុំនឹងទៅជំរំបុរស ហើយចាប់ផ្តើមស្វែងរកឪពុករបស់ខ្ញុំ។ អស់រយៈពេលជាច្រើនថ្ងៃបានកន្លងផុតទៅទើបខ្ញុំអាចអបអរនឹងសេរីភាពបាន។

ខ្ញុំពិតជារីករាយណាស់ប៉ុន្តែការអបអរនេះត្រូវការកម្លាំងកាយ ហើយខ្ញុំត្រូវការពេលវេលាដើម្បីឱ្យមានកម្លាំងឡើងវិញ។

ខ្ញុំមានអារម្មណ៍សប្បាយរីករាយ ដំបូងគឺនៅពេលដែលយើងទៅដល់ប្រទេសស៊ុយអែត។ នៅពេលនោះខ្ញុំនិងប្អូនស្រីបានដើរឆ្លងកាត់ស្ពានវ៉ាស្ទឺប្រុន ដែលជាស្ពានមួយនៅក្នុងទីក្រុងស្តុកខុល។ នៅពេលដែលខ្ញុំងាកមើលទៅខាងក្រោយខ្នងរបស់ខ្ញុំ គឺមិនមានកងការពារណាហ្ស៊ីទៀតនោះទេ។ ខ្ញុំក៏មិនឮសំឡេងឆ្កែព្រុសដែរ ហើយជំនួសទៅវិញអ្វីដែលខ្ញុំឃើញគឺក្រុមគ្រួសារស៊ុយអែតមួយដែលពោរពេញទៅដោយសេចក្តីសុខ ហើយកំពុងតែជិះកង់យ៉ាងសប្បាយរីករាយនៅក្រោមពន្លឺព្រះអាទិត្យនារសៀលថ្ងៃអាទិត្យ។ លីវី និងខ្ញុំគិតដូចគ្នា។ យើងមើលមុខគ្នាទៅវិញទៅមកហើយក៏ចាប់ផ្តើមរាំនៅកណ្តាលស្ពាន។

[៧០] គឺជាទីក្រុងរបស់ប្រទេសអាល្លឺម៉ង់។

“

# VARFÖR VALDE DU SVERIGE?

” “

# WHY DID YOU CHOOSE SWEDEN?

”



## "ហេតុអ្វីបានជាអ្នកសម្រេចចិត្តជ្រើសរើសយកប្រទេសស៊ុយអែត ?"

ជាធម្មតាខ្ញុំតែងតែនិយាយថាប្រទេសស៊ុយអែត ជ្រើសរើសយកខ្ញុំ។ នៅពេលដែលសង្គ្រាមជិតបញ្ចប់ អាល្លឺម៉ង់ បានយល់ថាការបរាជ័យជិតមកដល់ ដូច្នេះអ្វីៗគ្រប់យ៉ាងនិងមនុស្សគ្រប់រូបដែលអាចធ្វើជាសាក្សីនៃឧក្រិដ្ឋកម្មរបស់ពួកគេត្រូវបានបំផ្លាញ។ ទាហានអាល្លឺម៉ង់ ត្រូវតែសម្លាប់អ្នកនៅក្នុងជំរំទាំងអស់។ នៅពេលនោះ ប្អូនស្រីនិងខ្ញុំកំពុងតែនៅក្នុងជំរំពលកម្មនៅជិតទីក្រុងហែមបឺក[៧១]។

ថ្ងៃមួយនៅដើមខែមេសា យើងដែលមានគ្នាចំនួន២០០នាក់ បានទទួលបញ្ជាឱ្យប្រមូលផ្តុំគ្នានៅក្នុងបន្ទប់មួយនៅក្នុងជំរំ។ ប៉ុន្តែនេះគឺគ្មានអ្វីដែលគួរឱ្យកត់សម្គាល់ទេ ប្រសិនបើយើងប្រៀបធៀបជាមួយនឹងអ្វីដែលបានកើតឡើងបន្ទាប់។ កងការពារនារីណាហ្ស៊ីចិត្តអាក្រក់ដែលយើងហៅថា "អាណាធាត់" បានបញ្ជាឱ្យយើងស្រាតសម្លៀកបំពាក់។ "កន្លែងដែលពួកឯងទៅគឺមិនត្រូវការសម្លៀកបំពាក់ទេ" នាងនិយាយបន្ថែម។ យើងបានដោះសម្លៀកបំពាក់ចេញនិងអង្គុយនៅទីនោះ ដោយរាងកាយញ័រពីព្រោះភាពរងារនិងភាពភ័យខ្លាច។ បន្ទាប់មកមេបញ្ជាការជំរំបានដើរកាត់និងសម្លឹងមើលមកយើងដោយភាពងឿងឆ្ងល់ ហើយបានសួរថាហេតុអ្វីបានជាយើងអង្គុយនៅទីនេះដោយអាក្រាតកាយ។ នៅពេលដែលគាត់ឮថាយើងបានធ្វើតាមបញ្ជារបស់ "អាណា" គាត់បានមើលទៅនាងដោយមិនពេញចិត្ត ហើយបន្ទាប់មកក៏ឱ្យយើងប្រញាប់ប្រញាល់ស្លៀកសម្លៀកបំពាក់វិញ។ យើងអាចដកដង្ហើមវិញបានស្រួលបន្តិច ប៉ុន្តែនៅតែមិនដឹង

[៧១] គឺជាទីក្រុងធំទី២នៅក្នុងប្រទេសអាល្លឺម៉ង់ដែលមានប្រជាជនរស់នៅជាង១លាននាក់។

ថាមានរឿងអ្វីបានកើតឡើង។ យើងនៅតែមានអារម្មណ៍ភ័យខ្លាច។ បន្ទាប់ពីស្លៀកពាក់រួចយើងត្រូវបានគេនាំទៅស្ថានីយរថភ្លើង ទៅដល់ទីនោះខ្ញុំមានញ្ញាណទី៧ ពីព្រោះជាថ្មីម្តងទៀតយើងត្រូវបានគេយកទៅដាក់នៅក្នុងទូរថភ្លើងជាមួយនឹងធុងទឹកពីរ និងធុងមួយទៀតសម្រាប់ឱ្យយើងធ្វើជាបង្គន់និងគ្មានអាហារនោះទេ។ តើយើងទៅទីណា? ទៅជំរំអូសឈ្វិចវិញ? នៅពេលនោះជំរំអូសឈ្វិច ត្រូវបានរំដោះរួចទៅហើយ ប៉ុន្តែយើងមិនបានដឹងអំពីរឿងនោះទេ។

រថភ្លើងបានធ្វើដំណើរដោយល្បឿនយឺតក្នុងរយៈពេលបីយប់បីថ្ងៃ វាបានបោះពួយទៅមុខ ហើយឈប់រង់ចាំនៅផ្លូវមួយចំហៀងទៀតនៅពេលណាដែលរថភ្លើងទាហានបានឆ្លងកាត់ បន្ទាប់មកទើបធ្វើដំណើរបន្តទៀត។ យប់មួយ នៅពេលដែលយើងកំពុងឈរស្មៀម យើងបានឮសំឡេងបើកទ្វារនិងសូរសំឡេងកាំភ្លើង។ ពេលនោះយើងជឿជាក់ថាពេលវេលាចុងក្រោយរបស់យើងបានមកដល់ពិតប្រាកដណាស់។ យើងទាំងអស់គ្នានឹងត្រូវបានគេប្រហារជីវិត។ ខ្ញុំរង់ចាំសូរសំឡេងបាញ់បន្ទាប់ដោយភ័យខ្លួនយ៉ាងខ្លាំង។ មិនយូរមិនឆាប់ទ្វាររថភ្លើងរបស់យើងនឹងត្រូវបានបើក ហើយវានឹងដល់វេនរបស់យើងជាមិនខាន។

ប្រៀបបានដូចជារូបចម្លាក់មួយ ខ្ញុំច្របាច់ដៃរបស់ លីវី ហើយនៅស្ងៀមធ្មឹងដោយសឹងតែមិនហ៊ានដកដង្ហើមផង។ ប៉ុន្តែមិនមានរឿងអ្វីបានកើតឡើងបន្ទាប់នោះទេ។ មួយនាទីកន្លងផុតទៅ ពីរនាទី បីនាទី បួននាទី បន្ទាប់មកទើបខ្ញុំចាប់ផ្តើមដកដង្ហើមម្តងទៀត។ ខ្ញុំមិនដែលបានដឹងថាអ្នកណាត្រូវបានបាញ់សម្លាប់ ហើយព្រោះតែហេតុអ្វីនោះទេ ប៉ុន្តែបន្ទាប់ពីប៉ុន្មានម៉ោងក្រោយមក រថភ្លើងក៏ចាប់ផ្តើមធ្វើដំណើរម្តងទៀត ក្រោយមកយើងក៏ត្រូវបានគេយកទៅទម្លាក់ចោលនៅវាលមួយដែលព័ទ្ធជុំវិញដោយរបងបន្លាលួស។ មានមនុស្សស្រីម្នាក់ឈរក្បែររបង ខ្ញុំក៏បានសួរ



នាងថាតើយើងបានមកដល់ទីណា។ នាងបានឆ្លើយប្រាប់ថា "បែលជិន-បឺសិន" ហើយក៏បន្ថែមទៀតថា "មានការងារត្រូវធ្វើ គ្មាននំប៉័ង គ្មានផ្សែងពុល"។ ខ្ញុំធូរចិត្តបន្តិច ហើយក៏បានគិតថា "ខ្ញុំនៅមានកម្លាំងធ្វើការបានខ្ញុំប្រហែលជាអាចទ្រាំទ្របានមួយរយៈពេល ទោះបីជាគ្មាននំប៉័ងក៏ដោយ អ្វីដែលសំខាន់គឺមិនមានបន្ទប់ផ្សែងពុលទេ។ បន្ទាប់មកទើបខ្ញុំដឹងថាពេលនោះគឺថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៤៥។

យើងត្រូវបានគេដាក់ឱ្យស្នាក់នៅក្នុងជំរំស្អាតមួយ។ បន្ទាប់ពីបានរំដោះទើបខ្ញុំយល់ថា តើយើងមានសំណាងល្អយ៉ាងណា នៅពេលដែលខ្ញុំបានឃើញអំពីស្ថានភាពអាក្រក់របស់ជំរំផ្សេងទៀត។ ជនជាតិជ្វីហ្វមួយក្រុមត្រូវបានយកទៅឃុំឃាំងនៅទីនោះមុនយើង ដើម្បីរង់ចាំការផ្លាស់ប្តូរជាមួយនឹងអ្នកទោសអាល្លឺម៉ង់។ យើងបានជួបជាមួយពួកគេនៅពេលដែលយើងបានមកដល់ជំរំ ហើយពួកគេកំពុងតែដើរសំដៅទៅរថភ្លើង។

មិនត្រឹមតែនំប៉័ងនោះទេដែលមិនមាន សូម្បីតែទឹកក៏មិនមានផឹកដែរ។ យើងមានតែកាហ្វេដែលជួយឱ្យយើងបន្តរស់រានមានជីវិតបាន។ ទឹកពណ៌ខ្មៅនោះត្រូវបានផ្តល់អោយក្នុងរយៈពេលពីរដងក្នុងមួយថ្ងៃ។ យើងដេកនៅលើគ្រែតូចរបស់យើង ដោយកាន់តែមានសុខភាពខ្សោយទៅៗ និងគ្មានចាប់អារម្មណ៍អំពីអ្វីទាំងអស់ហើយរង់ចាំតែសេចក្តីស្លាប់ប៉ុណ្ណោះ។ មិនយូរប៉ុន្មានក៏មានសំឡេងអ៊ូអរចេញមកពីខាងក្រៅ។ ទាហានអង់គ្លេសដែលកំពុងធ្វើដំណើរទៅទីក្រុងបែរឡាំង បានរកឃើញជំរំរបស់យើង ហើយក៏សម្រេចចិត្តចូលមករំដោះយើង។ នៅពេលនោះគឺថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៤៥។

ខ្ញុំមានការចងចាំស្រពេចស្រពិលអំពីអ្វីដែលបានកើតឡើងបន្ទាប់។ អ្វីដែលខ្ញុំចាំបានគឺ ខ្ញុំបានធ្លាក់ខ្លួនឈឺយ៉ាងខ្លាំង។ ខ្ញុំកើតជំងឺគ្រុនពោះវៀន ពីព្រោះតែខ្ញុំបានរត់ទៅគ្រប់កន្លែងដែលមានរបងបន្លាលួសហ៊ុមព័ទ្ធដើម្បី

រកមើលឪពុករបស់ខ្ញុំ។ លីវី បានមើលថែខ្ញុំ ហើយខ្ញុំត្រូវអរគុណប្អូនដែលបានជួយជីវិតរបស់ខ្ញុំ។ ប៉ុន្មានខែកន្លងផុតទៅ គណៈប្រតិភូរបស់ប្រទេសស៊ុយអ៊ែត បានមកជំរំបែលជិន-បឺសិន ជាមួយនឹងបេសកកម្មក្នុងការនាំជនរងគ្រោះចំនួន១ម៉ឺននាក់ ទៅប្រទេសស៊ុយអែតក្នុងរយៈពេល៦ខែដើម្បីព្យាបាលជំងឺ។ លីវី និងខ្ញុំ គឺនៅក្នុងចំណោមមនុស្សទាំងអស់នោះ។ បន្ទាប់ពីធ្វើដំណើរតាមរថភ្លើង និងធ្វើការសម្លាប់មេរោគនៅទីក្រុងលូបេក យើងត្រូវបានដាក់នៅលើទូកសង្គ្រោះបន្ទាន់ដើម្បីបន្តដំណើរទៅទីក្រុងម៉ាលម៉ូក្នុងប្រទេសស៊ុយអែត។ ការធ្វើដំណើរមួយនោះនិងអារម្មណ៍នៃសេរីភាពមួយនោះ ខ្ញុំគ្មានថ្ងៃអាចបំភ្លេចបាននោះទេ។



# “HUR BLEV NI MOTTAGNA I SVERIGE?”

# “HOW WERE YOU RECEIVED IN SWEDEN?”

# "តើអ្នកត្រូវបានទទួលនៅប្រទេសស៊ុយអែតយ៉ាងដូចម្តេច?"

ទូកដែលនាំយើងទៅដល់ប្រទេសស៊ុយអែត មានឈ្មោះថា រ៉ូនស្តាប៉ាន់ ហើយគឺជាទូកដឹកទំនិញដែលបានកែប្រែឱ្យទៅជាទូកសង្គ្រោះបន្ទាន់។ នោះគឺជាបទពិសោធន៍ថ្មីមួយសម្រាប់ខ្ញុំ ពីព្រោះខ្ញុំមិនដែលបានធ្វើដំណើរតាមទូកនោះទេ ហើយក៏មិនដែលបានឃើញសមុទ្រដែរ។ ពេលនោះខ្ញុំត្រូវបានអនុញ្ញាតឱ្យឡើងទៅជាន់លើដើម្បីស្រូបខ្យល់អាកាសសមុទ្រ ហើយខ្ញុំមានអារម្មណ៍រីករាយយ៉ាងខ្លាំងជាមួយទេសភាពសមុទ្រដ៏សែនធំទូលាយនោះ។ ខ្ញុំរីករាយនឹងការធ្វើដំណើរមួយនេះ។ យើងទាំងអស់គ្នាមានក្តីរំពឹងទុកមួយយ៉ាងខ្លាំង។ អ្នកធ្វើដំណើរមកជាមួយដទៃទៀត ព្រមទាំងខ្ញុំមានអារម្មណ៍ថា យើងត្រូវបានជ្រើសរើសសម្រាប់ជីវិតថ្មីមួយដែលយើងនឹងត្រូវបានចាត់ទុកថាជាភ្ញៀវពិសេស ហើយគេនឹងបំពេញគ្រប់តម្រូវការទាំងអស់របស់យើង។ គ្រែរបស់យើងនៅលើទូកនោះក្រាលដោយកម្រាលពណ៌ស ហើយតែងតែបន្លឺសំឡេងរាល់ពេលដែលខ្ញុំធ្វើចលនា។ វាធ្វើឱ្យខ្ញុំមានអារម្មណ៍ពិសេស ប្រៀបបានដូចជាខ្លួនឯងគឺជាស្គរសណ្តែកដីមួយគ្រាប់ដែលខ្ចប់ដោយថង់ពណ៌ប្រាក់។ បីយប់បីថ្ងៃបានរំលងផុតទៅយ៉ាងឆាប់រហ័ស យើងទាំងអស់គ្នាមានអារម្មណ៍សប្បាយរីករាយនៅពេលដែលបានទៅដល់ទីក្រុងម៉ាលម៉ូ[៧២]។ យើងបានជួបជាមួយឡូតូដែលជាសមាជិករបស់កងកម្លាំងនារីប្រដាប់អាវុធនៃប្រទេសស៊ុយអែត[៧៣] ដែលបានយកទឹកកាកាវនិងសាំងវិចអោយយើងបរិភោគ។ យើងគិតថាខ្លួនឯងបានមកដល់

[៧២] គឺជាទីក្រុងធំទី៣របស់ប្រទេសស៊ុយអែត។

[៧៣] ជាភាសាអង់គ្លេស **The Women's Wing of the Swedish Home Guard** គឺជាផ្នែកនារីនៃកងកម្លាំងបម្រុងយោធារបស់កងកម្លាំងប្រដាប់អាវុធប្រទេសស៊ុយអ៊ែតដែលត្រូវបានបង្កើតឡើងជាផ្លូវការនៅថ្ងៃទី២៩ខែឧសភាឆ្នាំ១៩៤០។



ឋានសួគ៌ហើយមិនដែលឆ្អែតជាមួយនឹងសាន់វិចព្រមទាំងទឹកកាកាវដែលល្អវិសេសនោះទេ។ ចាប់តាំងពីពេលនោះមកទឹកកាកាវប្រៀបបានដូចជានិមិត្តសញ្ញាដែលបញ្ជាក់អំពីអំពើល្អរបស់ប្រទេសស៊ុយអែត។ ពីកំពង់ផែមក យើងធ្វើដំណើរតាមរថអគ្គីសនី[៧៤] ទៅសាលារៀនលីនៀអឺស គឺជាកន្លែងដែលគេបានទទួលយើងឱ្យស្នាក់នៅ។ អ្វីដែលខ្ញុំចងចាំជាងគេគឺមុខម្ហូបនៅទីនោះ។ អាហារដ៏ឆ្ងាញ់ គឺសាច់គោផ្សំជាមួយនឹងរំដេងនិងអាហារចម្លែក ក៏ប៉ុន្តែមានរស់ជាតិឆ្ងាញ់ដូចគ្នាហៅថា បង្អែមសង់ខ្យារពណ៌ខ្មៅជាមួយនឹងលីនង៉នបឺរី។ យើងបរិភោគហើយបរិភោគទៀតតែយើងមិនដែលឆ្អែតទាល់តែសោះ។ អាហារ គឺជាពន្លឺមួយនៅក្នុងជីវិតរបស់យើង ហើយយើងរីករាយនឹងវាយ៉ាងខ្លាំង។ គេផ្តល់អាហារឱ្យយើងមួយថ្ងៃប្រាំដង ប៉ុន្តែយើងតែងតែខ្លាចថាវានឹងមិនគ្រប់គ្រាន់នោះទេ។ គ្នាយើងមួយចំនួនធំបានលួចយកអាហារពីសាលបរិភោគអាហារហើយលាក់ទុកនៅក្រោមខ្នើយដេក។ ទោះបីជាគេអនុញ្ញាតឱ្យយើងបរិភោគសាន់វិចក្នុងចន្លោះពេលអាហារ ឬពាក្យធានាយ៉ាងអត់ធ្មត់ពីក្រុមការងារថានឹងតែងតែមានអាហារគ្រប់គ្រាន់យ៉ាងណាក៏ដោយក៏មិនអាចបញ្ឈប់យើងបានដែរ។ ក្នុងករណីនេះខ្ញុំអាចប្រាប់អ្នកបានថា សេចក្តីស្រេកឃ្លានបានប៉ះពាល់យើងអស់មួយជីវិត។ អ្នករស់រានមានជីវិតមួយចំនួនមានជំងឺមិនឃ្លានអាហារ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏គ្នាយើងមួយចំនួនធំគឺតែងតែទិញអាហារយ៉ាងច្រើនលើសលុបដាក់នៅក្នុងទូរទឹកកក។

អ្នកនៅតំបន់នោះបានឈរផ្តុំគ្នានៅក្រៅរបងសាលារៀនដើម្បីរង់ចាំមើលអ្នកដែលរួចរានមានជីវិតពីជំរំបែលជិន-បឺសិន ប៉ុន្តែយើងត្រូវបានហាមឃាត់មិនឱ្យទៅជិតអ្នកទាំងនោះទេ។ យើងត្រូវបានដាក់ឱ្យនៅដាច់ដោយ

[៧៤] គឺជារថភ្លើងមួយប្រភេទដែលដើរដោយកម្លាំងអគ្គិសនីខ្សែកាបនិងរត់នៅលើផ្លូវដែកនៅតាមដងផ្លូវសាធារណៈ។

ឡែកពីគេដើម្បីការពាររោគឆ្លងអស់រយៈពេលប្រាំមួយសប្តាហ៍ បន្ទាប់មកទើបត្រូវបានអនុញ្ញាតឱ្យមានទំនាក់ទំនងជាមួយជនជាតិស៊ុយអែតនៅខាងក្រៅ។ ជនជាតិស៊ុយអែតទាំងនោះ មានចិត្តល្អនិងមានការងឿងឆ្ងល់ច្រើន។ អ្នកខ្លះឱ្យកាដូយើងបន្តិចបន្តួច ប៉ុន្តែគេមិនចង់ដឹងរឿងរបស់យើងទេ។ យើងត្រូវបានទទួលស្វាគមន៍យ៉ាងកក់ក្តៅ។ នៅពេលនោះគឺមិនទាន់ជាពេលវេលាសមស្របមួយសម្រាប់មនុស្សដើម្បីបង្ហាញអំពីការប្រកាន់ពូជសាសន៍របស់ខ្លួន ការរៀនសូត្រតាមណាហ្ស៊ី ឬក៏ការប្រឆាំងនឹងជនជាតិជ្វីហ្វនោះទេ។ ទាំងអស់នេះត្រូវបានគេបំភ្លេចចោល។ រហូតមកដល់ទសវត្សរ៍ឆ្នាំ១៩៨០ ទើបណាហ្ស៊ីនិយមបានរីករាលដាលម្តងទៀត។ នៅពេលដែលខ្ញុំគិតអំពីសព្វថ្ងៃនេះ ខ្ញុំនៅតែអាចឃើញគំរូនេះដដែល។ មនុស្សមានចិត្តអាណិតអាសូរ ចង់ជួយ ចង់ចែករំលែកភាពបរិបូណ៌ ប៉ុន្តែនៅពេលណាដែលមានសំណួរទាក់ទងអំពីការលះបង់ ឬក៏លះបង់ពេលវេលារបស់នរណាម្នាក់ ការជួយគ្នាទៅវិញទៅមកបានក្លាយទៅជារឿងមួយដែលពិបាកធ្វើទៅវិញ។

យើងមានអារម្មណ៍ស្វាគមន៍នៅក្នុងប្រទេសស៊ុយអែត។ ប៉ុន្តែបន្ទាប់ពីសេចក្តីរីករាយបានបញ្ចប់ទៅ ហើយយើងបានជួបប្រទះការលំបាកជាលើកដំបូង លីវីនិងខ្ញុំបានចាប់ផ្តើមគិតអំពីការចាកចេញពីប្រទេសមួយនេះ។ ប៉ុន្តែយើងចាប់ផ្តើមទម្លាប់ខ្លួនជាមួយនឹងប្រទេសស៊ុយអែតទៅហើយដូចគ្នាទៅនឹងប្រទេសស៊ុយអែតដែលកំពុងតែចាប់ផ្តើមទទួលស្គាល់យើង។ យើងដឹងថាគ្មានឋានសួគ៌ពិតនៅលើពិភពលោកនេះទេ។ នៅប្រទេសស៊ុយអែត ក៏ដូចជាប្រទេសដ៏ទៃទៀតដែរ មានរឿងខ្លះល្អ ឯរឿងខ្លះទៀតអាក្រក់។ ប៉ុន្តែបច្ចុប្បន្ននេះ ខ្ញុំមានអារម្មណ៍ថាកក់ក្តៅដូចជានៅក្នុងផ្ទះរបស់ខ្លួន។

“

# VAR DET SVÅRT ATT ANPASSA SIG TILL ATT LEVA I SVERIGE?

” “

# WAS IT DIFFICULT TO ADAPT TO LIFE IN SWEDEN?

”

# "តើមានការលំបាកក្នុងការសម្របខ្លួនទៅនឹងជីវិតនៅប្រទេសស៊ុយអែតដែរឬទេ ?"

សំណួរមួយដែលខ្ញុំត្រូវបានសួរជាច្រើនឆ្នាំគឺ តើវាចំណាយអស់រយៈពេលយូរដែរឬទេដើម្បីរៀនអំពីរបៀបរបបរបស់ប្រទេសស៊ុយអែត ?។ ការសន្និដ្ឋានរបស់ខ្ញុំគឺ មិនមានអ្វីដែលហៅថាគុណតម្លៃរបស់ប្រទេសស៊ុយអែតទេ។ នៅប្រទេសស៊ុយអែតខ្ញុំបានឃើញអំពីគុណតម្លៃដែលខ្ញុំបានដឹងពីស្រុកកំណើតរបស់ខ្ញុំនិងពីប្រទេសប្រជាធិបតេយ្យដ៏ទៃទៀត។ គោលការណ៍ចម្បងនោះ គឺមិនឱ្យមានឃាតកម្ម មិនឱ្យមានការលួច មិនត្រូវធ្វើអ្វីទៅលើអ្នកដទៃនូវអ្វីដែលអ្នកមិនចង់ឱ្យអ្នកដទៃធ្វើមកលើអ្នក ហើយគោលការណ៍ទាំងនេះអាចរកឃើញនៅក្នុងពាក្យខុសៗគ្នា និងភាសាខុសៗគ្នានៅគ្រប់សាសនាទាំងអស់ក្នុងពិភពលោក។

សញ្ញាណនៃ "គុណតម្លៃ" គឺទូលំទូលាយណាស់ហើយជាញឹកញាប់ត្រូវបានយល់ច្រឡំជាមួយ " វប្បធម៌ " ។ ខ្ញុំមកពីវប្បធម៌ដែលពោរពេញទៅដោយភាពអាម៉ាស់ ហើយនៅក្នុងឆ្នាំ១៩៤៥ ខ្ញុំបានជួបនឹងប្រទេសស៊ុយអ៊ែត ដែលកសាងឡើងនៅលើវប្បធម៌ដែលមានពិរុទ្ធភាពមួយ។ ខ្ញុំយល់ដឹងច្រើននៅពេលមានសកម្មភាពមួយចំនួនត្រូវបានគេបញ្ចេញមតិដោយពាក្យថា "យើងមិនធ្វើបែបនេះនៅក្នុងប្រទេសស៊ុយអែតទេ"។ ផ្កាដែលដុះតាមរបងរបស់អ្នកជិតខាងគឺមិនត្រូវបេះទេ នៅពេលណាដែលយើងត្រូវបានគេអញ្ជើញឱ្យទៅញ៉ាំអាហារពេលល្ងាច គឺយើងមិនអាចទៅយឺតបានទេ មិនអាចចូលផ្ទះដោយមិនដោះស្បែកជើងទេ ហើយនៅមានជាច្រើនបន្តទៀត។ នៅពេលដែលបានមកដល់ប្រទេសស៊ុយអែតលើកដំបូង មានរឿងច្រើនណាស់ដែលខ្ញុំពុំបានដឹងព្រមទាំងទាល់គំនិត។ ប៉ុន្តែ



នេះគឺជាផ្នែកមួយនៃវប្បធម៌ប្រទេសស៊ុយអែត ហើយគឺមិនមែនជាគុណតម្លៃរបស់ប្រទេសស៊ុយអែតនោះទេ។

អ្វីដែលខ្ញុំពិបាកយល់ជាងគេនោះគឺ នៅពេលដែល "បាទ/ចាស" មានន័យថាប្រហែលជា ហើយ "ប្រហែលជា" មានន័យថា "ទេ"។ ខ្ញុំចងចាំអំពីកំហុសដំបូងរបស់ខ្ញុំ ហើយនោះគឺជាបទល្មើសទៅលើវប្បធម៌ជាជាងការរំលោភបំពានទៅលើគុណតម្លៃ។ ទម្លាប់នៅលើតុអាហារក៏ខុសគ្នាពីអ្វីដែលខ្ញុំបានដឹង។

ថ្ងៃមួយខ្ញុំត្រូវបានគេអញ្ជើញឱ្យទៅញ៉ាំអាហារពេលល្ងាច។ ខ្ញុំបានចេញពីផ្ទះមុនពេលកំណត់ ហើយបានដើរទៅដើរមកនៅមុខផ្ទះរបស់គេរហូតទាល់តែកណ្តឹងរបស់វិហារឱ្យសញ្ញាថាម៉ោង៦។ ខ្ញុំមិនហ៊ានចូលទៅមុនម៉ោងនោះទេ។ នៅពេលដែលម្ចាស់ផ្ទះបានឱ្យចានអាហារមកខ្ញុំ ខ្ញុំយកតែបន្តិចបន្តួចតែប៉ុណ្ណោះដើម្បីបង្ហាញអំពីអាកប្បកិរិយាល្អ ព្រោះខ្ញុំយល់ថាជាធម្មតាម្ចាស់ផ្ទះគួរតែទទូចឱ្យអាហារមកខ្ញុំជាច្រើនដង ហើយពេលខ្លះទៀតក៏គួរតែបង្ខំដែរ។ ប៉ុន្តែនៅប្រទេសស៊ុយអែត គេមិនបង្ខំភ្ញៀវឱ្យហូបអាហារទេ។ ដូច្នេះហើយខ្ញុំក៏ចាកចេញពីតុអាហារទាំងពោះមិនទាន់ឆ្អែត។

នៅប្រទេសស៊ុយអែត ខ្ញុំបានរៀនពីការឈប់ឆ្លើយតបជាមួយនឹងពាក្យថា "អរគុណ" ដោយអៀនខ្មាសនៅពេលដែលគេអោយអ្វីមួយ។ គឺត្រូវតែជា "ចាស" ឬ "អត់ទេ"។

នៅពេលដែលខ្ញុំមានភ្ញៀវ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលដែលខ្ញុំឮគេប្រើពាក្យថា "មានមនុស្សចម្លែកចូលមកក្នុងផ្ទះ"។ ហេតុអ្វីបានជាជនជាតិស៊ុយអែតហៅមិត្តរបស់ខ្លួនថាជាមនុស្សចម្លែក ? តើនេះឬគឺជាគុណតម្លៃរបស់ប្រទេសស៊ុយអែត ?

ក្នុងរដូវក្តៅមួយ ខ្ញុំបានធ្វើការនៅលើនាវាទេសចរណ៍មួយដែលធ្វើដំណើរទៅតាមប្រជុំកោះ។ ភារកិច្ចរបស់ខ្ញុំ គឺសម្អាតបន្ទប់របស់នាយនាវា និងបម្រើអាហារនៅក្នុងភោជនីយដ្ឋានរបស់នាវា។ ខ្ញុំបានខំប្រឹងធ្វើការឱ្យបានល្អបំផុតតាមដែលខ្ញុំអាចធ្វើទៅបាន។ ប៉ុន្តែនៅពេលចុងខែ ខ្ញុំមិនបានទទួលប្រាក់ឈ្នួលរបស់ខ្ញុំទេ ហើយបែរជាទទួលនូវពាក្យពន្យល់មួយថាខ្ញុំគឺជាអ្នកសម្អាតដែលធ្វេសប្រហែស។ នេះគឺជាការពិត ហើយខ្ញុំមានការអៀនខ្មាសយ៉ាងខ្លាំង ប៉ុន្តែប្រសិនបើពេលនោះខ្ញុំត្រូវបានគេរិះគន់ខ្ញុំប្រហែលជាព្យាយាមខ្លាំងជាងនេះ។ នៅពេលដែលខ្ញុំលើកឡើងអំពីចំណុចនេះ ថៅហ្វាយរបស់ខ្ញុំបាននិយាយថា នៅប្រទេសស៊ុយអែត យើងមិនរិះគន់បុគ្គលិកនោះទេ។ អ្នកដែលមិនបានបំពេញការងាររបស់ខ្លួនឱ្យបានល្អត្រឹមត្រូវគឺមិនទទួលបានប្រាក់ខែទេ។

ខ្ញុំបានចំណាយអស់រយៈពេលជាច្រើន ដើម្បីរៀនរស់នៅក្នុងវប្បធម៌របស់ប្រទេសស៊ុយអែត ប៉ុន្តែខ្ញុំបានយកគុណតម្លៃមូលដ្ឋានមួយមកជាមួយខ្ញុំ។ ជាច្រើនឆ្នាំមកនេះមានការហូរចូលនៃជនអន្តោប្រវេសន៍ជាច្រើន ហើយយើងក៏អាចតាមដានការផ្លាស់ប្តូរវប្បធម៌តាមរយៈនេះបានដែរ។ ប្រទេសស៊ុយអែតបានបើកនិងផ្តល់ឱកាសឱ្យជនអន្តោប្រវេសន៍ ហើយអ្នកទាំងនោះបានសម្របខ្លួនទៅតាមមជ្ឈដ្ឋានថ្មីមួយនោះដែរ។ ជនអន្តោប្រវេសន៍ទាំងនោះបានទទួលយកវប្បធម៌របស់ប្រទេសស៊ុយអែត ក្នុងខណៈពេលដែលប្រទេសស៊ុយអែត កាន់តែរីកចម្រើនដោយសារតែការចូលរួមអភិវឌ្ឍន៍របស់ជនបរទេសទាំងអស់នោះ។

នេះគឺមិនមែនជាគុណតម្លៃរបស់ជនជាតិស៊ុយអែតទេ ដែលធ្វើឱ្យវិធីនៃការធ្វើសមាហរណកម្មទទួលបានជោគជ័យ ប៉ុន្តែគឺជាសំណួរដែលចោទទៅលើគោលបំណងល្អរបស់មនុស្សទៅវិញទេ។ ទាំងនេះមិនអាចកើតឡើងបានដោយឆាប់រហ័សទេ ជាពិសេសនៅពេលដែលដំណើរការរបស់អាជ្ញាធរមានភាពយឺតយ៉ាវនៅឡើយ។ ដូច្នេះហើយទើបមានសារសំខាន់ខ្លាំងណាស់ក្នុងការកាត់បន្ថយរយៈពេលរង់ចាំនិងបង្កើនឱកាសសម្រាប់ប្រជាជនស៊ុយអែត និងជនអន្តោប្រវេសន៍វ័យក្មេងជួបជុំគ្នានិងទទួលស្គាល់គ្នាទៅវិញទៅមកនៅក្រោមកាលៈទេសៈមួយដែលសប្បាយរីករាយ។

ការខិតខំប្រឹងប្រែងនីមួយៗជាធម្មតា គឺតែងតែផ្តល់ផលប្រយោជន៍ដ៏ល្អប្រសើរមួយ។ ប្រទេសស៊ុយអែតក៏អាចក្លាយទៅជាទីកន្លែងមួយដែលប្រមូលផ្តុំដោយជាតិសាសន៍ជាច្រើនប្រសិនបើរដ្ឋាភិបាលបង្កើតកិច្ចខិតខំប្រឹងប្រែងដែលអាចប្រមូលផ្តុំជនអន្តោប្រវេសន៍ និងជនជាតិស៊ុយអែតតាមរយៈសកម្មភាពកម្សាន្តជាច្រើន។

“

# HUR HANTERADE DU DINA TRAUMAN?

” “

# HOW DID YOU DEAL WITH YOUR TRAUMA?

”

## "តើអ្នកដោះស្រាយជាមួយនឹងការប៉ះទង្គិចផ្លូវចិត្តបានដោយរបៀបណា?"

ខ្ញុំសំណាងល្អដែលអាចមកប្រទេសស៊ុយអែត នៅរដូវក្តៅក្នុងឆ្នាំ ១៩៨៥។ ប៉ុន្តែវានៅតែជាពេលវេលាមួយដែលលំបាក។ ខ្ញុំឈឺចាប់ដោយសារតែបានបាត់បង់គ្រួសារមួយទាំងមូលលើកលែងតែប្អូនស្រីរបស់ខ្ញុំ។ ខ្ញុំបានទទួលរងទារុណកម្មផ្លូវចិត្តពីព្រោះខ្ញុំគិតអំពីឪពុកម្តាយរបស់ខ្ញុំ ដែលត្រូវបានគេសម្លាប់ក្នុងអំឡុងពេលដែលខ្ញុំរួចជីវិត។ តើមានប៉ុន្មានអ្នកដែលអាចរស់រានមានជីវិតនៅក្នុងចំណោមសមាជិកគ្រួសារទាំង៥៦នាក់ របស់ខ្ញុំ? ពាក្យថា "ការប៉ះទង្គិចផ្លូវចិត្ត" ត្រូវបានគេស្គាល់មិនច្បាស់លាស់ទេ ហើយគ្មាននរណាម្នាក់បានដឹងអំពីដំណើរការនៃ "ការប៉ះទង្គិចផ្លូវចិត្ត" នោះដែរ។ ការយល់ដឹងថាមនុស្សម្នាក់អាចរងទុក្ខពីការប៉ះទង្គិចផ្លូវចិត្តបានយូរអង្វែងត្រូវបានគេចាប់អារម្មណ៍នៅពេលដែលអ្នករស់រានមានជីវិតកាន់តែច្រើនបានចាប់ផ្តើមត្អូញត្អែរអំពីបញ្ហាសុខភាព។ ក្នុងអំឡុងពេលសង្គ្រាមលោកលើកទី១ ទាហានមួយចំនួនបានរងទុក្ខដោយសារតែអ្វីៗដែលខ្លួនបានជួបប្រទះនៅក្នុងសង្គ្រាម។ ប៉ុន្តែអស់រយៈពេលជាយូរ ការរងទុក្ខនេះមិនត្រូវបានចាត់ទុកថាជាជំងឺផ្លូវចិត្តនោះទេ។ វាត្រូវបានគេហៅថា "ភាពភ្ញាក់ផ្អើល" ហើយទាហានត្រូវបានបញ្ជូនទៅសមរភូមិដូចធម្មតាវិញ។ នៅពេលដែលរោគសញ្ញាទាំងនោះវិលត្រឡប់មកវិញ ទាហានទាំងនោះត្រូវបានចោទប្រកាន់ថាធ្វើពុតជាឈឺ។

“

# VAD FICK DIG ATT BÖRJA FÖRELÄSA?

” “

# WHAT MADE YOU START LECTURING?

”



# "តើអ្វីដែលជម្រុញឱ្យអ្នកចាប់ផ្ដើមបង្រៀន ?"

ទីបំផុតខ្ញុំបានយល់ថា ខ្ញុំរស់រានមានជីវិតពីព្រោះតែខ្ញុំដឹងថាត្រូវតែមាននរណាម្នាក់មានជីវិតដើម្បីប្រាប់អំពីរឿងរ៉ាវដែលបានកើតឡើងនៅហូឡូខសន៍[៧៥]។ ប្រសិនបើគ្មាននរណាម្នាក់និយាយអំពីអ្វីដែលបានកើតឡើងនៅហូឡូខសន៍ទេនោះ អ្វីៗនឹងត្រូវបានបំភ្លេចចោល ហើយអ្វីដែលត្រូវបានបំភ្លេចចោលហើយនោះអាចនឹងកើតឡើងម្ដងទៀតបានយ៉ាងងាយស្រួល។ ប្រសិនបើហូឡូខសន៍សាបរលាបបាត់ដោយគ្មាននរណាម្នាក់ចងចាំ ជនជាតិជ្វីហ្វចំនួន៦លាននាក់ និងកុម្មុយនីស្ដជាច្រើននាក់ ព្រមទាំងអ្នកដែលស្រឡាញ់ភេទដូចគ្នា មនុស្សពិការ ជនជាតិរ៉ូម៉ាំង និង អ្នកដទៃទៀតដែលត្រូវបានចាត់ទុកថាមិនមានតំលៃស្មើនឹងមនុស្សនោះ នឹងបាត់បង់ជីវិតដោយគ្មាននរណាម្នាក់ចងចាំអំពីពួកគេឡើយ។

លើកទី១ដែលខ្ញុំដឹងគឺនៅពេលដែលមានគ្រូម្នាក់បានហៅខ្ញុំឱ្យទៅនិយាយនៅសាលារបស់គាត់។

នៅពេលដែលខ្ញុំចូលនិវត្តន៍ នៅដើមឆ្នាំ១៩៨០ ខ្ញុំបានចាប់ផ្ដើមសរសេរសៀវភៅអំពីអ្វីដែលបានកើតឡើង។ សៀវភៅដំបូងគឺ ដំណើរទៅអូសឈ្វិច៖ បំណែកនៃជីវិត (បកប្រែជាភាសាអង់គ្លេសដោយ មែយែល មេយឺ) ។

ចាប់តាំងពីពេលនោះមក ខ្ញុំបានបង្រៀនអស់រយៈពេលជាច្រើនឆ្នាំ ហើយខ្ញុំធ្វើដូច្នេះដោយសារតែមូលហេតុពីរគឺបែបនេះឈ្មោះ ហ្វ្រីដា ឃ្លែន ស្មាក់ **(Frida Klein Szmuk)** និង អ៊ីរីណាត់ ស្មាក់ **(Ignatz Szmuk)** [៧៦] នឹងនៅតែមានក្នុងការចងចាំ ហើយដូច្នេះអ្នកជំនាន់ក្រោយអាចយកមេរៀនរបស់

[៧៥] គឺជាការធ្វើបាបយាយីនិងអំពើប្រល័យពូជសាសន៍ទៅលើជនជាតិជ្វីហ្វ ចំនួន៦លាននាក់ ដោយរបបណាហ្ស៊ីរបស់ហ៊ីត្លែរ ចាប់តាំងពីឆ្នាំ១៩៣៣ រហូតដល់ចុងបញ្ចប់សង្គ្រាមលោកលើកទី២។ ហូឡូខសន៍ គឺជាពាក្យដើមនៃភាសាក្រិកមានន័យថា "បូជាដោយភ្លើង" ឬ "បូជាភ្លើង" ។

[៧៦] ឈ្មោះម្ដាយឪពុករបស់ហេឌី ហ្វ្រាយ។

ហូឡូខសន៍ដាក់ក្នុងដួងចិត្តរបស់ខ្លួនទើបអ្នកទាំងនោះនឹងមិនមានបទពិសោធន៍ដូចអ្វីដែលខ្ញុំបានឆ្លងកាត់។

ក្មេងជំទង់ជារឿយៗមានការលំបាកនៅពេលដែលជួបសំណួរអំពីអត្ថន័យនៃជីវិតរបស់ខ្លួន។ អ្នកខ្លះជួបរឿងបែបនេះដោយពេលខ្លះសូម្បីតែមិនធ្លាប់បានឆ្លងកាត់សង្គ្រាមនិងការធ្វើបាបយាយីក៏ដោយ។ ខ្ញុំសូមបកស្រាយពាក្យអ្នកនិពន្ធជនជាតិសូម៉ាលីម្នាក់ដែលមានឈ្មោះថា ណូរូឌីនហ្វារ៉ា។ គាត់បាននិយាយថា អត្ថន័យនៃជីវិត គឺធ្វើអំពើល្អនិងជួយអ្នកជិតខាងព្រោះវាក៏ធ្វើឱ្យអ្នកមានអារម្មណ៍ល្អដូចគ្នាដែរ។

សម្រាប់ខ្ញុំៗជឿថា អត្ថន័យនៃជីវិត គឺជីវិតនោះឯង។



# “ KÄNNER DU DIG SVENSK? ”

# “ DO YOU FEEL SWEDISH? ”

# "តើអ្នកមានអារម្មណ៍ថាជាជនជាតិស៊ុយអែតដែរឬទេ?"

សំណួរដែលសួរថា តើខ្ញុំមានអារម្មណ៍ថាជាជនជាតិស៊ុយអែតដែរឬទេ គឺពិតជាស្មុគស្មាញណាស់។ វាលើកឡើងនូវសំណួរជាច្រើនទៀតថាតើខ្ញុំជាអ្នកណា? តើកន្លែងណាដែលខ្ញុំមានអារម្មណ៍ថាគឺជាផ្ទះ? តើខ្ញុំគួរតែនៅកន្លែងណា? តើវាគឺជាកន្លែងដែលខ្ញុំកើតឬក៏ជាកន្លែងដែលខ្ញុំធំធាត់? តើវាគឺជាកន្លែងដែលខ្ញុំមានគ្រួសារ ការងារ ឬតើវាទាក់ទងនឹងសញ្ជាតិ ជាតិសាសន៍ ឬក៏សាសនាដែលខ្ញុំគោរព? ដើម្បីឈានទៅដល់ការឆ្លើយសំណួរទាំងនេះគឺត្រូវការពេលវេលាជាច្រើន។

ខ្ញុំកើតនៅក្នុងប្រទេសរូម៉ានី ក្នុងគ្រួសារជនជាតិជ្វីហ្វមួយ ដែលនិយាយភាសាហុងគ្រី។ ជាកូនក្មេងម្នាក់ វាគឺជារឿងធម្មតានោះទេដែលក្មេងៗដទៃទៀតនិយាយភាសាផ្សេងពីខ្លួន បរិភោគម្ហូបអាហារផ្សេង ហើយស្លៀកសម្លៀកបំពាក់ផ្សេង។ យើងលេងជាមួយគ្នាហើយយោគយល់គ្នាទៅវិញទៅមក។ នៅពេលដែលខ្ញុំទៅសាលារៀនទើបខ្ញុំដឹងថា ក្រុមខ្លះត្រូវបានចាត់ទុកថាល្អជាងក្រុមដ៏ទៃទៀត។ យើងត្រូវបានគេដាក់ទោសដោយសារតែយើងនិយាយភាសាផ្សេងទៀតក្រៅពីរូម៉ានី។ ថ្ងៃដំបូងនៅសាលារៀន ខ្ញុំត្រូវបានគ្រូវាយដែលធ្វើឱ្យមានស្នាមក្រហមលើបាតដៃរបស់ខ្ញុំព្រោះតែខ្ញុំនិយាយភាសាផ្សេងទៀត។ ក្នុងរយៈពេលប៉ុន្មានឆ្នាំបន្ទាប់មក ខ្ញុំបានជៀសផុតពីការត្រូវរំពាត់បានច្រើនក៏ពិតមែន ប៉ុន្តែជារឿយៗប្រាក់ប្រចាំសប្តាហ៍របស់ខ្ញុំត្រូវបានបាត់បង់ពីព្រោះខ្ញុំត្រូវបង់ប្រាក់នៅពេលណាដែលខ្ញុំត្រូវចាប់បានថានិយាយភាសាហុងគ្រី។ យើងត្រូវបានពិន័យ ១ ឡេអ៊ូ[៧៧] ក្នុងមួយពាក្យ។ គោលបំណងរបស់ប្រទេសរូម៉ានីគឺប្រើខ្សែតីដើម្បីធ្វើឱ្យក្រុមជនជាតិភាគតិចទាំងអស់ ក្លាយទៅជាជនជាតិរូម៉ានីពេញលេញ។ នៅក្នុងផ្នែកខ្លះ វិធីនេះទទួលបានជោគជ័យ។ នៅពេលហុងគ្រីបានចូលមកត្រង់ស៊ីលវ៉ានី ក្នុងឆ្នាំ១៩៤២ ខ្ញុំគឺជាអ្នកជាតិនិយមរូម៉ានី ពេញទំហឹងបាត់ទៅហើយ។ ពេលនោះប្រទេសហុងគ្រី ចង់ឱ្យយើងប្រែទៅជាអ្នកជាតិនិយមហុងគ្រីវិញ ពួកគេថែមទាំងបានប្រើឧបករណ៍ដូចគ្នាទៀតផងហើយនោះគឺ ខ្សែតី។

[៧៧] រូបិយប័ណ្ណរបស់ប្រទេសរូម៉ានី (១ឡេអ៊ូមានតម្លៃស្មើនឹង១០០០រៀលលុយខ្មែរ)។



នៅពេលដែលខ្ញុំបានមកដល់ប្រទេសស៊ុយអែតដំបូង ខ្ញុំមិនបានដឹងថាតើខ្ញុំជាអ្នកណានោះទេ។ ខ្ញុំមកពីពិភពមួយដែលយើងមិនត្រូវបានគេរាប់បញ្ចូលថាជាមនុស្ស។ អ្វីដែលគួរឱ្យកត់សម្គាល់នោះ គឺភាពងាយស្រួលក្នុងការមើលខ្លួនឯងតាមរយៈខ្សែភ្នែករបស់អ្នកដ៏ទៃ។ ប្រសិនបើអ្នកដទៃគិតថាខ្ញុំល្អ ខ្ញុំមានអារម្មណ៍ល្អ ប្រសិនបើអ្នកដ៏ទៃគិតថាខ្ញុំមិនល្អ ខ្ញុំមានអារម្មណ៍មិនល្អ។ ដូចជាអ្នកដ៏ទៃដែរ ខ្ញុំត្រូវការឃើញភាពអះអាងតាមរយៈខ្សែភ្នែករបស់ជនជាតិស៊ុយអែតជាមុនសិន មុននឹងខ្ញុំអាចឆ្លើយតបបានថាតើខ្ញុំជាអ្នកណា។ ខ្ញុំមកពីត្រង់ស៊ីលវ៉ានីដែលពេលនោះគឺជាផ្នែកមួយរបស់ប្រទេសហុងគ្រី។ ដូច្នេះហើយបានជាខ្ញុំត្រូវបានចាត់ទុកថាជាជនជាតិហុងគ្រី-ជ្វីហ្វ។ ប៉ុន្តែប្រទេសហុងគ្រីនោះហើយគឺជាពេជ្ឈឃាតរបស់យើងទៅវិញទេ។ ប្រទេសហុងគ្រីបានបញ្ជូនយើងទៅឱ្យប្រទេសអាល្លឺម៉ង់។ ដូច្នេះហើយបានជាខ្ញុំមិនចង់ប្រកាសថាខ្លួនឯងគឺជាជនជាតិហុងគ្រី-ជ្វីហ្វនោះទេ។

កាលពីក្មេងខ្ញុំចង់ចាត់ទុកខ្លួនឯងថាគឺជាជនជាតិរូម៉ានី។ ប៉ុន្តែអ្វីដែលខ្ញុំទទួលបានគឺមានតែការបដិសេធតាមរយៈខ្សែភ្នែករបស់អ្នកជិតខាងយើងដែលជាជនជាតិរូម៉ានី។ ខ្ញុំក៏មិនបានក្លាយទៅជាជនជាតិហុងគ្រីនៅពេលដែលខ្ញុំមកដល់ប្រទេសហុងគ្រីដែរ។ ខ្ញុំបានជួបការបដិសេធនោះដដែល ទោះបីជាខ្ញុំប៉ងប្រាថ្នាយ៉ាងណាក៏ដោយ។ នៅពេលដែលខ្ញុំបានមកដល់ប្រទេស

ស៊ុយអែតខ្ញុំមិនមែនជាអ្វីទាំងអស់។ តើខ្ញុំនឹងអាចក្លាយទៅជាជនជាតិស៊ុយអែតដែរឬទេ? ខ្ញុំសង្ឃឹមថាដូច្នេះ។ ដរាបណាខ្ញុំរៀនភាសាហើយរកការងារបានធ្វើ ខ្ញុំគិតថាខ្ញុំប្រហែលជាអាចក្លាយទៅជនជនជាតិស៊ុយអែតបាន។

អារម្មណ៍នៃការទទួលស្គាល់កើតមានឡើងដោយសារតែទំនាក់ទំនងរវាងការទទួលស្គាល់យ៉ាងបើកចំហពីសហគមន៍និងឆន្ទៈក្នុងការសម្របខ្លួន។ ឆន្ទៈក្នុងការសម្របខ្លួនមាននៅក្នុងខ្លួនរបស់ខ្ញុំតាំងពីដំបូង។ វាគឺពិតជាអស្ចារ្យណាស់ដែលបានទទួលស្វាគមន៍ពីសង្គមស៊ុយអែតនៅពេលយើងទៅដល់ទីក្រុងម៉ាលម៉ូ ប៉ុន្តែគួរឱ្យសោកស្តាយដែលអារម្មណ៍បែបនេះមិនមានរយៈពេលយូរ។ ពេលវេលាកន្លងផុតទៅទើបខ្ញុំដឹងថាខ្ញុំបានយល់ច្រឡំសេចក្តីអាណិតពីបុគ្គលម្នាក់ៗថាគឺជាការស្វាគមន៍ទៅវិញ។ ខ្ញុំបានចំណាយអស់រយៈពេលជាច្រើនឆ្នាំទើបខ្ញុំបានយល់ដឹងច្បាស់។មកដល់ពេលនោះខ្ញុំមានការងារធ្វើនិងបានចាប់ផ្តើមរៀនភាសាស៊ុយអែត ប៉ុន្តែខ្ញុំនៅតែត្រូវបានគេចាត់ទុកថាជាជនបរទេសនិងនៅតែជាប់ឈ្មោះបែបនេះរហូតទាល់តែខ្ញុំទទួលបានសញ្ជាតិពេញលេញ។ ខ្ញុំដឹងថាខ្ញុំមិនមែនជាជនជាតិស៊ុយអែតនោះទេ ប្រសិនបើមិនមានសញ្ជាតិពេញលេញ។ ខ្ញុំត្រូវរង់ចាំរយៈពេល៧ឆ្នាំជាមុនសិនមុននឹងទទួលបានសញ្ជាតិជាជនជាតិស៊ុយអែត។

ជាច្រើនឆ្នាំបានកន្លងផុតទៅ ខ្ញុំរៀបការហើយមានកូន៣នាក់។ មកដល់ពេលនេះខ្ញុំមានកន្លែងដាក់លាក់និងមានផ្ទះជារបស់ខ្លួននៅក្នុងប្រទេសស៊ុយអែត ហើយក៏បានចាប់ផ្តើមចាត់ទុកថាខ្លួនឯងគឺជាជនជាតិស៊ុយអែតម្នាក់។ ប៉ុន្តែសង្គមស៊ុយអែតនៅតែមានគំនិតផ្សេង ខ្ញុំនៅតែជាជនអន្តោប្រវេសន៍ម្នាក់។ ខ្ញុំនិងប្តីរបស់ខ្ញុំដែលមកពីតំបន់ផ្សេងពីគ្នាបានខិតខំប្រឹងប្រែងធ្វើការនិងចូលរួមអភិវឌ្ឍន៍សង្គមរបស់ប្រទេសស៊ុយអែត។



មកដល់សព្វថ្ងៃនេះ ខ្ញុំបានចាត់ទុកខ្លួនឯងថាជាជនជាតិស៊ុយអែត ប៉ុន្តែខ្ញុំមិនហ៊ាននិយាយឱ្យឮខ្លាំងនៅចំពោះមុខអ្នកដែលខ្ញុំមិនស្គាល់នោះទេ។ ដោយសារតែភាពឈឺចាប់យ៉ាងខ្លាំងប្រសិនបើគេបដិសេធជាមួយនឹងទឹកមុខដែលបង្ហាញថា "អ្នកមិនមែនជាជនជាតិរបស់យើងនោះទេ អ្នកគឺជាជនអន្តោប្រវេសន៍ហើយយើងអាចទទួលអ្នកថាជាជនអន្តោប្រវេសន៍នៅក្នុងប្រទេសស៊ុយអែតបាន" ។

ទោះបីជាយ៉ាងណាក៏ដោយ អ្វីៗបានប្រែប្រួលបន្តិចបន្តួចតាំងពីពេលដែលយើងមកដល់ប្រទេសស៊ុយអែតលើកដំបូង។ ឥឡូវនេះមនុស្សកាន់តែច្រើនបានមករកខ្ញុំដោយមិនមានទឹកមុខសង្ស័យដែលបង្ហាញថា "តើអ្នកជាអ្នកណា អ្នកមិនមែនជាជនជាតិរបស់យើងទេ?" មនុស្សជាច្រើនបានចាប់ផ្តើមបោះបង់ចោលបុរេនិច្ឆ័យរបស់ខ្លួន ហើយខ្ញុំសង្ឃឹមថានឹងមិនមានបន្តទៀតនោះទេ។ បែបនេះអាចធ្វើឱ្យប្រទេសស៊ុយអែត ក្លាយទៅជាប្រទេសមួយដែលបានបោះបង់ចោលនូវការប្រកាន់ពូជសាសន៍ដែលរារាំងការទទួលស្គាល់ដោយស្មោះត្រង់ចំពោះអ្នកដទៃ។ ប្រទេសស៊ុយអែតនឹងអោបក្រសោបអ្នកដែលរួចផុតពីការលិចលង់នាវា ព្រមទាំងរាប់បញ្ចូលអ្នកទាំងអស់នោះទៅក្នុងសង្គមរបស់ខ្លួន។ ប្រសិនបើជនអន្តោប្រវេសន៍និងជនជាតិស៊ុយអែតសហការគ្នាទៅវិញទៅមក យើងនឹងរីកចម្រើនទាំងអស់គ្នា។

“

# KÄNNER DU IGEN DIG I DAGENS FLYKTINGAR?

” “

# DO YOU SEE YOURSELF IN TODAY’S REFUGEES?

”



## "តើអ្នកអាចស្រមៃឃើញខ្លួនឯងដូចជាជនភៀសខ្លួនសព្វថ្ងៃនេះដែរឬទេ ?"

ខ្ញុំបានមកដល់ប្រទេសស៊ុយអែតនៅរដូវក្ដៅក្នុងឆ្នាំ១៩៤៥ តាមរយៈការសន្យាដ៏សប្បុរសធម៌របស់រដ្ឋាភិបាលប្រទេសស៊ុយអែត ក្នុងការទទួលយកអ្នករស់រានមានជីវិតដែលមានជំងឺចំនួន១ម៉ឺននាក់ ដើម្បីព្យាបាលជំងឺក្នុងរយៈពេល៦ខែ។ ប៉ុន្តែ៦ខែនោះបានប្រែទៅជាមួយជីវិតដែលពោរពេញទៅដោយការតស៊ូរួមទាំងភាពបរាជ័យ និងភាពជោគជ័យ។

យើងគឺជាជនភៀសខ្លួនចេញពីអតីតកាលនិងបានដឹងគុណចំពោះសប្បុរសធម៌ដែលបានធ្វើមកលើយើង។ ដើម្បីទទួលបាននូវសេចក្តីថ្លៃថ្នូរមកវិញ យើងចង់ចាប់ផ្តើមធ្វើការងារឱ្យបានឆាប់នៅពេលណាដែលមានកម្លាំងភ្លាមៗ។ ការងារអ្វីគឺមិនសំខាន់នោះទេ យើងទទួលយកអ្វីទាំងអស់ដែលគេឱ្យធ្វើ។ យើងបានគិតថាប្រសិនបើរៀនចេះភាសា យើងនឹងអាចសម្រេចក្តីបំណងដ៏ធំបំផុតដើម្បីឱ្យខ្លួន យើងក្លាយទៅជាពលរដ្ឋដែលមានប្រយោជន៍ម្នាក់។ យើងដឹងច្បាស់ថា យើងមិនចង់វិលត្រឡប់ទៅប្រទេសរបស់ខ្លួនវិញនោះទេ ដូច្នេះហើយយើង គឺមិនខុសគ្នាពីជនភៀសខ្លួនសព្វថ្ងៃនេះនោះទេ។ អ្វីដែលខុសគ្នានោះគឺយើងមិនចង់ត្រឡប់ទៅវិញ ប៉ុន្តែពួកគេគឺមិនអាចត្រឡប់ទៅវិញ។

នៅពេលដែលខ្ញុំឃើញរូបភាពរន្ធត់របស់អាគារដែលទ្រុឌទ្រោម និងទូកដែលណែនតាន់តាប់ដោយមនុស្សនៅលើសមុទ្រមេឌីទែរ៉ាណេ ខ្ញុំអាចស្រមៃឃើញខ្លួនឯងកំពុងតែអង្គុយនៅទីនោះ។ ខ្ញុំក៏ប្រហែលជាឡើងទៅលើទូកនោះដែរទោះបីជាមានក្តីសង្ឃឹមតិចតួចក្នុងការរស់រានមានជីវិតក៏ដោយ។ មនុស្សទាំងអស់នោះដឹងថាខ្លួននឹងមិនត្រូវបានទទួលស្វាគមន៍

នៅទីកន្លែងណានោះទេដូចដែលយើងបានដឹងដែរថាជនជាតិជ្វីហ្វមិនត្រូវបានទទួលស្វាគមន៍នោះទេនៅក្នុងអំឡុងឆ្នាំ១៩៣៨។ ទោះបីជាបន្ទាប់ពីឆ្នាំ១៩៤៥ ក៏ដោយ ក៏នៅតែមិនប្រសើរឡើងដែរ បុរេវិនិច្ឆ័យគឺនៅតែមានជាប់ជានិច្ច។

បុរេវិនិច្ឆ័យបានចាប់ផ្ដើមក្លាយទៅជាការស្លាបនាសង្គមមួយដែលស្វែងរកការអះអាង។ គឺប្រៀបបានដូចជាទំនាយមួយដែលឆ្លើយតបសំណួរដោយខ្លួនឯងហើយក៏ក្លាយទៅជាដំណើរវិលជុំដ៏កាចសាហាវមួយ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសស៊ុយអែត បានបើកទទួលយ៉ាងហោចណាស់យើងទាំងអស់គ្នាចំនួន១ម៉ឺននាក់។

នៅពេលដែលខ្ញុំមើលទៅជនភៀសខ្លួនសព្វថ្ងៃនេះ ខ្ញុំយល់អារម្មណ៍របស់អ្នកដែលបាត់បង់ក្ដីសង្ឃឹមទាំងនោះដែលជម្រើសតែមួយគត់សម្រាប់ឱ្យពួកគេជៀសផុតពីសេចក្ដីស្លាប់បាននោះ គឺការធ្វើដំណើរដែលប្រឈមមុខនឹងគ្រោះថ្នាក់ទៅទីកន្លែងដែលគ្មាននរណាម្នាក់ដឹង។ ជំនួសទៅដោយការជួយយកអាសារ អ្នកទាំងនោះបែរជាជួបជាមួយនឹងជញ្ជាំងខ្ពស់និងមនុស្សព្រងើយកន្តើយដែលបានបាត់បង់សេចក្ដីករុណាទៅវិញ។ ខ្ញុំមើលឃើញភាពអាត្មានិយមនិងភាពមិនទទួលខុសត្រូវដូចដែលមាននៅក្នុងដើមទសវត្សរ៍ឆ្នាំ១៩៣០ដដែល។ ក៏ប៉ុន្តែវាគឺមានកាន់តែខ្លាំងឡើងៗ។

កាលពីមុនដូចជាបច្ចុប្បន្ននេះដែរ មិនមានមនុស្សជាច្រើនទេដែលអាចស្រមៃឃើញថានឹងមានរឿងអាក្រក់កើតឡើងចំពោះខ្លួន។ បុព្វជិតប្រូតេស្តង់ជនជាតិអាល្លឺម៉ង់លោក ម៉ាទីន ម័រលើ ក៏មិនបានជឿដូចគ្នាពីព្រោះតែ ហ៊ីត្លែរ មុនដំបូងមិនបានប៉ះពាល់វិហារប្រូតេស្តង់នោះទេ។ ក្រោយមកនៅពេលដែលត្រូវបានចាប់ដាក់ពន្ធនាគារ បុព្វជិតនោះបាននិយាយថា "ដំបូងពួកគេបានមករកអ្នកកាន់លិទ្ធិកុម្មុយនីស្ត ខ្ញុំមិនបាននិយាយអ្វីនោះទេពីព្រោះខ្ញុំមិនមែនជាកុម្មុយនីស្ត ។ បន្ទាប់មកពួកគេបានមករកជនជាតិជ្វីហ្វ ហើយខ្ញុំក៏មិននិយាយអ្វីដែរពីព្រោះខ្ញុំមិនមែនជាជនជាតិជ្វីហ្វ។ បន្ទាប់មកពួកគេមករកខ្ញុំ ហើយនៅពេលនោះគឺគ្មានសេសសល់នរណាម្នាក់ដែលអាចនិយាយការពារខ្ញុំនោះទេ"។

ហេតុការណ៍ដែលអាក្រក់បំផុតអាចកើតឡើងចំពោះយើងគ្រប់រូបទោះបីជាយើងព្យាយាមប្រាប់ខ្លួនឯងយ៉ាងណាក៏ដោយ។ យើងនៅមិនទាន់អាចមើលឃើញទីបញ្ចប់នៃវិបត្តិអន្តោប្រវេសន៍ដែលកំពុងកើតមានឡើងសព្វថ្ងៃនេះទេ ហើយក៏មិនអាចនិយាយបានដែរថាថ្ងៃណាមួយយើងនឹងមិនត្រូវផ្លាស់ទីកន្លែងហើយស្វែងរកផ្ទះថ្មីម្ដងទៀតឡើយ។ ប្រសិនបើអ្នកធ្លាប់ឆ្លងកាត់ម្ដងហើយអ្នកនឹងដឹងថាវាអាចកើតឡើងម្ដងទៀតបាន។

“

# HAR DU VARIT UTSATT FÖR NYNAZISTER?

” “

# HAVE YOU BEEN THREATENED BY NEO-NAZIS?

”



# "តើអ្នកត្រូវបានគំរាមកំហែងដោយណាហ្ស៊ីថ្មីដែរឬទេ ?"

កាលពី៣០ឆ្នាំមុន ខ្ញុំបានទទួលទូរស័ព្ទពីអ្នកកាសែតម្នាក់ដែលចង់ពិភាក្សាជាមួយខ្ញុំអំពីហូឡូខសន៍[៧៨] នៅលើកញ្ចក់ទូរទស្សន៍ជាមួយនឹងអតីតមេដឹកនាំណាហ្ស៊ីម្នាក់ ។ គេគឺជាអ្នកដែលមិនយល់ព្រមទទួលស្គាល់ថាហូឡូខសន៍ពិតជាបានកើតឡើងមែន ហើយទើបនឹងតែត្រូវបានដោះលែងពីពន្ធនាគារ ។ ខ្ញុំបានបដិសេធ ។ ខ្ញុំអាចនិយាយតែអំពីអ្វីដែលខ្ញុំបានឆ្លងកាត់ ខ្ញុំមិនអាចបញ្ចុះបញ្ចូលអ្នកដែលមិនជឿខ្ញុំទេ ។ នៅពេលដែលពួកគេប្រកែកថាគ្មាននរណាម្នាក់បានឃើញបន្ទប់ផ្សែងពុលពីខាងក្នុងនោះ ខ្ញុំបានត្រឹមតែយល់ស្របតែប៉ុណ្ណោះ ។ ពីព្រោះនេះគឺជាការពិត មិនមាននរណាម្នាក់ធ្លាប់ឃើញបន្ទប់ផ្សែងពុលពីខាងក្នុងនោះទេ ពីព្រោះគ្មាននរណាម្នាក់ដែលបានចូលទៅក្នុងបន្ទប់ផ្សែងពុលនោះហើយមានជីវិតចេញមកខាងក្រៅនោះទេ ។

វាគឺពិតជាមានការលំបាកក្នុងការផ្លាស់ប្តូរផ្នត់គំនិតរបស់ណាហ្ស៊ីនិយម ប៉ុន្តែអ្វីដែលសំខាន់នោះគឺការអប់រំយុវវ័យមុនពេលដែលពួកគេធ្លាក់ចូលទៅក្នុងមនោគមន៍វិជ្ជានៃការស្អប់ខ្ពើម ។ អប់រំអ្នកដែលចូលរួមជាមួយណាហ្ស៊ីព្រោះគិតថាគឺជាគំនិតមួយដែលសប្បាយ ។ តើយុវវ័យអាចទទួលយកអ្វីដែលបានកើតឡើងនៅហូឡូខសន៍មកដាក់ក្នុងបេះដូងរបស់ខ្លួនដែរឬទេ ? តើវាអាចរារាំងពួកគេមិនឱ្យចូលរួមជាមួយក្រុមណាហ្ស៊ីដែលទាក់ទាញពួកគេតាមរយៈវិធីផ្សេងៗដូចជា ចម្រៀងតន្ត្រី ស្រានិងដំណើរផ្សងព្រេងដែរឬទេ ?

[៧៨] គឺជាការធ្វើបាបឃោឃៅនិងអំពើប្រល័យពូជសាសន៍ទៅលើជនជាតិជ្វីហ្វចំនួន៦លាននាក់ដោយរបបណាហ្ស៊ីរបស់ហ៊ីត្លែរចាប់តាំងពីឆ្នាំ១៩៣៣រហូតដល់ចុងបញ្ចប់សង្គ្រាមលោកលើកទី២ ។ ហូឡូខសន៍គឺជាពាក្យដើមនៃភាសាក្រិកមានន័យថា "បូជាដោយភ្លើង" ឬ "បូជាភ្លើង" ។

ដើម្បីលើកជាឧទាហរណ៍ថាការអប់រំអ្នកដែលបានចូលរួមជាមួយណាហ្សុីយ៉ាងស្មោះស្ម័គ្រ ម្នាក់មានការលំបាកយ៉ាងដូចម្តេច ខ្ញុំនឹងប្រាប់អំពីរឿងរបស់ជូឌីត អ្នករស់រានមានជីវិតម្នាក់ដែលបានជួបជាមួយនឹងជនអនាមិកណាហ្សុីក្មេងខ្ចីម្នាក់ដែលបានដើរចែកខិត្តប័ណ្ណសរសេរថា "អូសឈ្វិច មិនដែលកើតឡើងនោះទេ" ។ ជូឌីត បានដើរទៅរកក្មេងម្នាក់នោះហើយសួរថា តើក្មេងម្នាក់នោះអាចដឹងបានដោយរបៀបណាពីព្រោះគេមានវ័យក្មេងណាស់នៅពេលដែលរឿងនោះបានកើតឡើង។ ណាហ្សុីក្មេងខ្ចីម្នាក់នោះឆ្លើយថាខ្លួនបានឮវាមកពីសាស្ត្រាចារ្យល្បីឈ្មោះម្នាក់។ ជូឌីត បានលាត់ដៃអាវរបស់ខ្លួនដើម្បីបង្ហាញលេខសាក់នៅលើដៃ **A-51792**។ ក្មេងណាហ្សុីម្នាក់នោះសើចហើយនិយាយថា ជូឌីត អាចធ្វើបែបនេះដោយខ្លួនឯងបាន។

ខ្ញុំបានជួបណាហ្សុីថ្មីនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ នៅពេលដែលគេត្រូវបានកាត់ទោសពីបទបរិហាកេរ្តិ៍។ បុរសម្នាក់នោះបានសរសេរសំបុត្រស្អប់ខ្ពើមផ្ញើទៅអ្នករស់រានមានជីវិតជាច្រើននាក់រួមទាំងខ្ញុំទៀតផង។ ខ្ញុំត្រូវបានតុលាការកោះហៅដើម្បីធ្វើជាសាក្សី ហើយបានស្នើឱ្យនិយាយអំពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់ខ្ញុំ។ បុរសម្នាក់នោះត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ ប៉ុន្តែសូម្បីតែនៅទីនោះក៏គេនៅតែបន្តផ្ញើសំបុត្រស្អប់ខ្ពើមនោះមកខ្ញុំដដែល។ ខ្ញុំបានប្រគល់សំបុត្រនោះឱ្យទៅប៉ូលីស។ អ្វីដែលកើតឡើងបន្ទាប់ខ្ញុំមិនបានដឹងនោះទេ។ នាយកសាលារៀននៅទីក្រុងតាប៊ី[៧៩] បានហៅខ្ញុំឱ្យទៅបង្រៀននៅទីនោះពីព្រោះតែមានក្មេងខូចៗដែលវាយតប់គ្នានិងបានគូររូបសញ្ញាណាហ្សុីនៅលើជញ្ជាំងសាលារៀន។ បន្ទាប់ពីការបង្រៀនរបស់ខ្ញុំដែលជារឿងធម្មតាដែលក្មេងប្រុសៗទាំងនោះមិនមកចូលរួម មានក្មេងស្រីមួយចំនួនបានមករកខ្ញុំហើយនិយាយអរគុណខ្ញុំ។ ក្មេងស្រីទាំងនោះគិតថាគឺពិត

[៧៩] គឺជាឈ្មោះទីក្រុងមួយនៅក្នុងប្រទេសស៊ុយអែត។



ជាមានសារសំខាន់ ខ្លាំងណាស់ក្នុងការស្តាប់អំពីរឿងរ៉ាវរបស់ខ្ញុំហើយឥឡូវនេះពួកគេនឹងមិនទៅលេងជាមួយក្មេងប្រុសទាំងនោះទៀតនោះទេ។ នៅពេលដែលក្មេងប្រុសទាំងនោះបានបាត់បង់ការគាំទ្រ សាលារៀនបានវិលត្រឡប់ទៅរកភាពស្ងប់ស្ងាត់វិញ ហើយរូបសញ្ញាណាហ្សុីក៏បាត់ទៅជាមួយដែរ។ ខ្ញុំបានទទួលរងការប្រមាថនិងសំបុត្រគំរាមកំហែងជាច្រើនឆ្នាំមកហើយ។ ជាធម្មតាខ្ញុំតែងតែ ប្រគល់សំបុត្រទាំងនោះទៅឱ្យប៉ូលីស។ សំបុត្រទាំងនោះមិនអាចបំភ័យខ្ញុំបានទេ។ គោលបំណងរបស់អ្នកសរសេរសំបុត្រទាំងនោះគឺគ្រាន់តែដើម្បីបង្កើតឱ្យមានភាពភ័យខ្លាចតែប៉ុណ្ណោះ។

"HATAR DU TYSKARNA?"

"DO YOU HATE THE GERMANS?"



# "តើអ្នកស្អប់ជនជាតិអាល្លឺម៉ង់ដែរឬទេ ?"

ក្រុមការងាររបស់យើងទើបតែត្រឡប់មកជំរំវិញបន្ទាប់ពីចេញទៅធ្វើការនៅក្រោមភ្លៀងដ៏ធំ មួយនៅតាមសំណង់បាក់បែក។ ស្បែកជើងគ្នាយើងមួយចំនួនមានសភាពចាស់និងដាច់រហែក។ នៅពេលនោះមានពាក្យចចាមអារ៉ាមថាមានកប៉ាល់ដឹកអីវ៉ាន់ថ្មីបានចូលមកដល់។ តើអ្នកណាអាចយកបានអីវ៉ាន់ថ្មីនោះ ? ឃ្លានហើយរងាជាមួយនឹងជើងដែលសើមនៅក្នុងស្បែកជើងដែលមានតែឈ្មោះ នោះខ្ញុំបានដើរទៅរកប្រធានជំរំ ហើយសួរថាតើខ្ញុំអាចបានស្បែកជើងថ្មីមួយគូដែរឬទេ។ ប្រធានជំរំបានសម្លឹងមើលមកខ្ញុំដោយទឹកមុខចំអកឡកឡឺយ ហើយទះកំភ្លៀងខាងឆ្វេងរបស់ខ្ញុំយ៉ាងខ្លាំងរហូតដល់ខ្ញុំហ៊ឹងស្លឹកត្រចៀក។ ខ្ញុំស្ទើរតែដួលទៅហើយនៅពេលដែលមួយកំភ្លៀង ក្រោយទៀតមកលើថ្ពាល់ស្តាំរបស់ខ្ញុំដែលជំនួសឱ្យខ្ញុំមានលំនឹងឡើងវិញ វាបានធ្វើឱ្យខ្ញុំដួលទៅលើដី។ ការឈឺចាប់ត្រូវបានគ្របដណ្តប់ដោយការស្អប់ខ្ពើម ខ្ញុំចង់ហក់ទៅរកប្រធានជំរំនោះហើយវាយគេម្តងហើយម្តងទៀត។ ប៉ុន្តែខ្ញុំមិនហ៊ាននោះទេ។ គេមានអំណាចជាងខ្ញុំ។

មកពីប្រទេសហុងគ្រី ខ្ញុំមានគោលដៅចំនួនពីរ នោះគឺស្អប់ជនជាតិអាល្លឺម៉ង់និងជនជាតិហុងគ្រី។ ជនជាតិអាល្លឺម៉ង់គឺជាអ្នកដែលធ្វើទារុណកម្មយើង ប៉ុន្តែជនជាតិហុងគ្រី គឺជាអ្នកដែលបានប្រគល់យើងឱ្យទៅឃាតករ។ បន្ទាប់ពីសង្គ្រាមបានបញ្ចប់ ខ្ញុំបានចំណាយអស់រយៈពេលជាច្រើនដើម្បីបញ្ឈប់ការស្អប់មួយនេះ។ គួរឱ្យចម្លែកដែលខ្ញុំស្អប់ជនជាតិហុងគ្រីយូរជាងពេលដែលខ្ញុំស្អប់ជនជាតិអាល្លឺម៉ង់។ រូបភាពនៃមួកក្រណាត់របស់ប៉ូលីសហុងគ្រីនឹងតាមលងបន្លាចនៅក្នុងសុបិនអាក្រក់របស់ខ្ញុំជានិច្ច។

ខ្ញុំអាចរួចផុតពីសុបិនអាក្រក់នេះបានដោយសារតែជនអន្តោប្រវេសន៍ជនជាតិហុងគ្រីម្នាក់ដែលខ្ញុំបានជួបកាលពីប៉ុន្មានឆ្នាំមុន។ គាត់បានប្រាប់ខ្ញុំថា គាត់បានកើតនៅភូមិតូចមួយនៅ ហុងគ្រី-ភូស្តា[៨០] ហើយគាត់មិនដែលបានឃើញជនជាតិជ្វីហ្វទេ រហូតទាល់តែគាត់បានមកដល់ប្រទេសស៊ុយអែត។ ប៉ុន្តែគាត់បានដឹងថាជនជាតិជ្វីហ្វ គឺត្រូវតែស្អប់ខ្ពើមព្រោះពួកគេបានធ្វើឱ្យព្រះយ៉េស៊ូស្លាប់។ គាត់បានរៀនអំពីរឿងនេះមុនគាត់ចេះអានអក្សរទៅទៀត។ គាត់រៀនអំពីរឿងនេះមកពីបុព្វជិតគ្រិស្តសាសនាម្នាក់នៅសាលារៀនរៀងរាល់ថ្ងៃអាទិត្យ។

ខ្ញុំបានសញ្ជឹងគិត ហើយទីបំផុតអាចមើលឃើញជ្រុងម្ខាងទៀតនៃកាក់។ ខ្ញុំចាប់ផ្តើមដឹងថា គឺមិនមែនជាប្រទេសជិតខាងរបស់យើងនៅស៊ីហ្គេតនោះទេដែលបាននាំយើងទៅរកទូរថភ្លើង ប៉ុន្តែគឺជាប៉ូលីសវ័យក្មេងទៅវិញទេដែលចិញ្ចឹមនិងបណ្តុះនូវគំនិតស្អប់ខ្ពើម។ អ្នកដទៃទៀតដែលរស់នៅស៊ីហ្គេត ប្រហែលជាមិនមានអារម្មណ៍រីករាយក្នុងការកម្ចាត់យើងចោលនោះទេ។ អ្នកជិតខាងរបស់យើងខ្លះបានព្យាយាមជួយយើង។ ជាងកាត់សក់ម្តាយរបស់ខ្ញុំបានប្រឆាំងនឹងការហាមឃាត់មិនឱ្យចូលមកក្នុងហ្គេតូដោយបានមកសួរសុខទុក្ខយើងនិងយកគ្រឿងទេសមួយចំនួនមកឱ្យ។

សេចក្តីស្អប់ខ្ពើមគឺជាប្រតិកម្មស្វ័យប្រវត្តិមួយនៅពេលដែលនរណាម្នាក់ធ្វើទង្វើមិនល្អអ្វីមួយទៅលើនរណាម្នាក់ផ្សេងទៀត។ ប៉ុន្តែយើងមិនអាចទទួលបានជោគជ័យជាមួយនឹងសេចក្តីស្អប់ខ្ពើមនោះទេ ពីព្រោះឥទ្ធិពលរបស់វាអាចវាយបកត្រឡប់មកវិញបាន។ សេចក្តីស្អប់ខ្ពើមមិនបានប៉ះពាល់ដល់អ្នកដែលត្រូវគេស្អប់នោះទេ ប៉ុន្តែអ្នកដែលស្អប់គេទៅវិញទេដែលមានអារម្មណ៍មិនល្អ។ នេះបង្កឱ្យមានអារម្មណ៍សងសឹកគ្នាទៅវិញទៅមកហើយ

[៨០] មានឈ្មោះជាភាសាអង់គ្លេសថា **Hungry Puszta** (ហុងគ្រី ភូស្តា) គឺជាវាលស្មៅដ៏ធំមួយនៅអ៊ឺរ៉ុបដែលមានសត្វព្រៃរបស់ប្រទេសហុងគ្រីរស់នៅ តំបន់នោះត្រូវបានដាក់បញ្ចូលជាបេតិកភណ្ឌពិភពលោកនៅក្នុងឆ្នាំ១៩៩៩។



នៅពេលនោះអ្នកដែលស្អប់គេនឹងត្រូវបានគេស្អប់វិញហើយវានឹងក្លាយទៅជាវដ្តនៃការស្អប់ខ្ពើមដែលគ្មានទីបញ្ចប់។ យើងត្រូវការពេលវេលាមុនពេលដែលយើងអាចលះបង់សេចក្តីស្អប់ខ្ពើមបាន យើងត្រូវសញ្ជឹងគិតអំពីអ្វីដែលបានកើតឡើងដើម្បីបញ្ចប់ការស្អប់ខ្ពើមនោះ។ បន្ទាប់មកទើបយើងអាចរស់នៅក្នុងជីវិតមួយដែលគ្មានភាពជូរចត់បាន។ នេះគឺមិនមែនជាសំណួរអំពីការអត់ឱននោះទេ។ ខ្ញុំមិនអាចអត់ទោសជំនួសអ្នកដែលត្រូវបានគេសម្លាប់នោះទេ ដូចដែលអ្នកប្រមាញ់ណាហ្ស៊ីដ៏ល្បីល្បាញលោក សាយម៉ុន វៀសេនសាល បាននិយាយដូច្នេះដែរ។ ប៉ុន្តែយើងអាចរៀនរស់នៅជាមួយអ្វីដែលកើតឡើងបាន។ យើងអាចរស់នៅជាមួយអតីតសត្រូវ ហើយទទួលស្គាល់គ្នាទៅវិញទៅមក។ យើងគួរយល់ដឹងឱ្យបានច្បាស់ថា យើងនឹងមិនអាចដឹងបានទេថាខ្លួនឯងនឹងមានប្រតិកម្មយ៉ាងណាក្នុងស្ថានភាពដែលងាយធ្វើឱ្យឈឺចាប់។ ពេលដែលខ្ញុំនៅក្នុងជំរំ ខ្ញុំស្អប់ជនជាតិអាល្លឺម៉ង់ទាំងអស់ ខ្ញុំមានអារម្មណ៍សងសឹក។ ប្រសិនបើខ្ញុំមានឱកាសខ្ញុំប្រហែលអាចនឹងធ្វើការសងសឹក។ ប៉ុន្តែបន្ទាប់ពីការរំដោះ ខ្ញុំនិងអ្នកដទៃទៀតជាច្រើនបានយល់ថាការសងសឹកនឹងធ្វើឱ្យយើងមានកម្រិតស្មើគ្នាទៅនឹងឃាតករ។ បន្ទាប់ពីការរំដោះនៅបែលជិន-បឺសិន ទាហានអង់គ្លេសបានប្រមូលអតីតអ្នកយាមរបស់យើងដាក់នៅលើឡានហើយបានបើកជុំវិញជាមួយពាក្យប្រកាសថា "នៅទីនេះមានឃាតកររបស់អ្នកៗ អាចធ្វើតាមចិត្តរបស់អ្នកបាននិងធ្វើការសងសឹក" ។ មិនមានមនុស្សជាច្រើនទេដែលធ្វើដូច្នេះ។ ភាគច្រើនគឺគ្រាន់តែដើរចេញឆ្ងាយហើយសប្បាយចិត្តដែលដឹងថាអ្នកយាមទាំងនោះមិនអាចគ្រប់គ្រងលើយើងទៀតនោះទេ។

សម្រាប់យើងទាំងអស់គ្នាការសងសឹកនោះគឺ យើងដែលត្រូវបានសន្មតថានឹងត្រូវសម្លាប់ចោល នៅតែបន្តរស់រានមានជីវិតនិងមានក្រុមគ្រួសារថ្មី។ ការសងសឹករបស់យើង គឺណាហ្ស៊ីនាពេលអតីតកាលបាន

បាត់បង់ទៅហើយ។ សព្វថ្ងៃនេះកូនចៅរបស់ពួកគេកាន់តែច្រើនបានស្តាប់អំពីរឿងរ៉ាវរបស់យើងហើយក៏កំពុងតែធ្វើសកម្មភាពផ្សេងៗដើម្បីឱ្យប្រាកដថាហូឡូខសន៍[៨១] នឹងមិនកើតឡើងម្តងទៀត។

សព្វថ្ងៃនេះខ្ញុំមានមិត្តភក្តិជាច្រើនដែលជាជនជាតិអាល្លឺម៉ង់ និងជនជាតិហុងគ្រីដែលភាគច្រើនជាកូនៗរបស់ជនល្មើសអ្នកទាំងនោះមានគោលដៅដូចខ្ញុំដែរ។

ជាអកុសល ជួនកាលខ្ញុំនៅតែជួបមនុស្សមួយចំនួនដែលជាថ្មីម្តងទៀតបានជឿងប់ងល់ទៅលើមនោគមន៍វិជ្ជានៃការស្អប់ខ្ពើម។ អ្នកទាំងនោះមិនស្តាប់រឿងរ៉ាវរបស់ខ្ញុំនោះទេ ពួកគេគ្រាន់តែនិយាយឡើងវិញនូវឃ្លាដែលពួកគេព្យាយាមផ្សព្វផ្សាយនៅក្នុងចំណោមមនុស្សវ័យក្មេង។ ក្រុមណាហ្ស៊ីថ្មីទាំងនេះត្រូវតែបំបែកចេញឱ្យឆ្ងាយដើម្បីបង្ការកុំឱ្យមានអ្នកចូលរួមកាន់តែច្រើនឡើង។

នៅពេលខ្លះមានមនុស្សមួយចំនួនដែលនៅក្នុងរង្វង់អ្នកស្គាល់គ្នាបាននិយាយដោយមានបុរេវិនិច្ឆ័យអំពីរឿងដែលបានកើតឡើង។ នៅពេលនោះខ្ញុំពិតជាចង់សួរថាតើពួកគេសំអាងលើអ្វី? ខ្ញុំចង់ឱ្យអ្នកទាំងនោះពិនិត្យពិច័យលើមតិរបស់ខ្លួនឯងនិងអ្នកដទៃឡើងវិញនិងធ្វើការវិនិច្ឆ័យដោយខ្លួនឯងម្តងទៀតអំពីការពិត។ ខ្ញុំបានចាប់ផ្តើមការពិភាក្សាដែលមិនអាចមានលទ្ធផលភ្លាមៗប៉ុន្តែប្រសិនបើមានការលើកឡើងជាច្រើនដងខ្ញុំអាចសង្ឃឹមបានថានឹងមានការផ្លាស់ប្តូរមួយ។

[៨១] គឺជាការធ្វើបាបឃោរឃៅនិងអំពើប្រល័យពូជសាសន៍ទៅលើជនជាតិជ្វីហ្វចំនួន៦លាននាក់ដោយរបបណាហ្ស៊ីរបស់ហ៊ីត្លែរចាប់តាំងពីឆ្នាំ១៩៣៣រហូតដល់ចុងបញ្ចប់សង្គ្រាមលោកលើកទី២។ ហូឡូខសន៍គឺជាពាក្យដើមនៃភាសាក្រិកមានន័យថា "បូជាដោយភ្លើង" ឬ "បូជាភ្លើង" ។



“

# HAR DU TRÄFFAT EN FÖRÖVARE?

” “

# HAVE YOU MET A PERPETRATOR?

”

# "តើអ្នកធ្លាប់បានជួបជាមួយជនល្មើសដែរឬទេ ?"

បន្ទាប់ពីសង្គ្រាមបានបញ្ចប់ទៅភាពស្អប់ខ្ពើមរបស់ខ្ញុំចំពោះជនជាតិអាល្លឺម៉ង់នៅតែមាន។ ខ្ញុំបានចំណាយពេលអស់ជាច្រើនដើម្បីលះបង់វាចោល។ អ្វីដែលនៅតែមាននោះគឺភាពភ័យខ្លាចដោយមិនដឹងខ្លួន។ នៅក្នុងរយៈពេលពីរទៅបីឆ្នាំបន្ទាប់ពីសង្គ្រាមបានបញ្ចប់ ខ្ញុំបានធ្វើដំណើរតាមរថភ្លើងនៅពេលយប់ដែលធ្វើដំណើរឆ្លងកាត់ប្រទេសអាល្លឺម៉ង់ ហើយក៏បានភ្ញាក់ដឹងខ្លួនដោយបែកញើសជោគពីសុបិនអាក្រក់មួយថាជនជាតិអាល្លឺម៉ង់ហៀបនឹងព្យួរកខ្ញុំ។ ខ្ញុំភ្ញាក់ឡើងដោយភ័យស្លន់ស្លោ។ ខ្ញុំចំណាយពេលមួយភ្លែតទើបដឹងថាវាគឺគ្រាន់តែជាសុបិនមួយដែលបណ្តាលមកពីរូបដេកយប់ដែលព័ទ្ធរុំករបស់ខ្ញុំ ។

មុនដំបូងខ្ញុំបានបដិសេធមិននិយាយភាសាអាល្លឺម៉ង់ឬក៏ធ្វើដំណើរទៅប្រទេសអាល្លឺម៉ង់នោះទេ។ ក្រោយមកនៅពេលដែលខ្ញុំបើកក្រុមហ៊ុនតូចមួយ ខ្ញុំគ្មានជម្រើសច្រើនទេហើយកាន់តែមានភាពពិបាកថែមទៀត។ ខ្ញុំបានសង្កេតមើលទៅមនុស្សគ្រប់គ្នាដែលមានអាយុជំណាលខ្ញុំឬចាស់ជាងខ្ញុំ ហើយក៏បានចាត់ទុកអ្នកទាំងនោះថាគឺជាជនល្មើស។ ខ្ញុំមិនដែលអនុញ្ញាតឱ្យខ្លួនឯងចូលរួម នៅក្នុងសន្ទនាណាដែលមានលក្ខណៈជាឯកជនជាមួយអ្នកទាំងនោះទេ។ បែបនេះគឺជាការដាក់ទោសដោយមិនទាន់បានកាត់ក្តី។ ខ្ញុំបានចំណាយអស់រយៈពេលជាច្រើនឆ្នាំមុនពេលដែលខ្ញុំយល់ថា នេះគឺជាការរើសអើងដែលខ្ញុំយល់ឃើញថាជនជាតិអាល្លឺម៉ង់ទាំងអស់គឺជាជនល្មើស។ ប៉ុន្តែទីបញ្ចប់ ខ្ញុំបានដោះលែងខ្លួនឯងអំពីការសង្ស័យ និងការស្អប់ខ្ពើមទាំងនោះ។ ច្រើនឆ្នាំកន្លងផុតទៅ ខ្ញុំចាប់ផ្តើមទទួលការអញ្ជើញទៅកម្មវិធីជាច្រើននៅក្នុងប្រទេសអាល្លឺម៉ង់ ហើយក៏ឃើញថាគឺកាន់តែមានភាពងាយស្រួលក្នុងការទាក់ទងជាមួយជនជាតិអាល្លឺម៉ង់។ ខ្ញុំថែមទាំងបានធ្វើមិត្តភក្តិជាមួយពួកគេទៀតផង។ ក្នុងចំណោមនោះ គឺមានកូនប្រុសរបស់ជនល្មើសឈ្មោះថា ម៉ាទីន បូម៉ាន់ ដែលជាដៃស្តាំរបស់ហ៊ីត្លែរ។ មិត្តម្នាក់នោះក៏មានឈ្មោះថា ម៉ាទីនដែរ។ ដូចជាយុវវ័យដ៏ទៃទៀតដែរ គាត់ក៏ធ្លាប់ជាសមាជិករបស់ ហ៊ីត្លែរជូយេន៍ ហើយនៅពេលដែលសង្គ្រាមបានបញ្ចប់គាត់កំពុងតែធ្វើការប្រយុទ្ធនៅក្នុងសមរភូមិនៅឡើយ។គាត់មានភាពលំបាកវេទនាណាស់នៅពេលដែលហ៊ីត្លែរចុះចាញ់សង្គ្រាម។ គាត់មានគម្រោងធ្វើអត្តឃាត ហើយក៏ដើរចូលទៅក្នុងព្រៃជាមួយនឹងកាំភ្លើងមួយដើម និងដោយគ្មានអាហារបរិភោគអស់រយៈពេលជាច្រើនសប្តាហ៍។ ប៉ុន្តែសេចក្តីស្រេកឃ្លានបានធ្វើឱ្យគាត់សម្រេចចិត្តគោះទ្វារផ្ទះស្បូវមួយ។ នោះគឺជាផ្ទះរបស់បុព្វជិតគ្រិស្តសាសនាម្នាក់។ មិត្តរបស់ខ្ញុំបានប្រាប់ឈ្មោះផ្សេងរបស់ខ្លួនហើយបានសុំអាហារដើម្បីបរិភោគ។ នៅពេលដែលបុព្វជិតគ្រិស្តសាសនាម្នាក់នោះសួរនាំ ម៉ាទីនបានឆ្លើយប្រាប់ថាឪពុករបស់គាត់បានស្លាប់នៅក្នុងសមរភូមិ ចំណែកឯម្តាយរបស់គាត់បានបាត់ខ្លួន។ បុព្វជិតនោះមានចិត្តអាណិតអាសូរគាត់ ហើយក៏អនុញ្ញាតឱ្យគាត់ស្នាក់នៅទីនោះអស់រយៈពេលជាច្រើនឆ្នាំ។ នៅពេលនោះហើយគឺជាលើកដំបូងដែលគាត់បានស្គាល់អំពីសេចក្តីស្រឡាញ់ ហើយវាបានដក់ជាប់នៅក្នុងអារម្មណ៍របស់គាត់ជារៀងរហូត។ គាត់បានដឹងពីភាពខុសគ្នារវាងជីវិតពីរផ្សេងគ្នាដែលគាត់បានរស់នៅ ហើយក៏សម្រេចចិត្តចែកចាយក្តីស្រលាញ់ទៅអ្នកដទៃទៀត។

ម៉ាទីនមិនមែនជាមនុស្សតែម្នាក់ដែលបានដកខ្លួនចេញឆ្ងាយចេញពីអតីតកាលរបស់ខ្លួននោះទេ។ ខ្ញុំបានជួបជនជាតិអាល្លឺម៉ង់ជាច្រើននាក់ដែលខុសប្លែកពីជំនាន់ឪពុកម្តាយរបស់ពួកគេ ហើយអ្នកទាំងនោះមានគោលបំណងក្នុងការកែប្រែកំហុសខុសឆ្គងរបស់ឪពុកម្តាយខ្លួន។

ថៅគីម គឺជាអ្នកជំនួញវ័យក្មេងម្នាក់ដែលរឿងរ៉ាវជីវិតរបស់គាត់បានធ្វើឱ្យខ្ញុំរំជួលចិត្តយ៉ាងខ្លាំង។ គាត់គ្មានឪពុកនោះទេហើយបានជឿជាក់ថាឪពុករបស់គាត់បានស្លាប់នៅក្នុងសមរភូមិដូចជាអ្នកដ៏ទៃទៀតដែលនៅក្នុងជំនាន់នោះដែរ។ ម្តាយរបស់គាត់បានរៀបការជាមួយអតីតទាហានម្នាក់ ហើយមិនយូរប៉ុន្មានក៏មានកូនទៀតផង។ គាត់ធំធាត់ឡើងនៅក្នុងមជ្ឈដ្ឋានដែលពោរពេញទៅដោយសេចក្តីស្រឡាញ់ប៉ុន្តែត្រូវបានលាបពណ៌ដោយគំនិតណាហ្ស៊ីនិយមដែលនៅតែមានឥទ្ធិពលនៅក្នុងគ្រួសាររបស់គាត់ជានិច្ច។ គាត់ចងចាំពាក្យជីដូនរបស់គាត់ដែលបាននិយាយថា "ទោះបីជាយ៉ាងណាក៏ដោយកុំរៀបការជាមួយជនជាតិជ្វីហ្វ"។ គាត់មិនអាចចាំបានទេថានៅពេលណាដែលគាត់បានឮជាលើកដំបូងថាឪពុករបស់គាត់គឺជាជនល្មើស។ គាត់បានសួរជីដូនរបស់គាត់ដែលជាអ្នកបញ្ជាក់អំពីទំនាក់ទំនងរបស់ឪពុកគាត់ជាមួយណាហ្ស៊ី ដែលនៅពេលនោះគឺជាតម្រូវការសម្រាប់ជនជាតិអាល្លឺម៉ង់ទាំងអស់។ ប៉ុន្តែជីដូនរបស់គាត់មិនចង់សារភាពថាឪពុករបស់គាត់បានប្រព្រឹត្តបទល្មើសណាមួយនោះឡើយ។ នៅពេលធំដឹងក្តីឡើងគាត់បានស្តាប់ឮការចោទប្រកាន់ជាញឹកញាប់ថាឪពុករបស់គាត់គឺជាឧក្រិដ្ឋជនណាហ្ស៊ីម្នាក់ដែលបានរត់គេចខ្លួនចេញពីសំណាញ់យុត្តិធម៌បន្ទាប់ពីសង្គ្រាមបានបញ្ចប់។ គាត់បានគិតថានោះគឺគ្រាន់តែជាការកុហកហើយបានជួលមេធាវីម្នាក់ដើម្បីបង្ហាញភស្តុតាងឱ្យច្បាស់លាស់។ មេធាវីបានស៊ើបអង្កេត ហើយអ្វីដែលធ្វើឱ្យគាត់អស់សង្ឃឹមខ្លាំង គឺនៅពេលដែលមេធាវីបានបញ្ជាក់ថាការចោទប្រកាន់នោះគឺជាការពិត។ ឪពុករបស់គាត់ធ្លាប់ជាមន្ត្រីកាន់តំណែងធំម្នាក់ដែលទទួលមើលការខុសត្រូវចំពោះការសម្លាប់ជនជាតិជ្វីហ្វនៅព្រំប្រទល់នៅប្រទេសអ៊ុយក្រែន។ នៅពេលសង្គ្រាមបានបញ្ចប់ គាត់បានជំនួយពីវិហារកាតូលិកមួយហើយបានរត់គេចខ្លួនទៅប្រទេសអ៊ីតាលីដើម្បីរង់ចាំទិដ្ឋាការចូលទៅក្នុងប្រទេស



អាហ្សង់ទីន[៨២]។ នៅពេលដែលគាត់បានដឹងអំពីរឿងទាំងអស់នេះ គាត់បានកាត់ផ្តាច់ទំនាក់ទំនងទាំងអស់ជាមួយក្រុមគ្រួសារ ហើយបានប្តេជ្ញាចិត្តប្រើជីវិតរបស់គាត់ដើម្បីប្រយុទ្ធប្រឆាំងនឹងណាហ្ស៊ីនិយម។

ខ្ញុំបានជួបបុរសវ័យក្មេងម្នាក់ឈ្មោះថាហ្វ្រាយរីជ នៅពេលដែលខ្ញុំធ្វើដំណើរទៅសន្និសីទស្តីអំពីសិទ្ធិមនុស្សមួយ។ អំឡុងពេលដែលយើងកំពុងសន្ទនាគ្នា គឺបានបង្ហាញយ៉ាងច្បាស់ថាគាត់ធ្លាប់ជាសមាជិកម្នាក់របស់ហ៊ីត្លែរជូយេន៍។ នៅពេលនេះគាត់កំពុងព្យាយាមស្វែងយល់អំពីអតីតកាលរបស់ខ្លួនដើម្បីទទួលបានចម្លើយឱ្យច្បាស់ពីមូលហេតុដែលធ្វើឱ្យគាត់មិនដែលគិតអំពីខ្លួនឯង ហើយតែងតែស្តាប់បង្គាប់និងធ្វើតាមអ្វីដែលគេបានបញ្ជា។ គាត់បានសួរអំពីជីវប្រវត្តិរបស់ខ្ញុំហើយមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលដែលគាត់ដឹងថាខ្ញុំធ្លាប់នៅក្នុងជំរំប្រមូលផ្តុំ។ ខ្ញុំមិនចង់ដឹងបន្ថែមអំពីអតីតកាលរបស់គាត់ថា តើគាត់ធ្លាប់ទៅទីណា? ហើយតើគាត់ធ្លាប់បានធ្វើអ្វីខ្លះនោះទេ។ បច្ចុប្បន្នគាត់បានចូលរួមធ្វើកិច្ចការដូចជាខ្ញុំដែរ ដូចនេះអតីតកាលមិនសំខាន់នោះទេ។ លុះត្រាណាតែអតីតសត្រូវអាចផ្សះផ្សានិងធ្វើការរួមគ្នាសម្រាប់គោលដៅតែមួយ ទើបយើងអាចសង្ឃឹមថានឹងមានអនាគតមួយដ៏ល្អប្រសើរដែលជាអនាគតនៅក្នុងសង្គមប្រកបដោយភាពថ្លៃថ្នូរនិងជីវិតដែលគ្មានភាពស្អប់ខ្ពើមឬការសងសឹក។

[៨២] មានឈ្មោះជាផ្លូវការថាសាធារណរដ្ឋអាហ្សង់ទីនគឺជាប្រទេសមួយដែលមានទីតាំងស្ថិតនៅភាគខាងត្បូងនៃទ្វីបអាមេរិកខាងត្បូង។

“ KAN DU FÖRLÅTA? ” “ ARE YOU ABLE TO FORGIVE? ”



## "តើអ្នកអាចអត់ឱនទោសបានដែរឬទេ ?"

នេះគឺជាសំណួរមួយដែលខ្ញុំតែងតែគិតដល់រហូតទាល់តែខ្ញុំដឹងថា ខ្ញុំមិនចាំបាច់គិតអំពីវានោះទេ។ អ្វីដែលកើតឡើងហើយមិនអាចកែប្រែបានទេ។ ពេលវេលាក៏មិនអាចវិលត្រឡប់ក្រោយបានដែរ ចំណែកឯអ្នកដែលបានស្លាប់ហើយក៏មិនអាចមានជីវិតវិញបានដែរ។ ថ្ងៃនេះគឺសម្រាប់អនាគតកាល។ អ្វីដែលយើងអាចធ្វើថ្ងៃនេះបាន គឺធ្វើកិច្ចការណាដែលមិនធ្វើឱ្យព្រឹត្តិការណ៍នេះកើតឡើងបានម្តងទៀត។

“

# HAR DU REST TILLBAKA TILL DIN HEMSTAD?

” “

# HAVE YOU TRAVELLED BACK TO YOUR HOMETOWN?

”



## "តើអ្នកបានធ្វើដំណើរត្រឡប់ទៅស្រុកកំណើតវិញដែរឬទេ ?"

ខ្ញុំត្រូវស៊ូទ្រាំជាមួយនឹងសុបិនអាក្រក់របស់ខ្ញុំអស់រយៈពេលយ៉ាងយូរអង្វែង ។ នៅពេលដែលខ្ញុំរៀបការហើយមានកូន ខ្ញុំបានយល់សប្តិថាខ្ញុំកំពុងតែនៅស៊ីហ្គេតឯក្រុមគ្រួសាររបស់ខ្ញុំនៅទីក្រុងស្តុកខុល ។ ខ្ញុំគិតថាខ្ញុំនឹងមិនហ៊ានត្រឡប់ទៅទីនោះម្តងទៀតទេ ។ ប៉ុន្តែពេលវេលាបានកន្លងផុតទៅហើយនៅពេលដែលកូនៗរបស់ខ្ញុំបានធំដឹងក្តី ពួកគេចាប់ផ្តើមសួរសំណួរជាច្រើននៅពេលដែលបានដឹងអំពី រឿងរ៉ាវដែលកើតឡើងមកលើគ្រួសាររបស់យើង ។ យ៉ាងណាមិញ កូនៗរបស់ខ្ញុំមិនមានជីដូនជីតា អ៊ំ មីង ឬគ្រួសារដែលអាចចំណាយពេលវេលាជាមួយនៅពេលវិសម្សកាលដូចជាមិត្តរួមថ្នាក់ដ៏ទៃទៀតរបស់ខ្លួននោះទេ ។ ពួកគេក៏មិនមានថ្ងៃឈប់សម្រាកដែលគ្រួសារទាំងមូលបានជួបជុំគ្នាដែរ ។ នៅពេលដែលកូនៗរបស់ខ្ញុំឈានចូលវ័យជំទង់ ខ្ញុំបានសម្រេចចិត្តថាយើងនឹងធ្វើដំណើរទៅស៊ីហ្គេតម្តងទៀត ។ ធ្វើបែបនេះពួកគេអាចនឹងមានអារម្មណ៍ជិតស្និទ្ធជាមួយនឹងដើមកំណើតរបស់ខ្លួនហើយអាចយល់ដឹងទាំងអស់គ្នាអំពីស្ថានភាពរបស់យើង ។

នៅពេលដែលធ្វើដំណើរ គឺពិតជាមានភាពពិបាកខ្លាំងណាស់ក្នុងការប្រាប់កូនៗរបស់ខ្ញុំអំពីសមាជិកគ្រួសារដែលយើងបានបាត់បង់ ។ ខ្ញុំមិនចង់ឱ្យពួកគេឃើញថាខ្ញុំពិបាកចិត្តនោះទេ ។ ដូច្នេះហើយទើបខ្ញុំនិយាយហាក់បីដូចជាខ្ញុំជាអ្នកទេសចរណ៍ម្នាក់ដែលមកធ្វើដំណើរកំសាន្តនៅបរទេស ។ ខ្ញុំមិនបានអនុញ្ញាតអោយខ្លួនឯងមានអារម្មណ៍អ្វីទាំងអស់ ។ ខ្ញុំមិនទាន់យល់ច្បាស់ថាការរៀបរាប់អំពីការពិតផ្តល់ចំណេះដឹងតែផ្នែកបញ្ញាដែលអាចជ្រាបដល់ត្រឹមតែស្មារតីរបស់មនុស្សម្នាក់ៗតែប៉ុណ្ណោះ ។

សម្រាប់ការយល់ដឹងច្បាស់ដោយអារម្មណ៍រឿងរ៉ាវទាំងនោះត្រូវតែជ្រាបឱ្យដល់បេះដូងរបស់មនុស្សម្នាក់ៗ។ កូនៗរបស់ខ្ញុំបានចម្លើយសម្រាប់សំណួររបស់ខ្លួន ប៉ុន្តែខ្ញុំមិនបានដឹងអំពីអ្វីដែលពួកគេបានគិតនោះទេ។ ខ្ញុំគ្មានបទពិសោធន៍ពិតប្រាកដអំពីការទៅលេងផ្ទះកុមារភាពរបស់ខ្លួននោះទេ។ ហើយនោះគឺជាមូលហេតុដែលខ្ញុំបានសម្រេចចិត្តធ្វើដំណើរទៅទីនោះម្តងទៀត។ ដើម្បីធ្វើធម្មយាត្រាជាមួយប្អូនស្រីខ្ញុំនិងទៅទស្សនាកន្លែងទាំងអស់ដែលមានសារសំខាន់ចំពោះយើងដើម្បីឱ្យអារម្មណ៍ទាំងនោះអោបក្រសោបយើងហើយធ្វើឱ្យយើងយំចេញមកក្រៅ។ នៅរដូវក្តៅបន្ទាប់យើងក៏បានចេញដំណើរ។ ដំណើរកំសាន្តលើកដំបូងរបស់យើងគឺទៅផ្នែកកណ្តាលនៃទីក្រុងដែលឧទ្យានត្រូវបានជំនួសទៅដោយហាងទំនិញជាច្រើន។ នេះហាក់បីដូចជាការចូលរោងភាពយន្តដើម្បីមើលការសម្តែងដែលខ្ញុំធ្លាប់បានឃើញម្តងរួចទៅហើយ។ ទេសភាពគឺនៅដដែលប៉ុន្តែតួអង្គទាំងអស់ត្រូវបានផ្លាស់ប្តូរ។ ឆាកតន្ត្រីនៅក្នុងឧទ្យាននៅតែមានប៉ុន្តែត្រូវបានកសាងថ្មី។ ផ្លាកនៅខាងក្រៅហាងទំនិញត្រូវបានផ្លាស់ប្តូរ។ ជំនួសទៅដោយឈ្មោះរបស់ជនជាតិជ្វីហ្វ ឥឡូវនេះគឺពោរពេញទៅដោយឈ្មោះជនជាតិរូម៉ានី។ ខ្ញុំបានដើរចូលទៅក្នុងហាងមួយដែលពីមុនធ្លាប់ជាកម្មសិទ្ធិរបស់ពូខ្ញុំ។ នៅពេលនេះវាគឺគ្រប់គ្រងដោយម្ចាស់ដែលខ្ញុំមិនស្គាល់និងលក់ក្រណាត់ដូចដែលខ្ញុំធ្លាប់បានជ្រើសរើសនៅក្នុងហាងរបស់ពូខ្ញុំ។ ខ្ញុំដើរជុំវិញទីក្រុងហើយបានឃើញមីងរបស់ខ្ញុំនៅជ្រុងម្ខាងនៃផ្លូវប៉ុន្តែពេលខ្ញុំដើរទៅរកគាត់ៗគឺជាមនុស្សផ្សេងទៅវិញទេ។

ផ្ទះចាស់របស់យើងនៅដដែល ប៉ុន្តែម្ចាស់ផ្ទះបានមើលមកយើងដោយសង្ស័យនៅពេលដែលយើងនិយាយថាធ្លាប់រស់នៅទីនេះក្នុងអំឡុងពេលកុមារភាពរបស់យើង។ ពួកគេភ័យខ្លាចថាយើងចង់យកផ្ទះវិញប៉ុន្តែពួកគេនៅតែអនុញ្ញាតឱ្យយើងចូលទៅក្នុងនិងដើរមើលជុំវិញ។ នៅខាងក្នុងខ្ញុំមិនបានឃើញអ្វីដែលនៅចំពីមុខខ្ញុំនោះទេ។ ផ្ទុយទៅវិញខ្ញុំបានឃើញបន្ទប់គេងរបស់ឪពុកម្តាយខ្ញុំដូចដែលនៅពេលនោះ។ នៅក្នុងបន្ទប់របស់ខ្ញុំៗបានឃើញវត្ថុដែលខ្ញុំស្រឡាញ់ជាងគេ គឺព្យាណូនិងសៀវភៅ។ ខ្ញុំស្ទើរតែអាចឮសម្លេងឆ្កែរបស់យើងព្រុសនៅខាងក្រៅទីធ្លា។ លីវីនិងខ្ញុំបានស្រក់ទឹកភ្នែកជាច្រើន។ យើងប្រៀបបានដូចជាកុមារដែលបានចាកចេញពីផ្ទះដោយគ្មានការអនុញ្ញាត ហើយឥឡូវនេះគឺកំពុងតែភ្លក់រសជាតិនៃផលវិបាកបន្ទាប់ពីនោះ។

ការធ្វើដំណើរនេះនាំមកនូវផលវិជ្ជមានជាច្រើន។ សុបិនអាក្រក់របស់ខ្ញុំបានកាត់បន្ថយ។ ទោះបីជាសុបិនអាក្រក់ទាំងនោះមិនបានបាត់ទៅណាប៉ុន្តែជារឿយៗខ្ញុំឈប់ភ្ញាក់ឡើងដោយបែកញើសជោគខ្លួននិងជាមួយអារម្មណ៍ថាកូនរបស់ខ្ញុំកំពុងនៅប្រទេសស៊ុយអែតហើយខ្ញុំនៅឆ្ងាយពីពួកគេនិងមិនអាចឃើញពួកគេម្តងទៀតទេ។ នេះធ្វើឱ្យខ្ញុំយល់ថា មនុស្សគឺត្រូវតែប្រឈមមុខនឹងភាពភ័យខ្លាច។ មានតែបែបនោះទេទើបយើងអាចយកឈ្នះភាពភ័យខ្លាចរបស់ខ្លួនបាន។

“

# HUR OFTA TÄNK-ER DU PÅ TIDEN I LÄGRET?

” “

# HOW OFTEN DO YOU THINK ABOUT YOUR TIME IN THE CAMPS?

”



# "តើអ្នកបានគិតអំពីពេលវេលានៅក្នុងជំរំជាញឹកញាប់ដែរឬទេ ?"

ខ្ញុំបានបង្រៀនអំពីពេលដែលខ្ញុំនៅតាមជំរំផ្សេងៗគ្នាស្ទើរតែជារៀងរាល់ថ្ងៃចាប់តាំងពីអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ហើយរាល់ពេលដែលខ្ញុំនិយាយអំពីវា ខ្ញុំមានអារម្មណ៍ថាធូរចិត្ត។ ទោះបីជាពិបាកខ្លាំងប៉ុន្តែវាបាននាំទៅរកអ្វីដែលល្អនិងបានក្លាយទៅជាវិធីមួយសម្រាប់ការជាសះស្បើយអំពីការប៉ះទង្គិចផ្លូវចិត្តរបស់ខ្ញុំ។ អ្នករស់រានមានជីវិតភាគច្រើនមានការពិបាកក្នុងការនិយាយអំពីអ្វីដែលបានកើតឡើងចំពោះខ្លួន។ ដូច្នេះហើយវាបានក្លាយទៅជាសេចក្តីឈឺចាប់មួយដែលមិនអាចប្រែប្រួលបាន។ ពីព្រោះតែខ្ញុំធ្វើការជារៀងរាល់ថ្ងៃដោយនិយាយអំពីវានិងសរសេរសៀវភៅអំពីវាៗមិនមានតទៅទៀតទេនៅពេលដែលខ្ញុំឈប់ធ្វើការ។ សេចក្តីឈឺចាប់ទាំងនោះមិនមានវត្តមាននៅក្នុងស្មារតីរបស់ខ្ញុំទៀតនោះទេ ទោះបីជានៅតែកប់នៅក្នុងដួងចិត្តរបស់ខ្ញុំហើយអាចលេចចេញមកក្រៅម្តងទៀតគ្រប់ពេលណាក៏ដោយ។

ប្រសិនបើខ្ញុំកំពុងតែដើរតាមផ្លូវហើយឮសំឡេងឆ្កែព្រុសនៅពីក្រោយខ្ញុំៗនឹងមានអារម្មណ៍ថាខ្លួនឯងបានវិលត្រលប់ទៅជំរំវិញភ្លាមៗដែលមានក្រុមក្មេងស្រីដើរជាប្រាំជួរនៅតាមផ្លូវទៅធ្វើការងារ និងមានកងការពារណាហ្ស៊ីដើរពីខាងក្រោយជាមួយសត្វឆ្កែ។ ប្រសិនបើមាននរណាម្នាក់ដួលចេញពីជួរ កងការពារណាហ្ស៊ីនោះនឹងឱ្យឆ្កែហក់មកខាំអ្នកនោះ។ ខ្ញុំនៅតែអាចចងចាំអំពីអារម្មណ៍ភ័យខ្លាចនិងខ្យល់បក់ត្រជាក់ដែលប៉ះសម្លៀកបំពាក់ដ៏ស្តើងរបស់ខ្ញុំនិងអារម្មណ៍ឈឺចាប់នៅលើជើងដែលបណ្តាលមកពីស្បែកជើងរបស់ខ្ញុំ។ នៅពេលខ្លះទៀតខ្ញុំស្រមៃ

ឃើញបំពង់ផ្សែងហើយមានអារម្មណ៍ឈឺចាប់នៅពេលដែលខ្ញុំដឹងថា បំពង់ផ្សែងនៅក្នុងអូសឈ្វិចនោះគេប្រើសម្រាប់ធ្វើអ្វី។

ពេលខ្ញុំរស់នៅជាមួយប្អូនស្រី យើងកម្រនិយាយគ្នាអំពីហូឡូខសន៍[៨៣] ណាស់។ ប៉ុន្តែអ្វីដែលធ្វើឱ្យខ្ញុំនឹកគិតឃើញអំពីអតីតកាល វាក៏បែបនោះសម្រាប់នាងដែរ។ យើងគ្រាន់តែមើលមុខគ្នាទៅវិញទៅមកតែប៉ុណ្ណោះ ដើម្បីដឹងថាយើងទាំងពីរនាក់កំពុងគិតអំពីអ្វី។

[៨៣] គឺជាការធ្វើបាបឃោឃៅនិងអំពើប្រល័យពូជសាសន៍ទៅលើជនជាតិជ្វីហ្វចំនួន៦លាននាក់ដោយរបបណាហ្ស៊ីរបស់ហ៊ីត្លែរ ចាប់តាំងពីឆ្នាំ១៩៣៣រហូតដល់ចុងបញ្ចប់សង្គ្រាមលោកលើកទី២។ ហូឡូខសន៍គឺជាពាក្យដើមនៃភាសាក្រិកមានន័យថា "បូជាដោយភ្លើង" ឬ "បូជាភ្លើង" ។



# "HUR KÄNNS DET ATT BLI GAMMAL?"

# "HOW DOES IT FEEL TO GROW OLD?"

# "តើអ្នកមានអារម្មណ៍បែបណាដែរនៅពេលដែលមានវ័យចំណាស់ទៅ?"

មានយប់មួយនោះខ្ញុំភ្ញាក់ដឹងខ្លួនហើយសប្បាយចិត្តពីព្រោះជើងយន្តហោះហើររបស់ខ្ញុំត្រូវបានពន្យារពេល។ ខ្ញុំនៅតែមិនយល់ថាតើទាំងអស់នេះគឺជាក្តីសុបិនឬថាតើខ្ញុំពិតជាកំពុងតែជិតចាប់ផ្តើមធ្វើដំណើរនោះទេ។ ប៉ុន្តែដោយសារតែជើងយន្តហោះហើរត្រូវបានពន្យារពេល ខ្ញុំមានអារម្មណ៍ល្អហើយខ្ញុំអាចទន្ទឹងរង់ចាំថ្ងៃនិទាឃរដូវថ្មីមួយទៀត។

តើខ្ញុំកំពុងតែយល់សុបិន ឬតើនេះគឺជាការពិត?

នៅក្នុងជំរំ ខ្ញុំបានព្យាយាមស្រមៃថា សុបិនគឺជាការពិតហើយពេលថ្ងៃគឺជាក្តីសុបិនទៅវិញ។ តើឥឡូវនេះគឺដូចដែលពេលនោះដែរឬទេ? តើអ្វីទៅជាការលំបាកដែលខ្ញុំកំពុងតែជួបប្រទះសព្វថ្ងៃនេះ? ចម្លើយគឺច្បាស់ណាស់គឺវ័យចំណាស់។

តើនៅពេលមួយណាដែលមនុស្សចាប់ផ្តើមមានវ័យចំណាស់? ថ្ងៃនេះវាបានចាប់ផ្តើមហើយបន្តពីមួយថ្ងៃទៅមួយថ្ងៃទៀត។ សព្វថ្ងៃនេះយើងនិយាយអំពីនិវត្តជនវ័យក្មេងដែលកំពុងនៅមានកម្លាំង។ ប៉ុន្តែកម្លាំងនោះនឹងកាន់តែថយចុះទៅតាមពេលវេលា ហើយមនុស្សវ័យចំណាស់ដែលក្មេងជាងគេក៏ក្លាយទៅជាមនុស្សវ័យចំណាស់ដែលចាស់ជាងគេ។ នេះគឺជារឿងបុគ្គលមួយយ៉ាងពិតប្រាកដ។ អាយុជីវសាស្ត្ររបស់មនុស្សម្នាក់ៗមិនតែងតែដូចគ្នានឹងអាយុដែលមនុស្សម្នាក់គិតអំពីនោះទេ។ ខ្ញុំខ្លួនឯងក៏មិនបានគិតអំពីអាយុរបស់ខ្ញុំដែររហូតទាល់តែដល់ថ្ងៃខួបកំណើត ៨២ ឆ្នាំរបស់ខ្លួន។ នោះហើយគឺជាពេលដែលខ្ញុំភ្ញាក់ផ្អើលថាខ្ញុំចាស់ហើយខ្ញុំមានអាយុ៨២ឆ្នាំហើយ។ ខ្ញុំចាប់ផ្តើមគិតលេខហើយភ្លាមៗនោះខ្ញុំបានដឹងថាខ្ញុំមានវ័យចំណាស់ចាប់តាំងពីខ្ញុំមានអាយុ២៨ឆ្នាំមកម្ល៉េះ។



វ័យចំណាស់មានគុណសម្បត្តិនិងគុណវិបត្តិរបស់វា។ រឿងដែលពិបាកបំផុតគឺការរៀនទទួលស្គាល់អំពីការបាត់បង់សមត្ថភាពបន្តិចម្តងៗរបស់មនុស្សម្នាក់ដែលចាប់ផ្តើមពីការលំបាកក្នុងការមើលឃើញនិងការស្តាប់ហើយបន្តជាមួយកំហុសឆ្គងផ្នែករាងកាយនិងផ្លូវចិត្តផ្សេងៗទៀត។ អ្វីៗគ្រប់យ៉ាងថយចុះចំណែកឯចលនារបស់យើងក៏កាន់តែយឺតយ៉ាវហើយសកម្មភាពរបស់យើងគឺកាន់តែដុនដាប។ យើងមិនគួរបន្តបើកបរទៀតនោះទេ។ មុនដំបូងខ្ញុំខឹងខ្លួនឯងដែលមិនមានកម្លាំងគ្រប់គ្រាន់ដើម្បីធ្វើអ្វីមួយដូចកាលពីមុនទៀត ប៉ុន្តែបន្តិចម្តងៗខ្ញុំបានយល់ថាខ្ញុំត្រូវតែទទួលស្គាល់ការពិតហើយរៀនបន្ថយល្បឿនរបស់ខ្លួន។ ដំបូងឡើយខ្ញុំបានព្យាយាមសងការខាតបង់របស់ខ្លួនឯងដោយធ្វើអ្វីមួយដោយយកចិត្តទុកដាក់ឱ្យបានកាន់តែច្រើនជាងមុននិងអត់ធ្មត់ថែមទៀត។ ប៉ុន្តែចុងក្រោយខ្ញុំបានត្រឹមតែសន្និដ្ឋានថាវាមិនអាចជួយអ្វីបានច្រើននោះទេ។ ការចងចាំរយៈពេលខ្លីរបស់យើងក៏បានបាត់បង់ទៅដែលធ្វើឱ្យកាន់តែមានភាពពិបាកក្នុងការចងចាំឈ្មោះរបស់មនុស្សម្នាក់។ នេះគឺហាក់បីដូចជាខ្ញុំបានបាត់បង់ការផ្សារភ្ជាប់ទៅនឹងខួរក្បាលរបស់ខ្លួនដែលមិនចង់ឱ្យចម្លើយដែលត្រឹមត្រូវនោះទេទោះបីជាខ្ញុំខំប្រឹងយ៉ាងណាក៏ដោយ។

ខ្ញុំកត់សម្គាល់ឃើញថាអ្វីៗដែលធ្លាប់តែមានសារសំខាន់បំផុតចំពោះខ្ញុំបានបាត់បង់សារសំខាន់របស់វា។ ប៉ុន្មានឆ្នាំមកនេះ ខ្ញុំមានអារម្មណ៍ថាដូចជាការឡើងភ្នំមួយដែលនៅពេលដែលយើងឡើងទៅដល់កំពូលភ្នំយើងអាចឃើញថាអ្វីៗទាំងអស់នៅខាងក្រោមកាន់តែតូចទៅៗ រហូតទាល់តែយើងមិនអាចមើលឃើញអ្វីបានទៀតនោះទេ។

ខ្ញុំឈប់ខឹងអំពីរឿងតូចតាចទៀតហើយ។ ខ្ញុំអាចអត់ឱនដល់ការនិយាយដែលឆោតល្ងង់និងទទួលយកការចោទប្រកាន់មិនយុត្តិធម៌ដើម្បីជៀសវាងពីជម្លោះ។ ខ្ញុំខ្លួនឯងក៏មិនមានអារម្មណ៍ថាមានសារសំខាន់

ទៀតនោះដែរ។ ជារៀងរាល់ព្រឹកខ្ញុំសប្បាយរីករាយនឹងថ្ងៃថ្មីការផ្លាស់ប្តូរនៃរដូវកាលថ្មី និងសប្បុរសធម៌ពីមនុស្សដទៃទៀត។ វាក៏កាន់តែមានសារសំខាន់ក្នុងការជួបជាមួយមនុស្សដទៃទៀតដែរ។ ខ្ញុំដែលធ្លាប់តែជាចចកឯកោម្នាក់នៅពេលនេះគឺសប្បាយរីករាយដែលមានមិត្តរាប់អានច្រើន។ នៅពេលដែលខ្ញុំបានធ្វើការស្រាវជ្រាវទៅរកការវិវត្តនៃអាយុ ខ្ញុំចាប់ផ្តើមយល់អំពីខ្លួនឯងបានច្បាស់ជាងមុន។ ជីវិតផ្លាស់ប្តូរគ្រប់ពេលវេលាហើយយើងស្ទើរតែមិនអាចដឹងបានទេថានៅពេលណាដែលយើងឆ្លងកាត់ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។ ទារកធំលូតលាស់ទៅជាក្មេងតូចឯកុមារទៅជាក្មេងជំទង់។មនុស្សស្រីឆ្លងកាត់ការអស់រដូវហើយសេចក្តីស្លាប់គឺជាដំណាក់កាលចុងក្រោយ។ សេចក្តីស្លាប់គឺជាអ្វីដែលកំពុងរង់ចាំយើងទាំងអស់គ្នា ប៉ុន្តែនិយាយអំពីវាគឺជាបម្រាមហាមឃាត់មួយទៅវិញ។រាងកាយដែលធ្លាក់ចុះទ្រុឌទ្រោមត្រៀមលក្ខណៈសម្រាប់សេចក្តីស្លាប់។ នេះហើយគឺជាអ្វីដែលអ្នកវិទ្យាសាស្រ្តកំពុងតែហៅថាជាការវិវត្តនៃអាយុ។ ការគិតអំពីសេចក្តីស្លាប់កាន់តែខិតជិតជាងមុនហើយបានបង្ហាញឱ្យឃើញកាន់តែច្បាស់នៅក្នុងសុបិនដែលកាន់តែបង្ហាញឱ្យឃើញអំពីចលនា អំពីការធ្វើដំណើរនិងអំពីអ្វីដែលមនុស្សម្នាក់បានភ្លេចយកទៅជាមួយ។

សេចក្តីស្លាប់មិនអាចបន្លាចខ្ញុំបានទេ។ ខ្ញុំមានជីវិតរស់នៅយូរណាស់មកហើយ យូរជាងអ្វីដែលខ្ញុំបានស្រមៃទៅទៀត ហើយពេលខ្លះអ្វីៗទាំងអស់នឹងបានបញ្ចប់ទៅ។ អ្នកចាស់ចាកចេញពីយើងទៅហើយអ្នកថ្មីផ្សេងទៀតចូលមកដល់។ ខ្ញុំដឹងថាមិនមានការពន្យល់មួយណាដែលអាចបកស្រាយបាននោះទេថាហេតុអ្វីបានជាយើងរស់នៅលើពិភពលោកនេះ។ អ្វីដែលសំខាន់នោះគឺថាតើយើងនឹងរស់នៅជារៀងរាល់ថ្ងៃនេះដោយរបៀបណាទើបអ្នកដែលកើតមកបន្ទាប់ពីយើងអាចរស់នៅក្នុងពិភពលោកមួយដែលល្អប្រសើរជាងពិភពលោកដែលយើងកំពុងតែរស់នៅ។



# “EFTER ALLT DETTA, TROR DU PÅ GUD?” “AFTER EVERYTHING, DO YOU BELIEVE IN GOD?”

# "បន្ទាប់ពីអ្វីៗដែលបានកើតឡើងមក តើអ្នកជឿទៅលើព្រះដែរឬទេ?"

តើអាចទៅរួចដែរឬទេដែលជឿទៅលើព្រះបន្ទាប់ពីអ្វីៗដែលបានកើតឡើងនៅហូឡូខសន៍[៨៤]? នេះគឺជាសំណួរដែលអ្នកនិពន្ធនិងអ្នកទស្សនវិទូជាច្រើនបានគិតនិងសរសេរអំពីវា។ ប្រសិនបើអ្នកសួរទៅអ្នកដែលរស់រានមានជីវិត អ្នកនឹងសង្កេតឃើញថាមនុស្សម្នាក់ៗនឹងមានប្រតិកម្មខុសៗគ្នា។ មនុស្សមួយចំនួនធំដែលមានជំនឿទៅលើព្រះយ៉ាងខ្លាំងមុនពេលសង្គ្រាមកើតឡើងបាននិយាយថា "ប្រសិនបើរឿងនេះអាចកើតឡើងបាន ខ្ញុំមិនជឿលើព្រះទៀតទេ"។ ខ្ញុំចងចាំស្ត្រីកាន់សាសនាម្នាក់នៅក្នុងទូរថភ្លើងនៅតាមផ្លូវទៅកាន់អូសឈ្វិចដែលបានសួរអ្នកជិតខាងថាតើនាងអាចសុំបរិភោគសាច់ជ្រូកបន្តិចបានទេ។ ម៉្យាងវិញទៀត មានអ្នកដែលមិនជឿថាមានព្រះជាច្រើននាក់បានកាន់សាសនាយ៉ាងខ្ជាប់ខ្ជួនបន្ទាប់ពីសង្គ្រាមបានបញ្ចប់ទៅ។ ពួកគេបានជឿជាក់យ៉ាងខ្លាំងថាព្រះគឺជាអ្នកដែលបានជួយពួកគេឱ្យរួចជីវិត។

ស្ត្រីកាន់សាសនាគ្រិស្តជាច្រើននាក់ដែលនៅក្នុងជំរំជាមួយខ្ញុំប្រកាន់វិន័យចាស់យ៉ាងខ្ជាប់ខ្ជួន និងមិនដែលបាត់បង់ជំនឿរបស់ខ្លួននោះទេ។ មានថ្ងៃមួយពួកគេបានត្រឡប់មកពីធ្វើការងារនៅក្នុងសំណង់បាក់បែកវិញដោយក្តីសប្បាយរីករាយ ពីព្រោះតែបានរកឃើញសៀវភៅអធិដ្ឋានមួយក្បាល។ ពួកគេបានអធិដ្ឋានជារៀងរាល់ព្រឹកនិងយប់។ ពួកគេជឿជាក់យ៉ាងពេញលេញនិងយ៉ាងមុតមាំថា "ព្រះបានជួយពួកគេឱ្យគេចពីបន្ទប់

[៨៤] គឺជាការធ្វើបាបយាយីនិងអំពើប្រល័យពូជសាសន៍ទៅលើជនជាតិជ្វីហ្វចំនួន៦លាននាក់ដោយរបបណាហ្ស៊ីរបស់ហ៊ីត្លែរចាប់តាំងពីឆ្នាំ១៩៣៣ រហូតដល់ចុងបញ្ចប់សង្គ្រាមលោកលើកទី២។ ហូឡូខសន៍គឺជាពាក្យដើមនៃភាសាក្រិកមានន័យថា "បូជាដោយភ្លើង" ឬ "បូជាភ្លើង" ។



ផ្សែងពុលនិងបន្តជួយពួកគេប្រសិនបើខ្លួនធ្វើតាមបទបញ្ញត្តិរបស់ទ្រង់"។ ទោះបីជាមានការត្រួតពិនិត្យជាញឹកញាប់ក៏ដោយពួកគេនៅតែអាចថែរក្សាសៀវភៅអធិដ្ឋានរបស់ខ្លួនហើយធ្វើតាមសេចក្តីបង្គាប់របស់សាសនាទោះបីជាមានការលំបាកក៏ដោយ។ អ្នកទាំងនោះថែមទាំងអាចរៀបចំគណនាថ្ងៃលាងបាប ដែលមនុស្សម្នាក់ៗមិនត្រូវបរិភោគអាហារឬផឹកទឹកឡើយ។ ហើយក៏មិនចាំបាច់សួរដែរថាតើពួកគេនឹងបរិភោគអាហារដែរឬអត់នោះ។ ដោយក្រពះទទេស្អាតសូម្បីតែមិនទាន់លាងមាត់របស់ខ្លួន ពួកគេចូលជួរដើម្បីដើរទៅកន្លែងធ្វើការងារ។ ដល់កន្លែងនោះ ពួកគេធ្វើការលើកបាវស៊ីម៉ងត៍ធ្ងន់ៗ ហើយសូម្បីតែទឹកមិនផឹកផង។

ជំនឿអាចមានផលប្រយោជន៍នៅក្នុងដំណើរជីវិតដោយមិនចាំបាច់គិតអំពីសាសនាមួយណារបស់មនុស្សឡើយ។ គ្រោះថ្នាក់អាចកើតមានឡើងនៅពេលដែលជំនឿត្រូវបានជឿហួសឆ្ងាយពេកហើយមនុស្សគិតថាអ្នកដទៃទៀតត្រូវតែមានជំនឿដូចខ្លួនដែរ។ នោះហើយគឺជាពេលដែលជំនឿបានប្រែក្លាយទៅជាជ្រុលនិយម ហើយបញ្ញត្តិនៃសេចក្តីស្រឡាញ់ត្រូវបានប្រែក្លាយទៅជាបទបញ្ញត្តិនៃសេចក្តីស្អប់ខ្ពើម។ នៅក្នុងជំរំមានអ្នកដែលមិនជឿទៅលើព្រះជាច្រើននាក់បានសើចចំអកដល់អ្នកដែលជឿទៅលើព្រះក្នុងអំឡុងពេលដែលពួកគេទាមទារឱ្យមានការគោរពចំពោះការមិនជឿរបស់ខ្លួន។ ពួកគេមានការលំបាកក្នុងការយល់ដឹងថាការទទួលស្គាល់ត្រូវតែស្របតាមវិធីទាំងពីរ។ ខ្ញុំមិនអាចទាមទារឱ្យមានការទទួលស្គាល់ចំពោះជំនឿរបស់ខ្ញុំទេ ប្រសិនបើខ្ញុំមិនអាចទទួលស្គាល់ជំនឿរបស់អ្នកបាន។ សម្រាប់ខ្លួនខ្ញុំផ្ទាល់ គ្មានអ្វីផ្លាស់ប្តូរឥរិយាបថពីមុនរបស់ខ្ញុំនោះទេ។ ខ្ញុំបានរក្សាជំនឿដូចដែលខ្ញុំធ្លាប់មាននៅមុនពេលហូឡូខសន៍[៨៥]។

[៨៥] គឺជាការធ្វើបាបយាយីនិងអំពើប្រល័យពូជសាសន៍ទៅលើជនជាតិជ្វីហ្វចំនួន៦លាននាក់ដោយរបបណាហ្ស៊ីរបស់ហ៊ីត្លែរចាប់តាំងពីឆ្នាំ១៩៣៣ រហូតដល់ចុងបញ្ចប់សង្គ្រាមលោកលើកទី២។ ហូឡូខសន៍គឺជាពាក្យដើមនៃភាសាក្រិកមានន័យថា "បូជាដោយភ្លើង" ឬ "បូជាភ្លើង" ។

ខ្ញុំបានធំធាត់ឡើងជាជនជាតិជ្វីហ្វ ហើយក៏នៅតែជាជនជាតិជ្វីហ្វដដែល។ ប៉ុន្តែខ្ញុំមិនជឿថាព្រះរបស់ខ្ញុំវិសេសវិសាលជាងគេនោះទេ។ ប្រសិនបើមានព្រះនោះ គឺជាព្រះតែមួយដែលយើងទាំងអស់គ្នាជឿទៅលើមិនថាព្រះយេហូវ៉ា ព្រះគ្រិស្ត ឬព្រះអាល់ឡាស់ ។ ខ្ញុំមិនជឿថាព្រះកំពុងគង់នៅលើស្ថានសួគ៌ហើយមើលថែរក្សាយើងម្នាក់ៗ និងប្រាប់យើងអំពីអ្វីៗគ្រប់យ៉ាងដែលយើងគួរតែធ្វើនោះទេ។ ព្រះគឺនៅក្នុងខ្លួនរបស់យើងគ្រប់ៗគ្នា។ គឺនៅក្នុងសីលធម៌ដែលជួយយើងឱ្យដោះស្រាយអំពីបញ្ហាជីវិតបាន។

ច្បាប់មួយបាននិយាយថា "កុំធ្វើទៅលើអ្នកដទៃនូវអំពើអ្វីដែលអ្នកមិនចង់ឱ្យគេធ្វើមកលើអ្នក"។ ច្បាប់នេះអាចរកឃើញនៅគ្រប់សាសនានិងគ្រប់ភាសាទាំងអស់។ ប្រសិនបើមនុស្សទាំងអស់ត្រូវបានដឹកនាំដោយច្បាប់មួយនេះ យើងនឹងរស់នៅក្នុងពិភពលោកមួយដែលកាន់តែប្រសើរឡើង។



# "HUR KAN SKOLAN BIDRA TILL ATT UNDVIKA NÅGOT LIKNANDE?"

# "HOW CAN SCHOOLS HELP US AVOID SOMETHING SIMILAR?"

# "តើសាលារៀនអាចជួយយើងឱ្យជៀសផុតពីរឿងដែលស្រដៀងនេះបានយ៉ាងដូចម្ដេច?"

សំណួរមួយដែលខ្ញុំត្រូវបានសួរជាញឹកញាប់គឺថា "តើយើងអាចជៀសវាងពីការកើតឡើងនូវរឿងនេះម្ដងទៀតបានយ៉ាងដូចម្ដេច?" ខ្ញុំអាចគិតឃើញអំពីវិធីមួយប៉ុណ្ណោះ។ វាគឺតាមរយៈការប្រៀនប្រដៅកូនៗរបស់យើង។ ការប្រៀនប្រដៅទូទៅនិងការអប់រំជាពិសេសនៅតាមសាលារៀន គឺដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចនូវអ្វីដែលអាចនឹងកើតឡើងនៅថ្ងៃស្អែកបាន។

មិនមែនកុមារគ្រប់រូបទាំងអស់ធំធាត់ឡើងនៅក្នុងផ្ទះដែលមានសីលធម៌រឹងមាំនោះទេ។ កុមារទាំងនេះមានឱកាសក្នុងការជួបប្រទះពិភពមួយផ្សេងទៀតដូចជានៅក្នុងសាលារៀនពួកគេអាចជួបជាមួយគ្រូបង្រៀនដែលអាចលើកឡើងនូវសំណួរមួយចំនួនដែលពួកគេមិនដែលគិតចង់សាកសួរ។

វានឹងមិនគ្រប់គ្រាន់នោះទេដែលចំណាយពេលមួយម៉ោងឬពីរម៉ោងនៅក្នុងថ្នាក់ប្រវត្តិសាស្ត្រដើម្បីរៀនអំពីហូឡូខសន៍[៨៦]។ ការបង្រៀនគឺត្រូវតែចាប់ផ្ដើមឱ្យបានឆាប់ជាងនេះដូចជានៅក្នុងថ្នាក់មត្តេយ្យជាដើម។ សូម្បីតែក្មេងតូចៗក៏អាចយល់អំពីរឿងអយុត្តិធម៌និងការរើសអើងបានដែរប្រសិនបើយើងបង្រៀនស្របតាមកម្រិតដែលពួកគេអាចទទួលយកបាន។ កុមារដែលមានអាយុចាប់ពី១០ទៅ១២ឆ្នាំជាធម្មតាគឺជាអ្នកគាំទ្រធំបំផុតនៅពេលដែលខ្ញុំទៅបង្រៀននៅសាលារៀន។ កុមារទាំងនោះចង់ដឹងចង់ឃើញហើយចង់រៀន និងមានសំណួរសួរច្រើនទៀតផងដែល

[៨៦] គឺជាការធ្វើបាបយាយីនិងអំពើប្រល័យពូជសាសន៍ទៅលើជនជាតិជ្វីហ្វចំនួន៦លាននាក់ដោយរបបណាហ្ស៊ីរបស់ហ៊ីត្លែរចាប់តាំងពីឆ្នាំ១៩៣៣ រហូតដល់ចុងបញ្ចប់សង្គ្រាមលោកលើកទី២។ ហូឡូខសន៍គឺជាពាក្យដើមនៃភាសាក្រិកមានន័យថា "បូជាដោយភ្លើង" ឬ "បូជាភ្លើង" ។



ខុសគ្នាពីក្មេងជំទង់ដែលពេលខ្លះមានការពិបាកក្នុងការសួរសំណួរ។ ហូឡូខសន៍បានកើតឡើង ហើយប្រសិនបើត្រូវបានបំភ្លេចចោលរឿងនេះអាចនឹងកើតឡើងម្ដងទៀត។ នោះហើយជាមូលហេតុដែលសាលារៀនត្រូវប្រាកដប្រជាថាក្មេងៗ បានដឹងអំពីប្រវត្តិសាស្ត្រយ៉ាងលម្អិតចំពោះរឿងរ៉ាវដែលបានកើតឡើងនៅក្នុងប្រទេសអាល្លឺម៉ង់ចាប់ពីឆ្នាំ១៩២០ដល់១៩៤៥។ មេរៀនប្រវត្តិសាស្ត្រត្រូវតែបង្រៀនអំពីអ្វីដែលបានកើតឡើងហើយទៅតាមរបៀបមួយដែលអាចជិតជាប់ក្នុងអារម្មណ៍របស់កុមារទាំងនោះ។ អស់រយៈពេលជាច្រើនឆ្នាំដែលមនុស្សជាច្រើនបានគិតថាគឺមានសារសំខាន់ណាស់ដែលកុមារត្រូវរៀនអំពីកាលបរិច្ឆេទនិងឈ្មោះសំខាន់ៗនៃសមរភូមិ។ កុមារត្រូវបានបង្រៀនតាមរបៀប "រៀនយ៉ាងវក់វី" ។ សិស្សទាំងនោះបានក្លាយទៅជាអ្នកស្ទួយប្រវត្តិកម្មដែលអាចរៀបរាប់បានអំពីព្រឹត្តិការណ៍ដែលបានកើតឡើង ដោយមិនបានយល់ដឹងច្បាស់អំពីអ្វីទាំងអស់ ។

ដើម្បីសម្រេចបាននូវការយល់ដឹងដ៏ត្រឹមត្រូវនិងជ្រៅជ្រះមួយ ការអប់រំត្រូវតែជ្រាបឱ្យដល់បេះដូងរបស់សិស្សទាំងនោះ។ វិធីបង្រៀនដែលមានតាមរយៈការបង្ហាញអំពីព្រឹត្តិការណ៍ធំៗដែលកើតឡើងនៅក្នុងពិភពលោកតូចមួយដោយយករឿងរ៉ាវជីវិតបុគ្គលម្នាក់ៗ ជាចំណុចចាប់ផ្ដើមដើម្បីពណ៌នាអំពីសម័យកាលមួយ។ មេរៀនត្រូវតែចាប់ផ្ដើមនៅក្នុងពេលឥឡូវនេះ។ ស្វែងរកព្រឹត្តិការណ៍ណាមួយ ដែលងាយស្រួលក្នុងការផ្សារភ្ជាប់ទៅនឹងអតីតកាលនិងបង្កើនការយល់ដឹងចំពោះរឿងរ៉ាវដែលងាយនឹងកើតឡើងនៅពេលអនាគតកាល។ មនុស្សម្នាក់ៗត្រូវតែចង្អុលបង្ហាញអំពីការទទួលខុសត្រូវរបស់បុគ្គលម្នាក់ចំពោះខ្លួនឯងនិងសង្គមព្រមទាំងបង្ហាញថាតើវាមានគ្រោះថ្នាក់យ៉ាងណានៅពេលដែលយើងនៅ

ស្មៀមស្ងាត់។ គឺមានសារសំខាន់ខ្លាំងណាស់ដែលរឿងរ៉ាវហូឡូខសន៍[៨៧] ត្រូវបានដាក់បញ្ចូលនៅក្នុងគ្រប់មុខវិជ្ជាទាំងអស់ ចាប់ផ្តើមពីសាសនានិងភូមិសាស្ត្រការអប់រំកាយនិងគីមីវិទ្យា។ វាក៏មានសារសំខាន់ខ្លាំងណាស់ដែរដែលគ្រូបង្រៀនទាំងអស់ដឹងនិងនិយាយប្រាប់សិស្សរបស់ខ្លួនថា តើមុខវិជ្ជារបស់ពួកគេត្រូវបានប៉ះពាល់ខ្លាំងយ៉ាងណាបន្ទាប់ពីអ្វីដែលបានកើតឡើងនៅពេលនោះ។ ការអប់រំក៏គួរតែកើតឡើងដោយ "ការធ្វើ"។ ឧទាហរណ៍នៅក្នុងថ្នាក់សិល្បៈគួរតែមានឱកាសសម្រាប់ឱ្យសិស្សបង្ហាញអំពីអារម្មណ៍របស់ខ្លួន ពង្រឹងនូវអ្វីដែលពួកគេបានរៀននិងដឹងអំពីអារម្មណ៍របស់ពួកគេបន្ទាប់ពីរៀនមេរៀនរួច។ បន្ទាប់ពីអានសៀវភៅដែលសមស្របសិស្សអាចធ្វើសកម្មភាពជាមួយដីឥដ្ឋ គំនូរ រូបភាពរចនាដោយក្រដាសគំនូរសិល្បៈដែលទាក់ទាញអារម្មណ៍របស់ពួកគេ។

ជាទូទៅ គ្រូបង្រៀនតែងតែមានគំនិតច្នៃប្រឌិត ហើយការប្រជុំពិគ្រោះយោបល់អាចពង្រីកវិធីសាស្ត្របង្រៀនអំពីហូឡូខសន៍[៨៨] បាន។ គ្រូបង្រៀនល្អអាចក្លាយទៅជាគំរូរបស់សិស្សបាន។ នៅក្នុងស្ថានភាពវិបត្តិដែលតែងតែមាននៅលើវិថីជីវិតរបស់មនុស្សគ្រប់រូប គ្រូបង្រៀនអាចធ្វើឱ្យមានការផ្លាស់ប្តូរដ៏ធំមួយបាន។

[៨៧,៨៨] គឺជាការធ្វើបាបឃាឃីនិងអំពើប្រល័យពូជសាសន៍ទៅលើជនជាតិជ្វីហ្វចំនួន៦លាននាក់ដោយរបបណាហ្ស៊ីរបស់ហ៊ីត្លែរ ចាប់តាំងពីឆ្នាំ១៩៣៣ រហូតដល់ចុងបញ្ចប់សង្គ្រាមលោកលើកទី២។ ហូឡូខសន៍គឺជាពាក្យដើមនៃភាសាក្រិកមានន័យថា "បូជាដោយភ្លើង" ឬ "បូជាភ្លើង" ។



“

# HUR SER DU PÅ FRAMTIDEN?

” “

# WHAT IS YOUR VIEW OF THE FUTURE?

”

# "តើអ្នកមានទស្សនៈយ៉ាងណាចំពោះអនាគតកាល?"

ខ្ញុំមិនជឿថាទស្សនៈរបស់ខ្ញុំខុសពីអ្នកដទៃនោះទេ នៅពេលដែលគិតអំពីពិភពលោកសព្វថ្ងៃនេះ។ ខ្ញុំមើលឃើញនយោបាយដែលវិលត្រឡប់ទៅរកការប្រឆាំងនឹងការកែទម្រង់ថ្មី ការកើនឡើងនៃការប្រឆាំងជនជាតិជ្វីហ្ការស្អប់ខ្ពើមជនបរទេស និងការបំផ្លិចបំផ្លាញបរិស្ថាន។ សម្រាប់ខ្ញុំការបើកទំព័រកាសែតអានជារៀងរាល់ពេលព្រឹក គឺជាបទពិសោធន៍ដ៏រន្ធត់មួយ។

ទោះបីជាបែបនេះហើយ ខ្ញុំនៅតែមានសេចក្តីសង្ឃឹម។

ក្រឡេកមើលទៅសតវត្សរ៍កន្លងមកចាប់តាំងពីដើមដំបូង យើងឃើញថាសន្តិភាពនិងវិបុលភាពជារឿយៗបានកើតឡើងបន្ទាប់ពីជម្លោះ។ មានន័យថា គឺមានដំណើរការទៅមុខ ក៏ប៉ុន្តែគឺទៅតាមរូបរាងដូចគូទខ្យង។ នៅពេលនេះយើងមិនស្ថិតនៅក្នុងកន្លែងដែលល្អនោះទេប៉ុន្តែអ្វីៗនឹងផ្លាស់ប្តូរ ហើយមិនយូរប៉ុន្មានយើងនឹងមានដំណើរការទៅមុខម្តងទៀត។

នៅពេលដែលខ្ញុំមើលទៅយុវវ័យសព្វថ្ងៃនេះ ខ្ញុំមានអារម្មណ៍សុទិដ្ឋិនិយម។ ពួកគេបានក្លាយទៅជាមនុស្សដែលដឹងអំពីខ្លួនឯង និងមានចំណេះដឹងខ្ពស់ ហើយមានការចាប់អារម្មណ៍ច្រើនទៅលើពិភពលោកជាងពេលដែលយើងមានអាយុស្របាលពួកគេ។ ខ្ញុំមានជំនឿយ៉ាងមុតមាំថាយុវវ័យសព្វថ្ងៃនេះមានឆន្ទៈ និងសក្តានុពលក្នុងការដោះស្រាយបញ្ហានាពេលបច្ចុប្បន្ននេះ។

នៅពេលដែលខ្ញុំជួបជាមួយយុវវ័យបច្ចុប្បន្ននេះ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះការផ្លាស់ប្តូររបស់ពួកគេក្នុងអំឡុងពេលជាច្រើនឆ្នាំដែលខ្ញុំបានបង្រៀន។ ពួកគេបានផ្លាស់ប្តូរពីការបង្ហាញចំណាប់អារម្មណ៍បន្តិចបន្តួចទៅជាការចាប់អារម្មណ៍កាន់តែច្រើនឡើងៗ។ ពួកគេចាប់ផ្តើមសួរសំណួរបន្ថែម និងទទួលយកចំណេះដឹងដែលជ្រាបដល់ស្មារតីព្រមទាំងបេះដូងរបស់ខ្លួន។ ការយល់ដឹងរបស់យុវវ័យទាំងនោះគឺតាមរយៈបញ្ញា និងសតិអារម្មណ៍។

នាចុងបញ្ចប់នៃការបង្រៀនរបស់ខ្ញុំ មានសិស្សមួយចំនួនបានប្រាប់ខ្ញុំថា "កុំបារម្ភ យើងនឹងចែកចាយអំពីអ្វីដែលអ្នកបានប្រាប់យើង ពីព្រោះយើងមិនចង់ឱ្យវាកើតឡើងម្តងទៀតនោះទេ" ។

ខ្ញុំក៏ជឿជាក់ដែរថា អ្នកគ្រប់គ្រងសាលារៀនបានចាប់ផ្តើមយល់អំពីសារសំខាន់ក្នុងការបន្តតស៊ូប្រឆាំងអំពីការបំភ្លេច ហើយនេះគឺជាសញ្ញាដ៏ល្អមួយ។ ប្រសិនបើមនុស្សគ្រប់ពណ៌សម្បុរគ្រប់សាសនា ជាតិសាសន៍ និងគ្រប់អាយុទាំងអស់ ក្រោកឈរឡើងប្រឆាំងនឹងអ្នកដែលមិនយល់ថា តើពួកគេរស់នៅដោយសុខសាន្តក្រោមលទ្ធិប្រជាធិបតេយ្យរបស់យើងយ៉ាងដូចម្តេចនោះ។ យើងនឹងអាចប្រកាន់បាននូវជំហរដែលយើងមាន។

“

# VAD KAN VI LÄRA OSS AV FÖRINTELSEN?

” “

# WHAT CAN WE LEARN FROM THE HOLOCAUST?

”



## "តើយើងអាចរៀនសូត្របានអ្វីខ្លះអំពីហូឡូខសន៍?"

ខ្ញុំបានឆ្លងកាត់រឿងរ៉ាវជាច្រើន ប៉ុន្តែនៅតែអាចមានជីវិតបានយូរហូតអាចឈានដល់វ័យចំណាស់។ ខ្ញុំនិពន្ធសៀវភៅ អត្ថបទកាសែត និងបានបង្រៀនអស់រយៈពេល៣០ឆ្នាំមកហើយ។ អ្វីដែលខ្ញុំតែងតែចង់និយាយនិងនៅតែធ្វើ គឺរៀនអំពីបទពិសោធន៍របស់ខ្ញុំនិងអ្នកដទៃ។ នេះគឺជាការលំបាក ប៉ុន្តែក៏ជាមធ្យោបាយតែមួយគត់ដើម្បីគេចផុតពីការឈឺចាប់ដែលយើងបានទទួលរងនៅក្នុងហូឡូខសន៍[៨៩]។

ខោនទេស៍ម្នាក់[៩០] ដែលជាកូនស្រីរបស់ឯកអគ្គរដ្ឋទូតអេស្ប៉ាញដែលផ្ទះរបស់គាត់ធ្លាប់ជាកន្លែងជួបជុំរបស់គូប្រជែងហ៊ីត្លែរបាននិយាយនៅក្នុងឆ្នាំ១៩៤៨ ថាពិភពលោកមិនបានរៀនអ្វីសោះពីឃាតករ ជនរងគ្រោះ ឬអ្នកដែលបានត្រឹមតែឈរមើលបំណាំឡើយ។ ពេលវេលារបស់យើងគឺប្រៀបបានដូចជាការរាំរែកជាមួយនឹងសេចក្តីស្លាប់ ហើយមានមនុស្សតិចណាស់ដែលយល់ពីចង្វាក់ដ៏ចម្លែករបស់វា។

ពាក្យនេះគឺត្រឹមត្រូវណាស់សម្រាប់ធ្វើការបកស្រាយអំពីស្ថានភាពសព្វថ្ងៃនេះ។ ប៉ុន្តែយើងមិនត្រូវទទួលយកឬអនុញ្ញាតឱ្យខ្លួនយើងរស់នៅសុខសាន្តជាមួយនឹងវាឡើយ។ យើងមិនត្រូវបោះបង់ចោលការតស៊ូនោះទេ យើងត្រូវតែបន្តផ្សព្វផ្សាយចំណេះដឹងដើម្បីជួយដល់យុវវ័យជំនាន់ថ្មីឱ្យយល់ដឹងច្បាស់អំពីចង្វាក់របស់វា ហើយជៀសវាងកំហុសឆ្គងរបស់មនុស្សកាលពីជំនាន់មុន។

---

[៨៩] គឺជាការធ្វើបាបឃាឃីនិងអំពើប្រល័យពូជសាសន៍ទៅលើជនជាតិជ្វីហ្វចំនួន៦លាននាក់ដោយរបបណាហ្ស៊ីរបស់ហ៊ីត្លែរចាប់តាំងពីឆ្នាំ១៩៣៣ រហូតដល់ចុងបញ្ចប់សង្គ្រាមលោកលើកទី២។ ហូឡូខសន៍គឺជាពាក្យដើមនៃភាសាក្រិកមានន័យថា "បូជាដោយភ្លើង" ឬ "បូជាភ្លើង" ។

[៩០] ជាងាររបស់ស្ត្រីដែលមានឋានៈខ្ពង់ខ្ពស់នៅក្នុងសង្គមឬភរិយារបស់អ្នកអភិជន។

តើចង្វាក់នេះគឺជាអ្វី? នោះគឺជាមេដឹកនាំដែលមានកលល្បិចទាញយកផលប្រយោជន៍ពីការមិនសប្បាយចិត្តរបស់ប្រជាជនជាមួយកាលៈទេសៈបច្ចុប្បន្នមកធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន។ មេដឹកនាំទាំងនោះផ្តល់ចម្លើយងាយៗចំពោះសំណួរស្មុគស្មាញ និងសន្យាឱ្យប្រជាជននូវអនាគតនៃសុភមង្គលជានិរន្តរដែលហួសវិស័យ។ ព្យាការីក្លែងក្លាយទាំងនេះងាយនឹងធ្វើឱ្យប្រជាជនជឿ ហើយធ្វើឱ្យមានភាពងាយស្រួលក្នុងការធ្លាក់ក្នុងអំពើអាក្រក់។ លុះយូរបន្តិចក្រោយមក ទើបមានអ្នកកត់សម្គាល់ថា ការសន្យាទាំងនេះគឺមានផលអវិជ្ជមាន។ សេចក្តីសង្ឃឹមមិនត្រូវបានបំពេញហើយយើងបានបាត់បង់សេរីភាព និងផ្ទះរបស់ខ្លួន។ អ្វីដែលយើងមានអារម្មណ៍មិនពេញចិត្តជាមួយពីកាលដំបូងបានក្លាយទៅជាអ្វីមួយដែលយើងកំពុងតែចង់បានយ៉ាងខ្លាំង។

ប្រទេសអាល្លឺម៉ង់បានផ្លាស់ប្តូរសាធារណរដ្ឋវៀម៉ា[៩១] ដើម្បីក្តីសុបិនពាន់ឆ្នាំរបស់ ហ៊ីត្លែរ ដែលនាំឱ្យប្រទេសនោះសល់តែភាពវិនាសហិនហោច។ ងាកត្រឡប់ទៅឆ្នាំ១៩១៤វិញ យើងឃើញថាយុវជនវ័យក្មេងរបស់ប្រទេសអាល្លឺម៉ង់ និងប្រទេសបារាំង បានសម្រុកចូលទៅក្នុងភ្នក់ភ្លើងសង្គ្រាមយ៉ាងស្វិតស្វាញ។ យុវជនវ័យក្មេងទាំងនោះវិលត្រឡប់មកវិញបន្ទាប់ពី៤ឆ្នាំ មកក្នុងប្រទេសអ៊ឺរ៉ុបដែលខូចខាតខ្ទេចខ្ទាំជាមួយនឹងពាក្យវិប្បសារីថា "គ្មានសង្គ្រាមទៀតទេ" ។ បច្ចុប្បន្ននេះជាថ្មីម្តងទៀត យើងមិនសប្បាយចិត្តជាមួយនឹងស្ថានភាពបច្ចុប្បន្ន។ តើវានឹងនាំយើងទៅរកអ្វី? តើវានិងចាប់ផ្តើមនៅទីណានិងពេលណា?

នៅពេលដែលយើងក្រឡេកមើលទៅក្រោយវិញ ខណៈពេលដែលប្រវត្តិសាស្ត្រចាប់ផ្តើមដំបូង។ យើងឃើញថា បន្ទាប់ពីសង្គ្រាម គឺតែងតែមានភាពស្ងៀមស្ងាត់ ជាពេលវេលាដែលភ្លឺថែងចាំង បន្ទាប់មកក៏ងងឹតម្តងទៀត ហើយក៏បញ្ចប់នៅក្នុងភ្លើងសង្គ្រាមមួយទៀត។ តើយើងរកឃើញប្រភពដើមនៃគំរូនេះទេ?

[៩១] គឺជាឈ្មោះមិនផ្លូវការរបស់ប្រទេសអាល្លឺម៉ង់ចាប់ពីឆ្នាំ១៩១៨ដល់១៩៣៣។

ខ្ញុំគិតថាវាបានចាប់ផ្តើមនៅពេលដែលមានហេតុផលដំបូងក្នុងការប្រើប្រាស់ទស្សនវិស័យនៃ "ពួកយើង" និង "ពួកគេ" ។

ជាមួយនឹងទស្សនៈនេះ យើងសាកល្បងវិលត្រឡប់ទៅមនុស្សយុគសម័យដំបូងដែលបានបង្កើតសហគមន៍កសិកម្មដំបូងបង្អស់។ ក្រុមគ្រួសារនីមួយៗរស់នៅដាច់ដោយឡែកពីគ្នាដោយគ្មានទំនាក់ទំនងអ្វីទាំងអស់ ហើយនៅពេលដែលសមាជិកគ្រួសាររបស់ខ្លួនកើនឡើងនិងចាប់ផ្តើមមានអារម្មណ៍ថាត្រូវការទីធ្លាបន្ថែម ពួកគេបានក្រឡេកមើលទៅសហគមន៍ជិតខាង។ ដោយការយកឈ្នះលើដីរបស់ "ពួកគេ" "ពួកយើង" មានទីធ្លាដើម្បីដកដង្ហើម ហើយមានភាពស្ងប់ស្ងាត់មួយគ្រាមុនពេលដែលសង្គមចាប់ផ្តើមរីកចម្រើនសារជាថ្មីម្តងទៀត។ មនុស្សមាននិស្ស័យអាត្មានិយមដែលដំបូងឡើងមាន "ខ្ញុំ" បន្ទាប់មកមាន "យើង" ហើយអ្នកផ្សេងទៀតគឺ "គេ" ព្រមទាំងជនបរទេសដែលយើងមិនស្គាល់ និងអ្នកដែលគ្មានអ្វីពាក់ព័ន្ធជាមួយយើង។

ច្រើនឆ្នាំកន្លងផុតទៅ ចំនួនប្រជាជននៅលើផែនដីបានកើនឡើង ហើយស្របពេលដែលខួរក្បាលរបស់មនុស្សបានវិវឌ្ឍន៍ ឥរិយាបថរបស់យើងគឺនៅតែដូចដើម។ ជាមួយនឹងពេលវេលា ការកើនឡើងនូវតម្រូវការនៃកន្លែងរស់នៅ បានធ្វើឱ្យមានអាណានិគមនិយម ដែលរីករាលដាលកាន់តែច្រើនឡើងៗ។ ដើម្បីសម្រួលមនសិការរបស់ជនជាតិស្បែកសចំពោះការដាក់អាណានិគម ទ្រឹស្តីនៃពូជសាសន៍បានផ្សព្វផ្សាយដែលក្នុងនោះយើងអាចយកដំណើរស្វែងរករបស់អ្នកវិទូឈ្មោះដាវីន អំពីក្រុមសត្វមកធ្វើជាគំរូដើម្បីបកស្រាយ។

តើខ្ញុំបានរៀនអំពីអ្វីខ្លះដែលខ្ញុំចង់ចែករំលែកបន្ត? ដំបូងនិងសំខាន់បំផុតនោះមនុស្សគឺដូចគ្នាទាំងអស់។ ខ្ញុំបានរៀនអំពីវាតាមរយៈបទពិសោធន៍ផ្ទាល់ខ្លួន។ ពេលដែលខ្ញុំនៅក្មេង សម្រាប់ខ្ញុំគឺជារឿងធម្មតាដែលមានអ្នកអភិជននិងអ្នកបម្រើ។ យើងមិនមែនជាអ្នកមានស្តុកស្តម្ភទេ ប៉ុន្តែយើងក៏មានអ្នកបម្រើដែលចាំជួយធ្វើការងារផ្ទះដែរ។ អ្នកបម្រើរបស់យើងតែងតែក្រោកពីព្រលឹមដើម្បីបង្កាត់ភ្លើង ដើម្បីកុំឱ្យយើងរងានៅពេលបរិភោគអាហារពេលព្រឹក។ ខ្ញុំនៅតែអាចស្រមៃឃើញទឹកកកនៅលើបង្អួចដែលចាប់ផ្ដើមរលាយសន្សឹមៗ ខណៈពេលដែលអ្នកបម្រើស្លៀកពាក់ឱ្យខ្ញុំយ៉ាងទន់ភ្លន់។ ខ្ញុំនៅតែបន្តប្រើនាងដដែល ទោះបីជាខ្ញុំបានក្លាយទៅជាក្មេងជំទង់ហើយយ៉ាងណាក៏ដោយ។ ពេលវេលានៅក្នុងជំរំបានបង្រៀនខ្ញុំថា នេះគឺជាទង្វើមួយដែលខុសឆ្គង ហើយយើងមិនត្រូវឱ្យវាកើតឡើងម្តងទៀតនោះទេ។ គ្មាននរណាម្នាក់គួរមានអំណាចទៅលើមនុស្សម្នាក់ទៀតទេ ហើយលុយនិងពូជសាសន៍ក៏មិនមែនជាហេតុផលសមស្របមួយក្នុងការធ្វើទង្វើមិនល្អទៅលើមនុស្សដទៃទៀតដែរ។ ជាច្រើនសតវត្សរ៍កន្លងមកមនុស្សមួយចំនួនបានទិញដីបន្ថែមដែលធ្វើឱ្យពួកគេមានអំណាចកាន់តែខ្លាំងឡើងៗ។ អ្នកមានអំណាចត្រួតត្រាលើអ្នកក្រីក្រ និងអ្នកទន់ខ្សោយជាងហើយជាលទ្ធផលមនុស្សត្រូវបានគេបែងចែកតាមប្រភេទដែលប្រសើរជាងនិងអន់ជាង។ នៅដើមសតវត្សទី១៩ ការយល់ច្រឡំថាដែលមនុស្សជាតិអាចបែងចែកបានទៅតាមជាតិសាសន៍ខុសៗគ្នា បានចាប់ផ្តើមរីករាលដាល។ នេះបានក្លាយទៅជាបុរេវិនិច្ឆ័យមួយ ដែលយើងនៅតែឃើញមាននាសព្វថ្ងៃនេះ។ បុរេវិនិច្ឆ័យ គឺពិបាកក្នុងការប្រយុទ្ធប្រឆាំង ហើយភាពអាត្មានិយមរបស់មនុស្សមានន័យថា យើងទាំងអស់គ្នាចង់មានអារម្មណ៍ថាខ្លួនឯងល្អប្រសើរជាងអ្នកដទៃ។ មានជនជាតិស៊ុយអែតជាច្រើនដែលមានមោទកភាពក្នុងការចាត់ទុកខ្លួនឯងជាពួកអារីយ៉ាន[៩២] នៅពេល

[៩២] សាសន៍អារីយ៉ានគឺជាបណ្តុំពូជសាសន៍របស់ឥណ្ឌូ-អឺរ៉ុប ដែលកើតឡើងនៅចុងសតវត្សរ៍ទី១៩ និងពាក់កណ្តាលសតវត្សរ៍ទី២០។



ដែលហ៊ីត្លែរ បានអះអាងថាសាសន៍ណ័រឌីក-អាល្លឺម៉ង់ គឺល្អអស្ចារ្យជាងសាសន៍ដទៃទៀត។

ជនជាតិជ្វីហ្វ និងជនជាតិរ៉ូម ត្រូវបានគេប្រកាន់ពូជសាសន៍ចាប់តាំងពីការចាប់ផ្តើមនៃពេលវេលាដំបូង។ ធំធាត់ឡើងខ្ញុំត្រូវតែរស់នៅជាមួយការប្រកាន់ពូជសាសន៍ដែលប្រឆាំងនឹងជនជាតិជ្វីហ្វ ហើយនៅពេលជាមួយគ្នានោះដែរ វាក៏ជារឿងធម្មតាសម្រាប់ខ្ញុំដែលជនជាតិរ៉ូម គឺជាជនជាតិដែលអន់ជាងយើង។ ខ្ញុំបានចំណាយពេលអស់ជាច្រើនដើម្បីយល់ដឹងអំពីការរើសអើងរបស់ខ្លួន។ នៅពេលនោះ ខ្ញុំបានរស់នៅក្នុងប្រទេសស៊ុយអែតនៅទីក្រុងដាឡាណា ហើយមានកូនតូចចំនួន៣នាក់រួចទៅហើយ។ ថ្ងៃមួយកូនប្រុសអាយុ២ឆ្នាំរបស់ខ្ញុំបានបាត់ខ្លួន ហើយទោះបីជាខ្ញុំខំប្រឹងរកយ៉ាងណាខ្ញុំនៅតែមិនអាចរកវាឃើញឡើយ។ ខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំង ហើយបានទៅរកអ្នកជិតខាងម្នាក់ដែលបាននិយាយប្រាប់ខ្ញុំថា៖ "មានក្រុមជីបស៊ី[៩៣] បានឆ្លងកាត់ប្រហែលជាពួកគេចាប់យកកូនអ្នកទៅ" ។ ខ្ញុំបានជឿនាង។ តែនៅពេលដែលកូនរបស់ខ្ញុំបង្ហាញខ្លួនចេញពីគុម្ពផ្លែប្លែកប៊ីរី ខ្ញុំភ្ញាក់ខ្លួនថា ខ្ញុំគឺកំពុងតែរើសអើងជាតិសាសន៍ដែលបង្កឱ្យមានបញ្ហានៅពេលដែលខ្ញុំជឿពាក្យអ្នកជិតខាងខ្លាំងពេក។

វាគឺមានសារសំខាន់ណាស់ក្នុងការទទួលស្គាល់ភាពលំអៀងរបស់មនុស្សម្នាក់ៗ។ វិធីមួយគឺនៅពេលដែលអ្នកមានអារម្មណ៍មិនពេញចិត្តចំពោះនរណាម្នាក់ សូមសួរខ្លួនឯងជាមុនសិនថាព្រោះតែហេតុអ្វី? ដើម្បីពិនិត្យពិច័យខ្លួនឯង និងតាមដានពីប្រភពដើមនៃអារម្មណ៍នោះ។ ការប្រកាន់ពូជសាសន៍ គឺជាមូលដ្ឋានគ្រឹះនៃសេចក្តីស្អប់ខ្ពើមការប្រកាន់ជាតិសាសន៍ ការប្រឆាំងនឹងជនជាតិជ្វីហ្វ ការប្រឆាំងនឹងជនជាតិរ៉ូម និងការប្រឆាំងនឹងជនជាតិឥស្លាម ចេញមកពីអារម្មណ៍ដែលជួនកាលអាចកើត

[៩៣] គឺជាឈ្មោះរបស់ជនជាតិភាគតិចរបស់ប្រទេសរ៉ូមដែលមានដើមកំណើតមកពីអាស៊ីខាងត្បូង។

ឡើងបន្ទាប់ពីមាននរណាម្នាក់នៅក្នុងក្រុមនោះធ្លាប់បង្កឱ្យមានគ្រោះថ្នាក់ដល់យើងកាលពីអតីតកាល។ ប៉ុន្តែយើងត្រូវតែស្គាល់មនុស្សម្នាក់ឱ្យបានច្បាស់ជាមុនសិន ដើម្បីអាចវិនិច្ឆ័យបុគ្គលនោះបាន។ យើងដោយសភាវគតិភ័យខ្លាចចំពោះភាពមិនច្បាស់លាស់ ហើយនោះគឺជាអារម្មណ៍កើតឡើងដំបូងរបស់មនុស្ស។ នៅយុគសម័យដើមដំបូង មនុស្សរស់នៅក្នុងក្រុមសហគមន៍កសិកម្មតូចៗ ហើយនេះគឺជារបៀបនៃការចិញ្ចឹមជីវិតរបស់មនុស្សនៅសម័យនោះ សម្រាប់ពួកគេអ្វីដែលមិនច្បាស់លាស់ អាចធ្វើឱ្យមានគ្រោះថ្នាក់។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះ គឺបានក្លាយទៅជាផលវិបាក។

យើងទាំងអស់គ្នាមានការទទួលខុសត្រូវចំពោះសង្គមដែលយើងរស់នៅនិងចំពោះខ្លួនយើងផ្ទាល់។ មិនមានភាពខុសប្លែកគ្នាទេរវាងមនុស្សនៅក្នុងទសវត្សរ៍ឆ្នាំ១៩៣០ ឬឆ្នាំ១៩៤០ និងមនុស្សសព្វថ្ងៃនេះ។ នេះគឺត្រូវបានគេសង្កេតឃើញយ៉ាងល្អបំផុតនៅតាមសាលារៀន។ មានអ្នកប្រព្រឹត្តិបទល្មើសដែលជាអ្នកចូលចិត្តសម្លុតគេ  វាយគេ និងជនរងគ្រោះនិងអ្នកដែលគ្រាន់តែឈរមើលដោយមិនបានចូលហាមឃាត់ដោយសង្ឃឹមថានឹងមានអ្នកផ្សេងទៀតចូលមកជួយជនរងគ្រោះ។ អ្នកមិនគួរធ្វើខ្លួនជាជនល្មើស ប៉ុន្តែអ្នកក៏មិនគួរបានត្រឹមតែឈរមើលបំណាំដែរ ពីព្រោះនេះក៏ធ្វើឱ្យអ្នកមានកំហុសដែរ។ សព្វថ្ងៃនេះយើងរស់នៅក្នុងលទ្ធិប្រជាធិបតេយ្យមួយ។ ទោះបីជាមិនល្អឥតខ្ចោះ ប៉ុន្តែក៏គ្មានរដ្ឋាភិបាលណាផ្សេងទៀតដែលប្រសើរជាងនេះដែរ។ យើងត្រូវតែតស៊ូដើម្បីលទ្ធិប្រជាធិបតេយ្យរបស់យើងប្រសិនបើយើងចង់រក្សាឱ្យបានល្អគង់វង្ស។ បើមិនដូច្នេះទេ វាអាចនឹងងាយស្រួលដែលការមិនសប្បាយចិត្តជាមួយនឹងភាពអវិជ្ជមានរបស់លទ្ធិប្រជាធិបតេយ្យសព្វថ្ងៃនេះនឹងបង្កឱ្យអ្នកដឹកនាំអង់អាចម្នាក់ទៀតធ្វើឱ្យអ៊ឺរ៉ុបធ្លាក់ក្នុងគ្រោះថ្នាក់ម្តងទៀត។ យើងមិនត្រូវលិចលង់ចូលទៅក្នុងភាពបរាជ័យទេ យើងត្រូវតែបន្តប្រយុទ្ធទោះបីជាមួយនឹងរូបភាពអវិជ្ជមានដែលពិភពលោកកំពុងតែបង្ហាញសព្វថ្ងៃនេះក៏ដោយ។



# “SKULLE DET KUNNA HÄNDA IGEN?”

# “COULD IT HAPPEN AGAIN?”

# "តើអ្វីៗអាចនឹងកើតឡើងម្តងទៀតដែរឬទេ ?"

អ្វីដែលបានកើតឡើងម្តងហើយអាចនឹងកើតឡើងម្តងទៀត ទោះបីជាមិនទៅតាមរបៀបដូចគ្នាក៏ដោយប៉ុន្តែលទ្ធផលគឺដូចគ្នាជានិច្ច។

ប្រសិនបើយើងក្រឡេកមើលទៅដំណើរប្រវត្តិសាស្ត្រយើងអាចសន្និដ្ឋានបានថា ត្រឹមតែមួយជំនាន់ គឺគ្រប់គ្រាន់ដើម្បីបំភ្លេចបទពិសោធន៍ពីអតីតកាលបាន ។ យើងដឹងថាហូឡូខសន៍[៩៤] មិនមែនជាការសម្លាប់រង្គាលលើកដំបូងទៅលើ **"មនុស្សដែលអន់ជាង"** នោះទេ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយនោះគឺជាលើកដំបូងដែលត្រូវបានគេដាក់ឈ្មោះឱ្យថា **"អំពើប្រល័យពូជសាសន៍"** ហើយឃើញអ្នកដែលបានផ្តួចផ្តើមគំនិតត្រូវបានផ្តន្ទាទោស។ នៅក្រោមអាណានិគមនិយម ការជឿទៅលើឧត្តមភាពនៃជនជាតិស្បែកសបានរីករាលដាល ហើយការសម្លាប់ជនជាតិដើមភាគតិចដោយមិនបានថ្កោលទោសជាមុនសិន គឺជាច្បាប់ជាជាងករណីលើកលែង។ ការសម្លាប់រង្គាលពិតប្រាកដបានកើតឡើងនៅអាហ្វ្រិកខាងត្បូង- អាហ្វ្រិកខាងលិច (**បច្ចុប្បន្នជាណាមីប៊ី**[៩៥]) នៅសតវត្សរ៍ទី២០។ នៅពេលដែលជនជាតិអាល្លឺម៉ង់បានធ្វើអំពើយ៉ាងសាហាវឃោរឃៅដើម្បីកម្ចាត់មនុស្សជាង ៨០% នៃជនជាតិហឺរ៉ូ។ អ្នកវិទ្យាសាស្ត្រជាច្រើនបានអះអាងថា ហ៊ីត្លែរក្រោយមកបានចាត់ទុកថាការសម្លាប់នេះ គឺជាគំរូមួយសម្រាប់ការសម្លាប់ដ៏ទៃទៀត។ មនុស្សជាច្រើនត្រូវបានធ្វើបាបយាយីនិងសម្លាប់ដោយមិនមានការថ្កោលទោសជាមុនសិន រហូតដល់ដើមសតវត្សរ៍ទី២០ ទើបមាននិស្សិតផ្នែកច្បាប់ជនជាតិប៉ូឡូញវ័យក្មេងម្នាក់ឈ្មោះ រ៉ាហ្វាអែល ឡេមគីមបានគិតថាអំពើប្រល័យពូជសាសន៍ គឺគួរតែមានច្បាប់សម្រាប់កាត់ទោស។

ប៉ុន្តែដំបូងគឺត្រូវតែមានឈ្មោះសម្រាប់ហៅជាមុនសិន គាត់បានបង្កើតពាក្យ **"អំពើប្រល័យពូជសាសន៍"** ពីភាសាក្រិកហៅថា **"ឃាតកម្មមនុស្ស"** ដែល **“ជីនូស”** **“genos”** មានន័យថាមនុស្ស និងឡាតាំង **“ស៊ីត”** **“cide”** មានន័យថាឃាតកម្ម។ គាត់បានតស៊ូពេញមួយជីវិតរបស់គាត់ដើម្បីឱ្យសហគមន៍អន្តរជាតិទទួលស្គាល់ថា អំពើប្រល័យពូជសាសន៍ គឺជាអំពើឧក្រិដ្ឋកម្ម។ បន្ទាប់ពីហូឡូខសន៍[៩៦] នៅក្នុងឆ្នាំ១៩៤៨ ទើបទស្សនៈមួយនេះត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិដែលសព្វថ្ងៃនេះប្រទេសចំនួន១៤៩ ជាសមាជិកអនុសញ្ញា។ ទោះបីជាយ៉ាងនេះក្តី មិនយូរប៉ុន្មានអំពើប្រល័យពូជសាសន៍ថ្មីមួយទៀតបានកើតឡើងនៅក្នុងប្រទេសរវ៉ាន់ដា[៩៧] និងប៉ុន្មានឆ្នាំក្រោយមកទៀតនៅក្នុងប្រទេសស៊ែប៊ី[៩៨]។ នេះបានបង្ហាញយ៉ាងច្បាស់ថា ការគំរាមកំហែងអំពីការដាក់ទណ្ឌកម្ម គឺមិនគ្រប់គ្រាន់ក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍មិនឱ្យកើតឡើងម្តងទៀតនោះទេ។ សព្វថ្ងៃនេះយើងដឹងថាមានអ្វីផ្សេងទៀតដែលមានតម្រូវការចាំបាច់ ហើយនោះគឺជាការផ្លាស់ប្តូរអំពីរបៀបដែលយើងចិញ្ចឹមកូនៗរបស់យើង។ យុវវ័យជំនាន់ថ្មីត្រូវតែបន្តរំឭកអំពីឧក្រិដ្ឋកម្មដែលបានកើតឡើង។ អ្នកទាំងឡាយណាដែលចិញ្ចឹមក្មេងៗជំនាន់ក្រោយឪពុកម្តាយនិងគ្រូបង្រៀន ត្រូវតែផ្តល់ចំណេះដឹងនេះដល់កូនៗ និងសិស្សរបស់ខ្លួនដោយមានជំនួយពីសៀវភៅប្រវត្តិសាស្ត្រ បូជនីយស្ថាននិងសារមន្ទីរ។

---

[៩៤] គឺជាការធ្វើបាបយាយីនិងអំពើប្រល័យពូជសាសន៍ទៅលើជនជាតិជ្វីហ្វចំនួន៦លាននាក់ដោយរបបណាហ្ស៊ីរបស់ហ៊ីត្លែរចាប់តាំងពីឆ្នាំ១៩៣៣ រហូតដល់ចុងបញ្ចប់សង្គ្រាមលោកលើកទី២។ ហូឡូខសន៍គឺជាពាក្យដើមនៃភាសាក្រិកមានន័យថា "បូជាដោយភ្លើង" ឬ "បូជាភ្លើង" ។

[៩៥] មានឈ្មោះជាផ្លូវការថាសាធារណរដ្ឋណាមីប៊ី គឺជាប្រទេសមួយដែលស្ថិតនៅក្នុងអាហ្វ្រិកខាងត្បូង។

[៩៦] គឺជាការធ្វើបាបយាយីនិងអំពើប្រល័យពូជសាសន៍ទៅលើជនជាតិជ្វីហ្វចំនួន៦លាននាក់ដោយរបបណាហ្ស៊ីរបស់ហ៊ីត្លែរចាប់តាំងពីឆ្នាំ១៩៣៣ រហូតដល់ចុងបញ្ចប់សង្គ្រាមលោកលើកទី២។ ហូឡូខសន៍គឺជាពាក្យដើមនៃភាសាក្រិកមានន័យថា "បូជាដោយភ្លើង" ឬ "បូជាភ្លើង" ។

[៩៧] មានឈ្មោះជាផ្លូវការថាសាធារណរដ្ឋរវ៉ាន់ដាគឺជាប្រទេសដែលស្ថិតនៅក្នុងអាហ្វ្រិកកណ្តាលនិងអាហ្វ្រិកខាងកើត។

[៩៨] ជាប្រទេសដែលជាប់ព្រំដែនជាមួយប្រទេសហុងគ្រី រូម៉ានី ប៊ុលហ្គារី ម៉ាសេដូនី ក្រូអាស៊ី បូស្នី ហឺហ្គោវីណា និងម៉ុងតេណេហ្គ្រោ។

ប៉ុន្តែវិធីដែលត្រូវបានអនុវត្តក៏មានសារសំខាន់ខ្លាំងណាស់ដែរ ពីព្រោះប្រសិនបើចំណេះដឹងជ្រាបទៅដល់ត្រឹមតែគំនិតស្មារតី នោះនឹងអាចត្រូវបានបំភ្លេចចោលបានយ៉ាងងាយស្រួល។

ការបង្រៀន គឺត្រូវតែជ្រាបឱ្យដល់បេះដូងដើម្បីធ្វើឱ្យក្មេងជំនាន់ក្រោយមានអារម្មណ៍ចង់រៀនសូត្រអំពីព្រឹត្តិការណ៍ទាំងនោះ។ មានសាក្សីជាច្រើនដែលអាចនិយាយអំពីបទពិសោធន៍របស់ខ្លួនផ្ទាល់។ យើងយល់អំពីពិភពលោកដោយប្រើសតិអារម្មណ៍និងដួងចិត្ត។ ការសិក្សាស្រាវជ្រាវថ្មីៗកន្លងមកនេះក៏បានរាប់បញ្ចូលបេះដូងជាមួយនឹងប្រាជ្ញាដែលអាចទទួលបានការបណ្តុះបណ្តាលដូចគ្នាទៅនឹងបញ្ញាខួរក្បាលដែរ។

នេះគឺជាគំរូដ៏ល្អមួយដែលឪពុកម្តាយ និងគ្រូបង្រៀនអាចប្រៀនប្រដៅក្មេងជំនាន់ថ្មីឱ្យអោបក្រសោបសេចក្តីអាណិតអាសូរ សេចក្តីស្រឡាញ់ដោយគ្មានលក្ខខណ្ឌនិងពិភពលោកដែលគ្មានភាពស្អប់ខ្ពើម។

មិនយូរប៉ុន្មាននឹងគ្មានសាក្សីរស់នៅសេសសល់ទៀតទេ ហើយដើម្បីព្យាយាមរារាំងអំពើអាក្រក់ទាំងនេះកុំឱ្យកើតមានម្តងទៀតនោះ គឺរឿងរ៉ាវរបស់យើងត្រូវតែបន្តចែករំលែក។ រឿងរបស់យើងអាចបង្ហាញតាមរយៈដូចគ្នាទៅនឹងរឿងអំពីការចាកចេញរបស់ប្រជាជនពីប្រទេសអេហ្ស៊ីបក្នុងអំឡុងពេលបុណ្យជៀល (បុណ្យចម្លង) របស់ជនជាតិជ្វីហ្វ។ អ្នកអានគួរតែអានរឿងនោះ ប្រៀបបានដូចជាខ្លួនឯងគឺជាតួអង្គនៅក្នុងរឿង។ ខ្ញុំគិតថាវិធីនេះក៏ល្អសម្រាប់ការប្រាប់រឿងរ៉ាវរបស់ហូឡូខសន៍[៩៩] ដែរ។ ឥឡូវនេះយើងមានថ្ងៃនៃការចងចាំ គឺថ្ងៃទី២៧ ខែមករា។ ខ្ញុំសង្ឃឹមថារឿងនេះនឹងវិវឌ្ឍទៅជាប្រពៃណីដ៏យូរអង្វែងមួយ ដែលក្មេងជំនាន់ក្រោយអាចចែករំលែករឿងរ៉ាវហើយប្រាប់តាមរបៀបដែលអាចជ្រាបដល់ដួងចិត្តរបស់អ្នកស្តាប់បាន។

[៩៩] គឺជាការធ្វើបាបឃាឃីនិងអំពើប្រល័យពូជសាសន៍ទៅលើជនជាតិជ្វីហ្វចំនួន៦លាននាក់ដោយរបបណាហ្ស៊ីរបស់ហ៊ីត្លែរចាប់តាំងពីឆ្នាំ១៩៣៣ រហូតដល់ចុងបញ្ចប់សង្គ្រាមលោកលើកទី២។ ហូឡូខសន៍គឺជាពាក្យដើមនៃភាសាក្រិកមានន័យថា "បូជាដោយភ្លើង" ឬ "បូជាភ្លើង" ។



# សេចក្តីថ្លែងអំណរគុណពីអ្នកនិពន្ធហេឌី ហ្វ្រាយ

ខ្ញុំសូមអរគុណទៅដល់សិស្សទាំងអស់ដែលបានស្តាប់ និងលើកឡើងនូវសំណួរដ៏សំខាន់ទាំងអស់នេះ។ សំណួរពិតជាមានសារសំខាន់ជាងចម្លើយ។ មានតែតាមរយៈការសួរសំណួរតែប៉ុណ្ណោះទេដែលអាចធ្វើឱ្យយើងយល់អំពីអ្វីៗគ្រប់យ៉ាងបាន។

យើងមិនអាចទទួលចម្លើយច្បាស់លាស់ណាមួយបានទេថាហេតុអ្វីបានជាហូឡូខសន៍[១០០] កើតឡើង។ ប៉ុន្តែតាមរយៈការចងក្រងអំពីពេលវេលា និងអ្វីដែលបានកើតឡើងយើងអាចស្រមៃមើលឃើញអំពីរឿងរ៉ាវនៃអតីតកាលបាន។

បន្ទាប់ពីការបង្រៀនបានបញ្ចប់ អ្នកក្រោកឈរឡើងហើយសួរសំណួរនេះ គឺមិនមែនជារឿងមួយដែលងាយស្រួលនោះទេ។ សំណួរដែលខ្ញុំចង់សួរប្រហែលដូចជាឆោតល្ងង់ដែលមនុស្សជារឿយៗបានគិត ដូចនេះដែរទើបពួកគេជៀសវាងពីការសួរសំណួរ។ ប៉ុន្តែសំណួរដែលឆោតល្ងង់អាចក្លាយទៅជាសំណួរមួយដែលអាចនាំឱ្យមានការយល់ដឹងកាន់តែច្រើន។

[១០០] គឺជាការធ្វើបាបឃាឃីនិងអំពើប្រល័យពូជសាសន៍ទៅលើជនជាតិជ្វីហ្វចំនួន៦លាននាក់ដោយរបបណាហ្ស៊ីរបស់ហ៊ីត្លែរចាប់តាំងពីឆ្នាំ១៩៣៣ រហូតដល់ចុងបញ្ចប់សង្គ្រាមលោកលើកទី២។ ហូឡូខសន៍គឺជាពាក្យដើមនៃភាសាក្រិកមានន័យថា "បូជាដោយភ្លើង" ឬ "បូជាភ្លើង" ។

# មជ្ឈមណ្ឌលឯកសារកម្ពុជា

មជ្ឈមណ្ឌលឯកសារកម្ពុជា បង្កើតឡើងនៅឆ្នាំ១៩៩៥ បន្ទាប់ពីសភាសហរដ្ឋអាមេរិកអនុម័តឲ្យមាន ច្បាប់ស្តីពីយុត្តិធម៌សម្រាប់អំពើប្រល័យពូជសាសន៍ នៅខែមេសា ឆ្នាំ១៩៩៤ ដែលចុះហត្ថលេខាចូលជាធរមានដោយប្រធានាធិបតី ឃ្លីនតុន។ រាជរដ្ឋាភិបាលកម្ពុជា បានគាំទ្រមជ្ឈមណ្ឌលឯកសារកម្ពុជាជាផ្លូវការ។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលការកោតសរសើរ និងមេដាយជាច្រើនសម្រាប់កិច្ចការគាំទ្រឲ្យមានការចងចាំ និងយុត្តិធម៌ សម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ ក្នុងឆ្នាំ ២០១៧ ដដែលនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលពានរង្វាន់សិទ្ធិមនុស្ស ជូឌីត លី ស្រ្តូណាច់ ពីមជ្ឈមណ្ឌលសម្រាប់ការទទួលខុសត្រូវ និងយុត្តិធម៌។ ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនីទ្រង់ព្រះរាជទានគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ធិបឌិន្ទដល់លោក ឆាំង យុ ក្នុងការទទួលស្គាល់ស្នាដៃដ៏ល្បីល្បាញរបស់លោកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងឆ្នាំ ២០១៨ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ជាអ្នកឈ្នះពានរង្វាន់ រ៉ាម៉ុន ម៉ាក់សៃសៃ ដែលត្រូវបានចាត់ទុកថាជាពានរង្វាន់ណូបែលអាស៊ី សម្រាប់ការថែរក្សាការចងចាំជាប្រវត្តិសាស្រ្ត សម្រាប់ការព្យាបាលរបួសផ្លូវចិត្ត និងយុត្តិធម៌។